ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

## របាយការណ៍វិភាគស៊ីជម្រៅប្រធានបទ

# ពិការភាពនៅកម្ពុជា

## វិទ្យាស្ថានជាតិស្ថិតិ

## ក្រសួងផែនការ

ខែកក្កដា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងផែនការ
វិទ្យាស្ថានជាតិស្ថិតិ

EUROPEAN UNION

unicef
for every child

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

## របាយការណ៍វិភាគស៊ីជម្រៅប្រធានបទ

# ពិការភាពនៅកម្ពុជា


វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ



ខែកក្កដា ឆ្នាំ២០២២

EUROPEAN UNION

unicef for every child

# មាតិកា


**បុព្វកថា** ..... ៣

**អារម្ភកថា** ..... ៥

**ផែនទីព្រះរាជាណាចក្រកម្ពុជា** ..... ៦

**អក្សរកាត់** ..... ៧

**តារាង** ..... ៩

**រូបភាព** ..... ១១

**សេចក្តីសង្ខេប** ..... ១៦

**ជំពូក ១៖ សេចក្តីផ្តើម** ..... ២៣

..... ២៩

**ជំពូក ២៖ វិធីសាស្រ្ត** ..... ៣០

២.១ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៣០

២.២ និយមន័យពិការភាពក្នុងបរិបទអន្តរជាតិ ..... ៣០

២.៣ ការវាស់វែងពិការភាព ..... ៣២

២.៤ ព្រំដែនកំណត់នៃការវាស់វែងពិការភាព ..... ៣៦

**ជំពូក ៣៖ បរិបទពិការភាពក្នុងប្រទេសកម្ពុជា** ..... ៣៨

**ជំពូក ៤៖ ចរិតលក្ខណៈទូទៅរបស់ជនមានពិការភាព** ..... ៤៤

៤.១ ប្រេវ៉ាឡង់ពិការភាព ..... ៤៤

៤.២ បញ្ហាប្រឈមជុំវិញទិន្នន័យស្តីពីប្រេវ៉ាឡង់ពិការភាព ..... ៤៧

៤.៣ ប្រេវ៉ាឡង់ពិការភាពបែងចែកតាមអាយុ និងភេទ ..... ៤៩

៤.៤ ភាពខុសគ្នាតាមតំបន់រវាងទីប្រជុំជន និងជនបទ ..... ៥៥

**ជំពូក ៥៖ ចរិតលក្ខណៈនៃគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព** ..... ៦០

៥.១ សមាសភាគនៃគ្រួសារដែលមានសមាជិកមានពិការភាព ..... ៦០

៥.២. ស្ថានភាពអាពាហ៍ពិពាហ៍ ..... ៦៧

៥.៣ លទ្ធភាពបង្កើតកូន ..... ៧៤

**ជំពូក ៦៖ ជីវភាពរស់នៅ និងពិការភាព** ..... ៧៩

៦.១ សន្ទស្សន៍ទ្រព្យសម្បត្តិ ..... ៨០

៦.២ ស្ថានភាពលំនៅដ្ឋាន និងសម្ភារប្រើប្រាស់ក្នុងគ្រួសារ ..... ៨២

**ជំពូក ៧៖ ការអប់រំ និងពិការភាព** ..... ៩៤

៧.១ ការចូលរៀននៅសាលា ..... ៩៥

៧.២ អក្ខរភាព ..... ១០១

៧.៣ កម្រិតអប់រំ ..... ១០៥

**ជំពូក ៨៖ សកម្មភាពសេដ្ឋកិច្ច និងពិការភាព** ..... ១១០

**ជំពូក ៩៖ ពិការភាព និងទេសន្តរប្រវេសន៍** ............ ១១៩
**ជំពូក ១០៖ កុមារ និងយុវជន និងពិការភាព** ............ ១២៤
១០.១ ប្រេវ៉ាឡង់ពិការភាពក្នុងចំណោមកុមារ និងយុវជន ............ ១២៤
១០.២ ស្ថានភាពគ្រួសារ ............ ១២៥
១០.៣ កុមារ និងយុវជនក្នុងកម្លាំងពលកម្ម ............ ១២៨
១០.៤ អាពាហ៍ពិពាហ៍កុមារ ............ ១៣០
**ជំពូក ១១៖ មនុស្សចាស់ និងពិការភាព** ............ ១៣៤
១១.១ ប្រភេទគ្រួសារ ............ ១៣៤
១១.២ ស្ថានភាពអាពាហ៍ពិពាហ៍ ............ ១៣៧
១១.៤ ការចូលរួមក្នុងកម្លាំងពលកម្ម ............ ១៤១
**ជំពូក ១២៖ យេនឌ័រ និងពិការភាព** ............ ១៤៤
១២.១ អាពាហ៍ពិពាហ៍ ............ ១៤៤
១២.២ ភាពក្រីក្រ ............ ១៤៦
១២.៣ ការអប់រំ ............ ១៤៧
១២.៤ កម្លាំងពលកម្ម ............ ១៤៨
**ជំពូក ១៣៖ សេចក្តីសន្និដ្ឋាន និងភាពពាក់ព័ន្ធផ្នែកគោលនយោបាយ** ............ ១៥១
១៣.១ ការដោះស្រាយឧបសគ្គធំៗដែលធ្វើឱ្យមានការផាត់ចេញជនមានពិការភាព ............ ១៥២
១៣.២ ការពង្រឹងការប្រមូលទិន្នន័យស្តីពីពិការភាពក្នុងប្រទេសកម្ពុជា ............ ១៥៨
**ឧបសម្ព័ន្ធ ១** ............ ១៦៥
**ឧបសម្ព័ន្ធ ២៖ ការបង្កើតសន្ទស្សន៍ទ្រព្យសម្បត្តិ** ............ ១៨៦
**សន្ទានុក្រម** ............ ១៨៨
**ឯកសារយោង** ............ ១៩៣

# បុព្វកថា

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានផ្ដល់កាលានុវត្តភាពយ៉ាងសំខាន់ការវាយតម្លៃសមិទ្ធផលនានាដែលសម្រេចបានក្នុងអតីតកាល បានចង្អុលបង្ហាញនូវប្រសិទ្ធភាពនៃការអនុវត្តផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងឡាយសម្រាប់អនាគត។ ដោយមើលឃើញអំពីសារៈសំខាន់យ៉ាងធំធេងនៃការងារជំរឿន រាជរដ្ឋាភិបាលកម្ពុជាក្នុងភាពជាម្ចាស់បានបង្កើនការប្រើប្រាស់ថវិកាជាតិដ៏ច្រើនដែលការធ្វើជំរឿនរយៈកាលកន្លងមកពឹងផ្អែកជំនួយហិរញ្ញវត្ថុស្ទើរទាំងស្រុង ពីដៃគូអភិវឌ្ឍន៍។

ខ្ញុំពិតជាមានសេចក្ដីរីករាយ ដែលជំរឿននេះបានអនុវត្តដោយជោគជ័យ និងបានផ្ដល់ទិន្នន័យប្រកប ដោយភាពជឿទុកចិត្ត និងទាន់ពេលវេលា សម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នកធ្វើសេចក្ដីសម្រេចនានា របស់រាជរដ្ឋាភិបាល និងសម្រាប់អ្នកប្រើប្រាស់ទូទៅ។ របាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ជារបាយការណ៍ជាតិដំបូង ហើយក៏នឹងមានរបាយការណ៍លម្អិតបែងចែកតាមប្រធានបទជាច្រើនទៀត ដែលនឹងត្រូវផលិតឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ដោយមានការចូលរួមពីសំណាក់អ្នកជំនាញតាមវិស័យនានា ព្រមទាំងពីសំណាក់ស្ថាប័នសិក្សាស្រាវជ្រាវផងដែរ។

ខ្ញុំសូមសម្ដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្ដេចបានគាំទ្រយ៉ាងពេញទំហឹង និងបានណែនាំដ៏ថ្លៃថ្លាដល់ការអនុវត្តជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ នេះទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។ ខ្ញុំសូមគោរពថ្លែងអំណរគុណជូនចំពោះ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដែលបានផ្ដល់អនុសាសន៍ចង្អុលបង្ហាញយ៉ាងច្បាស់លាស់គ្រប់ពេលវេលានៅក្នុងដំណើរការជំរឿនទូទៅនេះ។

ខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយក្រៃលែង ក្នុងនាមក្រសួងផែនការ និងក្នុងនាមប្រធានគណៈកម្មការបច្ចេកទេសជំរឿន និងជាប្រធានគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ និងសូមថ្លែងអំណរគុណផងដែរចំពោះសមាជិកនៃគណៈកម្មាធិការជំរឿនថ្នាក់កណ្ដាល គណៈកម្មាធិការ ជំរឿនរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ទាំងអស់ ដែលបានបំពេញការងារយ៉ាងល្អរហូតទទួលបាននូវលទ្ធផលជាផ្លែផ្កាស្របទៅតាមពេលវេលាដែលបានគ្រោងទុក។

ខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត (Sida) ដែលបានរួមចំណែកផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបានផ្ដល់ជំនួយបច្ចេកទេស ក្នុងការរៀបចំផែនការជំរឿន ការរៀបចំបណ្ដាញវាយបញ្ចូលទិន្នន័យ និងសម្អាតទិន្នន័យ ការបណ្ដុះបណ្ដាលមន្ត្រីបច្ចេកទេសក្នុងការវិភាគទិន្នន័យ និងសរសេររបាយការណ៍ និងការរៀបចំរបាយការណ៍ចុងក្រោយសម្រាប់ជំរឿននេះ។

ខ្ញុំសូមថ្លែងអំណរគុណផងដែរដល់ លោកសាស្ត្រាចារ្យបណ្ឌិត Nott Rama Rao ដែលបានផ្ដល់ជំនួយបច្ចេកទេសក្នុងការរៀបចំផែនការជំរឿន និងបានពិនិត្យរាល់ទិដ្ឋភាពបច្ចេកទេសទាំងអស់របស់ជំរឿន លោកបណ្ឌិត Ricardo Neupert ប្រធានទីប្រឹក្សាបច្ចេកទេសជំរឿន ដែលបានជួយដល់ផ្នែកបច្ចេកទេសជំរឿន ជាពិសេសការសរសេរ

របាយការណ៍ជំរឿនចុងក្រោយនេះ លោកបណ្ឌិត Arij Dekker ទីប្រឹក្សាបច្ចេកទេស ដែលបានជួយដល់ការសម្អាតទិន្នន័យ និងតារាងអាទិភាពជំរឿន និងលោកទីប្រឹក្សា Kjell Tambour ដែលបានផ្តល់ជំនួយបច្ចេកទេសខាងការកែច្នៃទិន្នន័យ។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេស ចំពោះរាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានផ្តល់ជំនួយជាសម្ភារ រួមមានរថយន្ត ទោចក្រយានយន្ត កុំព្យូទ័រលើតុ និងកុំព្យូទ័រយួរដៃ ឧបករណ៍បោះពុម្ពអក្សរ ឧបករណ៍ថតចម្លង តាប្លេត (Tablet) ឧបករណ៍ផ្គត់ផ្គង់ព័ត៌មាន (Server) រួមទាំងឧបករណ៍អេឡិចត្រូនិចផ្សេងៗទៀត ដែលមានតម្លៃសរុបប្រមាណ ២,៥ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីបម្រើដល់ការធ្វើជំរឿននេះ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះមន្ត្រីវិទ្យាស្ថានជាតិស្ថិតិទាំងអស់ក្រោមការដឹកនាំរបស់លោកជំទាវ ហាង់ លីណា ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានសម្របសម្រួលយ៉ាងយកចិត្តទុកដាក់នូវរាល់កិច្ចសហប្រតិបត្តិការជំរឿន ដោយមានជំនួយការពីអគ្គនាយករងមួយចំនួនរួមមាន ឯកឧត្តម សុក សុកល ឯកឧត្តម សាំង ឡង់ឌី និង ឯកឧត្តម ថី យាម ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត។ ខ្ញុំសូមថ្លែងអំណរគុណជាពិសេស ជូនចំពោះបងប្អូនជនរួមជាតិទាំងអស់ ដែលបានគាំទ្រ និងចូលរួមសហការ នៅក្នុងដំណើរការនៃប្រតិបត្តិការជំរឿនទូទៅនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ សម្រេចបានជោគជ័យ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា គ្រប់ក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ គ្រឹះស្ថានសិក្សាស្រាវជ្រាវ វិស័យឯកជន និងសាធារណជនទូទៅ នឹងទទួលបាននូវអត្ថប្រយោជន៍ពីបាយការណ៍នេះ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**



**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ត្រូវបានធ្វើឡើងដើម្បីទទួលបានទិន្នន័យប្រជាសាស្ត្រ ចាំបាច់ក្រោយពីបញ្ចប់ជំរឿន និងជាមធ្យោបាយសម្រាប់ការកសាងសមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីមន្ទីរផែនការ ក្នុងការវិភាគទិន្នន័យបែងចែកតាមប្រធានបទនានា ជាពិសេសក្នុងដំណើរការអភិវឌ្ឍការវិភាគទិន្នន័យលើប្រធានបទស្តីពី "ពិការភាពនៅកម្ពុជា" ផ្អែកលើលទ្ធផលនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ របាយការណ៍បែងចែកតាមប្រធានបទជាច្រើនផ្សេងទៀតគ្រោងនឹងចេញផ្សាយ ដោយផ្អែកតាមលទ្ធផលនៃជំរឿននេះ ដែលពាក់ព័ន្ធនឹងប្រធានបទចំណាប់អារម្មណ៍ផ្សេងទៀត ដែលប្រធានបទមួយចំនួនត្រូវបានរំពឹងថានឹងបោះពុម្ព និងចេញផ្សាយនៅឆ្នាំ ២០២២។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ** ដែលតែងយកចិត្តទុកដាក់លើការងារជំរឿន និងការងារអង្កេតនានា។ ការយកចិត្តទុកដាក់នេះបានផ្តល់ការជំរុញលើកទឹកចិត្តដល់បុគ្គលិកជាតិ និងអន្តរជាតិដែលចូលរួមក្នុងគម្រោងនេះ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) ដែលបានជួយគាំទ្រដល់ដំណើរការទាំងស្រុងនៃការរៀបចំរបាយការណ៍នេះដោយបានផ្តល់ជាធនធាននិងជំនួយបច្ចេកទេសបែងចែកតាម រយៈអ្នកជំនាញផ្នែកជំរឿន លោក Frank Eelens និងលោកស្រី Marianne Eelens ដោយផ្តោតសំខាន់លើការអភិវឌ្ឍសមត្ថភាព។ ឆ្លៀតក្នុងឱកាសនេះ យើងសូមថ្លែងអំណរគុណចំពោះសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និងដៃគូអភិវឌ្ឍន៍ដែលចូលរួមផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់ដំណើរការជំរឿននេះ។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ការគាំទ្រទាំងស្រុងផ្នែកហិរញ្ញវត្ថុ។ ខ្ញុំសូមថ្លែងអំណរគុណដល់សាធារណរដ្ឋប្រជាមានិតចិន ដែលបានផ្តល់សម្ភារចាំបាច់សម្រាប់ដំណើរការជំរឿន រួមមាន រថយន្ត ទោចក្រយានយន្ត ម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនថតចម្លង ជាដើម។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិទាំងអស់ ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា និងមន្ត្រីជំរឿនរាជធានី ខេត្ត មន្ត្រីជំរឿនស្រុក ខណ្ឌ ក្រុង មន្ត្រីជំរឿនឃុំ សង្កាត់ មេភូមិ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ ដែលបានខិតខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យតាមមូលដ្ឋាន ដែលអាចឱ្យយើងផលិតបាននូវទិន្នន័យដែលមានគុណភាពខ្ពស់។ ខ្ញុំសូមកោតសរសើរដល់សាធារណជនទូទៅ ដែលបានសហការល្អក្នុងការផ្តល់ព័ត៌មានដ៏មានសារៈសំខាន់បំផុត ដោយគ្មានការលាក់លៀម។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហាន់ លីណា**

# ផែនទីព្រះរាជាណាចក្រកម្ពុជា



# អក្សរកាត់

| | |
|---|---|
| CDPO | អង្គការជនពិការកម្ពុជា |
| CMAA | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន |
| CMVIS | ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម |
| COVID19- | ជំងឺកូវីដ ១៩ |
| CRPD | អនុសញ្ញាស្តីពីសិទ្ធិជនពិការ |
| CSES | ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា |
| DAC | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DHS | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| EPR | ផលធៀបការងារ-ប្រជាជន |
| ERW | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| GDS | អគ្គនាយកដ្ឋានស្ថិតិ |
| GPCC | ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា |
| ICF | អ្នកផ្តល់ប្រឹក្សាសកល និងអ្នកផ្តល់សេវាឌីជីថល |
| ICF | ការធ្វើចំណាត់ថ្នាក់ជាអន្តរជាតិស្តីពីការបំពេញមុខងារ |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| ILO | អង្គការអន្តរជាតិខាងការងារ |
| NEE | យុវជនដែលមិនកំពុងទទួលបានការអប់រំ ឬមានការងារធ្វើ |
| NEET | យុវជនដែលមិនកំពុងទទួលបានការអប់រំ មានការងារធ្វើ ឬទទួលបានការបណ្តុះបណ្តាល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| PCA | ការវិភាគសមាសភាគសំខាន់ |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SMAM | អាយុជាមធ្យមនៅពេលរៀបការ |
| SRHR | សុខភាព និងសិទ្ធិផ្លូវភេទ និងបន្តពូជ |

| | |
|---|---|
| TFR | អត្រាលទ្ធភាពបង្កើតកូន |
| UN | អង្គការសហប្រជាជាតិ |
| UNDESA | នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ |
| UNFPA | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UNICEF | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| UNTC | កម្រងសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ |
| US$ | ដុល្លារអាមេរិក |
| WG | ក្រុមការងារវ៉ាស៊ីនតោន |
| WG-SS | កម្រងសំណួរខ្លីរបស់ក្រុមការងារវ៉ាស៊ីនតោនស្តីពីការបំពេញមុខងារ |
| WHO | អង្គការសុខភាពពិភពលោក |
| WIPO | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |

# តារាង

តារាង ១ ៖ ចំណុចដៅ និងសូចនាករស្តីពីពិការភាពក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ..... ២៦

តារាង ២ ៖ សំណួរទាំង៦ របស់ក្រុមការងារវ៉ាស៊ីនតោន ..... ៣៣

តារាង ៣.១ ៖ កម្រិតពិការភាពរបស់ក្រុមការងារវ៉ាស៊ីនតោន ..... ៣៥

តារាង ៣.២ ៖ ប្រភេទចម្លើយរបស់ក្រុមការងារវ៉ាស៊ីនតោន ..... ៣៥

តារាង ៤.១ ៖ របាយភាគរយប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមកម្រិតពិការភាព និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៤៤

តារាង ៤.២ ៖ ពិការភាព បែងចែកតាមកម្រិត ភេទ និងប្រភេទលំនៅដ្ឋាន ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៥៦

តារាង ៥.១ ៖ ចំនួនគ្រួសារប្រក្រតី បែងចែកតាមចំនួនសមាជិកពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៦០

តារាង ៥.២ ៖ ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទគ្រួសារដែលពួកគេរស់នៅ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៦២

តារាង ៥.២ ៖ ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទគ្រួសារដែលពួកគេរស់នៅ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៦៣

តារាង ៥.៣.ក ៖ ចំនួនស្ត្រីបែងចែកបែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ចំនួនកុមារដែលបានកើតក្នុងរយៈពេល ១២ ខែ មុនពេលជំរឿន និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៧៦

តារាង ៥.៣.ខ ៖ អត្រាលទ្ធភាពបង្កើតកូនតាមអាយុ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៧៧

តារាង ៦.១ ៖ កម្មសិទ្ធិលំនៅដ្ឋានគ្រួសារ បែងចែកទៅតាមថាតើគ្រួសារនោះមានសមាជិកម្នាក់ ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៨២

តារាង ៦.២ ៖ ចំនួនគ្រួសារធម្មតា បែងចែកតាមសម្ភារសាងសង់លំនៅដ្ឋានដែលពួកគេរស់នៅ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៨៤

តារាង ៦.៣ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមប្រភពភ្លើងបំភ្លឺ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៨៦

តារាង ៦.៤ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមប្រភពទឹកពិសាសំខាន់ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៨៧

តារាង ៦.៥ ៖ ចំនួនមធ្យមនៃសម្ភារបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដែលមានក្នុងគ្រួសារធម្មតា បែងចែកទៅតាមថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៨៨

តារាង ៦.៧ ៖ ចំនួនមធ្យមនៃយានយន្តធ្វើដំណើរដែលមានក្នុងគ្រួសារធម្មតា បែងចែកទៅតាមថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៩៣

តារាង ៧.១ ៖ ការចូលរៀននៅសាលារបស់កុមារអាយុ ១៥-១៩ ឆ្នាំ និងមនុស្សពេញវ័យអាយុ ២០-២៤ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ភេទ និងក្រុមអាយុទូទៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៩៧

តារាង ៧.២ ៖ មុខវិជ្ជាសិក្សាដ៏ពេញនិយមទាំង ១០ សម្រាប់ប្រជាជនអាយុ ១៥ ឆ្នាំឡើង បែងចែកតាមស្ថានភាពពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ១០៩

តារាង ៩.១ ៖ មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ១២២

តារាង ៩.១.ខ ៖ មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក បែងចែកតាមភេទ និងកម្រិតពិការភាពសម្រាប់ប្រជាជនដែលរស់នៅក្នុងគ្រួសារស្ថាប័ន CPHC ឆ្នាំ ២០១៩ ........ ១២៣

តារាង ១០ ៖ ស្ថានភាពការងាររបស់ប្រជាជនទាំងអស់ដែលមានការងារធ្វើ ( ១៥-៦៤ ឆ្នាំ ) បែងចែកតាមកម្រិតពិការភាព និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ១៥០

# រូបភាព


រូប ១.១ ៖ គោលដៅទាំង ១០ នៃយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" ........ ២៩

រូប ២.១ ៖ សមាសភាគ និងអន្តរកម្មនៃគំរូជីវចិត្តសង្គម ICF ស្តីពីពិការភាព ........ ៣១

រូប ៣.១ ៖ គោលដៅជាយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ ២០១៩-២០២៣ ........ ៤១

រូប ៣.២ ៖ អត្រាប្រេវ៉ាឡង់ក្នុងជំរឿន និងការអង្កេតផ្សេងៗនៅកម្ពុជា ឆ្នាំ ២០០៧-២០១៩ ........ ៤៣

រូប ៤.១ ៖ អត្រាប្រេវ៉ាឡង់ពិការភាព បែងចែកតាមកម្រិតពិការភាព និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៤៥

រូប ៤.២ ៖ ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៤៦

រូប ៤.៣ ៖ ប្រេវ៉ាឡង់ពិការភាពរបស់ប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៤៧

រូប ៤.៤ ៖ ចំនួនប្រជាជនមានពិការភាព បែងចែកតាមចំនួនពិការភាព និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៤៩

រូប ៤.៥ ៖ ប្រេវ៉ាឡង់ពិការភាពបូកបន្តតាមអាយុ បែងចែកតាមកម្រិតសម្រាប់ប្រជាជនអាយុ ៥ ឆ្នាំឡើង និងក្រុមអាយុ ៥ ឆ្នាំ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៥១

រូប ៤.៦ ៖ អត្រាប្រេវ៉ាឡង់ពិការភាពតាមអាយុសម្រាប់ប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៥២

រូប ៤.៧ ៖ ពីរ៉ាមីតប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៥៣

រូប ៤.៨ ៖ ពីរ៉ាមីតប្រជាជនអាយុ ៥ ឆ្នាំឡើងដែលមានពិការភាព បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៥៤

រូប ៤.៩ ៖ ផលធៀបភេទតាមអាយុសម្រាប់ប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៥៥

រូប ៤.១០ ៖ ភាគរយប្រជាជនមានពិការភាព បែងចែកតាមកម្រិតពិការភាព ភេទ និងប្រភេទលំនៅដ្ឋាន ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៥៧

រូប ៤.១១.ក-ខ ៖ ប្រេវ៉ាឡង់ពិការភាព បែងចែកតាមកម្រិត និងខេត្ត ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៥៨

រូប ៥.១ ៖ ភាគរយប្រជាជន បែងចែកតាមកម្រិតពិការភាព និងទំនាក់ទំនងរបស់ពួកគេជាមួយមេគ្រួសារ ឬ

អ្នកដឹកនាំក្នុងស្ថាប័ន ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៦៤

រូប ៥.២ ៖ ភាគរយនៃមេគ្រួសារជាស្ត្រី បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៦៥

រូប ៥.៣ ៖ ភាគរយប្រជាជន បែងចែកតាមកម្រិតពិការភាព និងប្រភេទគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៦៧

រូប ៥.៤.ក ៖ ភាគរយតាមអាយុនៃបុរសដែលបានរៀបការ បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៦៩

រូប ៥.៤.ខ ៖ ភាគរយតាមអាយុនៃស្ត្រីដែលបានរៀបការ បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៦៩

រូប ៥.៥ ៖ អាយុជាមធ្យមនៅពេលរៀបការ (SMAM) បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៧០

រូប ៥.៦ ៖ មេគុណរីហ្គ្រេសិនឡូជីស្ទិក (logistic regression) សម្រាប់អ្នកមិនដែលរៀបការ (៣០-៣៤ ឆ្នាំ) ........ ៧២

រូប ៥.៧.ក ៖ ភាគរយបុរសដែលលែងលះ ឬរស់នៅបែកគ្នា បែងចែកតាមអាយុ និងកម្រិតពិការភាព ........ ៧៤

រូប ៥.៧.ខ ៖ ភាគរយស្ត្រីដែលលែងលះ ឬរស់នៅបែកគ្នា បែងចែកតាមអាយុ និងកម្រិតពិការភាព ........ ៧៤

រូប ៥.៨ ៖ អត្រាលទ្ធភាពបង្កើតកូនតាមអាយុ សម្រាប់ស្ត្រីអាយុ ១៥-៤៩ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៧៨

រូប ៦.១ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមបញ្ជាភាគទ្រព្យសម្បត្តិ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៨១

រូប ៦.២ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមការប្រើប្រាស់អ៊ីនធឺណិតក្នុង និងក្រៅផ្ទះ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៨៩

រូប ៦.៣ ៖ ផលធៀបឱកាសនៃរីហ្គ្រេសិនឡូជីស្ទិកសម្រាប់ការប្រើប្រាស់អ៊ីនធឺណិតក្នុងផ្ទះ ក្នុងចំណោមប្រជាជនអាយុ ១៥ ឆ្នាំឡើង ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៩០

រូប ៧.១ ៖ ការចូលរៀននៅសាលាសម្រាប់កុមារអាយុ ៥-៩ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ភេទ និងក្រុមអាយុទូទៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៩៦

រូប ៧.២ ៖ ការចូលរៀននៅសាលាសម្រាប់កុមារអាយុ ១០-១៤ ឆ្នាំ បែងចែកតាមពិការភាព ភេទ និងក្រុមអាយុទូទៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ........ ៩៦

រូប ៧.៣ ៖ កុមារអាយុ ៥-៩ ឆ្នាំ បែងចែកតាមកម្រិតថ្នាក់ នៅពេលជំរឿន និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៩៨

រូប ៧.៤ ៖ ផលធៀបឱកាសនៃរីហ្គ្រេសិនឡូជីស្ទិកសម្រាប់ការចូលរៀននៅសាលា ក្នុងចំណោមកុមារ/មនុស្សពេញវ័យអាយុ ៥-២៤ ឆ្នាំ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ៩៩

រូប ៧.៥ ៖ អត្រាអក្ខរភាពបែងចែកតាមកម្រិតពិការភាព និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១០២

រូប ៧.៦.ក ៖ ភាគរយមនុស្សប្រុសអាយុ ១៥ ឆ្នាំឡើង ដែលចេះអក្សរ បែងចែកតាមកម្រិតពិការភាព អាយុ និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១០៣

រូប ៧.៦.ខ ៖ ភាគរយមនុស្សស្រីអាយុ ១៥ ឆ្នាំឡើង ដែលចេះអក្សរ បែងចែកតាមកម្រិតពិការភាព អាយុ និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១០៣

រូប ៧.៧ ៖ ផលធៀបឱកាសនៃរីហ្គ្រេសិនឡូជីស្ទិក (អក្ខរភាព) សម្រាប់ប្រជាជនអាយុ ១០ ឆ្នាំឡើង ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១០៤

រូប ៧.៨ ៖ ស្ថានភាពនៃការអប់រំ បែងចែកតាមភេទ និងពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១០៥

រូប ៧.៩ ៖ ភាគរយប្រជាជនអាយុ ១៥ ឆ្នាំឡើង ដែលយ៉ាងហោចណាស់មានកម្រិតអប់រំខ្លះ ដែលបានឈប់រៀននៅថ្នាក់ទី ១-៦ ឬថ្នាក់ទី ៧-១២ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១០៧

រូប ៧.១០ ៖ ភាគរយប្រជាជនអាយុ ១៥ ឆ្នាំឡើង ដែលបានបញ្ចប់ ក) អនុវិទ្យាល័យ វិទ្យាល័យ ការសិក្សាវិជ្ជាជីវៈមុនមធ្យមសិក្សា ឬការសិក្សាវិជ្ជាជីវៈក្រោយមធ្យមសិក្សា និង ខ) កម្រិតសាកលវិទ្យាល័យ (បរិញ្ញាបត្រ អនុបណ្ឌិត ឬបណ្ឌិត) បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១០៨

រូប ៨.១ ៖ ស្ថានភាពសកម្មភាពសំខាន់ បែងចែកតាមកម្រិតពិការភាពរបស់ប្រជាជនអាយុ ១៥-៦៤ ឆ្នាំ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១១៣

រូប ៨.២ ៖ អត្រាការងារ-ប្រជាជនតាមអាយុ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១១៥

រូប ៨.៣ ៖ អត្រាគ្មានការងារធ្វើតាមអាយុ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១១៦

រូប ៨.៤ ៖ ភាគរយប្រជាជនអាយុ ១៥-៦៤ ឆ្នាំដែលប្រឡូកក្នុងកម្លាំងពលកម្ម បែងចែកតាមស្ថានភាពមានការងារធ្វើ និងគ្មានការងារធ្វើ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ..... ១១៧

រូប ៨.៥ ៖ ស្ថានភាពការងាររបស់ប្រជាជនមានការងារធ្វើទាំងអស់ (១៥-៦៤ ឆ្នាំ) បែងចែកតាមកម្រិតពិការភាព CPHC ឆ្នាំ ២០១៩ ១១៨

រូប ៩.១ ៖ ភាគរយប្រជាជនអាយុ ៥ ឆ្នាំឡើងដែលបានធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១២០

រូប ១០.១ ៖ ភាគរយកុមារអាយុ៥-១៤ ឆ្នាំ និងយុវជនអាយុ ១៥-២៤ ឆ្នាំ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១២៥

រូប ១០.២ ៖ ភាគរយប្រជាជនអាយុ ៥-២៤ ឆ្នាំដែលរស់នៅក្នុងគ្រួសារស្ថាប័ន បែងចែកតាមភេទ ក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១២៦

រូប ១០.៣ ៖ ភាគរយកុមារអាយុ ៥-១៤ ឆ្នាំ ដែលគ្មានម្តាយរស់នៅក្នុងគ្រួសារតែមួយ បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១២៧

រូប ១០.៤ ៖ ភាគរយកុមារអាយុក្រោម ១៨ ឆ្នាំ ដែលជាទូទៅធ្វើការនៅអំឡុងឆ្នាំមុនពេលជំរឿន បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១២៩

រូប ១០.៥ ៖ ភាគរយយុវជន "ដែលមិនកំពុងទទួលបានការអប់រំ ឬមានការងារធ្វើ" បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣០

រូប ១០.៦ ៖ ភាគរយប្រជាជនអាយុ ២០-២៤ ឆ្នាំដែលបានរៀបការមុនអាយុរៀបការស្របច្បាប់ (១៨ ឆ្នាំសម្រាប់ស្ត្រី និង ២០ ឆ្នាំសម្រាប់បុរស) បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣១

រូប ១០.៧.ក ៖ ភាគរយស្ត្រីដែលបានរៀបការមុនអាយុ ១៨ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣២

រូប ១០.៧.ខ ៖ ភាគរយបុរសដែលបានរៀបការមុនអាយុ ២០ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣២

រូប ១១.១ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំដែលរស់នៅក្នុងគ្រួសារមានសមាជិកតែម្នាក់ ឬគ្រួសារដែលមានតែប្តី និងប្រពន្ធ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣៥

រូប ១១.២ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលរស់នៅម្នាក់ឯង បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣៦

រូប ១១.៣ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំដែលរស់នៅក្នុងគ្រួសារធំ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣៧

រូប ១១.៤ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើង ដែលបច្ចុប្បន្នមិនទាន់រៀបការ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣៨

រូប ១១.៥ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលពោះម៉ាយ/មេម៉ាយ បែងចែកតាមកម្រិតពិការភាព និងអាយុ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៣៩

រូប ១១.៦ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើង ដែលពោះម៉ាយ/មេម៉ាយ បែងចែកតាមកម្រិតពិការភាព អាយុ និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៤០

១១.៣ ភាពក្រីក្រ ១៤០

រូប ១១.៧ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត ២ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៤១

រូប ១១.៨ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលមានការងារធ្វើ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៤២

រូប ១១.៩ ៖ ភាគរយប្រជាជនមានការងារធ្វើ បែងចែកតាមអាយុ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៤៣

រូប ១២.១ ៖ ផលធៀបនៃភាគរយបុរសទល់នឹងស្ត្រី ដែលរៀបការហើយ បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៤៥

រូប ១២.២ ៖ ភាគរយគ្រួសារដែលស្ថិតក្នុងបញ្ចភាគក្រីក្របំផុត បែងចែកតាមភេទរបស់មេគ្រួសារ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៤៧

រូប ១២.៣ ៖ អត្រាមានការងារធ្វើសម្រាប់ប្រជាជនអាយុ ១៥-៦៤ ឆ្នាំ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៤៩

រូប ១២.៤ ៖ អត្រាគ្មានការងារធ្វើសម្រាប់ប្រជាជនអាយុ ១៥-៦៤ ឆ្នាំ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៤៩

រូប ១៣.១ ៖ ទម្រង់សំណួរស្តីពីពិការភាពក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១៦២

# សេចក្តីសង្ខេប

ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនវ័យចាស់ គឺជាបាតុភូតសកល និងគួបផ្សំនឹងការកើនឡើងនៃជំងឺមិនឆ្លង ដូចជា មហារីក ជំងឺបេះដូងសរសៃឈាម បញ្ហាសុខភាពផ្លូវចិត្ត ជំងឺសួត និងជំងឺទឹកនោមផ្អែម។ កត្តាទាំងនេះធ្វើឱ្យចំនួនប្រជាជនមានពិការភាពកើនឡើងឆាប់រហ័សផងដែរ។ តាមការប៉ាន់ស្មានប្រជាជន ចំនួន ១ ពាន់លាននាក់ (ឬ ១៥ ភាគរយនៃចំនួនប្រជាជនសរុបក្នុងពិភពលោក) មានពិការភាពមួយចំនួន។ ក្នុងចំណោមនេះប្រជាជនអាយុ ១៥ ឆ្នាំឡើងចំនួន ១៩០ លាននាក់ មានការលំបាកខ្លាំងក្នុងការបំពេញមុខងារ (WHO,2020)។ ជាញឹកញាប់ ជនមានពិការភាពប្រឈមនឹងការមាក់ងាយ និងការរើសអើង និងជួបការលំបាកក្នុងការទទួលបានសេវាមានគុណភាពដែលត្រូវការចាំបាច់ ដូចជា ការថែទាំសុខភាព ការអប់រំ និងការងារ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះពិភពលោកបាន និងកំពុងខិតខំសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាពតាមរយៈការជំរុញឱ្យប្រទេសនានាចាត់វិធានការកាន់តែច្រើនក្នុងការតាក់តែងគោលនយោបាយ ការរៀបចំកម្មវិធី និងការស្រាវជ្រាវស្តីពីពិការភាព។ ក្របខណ្ឌជាតិ និងអន្តរជាតិ ដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ អនុសញ្ញាឆ្នាំ ២០០៦ ស្តីពីសិទ្ធិជនពិការ (CRPD) និងយុទ្ធសាស្ត្រអ៊ីនឈាន់សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០១៣-២០២២ គឺជាកាតាលីករ និងជាត្រីវិស័យសម្រាប់សកម្មភាពពាក់ព័ន្ធនឹងពិការភាពនៅជុំវិញពិភពលោក។

ព្រះរាជាណាចក្រកម្ពុជាក៏ប្រឈមនឹងបញ្ហាដូចគ្នានេះដែរ។ កម្ពុជាធ្លាប់ឆ្លងកាត់ប្រវត្តិសាស្ត្រដែលពោរពេញដោយអស្ថិរភាព ជម្លោះ និងអំពើហិង្សាដែលធ្វើឱ្យប្រជាជនខ្មែរជាច្រើនរស់នៅដោយទទួលរងផលវិបាកផ្លូវកាយ និងផ្លូវចិត្តអស់មួយជីវិត។ ការប្តេជ្ញាចិត្តថ្នាក់ជាតិក្នុងការបង្កើតសង្គមប្រកបដោយបរិយាបន្ន និងការធានាសិទ្ធិជនពិការត្រូវបានរំលេចឡើងតាមរយៈការអនុម័តក្របខណ្ឌផ្សេងៗនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ នៅខែ ធ្នូ ឆ្នាំ ២០១២ កម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញាឆ្នាំ ២០០៦ ស្តីពីសិទ្ធិជនពិការ ប៉ុន្តែមិនបានផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមនៃអនុសញ្ញានេះទេ។ អនុសញ្ញានេះជាសន្ធិសញ្ញាដ៏សំខាន់បំផុត និងត្រូវបានទទួលស្គាល់ជាអន្តរជាតិ ក្នុងការលើកកម្ពស់ និងការពារសិទ្ធិរបស់ជនពិការ។ ក្រៅពីនេះ កម្ពុជាបានអនុម័តរបៀបវារៈសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ និងយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត"។ ក្របខណ្ឌគតិយុត្តិថ្នាក់ជាតិដ៏សំខាន់ជាងគេស្តីពីពិការភាព គឺ "ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ" ដែលត្រូវបានចុះហត្ថលេខានៅឆ្នាំ ២០០៩ និងផ្តល់សច្ចាប័ននៅខែ ធ្នូ ឆ្នាំ ២០១២។ ច្បាប់នេះជួយឱ្យកម្ពុជាបំពេញការទទួលខុសត្រូវរបស់ខ្លួនក្រោមអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ មាត្រា ២ នៃច្បាប់នេះមានគោលបំណង ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ ស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈដើម្បីធានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញ និងដោយស្មើភាពនៃជនពិការក្នុងសកម្មភាពនានារបស់សង្គមនិងការពារសិទ្ធិសេរីភាពនិងផលប្រយោជន៍របស់ជនពិការ។ ក្រោមច្បាប់នេះ ក្រុមប្រឹក្សាសកម្មភាពជនពិការដើរតួនាទីជាអ្នកសម្របសម្រួល និងទីប្រឹក្សាថ្នាក់ជាតិស្តីពីពិការភាពក្នុងប្រទេសកម្ពុជា (ព្រះរាជាណាចក្រកម្ពុជា ២០០៩)។ បច្ចុប្បន្ន ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មបន្ថែមដើម្បីឱ្យកាន់តែបន្សុីគ្នានឹងអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងអភិក្រមផ្អែកតាមសិទ្ធិ ហើយនឹងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រីនៅឆ្នាំ ២០២១។ ដើម្បីពង្រឹងការអនុវត្តច្បាប់នេះ ក្រុមប្រឹក្សាសកម្មភាពជនពិការបានបង្កើតផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពទី ២ (២០១៩-២០២៣) ដែលកំណត់ចក្ខុវិស័យថា "ប្រជាជនមានពិការភាព និងក្រុមគ្រួសារ មានគុណភាពជីវិតល្អ ចូលរួមយ៉ាងសកម្មពេញលេញស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ព្រមទាំងមានការធ្វើបរិយាបន្នពិការភាពក្នុងគ្រប់វិស័យ និងការអភិវឌ្ឍ" (ក្រុមប្រឹក្សាសកម្មភាពជនពិការ ២០១៩)។

ដើម្បីពិនិត្យតាមដានវឌ្ឍនភាពឆ្ពោះទៅរកសម្រេចបានក្របខណ្ឌខាងលើ និងឆ្លើយតបនឹងតម្រូវការរបស់ជនមានពិការភាព ចាំបាច់ត្រូវមានការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីស្ថានភាពបច្ចុប្បន្ន។ ដូច្នេះ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បានបញ្ចូលសំណួរ ៦ របស់ក្រុមការងារវ៉ាស៊ីនតោន ឧបករណ៍អន្តរជាតិដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់ការលំបាកបំពេញមុខងារ ដូចជា សំណួរស្តីពីលំបាកដែលលើកឡើងដោយសមាជិកគ្រួសារម្នាក់ៗពាក់ព័ន្ធនឹងការមើល ការស្តាប់ ការដើរ ឬការឡើងជណ្តើរ ការចងចាំ ឬការគិត ការមើលថែខ្លួនឯង និងទំនាក់ទំនង។ កម្រិតនៃការលំបាករួមមាន មិនលំបាក លំបាកខ្លះ លំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានទាំងអស់។

ការគណនាប្រេវ៉ាឡង់ពិការភាពដោយផ្អែកតាមចម្លើយសំណួរទាំងនេះ គឺមិនងាយស្រួលនោះទេ។ បញ្ហាគឺនៅត្រង់ថា គ្មានគោលការណ៍គ្រឹះដើម្បីកំណត់ថាតើនរណាម្នាក់មានពិការភាព និងនរណាម្នាក់គ្មានពិការភាព។ ការលំបាកបំពេញមុខងារមិនអាចញែកបានសុក្រិត្យរវាង "ភាពអាចធ្វើបាន/មិនអាចធ្វើបាន" ឡើយ ប៉ុន្តែគ្របដណ្តប់លើវិសាលភាពធំទូលាយនៃលទ្ធភាព និងដែនកំណត់របស់បុគ្គលម្នាក់ៗ។ ការញែកដាច់គ្នារវាងពិការភាព និងគ្មានពិការភាព ជះឥទ្ធិពលយ៉ាងខ្លាំងលើការប៉ាន់ស្មានចំនួនជនមានពិការភាព។ ដើម្បីបញ្ចៀសបញ្ហានេះ ការលំបាកបំពេញមុខងារទាំង ៣ កម្រិត ឬ "កម្រិតពិការភាព" (ពិការខ្លះ ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន) ត្រូវបានបង្ហាញដាច់ដោយឡែកពីគ្នា ដើម្បីផ្តល់ទិដ្ឋភាពទាំងស្រុងស្តីពីអ្នកដែលងាយប្រឈមនឹងការផាត់ចេញក្នុងសង្គមដោយតែសារភាពមានកម្រិត នៃការបំពេញមុខងាររបស់ខ្លួន។

ក្នុងពេលធ្វើជំរឿននេះ កម្ពុជាមានប្រជាជនអាយុ ៥ឆ្នាំឡើងចំនួន ១៤,១ លាននាក់ដែលកំពុងរស់នៅក្នុងគ្រួសារធម្មតា និងគ្រួសារស្ថាប័ន។ តាមរយៈការឆ្លើយថា "លំបាកខ្លះ" "លំបាកខ្លាំង" ឬ "មិនអាចធ្វើអ្វីបាន" ទៅនឹងសំណួរ ១ ឬច្រើននៃសំណួរទាំង ៦ របស់ក្រុមការងារវ៉ាស៊ីនតោន កម្ពុជាមានប្រជាជនមានពិការភាពចំនួន ៦៩០.០០០ នាក់ ។ ក្នុងចំណោមនេះ ប្រជាជន ៥២៣.០០០ នាក់ (៣,៧១ ភាគរយនៃចំនួនប្រជាជនសរុប) ឆ្លើយថា ពិការខ្លះ (លំបាកខ្លះ), ១២០.០០០ នាក់ (០,៨៧ ភាគរយនៃចំនួនប្រជាជនសរុប) ឆ្លើយថាពិការខ្លាំង (លំបាកខ្លាំង) និង ៤៤.០០០ នាក់ (០,៣១ ភាគរយនៃចំនួនប្រជាជនសរុប) ឆ្លើយថា ពិការមិនអាចធ្វើអ្វីបាន(មិនអាចធ្វើអ្វីបាន)។ នៅពេលបូកសរុបពិការភាពទាំង ៣ កម្រិតនេះ ចំនួនប្រជាជនមានពិការភាពគឺស្មើនឹង ៤,៨៩ ភាគរយនៃចំនួនប្រជាជនសរុប។ មានន័យថា ពួកគេមានការលំបាកខ្លះ ឬលំបាកខ្លាំងក្នុងការបំពេញមុខងារយ៉ាងតិចមួយក្នុងចំណោមការបំពេញមុខងារទាំង ៦។ ប្រសិនបើគិតត្រឹមអ្នកដែលលំបាកខ្លាំង ឬលំបាកមិនអាចធ្វើអ្វីបាន អត្រាពិការភាពគឺត្រឹមតែ ១,១៨ ភាគរយប៉ុណ្ណោះ។ មានស្ត្រីច្រើនជាង បុរសដែលរាយការណ៍ថា ពិការខ្លះ (៤០៣.០០០ នាក់ ទល់នឹង ២៨៧.០០០ នាក់)។ ពិការភាពនៅកម្ពុជាមានទំនាក់ទំនងវិជ្ជមានទៅនឹងអាយុ ព្រោះថានៅពេលមនុស្សកាន់តែចាស់ លទ្ធភាពនៃការរាយការណ៍ពីពិការភាពក៏កើនឡើងផងដែរ។ គេមិនអាចកំណត់ថាតើតួលេខទាំងនេះកើនឡើង ឬថយចុះ បើធៀបនឹងលទ្ធផលជំរឿនឆ្នាំ ២០០៨ បានទេ ព្រោះមានការសួរសំណួរផ្សេងគ្នាក្នុងជំរឿនទាំងពីរនេះ។

ការប្រៀបធៀបអត្រាប្រេវ៉ាឡង់នៃជំរឿននៅកម្ពុជាធៀបនឹងប្រភពផ្សេងទៀតមានភាពស្មុគស្មាញព្រោះក្នុងករណីភាគច្រើន មានការប្រើប្រាស់និយមន័យផ្សេងគ្នា និងដោយសារភាពខុសគ្នានៃវិធីសាស្ត្រនៃការប្រមូលទិន្នន័យ។ នៅកម្ពុជា ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១៤ ជាប្រភពដ៏ល្អសម្រាប់ការប្រៀបធៀបជាមួយនឹងទិន្នន័យជំរឿន ព្រោះមានការសួរសំណួរដូចគ្នា។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាព ប្រជាជនកម្ពុជាចំនួន ៩,៥ ភាគរយដែលមានអាយុ ៥ ឆ្នាំឡើង គូសបញ្ជាក់ថា ពួកគេលំបាកខ្លះ លំបាកខ្លាំង ឬមិនអាចបំពេញមុខងារ ១ ឬច្រើន ក្នុងចំណោមមុខងារទាំង ៦ និង ២,១ ភាគរយ លើកឡើងថា លំបាកខ្លាំង ឬមិនអាចបំពេញមុខងារ ១ ឬច្រើន ក្នុងចំណោមមុខងារទាំង ៦។ ភាគរយទាំងនេះគឺខ្ពស់ខ្លាំង ជាងភាគរយដែលបានរាយការណ៍ក្នុងជំរឿនទូទៅ

ប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩។ មានន័យថា ក្នុងជំរឿននេះ ការរាប់ចំនួនជនមានពិការភាព គឺអាចទាបជាងចំនួនជាក់ស្តែង។ ដោយសារការរាយការណ៍ពីការលំបាកបំពេញមុខងារតិចជាងចំនួនជាក់ស្តែង គេគួរបកស្រាយតួលេខប្រេវ៉ាឡង់ពីជំរឿននេះដោយប្រុងប្រយ័ត្ន។ ទោះបីមានចំណុចខ្វះខាតក្តី ក៏ជំរឿននេះបានផ្តល់ព័ត៌មានសំខាន់ៗជាច្រើនដែលលម្អិត និងអាចជឿជាក់បានស្តីពីលក្ខណៈសង្គមសេដ្ឋកិច្ចរបស់ប្រជាជនមានពិការភាព និងលើកមកបង្ហាញក្នុងរបាយការណ៍នេះ។

គួរកត់សម្គាល់ថា ទោះបីមានការរាយការណ៍ពីការលំបាកបំពេញមុខងារទាបជាងចំនួនជាក់ស្តែងក្នុងជំរឿនប្រជាជនក្តី ក៏គេនៅតែអាចច្បាមយកព័ត៌មានដ៏មានតម្លៃពីទិន្នន័យទាំងនេះបាន។ នៅកម្ពុជា មានការប្រមូលបណ្តុំព័ត៌មានយ៉ាងច្រើនសន្ធឹកស្តីពីលក្ខណៈសង្គមសេដ្ឋកិច្ច និងស្ថានភាពរស់នៅរបស់ប្រជាជនចំនួន ៧០០.០០០នាក់ដែលរាយការណ៍ពីភាពមានកម្រិតក្នុងការបំពេញមុខងារ។ ដូច្នេះ ជំរឿននេះជាប្រភពព័ត៌មានដ៏ល្អសម្រាប់ការពិពណ៌នាពីលក្ខណៈ និងស្ថានភាពរស់នៅរបស់ជនមានពិការភាព ជាជាងជាវិធីសម្រាប់ប៉ាន់ស្មានប្រេវ៉ាឡង់ពិការភាពក្នុងប្រទេសកម្ពុជា។

របាយការណ៍នេះបង្ហាញពីស្ថានភាពរស់នៅរបស់ជនមានពិការភាពនៅកម្ពុជា ដូចជា ចរិតលក្ខណៈគ្រួសារ ស្ថានភាព អាពាហ៍ពិពាហ៍ ជីវភាពរស់នៅ ការអប់រំ សកម្មភាពសេដ្ឋកិច្ច ទេសន្តរប្រវេសន៍ជាដើម។ មានភាពខុសគ្នាសំខាន់ៗរវាងជនមានពិការភាព និងជនគ្មានពិការភាព ដែលគូសបញ្ជាក់ពីបញ្ហាប្រឈម និងការលំបាកកាន់តែខ្លាំងក្នុងចំណោមជនមានពិការភាព ជាពិសេសជនមានពិការភាពធ្ងន់ធ្ងរ។

ក្នុងចំណោមប្រជាជនមានពិការភាពទាំង ៦៩០.០០០ នាក់ដែលត្រូវបានរាប់ក្នុងជំរឿននេះ ៣៤,៧ ភាគរយរស់នៅទីប្រជុំជន និង ៦៥,៣ ភាគរយរស់នៅជនបទ។ មានភាពខុសគ្នាតិចតួចពាក់ព័ន្ធនឹងប្រភេទលំនៅដ្ឋានរវាងបុរសមានពិការភាព និងស្ត្រីមានពិការភាព (បុរសមានពិការភាពចំនួន ៣៥,១ ភាគរយ រស់នៅទីប្រជុំជន ធៀបនឹងស្ត្រីមានពិការភាពចំនួន ៣៤,៤ ភាគរយ) ប៉ុន្តែមានភាពខុសគ្នាច្រើនពាក់ព័ន្ធនឹងប្រេវ៉ាឡង់ពិការភាពតាមបណ្តាខេត្តក្នុងប្រទេសកម្ពុជា។ ខេត្តបាត់ដំបងមានភាគរយប្រជាជនមានពិការភាពខ្ពស់ជាងគេ (៦,២ ភាគរយ) បន្ទាប់មកគឺខេត្តកំពង់ឆ្នាំង (៥,៨ ភាគរយ) និងខេត្តកំពង់ចាម (៥,៦ ភាគរយ) រីឯទីក្រុងភ្នំពេញ និងខេត្តរតនគីរីជាខេត្តក្រុងដែលមានប្រេវ៉ាឡង់ពិការភាពទាបជាងគេ (៣,២ ភាគរយ)។

នៅកម្ពុជា អាយុស្របច្បាប់ដែលអាចរៀបការបានគឺ ១៨ ឆ្នាំសម្រាប់ស្ត្រី និង ២០ ឆ្នាំសម្រាប់បុរស។ បញ្ហានៃការរៀបការវ័យក្មេងកើតមានច្រើនក្នុងចំណោមស្ត្រីជាងក្នុងចំណោមបុរសៈ ក្នុងចំណោមស្ត្រីមិនពិការអាយុ២០-២៤ឆ្នាំ មាន ១៤,៩ ភាគរយ បានរៀបការមុនអាយុ ១៨ ឆ្នាំ ធៀបនឹងបុរសត្រឹមតែ ៨,១ ភាគរយ ដែលរៀបការមុនអាយុ ២០ ឆ្នាំ។ អត្រានៃការរៀបការវ័យក្មេង (ទាំងពីរភេទ) សម្រាប់ជនមានពិការភាពខ្លះគឺខ្ពស់បន្តិចជាងជនគ្មានពិការភាព ប៉ុន្តែមានកម្រិតកាន់តែទាបសម្រាប់ជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ ក្នុងចំណោមស្ត្រីអាយុ ២០-២៤ ឆ្នាំ ដែលមានពិការភាពខ្លះ មាន ១៦,៣ ភាគរយ បានរៀបការមុនអាយុ ១៨ ឆ្នាំ។ ក្នុងក្រុមអាយុដដែលនេះ ស្ត្រីមានពិការភាពខ្លាំងចំនួន ១១.០ ភាគរយ បានរៀបការមុនអាយុ ១៨ ឆ្នាំ ធៀបនឹងស្ត្រីដែលពិការមិនអាចធ្វើអ្វីបានចំនួន ៨,៤ ភាគរយ។

ភាគរយនៃប្រជាជនមានពិការភាពខ្លះដែលរៀបការក្រោយអាយុ ៣០ ឆ្នាំ គឺទាប ដោយជាទូទៅ ស្ត្រីមានប្រូបាបីលីតេនៃការស្ថិតក្នុងសម្ព័ន្ធអាពាហ៍ពិពាហ៍ ទាបជាងបុរស។ ភាគរយនៃស្ត្រី និងបុរសដែលបានរៀបការមានកម្រិតទាបខ្លាំងក្នុងចំណោមប្រជាជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ ឧ. ក្នុងក្រុមអាយុ ៤៥-៤៩ ឆ្នាំ

បុរសពិការមិនអាចធ្វើអ្វីបានចំនួន ៥២,៤ ភាគរយ បានរៀបការ ធៀបនឹងបុរសចំនួន ៩៣,៥ ភាគរយ ដែលមិនពិការ។ ក្នុងក្រុមអាយុដូចគ្នានេះ ស្ត្រីពិការមិនអាចធ្វើអ្វីបានចំនួន ៥៤,៤ ភាគរយ បានរៀបការ ធៀបនឹងស្ត្រីចំនួន ៨៥,២ ភាគរយ ដែលមិនពិការ។ ក្រៅពីនេះ ពិការភាពពាក់ព័ន្ធនឹងលទ្ធភាពកាន់តែខ្ពស់នៃការរស់នៅបែកគ្នា ឬការលែងលះក្នុងក្រុមអាយុ ៤០-៦០ ឆ្នាំដែលមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ធៀបនឹងជនគ្មានពិការភាព។ តួលេខទាំងនេះបង្ហាញថា ការមាក់ងាយអាចបង្កផលប៉ះពាល់លើអត្រារៀបការ ហើយមនុស្សចាស់ដែលមានពិការភាព ទាមទារការគាំទ្រ និងការថែទាំកាន់តែច្រើន ព្រោះពួកគាត់ច្រើនតែរស់នៅម្នាក់ឯង។

សន្ទស្សន៍ទ្រព្យសម្បត្តិ ត្រូវបានគណនាសម្រាប់គ្រួសារនីមួយៗ ដោយផ្អែកលើទិន្នន័យជំរឿន។ សន្ទស្សន៍នេះមានតម្លៃ ១-៥ និងបញ្ជាក់ពីបញ្ចភាគទ្រព្យសម្បត្តិរបស់គ្រួសារមួយ។ គ្រួសារដែលមាន ឬគ្មានសមាជិកមានពិការភាព រំលេចប្រភេទផ្សេងៗនៃសន្ទស្សន៍ទ្រព្យសម្បត្តិ។ ក្នុងចំណោមគ្រួសារដែលមានសមាជិកម្នាក់មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មាន ១៤,០ ភាគរយស្ថិតក្នុងបញ្ចភាគស្តុកស្តម្ភបំផុត ខណៈដែលក្នុងចំណោមគ្រួសារដែលគ្មានសមាជិកមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មាន ២០,៧ ភាគរយ ស្ថិតក្នុងបញ្ចភាគស្តុកស្តម្ភបំផុត។ ផ្ទុយទៅវិញ ក្នុងចំណោមគ្រួសារដែលមានសមាជិកម្នាក់មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មាន ២៣,៥ ភាគរយ ស្ថិតក្នុងបញ្ចភាគក្រីក្របំផុត ខណៈដែលក្នុងចំណោមគ្រួសារដែលគ្មានសមាជិកមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មាន ១៩,០ ភាគរយ ស្ថិតក្នុងបញ្ចភាគក្រីក្របំផុត។ ក្នុងចំណោមគ្រួសារដែលមានសមាជិកម្នាក់មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានភាពខុសគ្នារវាងគ្រួសារមានស្ត្រីជាមេគ្រួសារ និងគ្រួសារមានបុរសជាមេគ្រួសារ។ ២៣,៥ ភាគរយនៃគ្រួសារដែលមានបុរស ជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ស្ថិតក្នុងបញ្ចភាគក្រីក្របំផុត ធៀបនឹង ២៨,៨ ភាគរយនៃគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាពខ្លាំង ឬពិការ មិនអាចធ្វើអ្វីបាន។

ក្មេងប្រុស និងក្មេងស្រីដែលមានពិការភាព ជួបការលំបាកក្នុងការចូលរៀននៅសាលា។ ក្នុងក្រុមអាយុ ៥-៩ ឆ្នាំ ក្មេងប្រុសគ្មានពិការភាពចំនួន ២២,៥ ភាគរយ មិនបានចូលរៀន ធៀបនឹងក្មេងប្រុសមានពិការភាពខ្លាំងចំនួន ៤៨,៧ ភាគរយ និងក្មេងប្រុសពិការមិនអាចធ្វើអ្វីបានចំនួន ៥៩,៩ ភាគរយ។ និន្នាការនេះមានភាពប្រហាក់ប្រហែលគ្នាសម្រាប់ក្មេងស្រី។ ក្នុងចំណោមក្មេងប្រុស និងក្មេងស្រីអាយុ ៥-៩ ឆ្នាំដែលមិនពិការ មានក្មេងប្រុសចំនួន ៧៦,៧ ភាគរយ និងក្មេងស្រីចំនួន ៧៧,៨ ភាគរយ បានចូលរៀននៅសាលា។ អត្រាចូលរៀននៅសាលាគឺ ៤៨.០ ភាគរយសម្រាប់ក្មេងប្រុសមានពិការភាពខ្លាំង និង ៣៨,៥ ភាគរយ សម្រាប់ក្មេងប្រុសពិការមិនអាចធ្វើអ្វីបាន និង ៥៣,៧ ភាគរយ សម្រាប់ក្មេងស្រីមានពិការភាពខ្លាំង និង ៤៥,៣ ភាគរយ សម្រាប់ក្មេងស្រីពិការមិនអាចធ្វើអ្វីបាន។ ក្នុងក្រុមអាយុ ១០-១៤ ឆ្នាំ, ១៥-១៩ ឆ្នាំ និង ២០-២៤ ឆ្នាំ កុមារ និងយុវជន មានពិការភាព ជួបការលំបាកក្នុងការចូលរៀននៅសាលា។ តួលេខសម្រាប់ក្រុមអាយុទាំងអស់គូសបញ្ជាក់ថា គួរផ្តោតកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងលើការលើកកម្ពស់ការអប់រំប្រកបដោយបរិយាបន្ន។

ការងារសមរម្យបង្កើតភាពអង់អាចផ្នែកសេដ្ឋកិច្ច ដែលជួយឱ្យមានភាពម្ចាស់ការក្នុងការរស់នៅ។ នេះជាវិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការលុបបំបាត់វដ្តនៃភាពក្រីក្រ និងការលំបាកក្នុងចំណោមប្រជាជនទាំងអស់ រួមទាំងជនមានពិការភាព។ ផលធៀបការងារ-ប្រជាជន បង្ហាញថា ខណៈដែលប្រជាជនមិនពិការក្នុងក្រុមអាយុ ១៥-៦៤ ឆ្នាំ ចំនួនជាង ៨០ ភាគរយ មានការងារធ្វើនៅអំឡុងឆ្នាំមុនពេលជំរឿន អត្រានេះគឺទាបជាងពាក់កណ្តាល សម្រាប់ប្រជាជនពិការមិនអាចធ្វើអ្វីបាន។ ជនមានពិការភាពខ្លាំងមានពិន្ទុទាបជាងជនគ្មានពិការភាព ជាង ២០ ភាគរយ ខណៈដែលជនពិការមិនអាចធ្វើអ្វីបាន មានពិន្ទុទាបជាងជនមិនពិការ ជាង ៣០ ភាគរយ។

ក្រៅពីនេះ លទ្ធផលរកឃើញពីជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បានបង្ហាញលទ្ធផលគួរឱ្យចាប់អារម្មណ៍ស្ដីពីសម្ភារ និងឧបករណ៍ប្រើប្រាស់ក្នុងគ្រួសារ។ គេមិនអាចកំណត់និន្នាការពិតប្រាកដដោយផ្អែកតាមប្រភេទនៃការផ្គត់ផ្គង់ទឹកសម្រាប់កម្រិតពិការភាពផ្សេងៗបានឡើយ។ ចំណុចខុសគ្នាដែលគួរឱ្យកត់សម្គាល់ គឺគ្រួសារ ដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មិនសូវមានលទ្ធភាពភ្ជាប់បណ្ដាញទឹកបំពង់ក្នុងលំនៅដ្ឋាន (២៥,៦ ភាគរយ សម្រាប់គ្រួសារដែលគ្មានសមាជិកមានពិការភាព ធៀបនឹង ២២,៤ ភាគរយសម្រាប់គ្រួសារដែលមានសមាជិកម្នាក់មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន)។ ក្រៅពីនេះ គ្រួសារដែលមានសមាជិកយ៉ាងតិចម្នាក់មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានចំនួនវិទ្យុប្រើប្រាស់ច្រើនជាង និងចំនួនទូរទស្សន៍ប្រើប្រាស់ដូចគ្នា ប៉ុន្តែមានចំនួនទូរស័ព្ទដៃ និងកុំព្យូទ័រប្រើប្រាស់តិចជាង និងមិនសូវមានលទ្ធភាពប្រើប្រាស់បណ្ដាញអ៊ីនធឺណិតក្នុងផ្ទះ។ គ្រួសារមានស្ត្រីជាមេគ្រួសារដែលមាន និងគ្មានសមាជិកមានពិការភាព មិនសូវមានសម្ភារឧបករណ៍ទាំងនេះសម្រាប់ការប្រើប្រាស់នោះទេ។

យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ប្រជាជនចំនួន ៣០៩.០០០ នាក់ រស់នៅក្នុងគ្រួសារស្ថាប័ន ។ ក្នុងចំណោមប្រជាជនមិនពិការអាយុ ៥ ឆ្នាំឡើង មាន ២,០ ភាគរយ រស់នៅក្នុងគ្រួសារស្ថាប័ន ធៀបនឹង ៤,០ ភាគរយនៃប្រជាជនមានពិការភាពខ្លាំង និង ៩,១ ភាគរយនៃប្រជាជនពិការមិនអាចធ្វើអ្វីបាន។ សម្រាប់កម្រិតពិការភាពនីមួយៗ ភាគរយបុរសដែលរស់នៅក្នុងគ្រួសារស្ថាប័នគឺខ្ពស់ជាងស្ត្រី។ គួរឱ្យសោកស្ដាយដែលសំណួរស្ដីពីប្រភេទគ្រួសារស្ថាប័ន មិនត្រូវបានបញ្ចូលក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩។

## អនុសាសន៍

អនុសាសន៍សំខាន់ៗមួយចំនួនត្រូវបានដាក់ចេញ ដោយផ្អែកតាមលទ្ធផលរកឃើញក្នុងរបាយការណ៍នេះ ៖

- សង្គមគួរផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើលទ្ធភាពទទួលបានការអប់រំរបស់កុមារ និងយុវជនមានពិការភាព។ ដើម្បីសម្រេចគោលដៅអ៊ីនឈាន់នៃការកាត់បន្ថយគម្លាតនៃការចុះឈ្មោះចូលរៀននៅបឋមសិក្សា និងមធ្យមសិក្សាឱ្យបាន ៥០ ភាគរយ កម្ពុជាត្រូវខិតខំប្រឹងប្រែងយូរអង្វែងទៅមុខទៀត។ ប្រព័ន្ធអប់រំនៅកម្ពុជាគួរធានាថា ជនមានពិការភាព "អាចទទួលបានឱកាសអប់រំ និងឱកាសសិក្សាពេញមួយជីវិតប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌" ដូចមានចែងក្នុងគោលនយោបាយស្ដីពីការអប់រំប្រកបដោយបរិយាបន្ន ដែលត្រូវបានអនុម័តនៅខែ មិថុនា ឆ្នាំ ២០១៨ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨ ទំ. ៣) និងតម្រឹមតម្រង់សកម្មភាពនៃគោលនយោបាយនេះឱ្យបន្សុីគ្នានឹងផែនការសកម្មភាពស្ដីពីការអប់រំប្រកបដោយបរិយាបន្ន ២០១៩-២០២៣ (អរយក ២០១៩)។ គួរផ្ដោតការយកចិត្តទុកដាក់បន្ថែមទៀតលើអ្នករស់នៅក្នុងគ្រួសារស្ថាប័ន។ ការជំរុញលើកទឹកចិត្តឱ្យរស់នៅដោយ ឯករាជ្យ ឬរស់នៅជាមួយគ្រួសារ នឹងផ្ដល់ប្រយោជន៍ដល់ជនមានពិការភាព។
- ជនមានពិការភាពច្រើនតែរស់នៅជនបទ និងប្រមូលផ្ដុំតាមតំបន់មួយចំនួន។ គេមិនច្បាស់ថាតើរបាយតាមតំបន់ឆ្លុះបញ្ចាំងពីកំហុសក្នុងការប្រមូលទិន្នន័យ ឬរំលេចទិដ្ឋភាពត្រឹមត្រូវនោះទេ។ ដូច្នេះចាំបាច់ ត្រូវមានការស្រាវជ្រាវបន្ថែមដើម្បីកំណត់ឱ្យបានច្បាស់។ ដំណោះស្រាយសមស្រប គឺសកម្មភាពស្រាវជ្រាវបន្ថែមដល់តំបន់មានអ្នករស់នៅមិនប្រមូលផ្ដុំ និងពិបាកចូលដល់។

- ជនមានពិការភាព មានអត្រារៀបការទាប ប៉ុន្តែមានអត្រាខ្ពស់នៃការលែងលះ និងការរស់នៅបែកគ្នា។ ដូច្នេះ គួរខិតខំកាត់បន្ថយដើមហេតុបង្កការលំបាកទាំងនេះ និងគួរផ្តល់ការគាំទ្រគ្រប់គ្រាន់ដើម្បីជួយសម្រាល ទុក្ខលំបាករបស់ជនមានពិការភាព។

- ចាំបាច់ត្រូវមានកិច្ចខិតខំបន្ថែមទៀត ដើម្បីធានាការងារសមរម្យសម្រាប់ជនមានពិការភាព ព្រោះពួកគេមានផលធៀបការងារ-ប្រជាជន ទាបជាងជនគ្មានពិការភាព។ ច្បាប់ និងគោលនយោបាយបែប បរិយាបន្នដូចជា ការកំណត់កូតាដើម្បីបង្កើនឱកាសការងារសម្រាប់ជនមានពិការភាព និងរបបគាំពារសង្គម ត្រូវបង្កើតឡើង និង/ឬ អនុវត្តបន្ថែមទៀត។ ចាំបាច់ត្រូវបង្កើតអន្តរាគមន៍/សេវាបែបបរិយាបន្ន និងបង្កើនលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធទាំងក្នុង និងក្រៅកន្លែងធ្វើការ។

- ត្រូវដោះស្រាយបញ្ហានៃការរើសអើង និងមាក់ងាយពិការភាព ក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗ ដូចជានិយោជក សាលារៀន អ្នកផ្តល់សេវា គ្រួសារ និងសហគមន៍ អ្នកតាក់តែងគោលនយោបាយ។ល។

- ត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងសម្រាប់ស្ត្រី និងក្មេងស្រីដែលមានពិការភាព ព្រោះពួកគេប្រឈមនឹងការលំបាកជាងបុរសមានពិការភាព។ ដូច្នេះ គួរបង្កើតសេវា និងកម្មវិធីជាក់លាក់ដើម្បីលុបបំបាត់វិសមភាពយេនឌ័រក្នុងពិការភាព។ លើសពីនេះទៀតគឺត្រូវបញ្ជ្រាបពិការភាព និងយេនឌ័រក្នុងគ្រប់គោលនយោបាយ និងវដ្តជីវិត។

- ភាគច្រើននៃកិច្ចខិតខំប្រឹងប្រែងដែលលើកឡើងខាងលើ មានចែងក្នុងច្បាប់ ឬផែនការយុទ្ធសាស្ត្រស្តីពីពិការភាព ប៉ុន្តែចាំបាច់ត្រូវបង្កើតធនធាន ការប្តេជ្ញាចិត្តផ្នែកនយោបាយ និងទិន្នន័យឱ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្តកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងតាមដានវឌ្ឍនភាពនៃការសម្រេចបានគោលដៅដែលចង់បាន។

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ បានបង្ហាញលក្ខណៈគួរឱ្យចាប់អារម្មណ៍ជាច្រើនរបស់ជនមានពិការភាព និងគ្រួសារដែលមានសមាជិកមានពិការភាព ធៀបនឹងជនគ្មានពិការភាព និងគ្រួសារដែលគ្មានសមាជិកមានពិការភាព។ ទោះជាយ៉ាងណា ទិន្នន័យស្តីពីពិការភាពក្នុងជំរឿននេះមិនអាចល្អឥតខ្ចោះនោះទេ។ មានកត្តាជាច្រើនដែលបង្កការលំបាកដល់ការកំណត់អត្តសញ្ញាណជនមានការលំបាកមួយ ឬច្រើន ក្នុងការបំពេញមុខងារទាំង ៦ ដូចជា ១) ការមាក់ងាយជាបន្តបន្ទាប់ និងកត្តាសង្គមវប្បធម៌ដែលច្រើនតែរាំងមិនឱ្យមន្ត្រីសម្ភាសន៍ និងអ្នកតបសម្ភាសន៍ផ្តល់ព័ត៌មានត្រឹមត្រូវឱ្យបានគ្រប់ពេលវេលា ២) គ្មានការប្រមូលទិន្នន័យស្តីពីពិការភាពសម្រាប់កុមារអាយុក្រោម៥ ឆ្នាំ ៣) ការរៀបចំសំណួរក្នុងកម្រងសំណួរអាចបង្កការភាន់ច្រឡំសម្រាប់មន្ត្រី សម្ភាសន៍ជាច្រើននាក់ និងធ្វើឱ្យពួកគេមិនអាចទទួលបានព័ត៌មានសម្រាប់សមាជិកគ្រួសារទាំងអស់ និងគូសបញ្ជាក់ដោយមិនត្រឹមត្រូវថា មនុស្សម្នាក់មានការលំបាកក្នុងការធ្វើសកម្មភាពទាំង ៦។ ខាងក្រោមនេះជាអនុសាសន៍ ដើម្បីកែលម្អការប្រមូលទិន្នន័យស្តីពីជនមានពិការភាព៖

- ធ្វើការស្រាវជ្រាវបន្ថែមដើម្បីស្វែងយល់ឱ្យបានច្បាស់ពីស្ថានភាពរបស់កុមារអាយុក្រោម ៥ ឆ្នាំដែលមានពិការភាព។ ចំណុចនេះអាចកែលម្អអន្តរាគមន៍ពីដំបូង និងបញ្ចៀសផលវិបាកអវិជ្ជមាននៃការពន្យារពេលផ្តល់សេវា ឬការគាំទ្រ។

- ធ្វើការស្រាវជ្រាវបន្ថែមស្តីពីពិការភាព ដោយប្រើកម្រងសំណួរបន្ថែមរបស់ក្រុមការងារវ៉ាស៊ីនតោនដើម្បីយល់កាន់តែច្បាស់អំពីប្រភេទទាំងអស់នៃពិការភាព និងបង្កើតទិដ្ឋភាពពេញលេញនៃពិការភាពក្នុង

ប្រទេសកម្ពុជា។ គួរធ្វើការស្រាវជ្រាវបន្ថែមក្នុងការអង្កេតដោយឡែកមួយ (មិនមែនជំរឿន) និងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍។

- ធានាថា សំណួរក្នុងជំរឿនលើកក្រោយ មានលក្ខណៈពេញលេញ និងត្រូវបានសួរទៅតាមគោលបំណង ហើយមន្ត្រីសម្ភាសន៍ត្រូវបានបណ្តុះបណ្តាលសមស្របដើម្បីទទួលបានចម្លើយកាន់តែសុក្រឹត។ បន្ថែមសំណួរស្តីពីដើមហេតុបង្កពិការភាព និងសួរអ្នកតបសម្ភាសន៍ទាំងអស់ស្តីពីផ្នែកជំនាញ និងការធ្វើសំបុត្រកំណើត។
- លើកកម្ពស់ការប្រមូលទិន្នន័យស្តីពីពិការភាព និងការបែងចែកទិន្នន័យជាប្រភេទបានឱ្យគ្រប់គ្រាន់ ដូចជា ពិការភាព និងភេទ អាយុ ប្រាក់ចំណូល ប្រភេទពិការភាព ក្រុមសង្គម។
- បង្កើនគុណភាពនៃទិន្នន័យជំរឿនស្តីពីពិការភាព ដោយកែលម្អទម្រង់កម្រងសំណួរ។ ជម្រើសមួយគឺការប្រើកម្រងសំណួរទម្រង់ឌីជីថល។

# ជំពូក ១៖ សេចក្តីផ្តើម

ចំនួនប្រជាជនវ័យចាស់ក្នុងពិភពលោកកំពុងកើនឡើងយ៉ាងឆាប់រហ័ស ខណៈដែលជំងឺមិនឆ្លង ដូចជា មហារីក ទឹកនោមផ្អែម ជំងឺបេះដូងសរសៃឈាម និងបញ្ហាសុខភាពផ្លូវចិត្ត ក៏មានការកើនឡើងផងដែរ។ ទោះបីប្រជាជនកាន់តែច្រើនមានអាយុវែងជាងមុនក្តី ប៉ុន្តែពួកគេច្រើនតែមានពិការភាពនៅដំណាក់កាលមួយចំនួនក្នុងជីវិត។ ជម្លោះ និងសង្គ្រាម បានរួមចំណែកបង្កើនពិការភាពរាងកាយ និងពិការភាពផ្លូវចិត្ត ដែលជាញឹកញាប់មានរយៈពេលជាច្រើនឆ្នាំក្រោយការបញ្ចប់ជម្លោះ។ ឧ. គ្រាប់មីនកប់ក្នុងដី និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ERWs) ជាដើមហេតុបង្កឱ្យដាច់អវៈយវៈ និងបាត់បង់អាយុជីវិត។

ពិការភាពត្រូវបានចាត់ទុកជាទស្សនាទានដែល "ស្មុគស្មាញ រស់រវើក ពហុវិស័យ និងមានការជេញដោល" និងវិវត្តឥតឈប់ឈរ (WHO & World Bank, 2011, p. 3)។ ដូច្នេះ គេពិបាកនឹងកំណត់ និងវាស់វែងពិការភាពឱ្យបានសុក្រឹត្យ។ និយមន័យខុសគ្នាធ្វើឱ្យមានទិន្នន័យប្រេវ៉ាឡង់ខុសគ្នា ដែលបង្កការលំបាកដល់ការប្រៀបធៀប។ ដូច្នេះ គ្មានចំនួនជាក់លាក់នៃប្រជាជនមានពិការភាព ឬអត្រាប្រេវ៉ាឡង់ជាក់លាក់នៃពិការភាពឡើយ។ ទោះជាយ៉ាងណា ការប្រើប្រាស់ដែនកំណត់ច្បាស់លាស់អាចឱ្យគេផ្តល់ព័ត៌មានដែលអាចជឿជាក់បាន។

នៅឆ្នាំ ២០០៦ អង្គការសុខភាពពិភពលោក ព្យាយាមគណនាប្រេវ៉ាឡង់នៃពិការភាពទូទាំងពិភពលោក ដោយផ្អែកលើទិន្នន័យអង្កេតសុខភាពពិភពលោក (២០០២-២០០៤) ដែលប្រមូលបានពី ៥៩ ប្រទេស និងការសិក្សាអំពីបន្ទុកជំងឺជាសកលរបស់អង្គការសុខភាពពិភពលោក (បច្ចុប្បន្នភាពឆ្នាំ ២០០៤)។ ដើម្បីប៉ាន់ស្មានប្រេវ៉ាឡង់ពិការភាពពីការអង្កេតសុខភាពពិភពលោក គេដាក់ពិន្ទុមនុស្សម្នាក់ៗ ពី ០ ដល់ ១០០ ដែលពិន្ទុខ្ពស់បង្ហាញពីភាពធ្ងន់ធ្ងរនៃពិការភាព និងមានការប្រើប្រាស់កម្រិត ២ ៖ ៤០ ដើម្បីគូសបញ្ជាក់ពីការលំបាកខ្លាំងគួរឲ្យកត់សម្គាល់ ក្នុងការធ្វើកិច្ចការប្រចាំថ្ងៃ និង ៥០ ដើម្បីគូសបញ្ជាក់ពីការលំបាកខ្លាំង។ ការសិក្សាអំពីបន្ទុកជំងឺជាសកល គណនាភាពធ្ងន់ធ្ងរនៃពិការភាពដោយប្រើប្រាស់ប្រេវ៉ាឡង់នៃជំងឺ របួស និងរបាយដែនកំណត់ក្នុងការបំពេញមុខងារ[1]។ ដោយបូកបញ្ចូលវិធីសាស្ត្រទាំងពីរនេះ អង្គការសុខភាពពិភពលោកប៉ាន់ស្មានថា ប្រជាជន ១ ពាន់លាននាក់ ឬ ១៥ ភាគរយនៃប្រជាជនសរុបទូទាំងពិភពលោក មានពិការភាពមួយចំនួន។ ក្នុងនោះ ប្រជាជន ១៩០ លាននាក់ (១៥ ឆ្នាំឡើង) មានការលំបាកខ្លាំងក្នុងការបំពេញមុខងារ (អង្គការសុខភាពពិភពលោក ២០២០)។

ចំនួនប្រជាជនមានពិការភាពក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ត្រូវបានប៉ាន់ស្មានថាមាន ៦៩០ លាននាក់ (នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ-UNDESA ២០១៨)។ និន្នាការប្រជាសាស្ត្រ និងការកើនឡើងនៃបញ្ហាសុខភាពរ៉ាំរ៉ៃ កំពុងធ្វើឱ្យចំនួនប្រជាជនមានពិការភាពកើនឡើងយ៉ាងគំហុក។ ភាគច្រើននៃប្រជាជនមានពិការភាពទាំងនេះត្រូវបានចាត់ទុកជាក្រុមចាញ់ប្រៀប (second-class citizens) និងត្រូវបានផាត់ចេញពីទិដ្ឋភាពជាច្រើនក្នុងសង្គម។ ជាទូទៅ ពួកគេគ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានសេវាថែទាំសុខភាព និងសេវាស្តារលទ្ធភាពពលកម្មដែលមានគុណភាព ដោយសារថ្លៃខ្ពស់ពេក ភាពអាចរកបានមានកម្រិត របាំងរូបវន្ត និងកង្វះជំនាញ និងចំណេះដឹងរបស់បុគ្គលិកសុខភាព (WHO, ២០២០)។ ជាញឹកញាប់ ពួកគេក៏មិនសូវមានលទ្ធភាពទទួលបានការអប់រំ ឬការងារផងដែរ (UNDESA ២០១៨)។

[1] សម្រាប់ការពិពណ៌នាពេញលេញស្តីពីវិធីសាស្ត្រដែលប្រើប្រាស់ក្នុងរបាយការណ៍ពិការភាពពិភពលោក សូមមើល WHO & World Bank (២០១១) ឧបសម្ព័ន្ធបច្ចេកទេស ខ (ទំ. ២៨១) និងឧបសម្ព័ន្ធ គ (ទំ. ២៨៧)។

ការកំណត់និយមន័យនៃ "ពិការភាព" ចែកចេញជា ២ ប្រភេទ ៖ គំរូវេជ្ជសាស្ត្រ និងគំរូសង្គម។ គំរូវេជ្ជសាស្ត្រផ្ដោតលើអសមត្ថភាពកាយសម្បទា ដែលជា "បញ្ហាចោទ" របស់ជនមានពិការភាព ខណៈដែលគំរូសង្គមចាត់ទុកសង្គមជាកត្តាបង្អាក់ ដែលបង្កើតឧបសគ្គដល់ជនមានការលំបាកបំពេញមុខងារ។ យូរៗទៅ គំរូសង្គមដែលកាន់តែមានបរិយាបន្ន ត្រូវបានប្រើប្រាស់ទូលំទូលាយជាងគំរូវេជ្ជសាស្ត្រ រហូតមានការទទួលយកជាទូទៅថា គួរបង្កើត ឬកែសម្រួលកាលៈទេសៈដើម្បីឱ្យជនមានពិការភាពទាំងអស់អាចចូលរួមពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃសង្គម (University of Leicester, n.d.)។ ទិន្នន័យដែលមានគុណភាពស្ដីពីពិការភាព ជួយដល់ការកំណត់រកបញ្ហាប្រឈមរបស់ជនមានពិការភាព ប៉ុន្តែជាញឹកញាប់ ការប្រមូលទិន្នន័យត្រូវបានបង្អាក់ដោយការ មាក់ងាយរើសអើងដែលនាំដល់ការបិទបាំងទំហំពិតប្រាកដនៃស្ថានភាព (Pettinicchio & Maroto ២០២១)។ ដូច្នេះហើយទើបមានភស្តុតាងតិចតួចស្ដីពីពិការភាពក្នុងបណ្ដាប្រទេសជាច្រើននៅជុំវិញពិភពលោក។ ដើម្បីដោះស្រាយបញ្ហានេះ និងការពារសិទ្ធិរបស់ជនមានពិការភាព សកលលោកបាន និងកំពុងជំរុញការអភិវឌ្ឍដែលមានបរិយាបន្នពិការភាព រួមទាំងការផលិតទិន្នន័យស្ដីពីពិការភាពបែងចែកជាប្រភេទ ឱ្យកាន់តែច្រើន និងប្រសើរជាងមុន។ របាយការណ៍បែងចែកតាមវិស័យស្ដីពីពិការភាពនៅកម្ពុជា គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ និងមានគោលបំណងលុបបំបាត់ចំណុចវាំងស្ទះមួយចំនួនក្នុងប្រទេសកម្ពុជា។

សកម្មភាពដែលផ្អែកតាមពិការភាព និងមានការបញ្ជ្រាបពិការភាព ត្រូវបានដាក់បញ្ចូលក្នុងក្របខណ្ឌអន្តរជាតិ ក្របខណ្ឌតំបន់ និងក្របខណ្ឌជាតិជាច្រើន ដូចជា របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងអនុសញ្ញាស្ដីពីសិទ្ធិជនពិការ (CRPD)។ ក្របខណ្ឌអភិវឌ្ឍន៍ដែលមានបរិយាបន្នពិការភាពនៅតំបន់អាស៊ីប៉ាស៊ីហ្វិក រួមមានសេចក្ដីប្រកាសថ្នាក់រដ្ឋមន្ត្រីស្ដីពីទសវត្សរ៍ជនមានពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ ២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" សម្រាប់ប្រជាជនមានពិការភាព។

ការអំពាវនាវជារួមនៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃរបៀបវារនេះ (GDGs) មានគោលបំណងបង្កើតសង្គមដែលមានសមធម៌ និងបរិយាបន្ន និងមិនមាននរណាម្នាក់ត្រូវបានទុកចោល។ ចំណុចដ៏សំខាន់មួយគឺការបង្កើនសិទ្ធិអំណាចរបស់ជនស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ដូចជា ការបំពេញតម្រូវការរបស់ជនមានពិការភាព និងក្រុមជួបការលំបាកផ្សេងទៀត (ឧ. ជនភៀសខ្លួន និងជនបាត់បង់ទីលំនៅក្នុងប្រទេស)។ ពិការភាពជាបញ្ហាអន្តរវិស័យក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១៧ ព្រោះវាពាក់ព័ន្ធនឹងដំណើរជីវិត និងផ្នែកទាំងអស់នៃជីវិតមនុស្សម្នាក់ៗ។ ដូច្នេះ គួរពិចារណាអំពីពិការភាពក្នុងការអនុវត្តគោលដៅទាំងអស់នេះ ដោយកត់សម្គាល់ថា ជនមានពិការភាពជាភ្នាក់ងារផង និងជាអ្នកទទួលផលផង។ មានចំណុចដៅ ៧ និងសូចនាករ ១០ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលផ្ដោតសំខាន់លើជនមានពិការភាព៖ លទ្ធភាពទទួលបានការអប់រំ និងការងារ ការមានសាលារៀនដែលគិតគូរពីសិស្សមានពិការភាព បរិយាបន្ន និងការបង្កើនភាពអង់អាចរបស់ជនមានពិការភាព មធ្យោបាយធ្វើដំណើរដែលផ្ដល់ភាពងាយស្រួល ទីកន្លែងសាធារណៈ និងទីធ្លាបរិស្ថានបៃតងដែលអាចចេញចូលបាន និងការកសាងសមត្ថភាពរបស់ប្រទេសនានាក្នុងការបែងចែកទិន្នន័យបែងចែកតាមពិការភាព" (United Nations (UN), n.d.a, p.1)។

ការរៀបរាប់លម្អិតអំពីចំណុចដៅ និងសូចនាករនីមួយៗដែលលើកឡើងពី "ពិការភាព" ក្នុងក្របខណ្ឌសូចនាករសកលសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងចំណុចដៅនៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព មានបង្ហាញក្នុងតារាង ១.១។ គួរកត់សម្គាល់ថា ការកែសម្រួលក្របខណ្ឌសូចនាករសកលឆ្នាំ ២០២១ មិនបានបញ្ជាក់ពី "ពិការភាព" ក្នុងសូចនាករ ៤.ក.១ ដូចពីមុនឡើយ (UNDESA ២០២១)។

អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) ជាសន្ធិសញ្ញាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដែលលើកកម្ពស់ ការពារ និងធានាសេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្សរបស់ជនមានពិការភាពទូទាំងសកលលោក។ អនុសញ្ញានេះផ្អែកតាមគោលការណ៍ ៨ ចំណុច ៖ ការគោរព ការមិនរើសអើង សមភាព បរិយាបន្ន សមភាពនៃឱកាស សមភាពយេនឌ័រ ការគោរពការវិវត្តសមត្ថភាពរបស់កុមារមានពិការភាព និងភាពងាយស្រួលទទួលបាន[2] (UN, n.d.b.)។ តំបន់អាស៊ីប៉ាស៊ីហ្វិកបានបង្កើត "ទសវត្សរ៍ជនមានពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ ២០១៣-២០២២" និងបានអនុម័តយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" (គណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក-UNESCAP, 2019a)។ យុទ្ធសាស្ត្រនេះផ្អែកតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងកំណត់ពីសកម្មភាពសម្រាប់ការលើកកម្ពស់សិទ្ធិ និងជីវភាពរស់នៅរបស់ជនមានពិការភាពទាំង ៦៩០ លាននាក់ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកចាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០២២។ យុទ្ធសាស្ត្រនេះជាជំនួយដល់ការផ្តល់សច្ចាប័ន និងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការនៅទូទាំងតំបន់ (UNDESA ២០១៨)។ យុទ្ធសាស្ត្រនេះផ្តល់ក្របខណ្ឌសម្រាប់គោលដៅនៃការអភិវឌ្ឍដែលមានបរិយាបន្ន ពិការភាព ដែលត្រូវបានសម្រេចអនុម័តនៅថ្នាក់តំបន់ និងគ្របដណ្តប់លើគោលដៅប្រទាក់ក្រឡាគ្នាចំនួន ១០ (សូមមើលរូប ១.១) ចំណុចដៅ ២៧ ចំណុច និងសូចនាករ ៦២ ចំណុច (UNESCAP ២០១៤)។ គោលដៅទី ៨ នៃយុទ្ធសាស្ត្រអ៊ីនឈាន់ មានគោលបំណង "បង្កើនភាពអាចជឿទុកចិត្តបាន និងភាពអាចប្រៀបធៀបបាននៃទិន្នន័យស្តីពីពិការភាព" តាមរយៈការផលិត និងផ្សព្វផ្សាយស្ថិតិស្តីពីពិការភាពដែលអាចជឿទុកចិត្តបាន និងអាចប្រៀបធៀបបានជាអន្តរជាតិ (ចំណុចដៅ ៨ក) និងបង្កើតស្ថិតិស្តីពីពិការភាពដែលអាចជឿទុកចិត្តបាននៅឆ្នាំ ២០១៧ ដើម្បីតាមដានវឌ្ឍនភាពនៃយុទ្ធសាស្ត្រអ៊ីនឈាន់ (ចំណុចដៅ ៨ខ) (UNESCAP ២០១៤)។

សមាសភាគដ៏សំខាន់មួយដែលជួយដល់ការសម្រេចបាន និងភាពជោគជ័យនៃគោលដៅដែលមានរៀបរាប់ក្នុងក្របខណ្ឌទាំងនេះ គឺស្ថិតិដែលអាចជឿទុកចិត្តបាន ទាន់ពេលវេលា និងមានគុណភាព។ ទិន្នន័យជំរឿនជាប្រភពដ៏សំខាន់មួយនៃទិន្នន័យទាំងនេះ។ ទិន្នន័យជំរឿនអាចផ្តល់ទិដ្ឋភាពថ្នាក់ជាតិស្តីពីស្ថានភាពនេះ ហើយប្រសិនបើប្រើប្រាស់សំណួរ និងនិយមន័យដូចគ្នា វាអាចផ្តល់ការប្រៀបធៀបជាអន្តរជាតិ។ ទោះបីមានចំណុចរាំងស្ទះក្នុងការប្រមូលទិន្នន័យស្តីពីពិការភាពក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ប៉ុន្តែជំរឿននេះនៅតែផ្តល់ចំណេះដឹងសំខាន់ៗស្តីពីជីវិតរស់នៅរបស់ជនមានពិការភាព និងអាចផ្តល់ព័ត៌មានដ៏មានតម្លៃសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣។ ប្រភពព័ត៌មានដ៏សំខាន់មួយទៀតដែលអាចប្រើប្រាស់សម្រាប់ការប្រៀបធៀបជាអន្តរជាតិ និងវាយតម្លៃវិសាលភាព និងខ្លឹមសារនៃព័ត៌មានស្តីពីពិការភាពគឺការអង្កេតប្រជាសាស្ត្រ និងសុខភាព។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពចុងក្រោយនៅកម្ពុជា ធ្វើឡើងនៅឆ្នាំ ២០១៤។ ខុសពីប្រភពថ្នាក់ជាតិផ្សេងទៀត ការអង្កេតប្រជាសាស្ត្រ និងសុខភាព ប្រើប្រាស់សំណួរស្តីពីពិការភាពដូចសំណួរក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩។ ដូច្នេះ គេអាចធ្វើការប្រៀបធៀបបាន។ ក្នុងផ្នែកផ្សេងៗនៃរបាយការណ៍នេះ នឹងមានការប្រៀបធៀបរវាងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ និងការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១៤។

2 *សម្រាប់ព័ត៌មានលម្អិតស្តីពីអនុសញ្ញានេះ សូមចូលទៅកាន់ ៖ https://www.un.org/disabilities/documents/convention/convoptprot-e.pdf*

តារាង ១ ៖ ចំណុចដៅ និងសូចនាករស្តីពីពិការភាពក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

| ក្របខណ្ឌសូចនាករសកលសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងចំណុចដៅនៃរបៀបវារៈឆ្នាំ ២០៣០សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | |
|---|---|
| **គោលដៅ និងចំណុចដៅស្តីពីពិការភាព** | **សូចនាករស្តីពីពិការភាព** |
| **គោលដៅទី ១ ៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង** | |
| ១.៣ អនុវត្តប្រព័ន្ធជាតិគាំពារសង្គម និងវិធានការផ្សេងៗ ឱ្យបានទូទាំង ប្រទេស និងសម្រេចឱ្យបានភាគច្រើននូវភាពគ្របដណ្តប់នៃប្រព័ន្ធនេះដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះនៅត្រឹមឆ្នាំ ២០៣០ | ១.៣.១ សមាមាត្រនៃប្រជាជនដែលគ្របដណ្តប់ដោយមូលដ្ឋាន/ប្រព័ន្ធ គាំពារសង្គម បែងចែកតាមភេទ កុមារមានតម្រូវការពិសេស ជនគ្មានការងារធ្វើ ចាស់ជរា ជនមានពិការភាព ស្ត្រីមានផ្ទៃពោះ ទារក ជនរងគ្រោះដោយសាររបួសក្នុងការងារ និងជនក្រីក្រ និងជនងាយរងគ្រោះ |
| **គោលដៅទី ៤ ៖ ធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប** | |
| ៤.៥ ត្រឹមឆ្នាំ ២០៣០ លុបបំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាការទទួលបានភាពស្មើភាពគ្នាក្នុងការអប់រំគ្រប់កម្រិត និងនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ក្រុមជនងាយរងគ្រោះ រួមទាំងក្រុមជនដែលបាត់បង់សមត្ថភាពពលកម្ម ប្រជាជន និងកុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។<br><br>៤.ក កសាង និងធ្វើឱ្យប្រសើរឡើងសម្ភារបរិក្ខារអប់រំដែលធ្វើឱ្យមានភាពប្រែប្រួលដល់កុមារអ្នកបាត់បង់សមត្ថភាពពលកម្ម និងយេនឌ័រ និងផ្តល់បរិស្ថាននៃការសិក្សាប្រកបដោយ បរិយាបន្ន និងមានប្រសិទ្ធភាពសម្រាប់ប្រជាជនគ្រប់រូប។ | ៤.៥.១ សន្ទស្សន៍យុគភាព (ស្រី/ប្រុស ជនបទ/ប្រជុំជន បញ្ចភាគទ្រព្យសម្បត្តិខាងក្រោម/ខាងលើ និងចំណុចផ្សេងទៀត ដូចជា ស្ថានភាពពិការភាព ជនជាតិដើមភាគតិច និងជនរងផលប៉ះពាល់ដោយសារជម្លោះ នៅពេលមានទិន្នន័យ) សម្រាប់សូចនាករអប់រំទាំងអស់ក្នុងតារាងនេះដែលអាចបែងចែកជាប្រភេទ។ |
| **គោលដៅទី ៨ ៖ ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន មានមុខរបរពេញលេញ និងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប** | |
| ៨.៥ ត្រឹមឆ្នាំ ២០៣០ សម្រេចបានមុខរបរពេញលេញ និងមានផលិតភាព និងការងារសមរម្យសម្រាប់ស្ត្រី និងបុរសគ្រប់រូប រួមទាំងយុវជន និងជនមានពិការភាព និងប្រាក់ឈ្នួលស្មើភាពសម្រាប់ការងារដែលមានតម្លៃដូចគ្នា។ | ៨.៥.១ ប្រាក់ចំណូលតាមម៉ោងជាមធ្យមរបស់និយោជិតបែងចែកតាមភេទ អាយុ មុខរបរ និងជនមានពិការភាព<br><br>៨.៥.២ អត្រាគ្មានការងារធ្វើ បែងចែកតាមភេទ អាយុ និងជនមានពិការភាព |

| | |
|---|---|
| **គោលដៅទី ១០ ៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេស និងក្នុងចំណោមបណ្ដាប្រទេសនានា** | |
| ១០.២ ត្រឹមឆ្នាំ ២០៣០ ផ្ដល់ភាពអង់អាច និងជំរុញបរិយាបន្នសង្គម សេដ្ឋកិច្ច និងនយោបាយ សម្រាប់ប្រជាជនគ្រប់រូបដោយមិនគិតពីស្ថានភាព អាយុ ភេទ ការបាត់បង់សមត្ថភាពពលកម្ម ពូជសាសន៍ ជនជាតិភាគតិច ជនជាតិដើម សាសនា ឬសេដ្ឋកិច្ច ឬស្ថានភាពផ្សេងទៀត។ | ៨.៥.១ ប្រាក់ចំណូលតាមម៉ោងជាមធ្យមរបស់និយោជិត បែងចែកតាមភេទ អាយុ មុខរបរ និងជនមានពិការភាព<br>៨.៥.២ អត្រាគ្មានការងារធ្វើ បែងចែកតាមភេទ អាយុ និងជនមានពិការភាព |
| **គោលដៅទី ១១ ៖ ធ្វើឱ្យទីក្រុង និងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជនមានលក្ខណៈបរិយាបន្ន សុវត្ថិភាព ធន់នឹងការប្រែប្រួលអាកាសធាតុ និងចីរភាព** | |
| ១១.២ ត្រឹមឆ្នាំ ២០៣០ ផ្ដល់លទ្ធភាពទទួលបានប្រព័ន្ធដឹកជញ្ជូនដែលមានសុវត្ថិភាព តម្លៃសមរម្យ ងាយស្រួលប្រើប្រាស់ និងមានចីរភាព សម្រាប់ប្រជាជនគ្រប់រូប ដោយបង្កើនសុវត្ថិភាព តាមដងផ្លូវ តាមរយៈការពង្រីកមធ្យោបាយ ធ្វើដំណើរសាធារណៈ ដោយផ្ដោតការយកចិត្តទុកដាក់ពិសេសលើតម្រូវការរបស់ជនរស់នៅក្នុងស្ថានភាពងាយរងគ្រោះ ស្ត្រី កុមារ ជនមានពិការភាព ចាស់ជរា។ | ១១.២.១ សមាមាត្រប្រជាជនដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ បែងចែកតាមភេទ អាយុ និងជនមានពិការភាព<br>១១.៧.១ ចំនួនមធ្យមនៃតំបន់មានការសាងសង់សំណង់ក្នុងទីក្រុង ដែលផ្ដល់ចន្លោះសម្រាប់ការប្រើប្រាស់ជាសាធារណៈ បែងចែកតាមភេទ អាយុ និងជនមានពិការភាព<br>១១.៧.២ សមាមាត្រជនរងគ្រោះដោយសារការបៀតបៀនផ្លូវកាយ ឬផ្លូវភេទ បែងចែកតាមភេទ អាយុ ស្ថានភាពពិការភាព និងកន្លែងកើតហេតុ ក្នុងរយៈពេល ១២ ខែកន្លងមក |
| **គោលដៅទី ១៦ ៖ លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្ដល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ននៅគ្រប់កម្រិត** | |

| | |
|---|---|
| ១៦.៧ ធានានូវការធ្វើសេចក្តីសម្រេច ដោយមានការចូលរួមពីគ្រប់តំណាង ដោយមានការទទួលខុសត្រូវប្រកបដោយ<br><br>បរិយាបន្ននៅគ្រប់កម្រិត | ១៦.៧.១ សមាមាត្រចំនួនមុខតំណែងក្នុងស្ថាប័នជាតិ និងស្ថាប័នមូលដ្ឋាន ដូចជា ក) នីតិបញ្ញត្តិ ខ) សេវាសាធារណៈ និង គ) តុលាការ ធៀបនឹងរបាយថ្នាក់ជាតិ បែងចែកតាមភេទ អាយុ ជនមានពិការភាព និងក្រុមប្រជាជន។<br><br>១៦.៧.២ សមាមាត្រប្រជាជនដែលជឿថា ការធ្វើសេចក្តីសម្រេចចិត្តមានបរិយាបន្ន និងឆ្លើយតបនឹងតម្រូវការ បែងចែកតាមភេទ អាយុ ពិការភាព និងក្រុមប្រជាជន |
| **គោលដៅទី ១៧ ៖ ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព** | |
| ទិន្នន័យ ការពិនិត្យតាមដាន និងគណនេយ្យភាព | |
| ១៧.១៨ ត្រឹមឆ្នាំ ២០២០ លើកកម្ពស់ការគាំទ្រការកសាងសមត្ថភាពដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច និងបណ្តារដ្ឋដែនកោះតូចៗកំពង់អភិវឌ្ឍន៍ ដើម្បីបង្កើនឱ្យបានច្រើនភាពអាចរកបានទាន់ពេលនៃទិន្នន័យដែលមានគុណភាពខ្ពស់ និងជឿជាក់បាន បំបែកតាមចំណូល យេនឌ័រ អាយុ ជាតិសាសន៍ ជនជាតិភាគតិច ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅ ការបាត់បង់សមត្ថភាពពលកម្ម ទីតាំងភូមិសាស្រ្ត និងលក្ខណៈផ្សេងទៀតដែលពាក់ព័ន្ធក្នុងបរិការណ៍ជាតិ។ | |

## រូប ១.១ ៖ គោលដៅទាំង ១០ នៃយុទ្ធសាស្ត្រអ៊ីនឈាន់ “ធ្វើឱ្យសិទ្ធិក្លាយជាការពិត[3]”




3 ប្រភព ៖ UNESCAP (2014)

# ជំពូក ២៖ វិធីសាស្ត្រ

ជំពូកនេះពន្យល់ពីទ្រឹស្តី និងវិធីសាស្ត្រពាក់ព័ន្ធនឹងការវិភាគ។ ផ្នែកដំបូងបង្ហាញពីទិដ្ឋភាពរួមនៃជំរឿនឆ្នាំ ២០១៩ ដែលជាប្រភពដ៏សំខាន់នៃរបាយការណ៍បែងចែកតាមវិស័យនេះ។ បន្ទាប់មកគឺការបង្ហាញពីនិយមន័យនៃពិការភាព និងរបៀបវាស់វែងពិការភាពក្នុងជំរឿន។ ផ្នែកចុងក្រោយពិភាក្សាពីដែនកំណត់ជុំវិញការផលិតទិន្នន័យស្តីពីពិការភាពន កម្ពុជា។

## ២.១ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ គឺជាជំរឿនលើកទី ៤ ដែលបានធ្វើជាបន្តបន្ទាប់នៅព្រះរាជាណាចក្រកម្ពុជា ហើយជំរឿនឆ្នាំ ២០១៩ ស្ថិតនៅក្នុងជំរឿនវិលជុំទីដប់នៃជំរឿនពិភពលោកឆ្នាំ ២០២០ ដែលផ្តល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ។ ការធ្វើជំរឿនលើកដំបូងនៅកម្ពុជាបានធ្វើនៅឆ្នាំ ១៩៦២ ជាមួយការអនុវត្តជាបន្តបន្ទាប់ ដែលត្រូវបានធ្វើឡើងនៅឆ្នាំ ១៩៩៨ និងឆ្នាំ ២០០៨។ ប្រទេសកម្ពុជានៅតែសម្រេចចិត្តប្រើកម្រងសំណួរជាក្រដាស និងខ្មៅដៃក្នុងការប្រមូលទិន្នន័យ។ កិច្ចការនេះតម្រូវឱ្យមានការរៀបចំយ៉ាងហ្មត់ចត់លើការរៀបចំកម្រងសំណួរ សេចក្តីណែនាំផ្សេងៗ ការបណ្តុះបណ្តាលស្រង់ទិន្នន័យសាកល្បង (ការធ្វើជំរឿននាំមុខ) ជាដើម ។ល។

ដំណើរការនៃការរៀបចំការងារជំរឿនជាផ្លូវការចាប់ផ្តើមនៅឆ្នាំ ២០១៦ តាមរយៈការរៀបចំពង្រាងឯកសារស្តីពីផែនការធ្វើជំរឿនដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា និងគណកម្មាធិការជាតិជំរឿននៅឆ្នាំ ២០១៧។ យុទ្ធសាស្ត្រនៃការធ្វើជំរឿនត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៧ ដែលសម្រេចអនុញ្ញាតអនុវត្តការប្រមូលទិន្នន័យចាប់ផ្តើមនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៩។ វិទ្យាស្ថានជាតិស្ថិតិបានគូសផែនទីជំរឿន ដោយប្រើផែនទីព្រាងដោយដៃនៅទូទាំងប្រទេស ហើយបានកំណត់ជាមណ្ឌលជំរឿន។

លទ្ធផលសម្រេចបានពីការធ្វើជំរឿនទាំងបីលើក បានផ្តល់ទិន្នន័យប្រជាសាស្ត្រដ៏មានតម្លៃសម្រាប់ជំរឿនបានធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាបន្តពង្រឹងសមត្ថភាពតាមរយៈការធ្វើជំរឿន ដែលហៅថា "ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩" ដោយបានដាក់បញ្ចូលទិន្នន័យទាក់ទងប្រជាជន និងលក្ខណៈផ្ទះសំបែងមួយចំនួនសម្រាប់ការវាយតម្លៃ និងរៀបចំផែនការ។

## ២.២ និយមន័យពិការភាពក្នុងបរិបទអន្តរជាតិ

មានការបង្កើតគំរូទស្សនាទានផ្សេងៗជុំវិញពិការភាព។ គំរូដែលមានការទទួលស្គាល់ទូលំទូលាយជាងគេនាពេលបច្ចុប្បន្នគឺគំរូនៃការធ្វើចំណាត់ថ្នាក់ជាអន្តរជាតិស្តីពីការបំពេញមុខងារ ពិការភាព និងសុខភាព (ICF) របស់អង្គការសុខភាពពិភពលោក (WHO) ដែលជាទូទៅសំដៅលើគំរូ ICF។ នៅឆ្នាំ ២០០១ គំរូនេះត្រូវបានរដ្ឋសមាជិកទាំង ១៩១ ប្រទេសរបស់ WHO ទទួលយកជាស្តង់ដារសម្រាប់ការងារផ្នែកវិទ្យាសាស្ត្រស្តីពីពិការភាព និងសុខភាព។ គំរូ ICF ប្រជាប់បញ្ចូលគ្នានូវអភិក្រមវេជ្ជសាស្ត្រ និងអភិក្រមសង្គមសម្រាប់ពិការភាព។ អភិក្រមវេជ្ជសាស្ត្រ ចាត់ទុកពិការភាពជាលទ្ធផលវេជ្ជសាស្ត្រនៃជំងឺ ការប៉ះទង្គិចផ្លូវចិត្ត ឬលក្ខខណ្ឌសុខភាព ខណៈដែលអភិក្រមសង្គមចាត់ទុក

ពិការភាពជាលទ្ធផលនៃបរិស្ថានសង្គម ជាជាងចរិតលក្ខណៈរបស់មនុស្សម្នាក់ៗ។ ដូច្នេះ គំរូ ICF គួរត្រូវបានកំណត់ជាគំរូជីវចិត្តសង្គមដែល "ចាត់ទុកការបំពេញមុខងារ និងពិការភាពជាអន្តរកម្មរស់រវើករវាងលក្ខខណ្ឌសុខភាព និងកត្តាបរិបទ ទាំងបុគ្គល និងបរិស្ថាន" (WHO, 2020; WHO, 2011, p. 4)។ រូបភាព ២.១ សង្ខេបពីសមាសភាគផ្សេងៗ និងអន្តរកម្មដែលលេចឡើងក្នុងគំរូ ICF។

រូប ២.១ ៖ សមាសភាគ និងអន្តរកម្មនៃគំរូជីវចិត្តសង្គម ICF ស្តីពីពិការភាព[4]




គំរូ ICF កំណត់ការបំពេញមុខងារជា "មុខងាររាងកាយទាំងអស់ សកម្មភាព និងការចូលរួម" (WHO, 2002) និងកំណត់ពិការភាពជា "ពាក្យទូទៅដែលគ្របដណ្តប់លើកម្សោយ ដែនកំណត់សកម្មភាព និងការរឹតត្បិតការចូលរួមដោយសំដៅលើទិដ្ឋភាពអវិជ្ជមាននៃអន្តរកម្មរវាងបុគ្គលម្នាក់ (ដោយមានលក្ខខណ្ឌសុខភាពជាក់លាក់) និងកត្តាបរិបទរបស់បុគ្គលនោះ (កត្តាបរិស្ថាន និងកត្តាបុគ្គល)" (WHO, 2011, p. 4)។ ទាំងនិយមន័យក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងនិយមន័យក្នុងយុទ្ធសាស្ត្រអ៊ីនឈាន់ សុទ្ធតែផ្អែកតាមគំរូ ICF។ របាយការណ៍នេះប្រើប្រាស់និយមន័យក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ៖ ជនមានពិការភាពសំដៅលើអ្នកទាំងឡាយណាដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទា ផ្លូវចិត្ត សតិបញ្ញា ឬញ្ញាណដឹង ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានាអាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គមដោយស្មើភាពគ្នាជាមួយអ្នកដទៃបាន" (UNESCAP, 2014, p. 2)។

និយមន័យដែលប្រើប្រាស់ក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពកម្ពុជា ឆ្នាំ ២០១៩-២០២៣យកលំនាំតាមគំរូទស្សនាទានអន្តរជាតិនៃ ICF និងនិយមន័យដែលប្រើប្រាស់ក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ ក្នុងផែនការយុទ្ធសាស្ត្រនេះ ជនមានពិការភាពសំដៅលើ "អ្នកទាំងឡាយណាដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយ

4 រូបនេះដកស្រង់ចេញពី WHO (2002), ICF

សម្បទា ផ្លូវចិត្ត សតិបញ្ញា ឬញ្ញាណដឹង ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានា អាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គមដោយស្មើភាពគ្នាជាមួយអ្នកដទៃបាន"។ និយមន័យនេះស៊ីសង្វាក់គ្នានឹងនិយមន័យក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ (2006, p. 4)។ ក្នុងបរិបទនេះ ការសំខាន់គឺត្រូវគូសបញ្ជាក់ថា អនុសញ្ញាស្តីពីសិទ្ធិជនពិការ ទទួលស្គាល់ថា "ពិការភាពជាទស្សនាទានមួយដែលមានការវិវត្ត ហើយពិការភាពកើតចេញពីអន្តរកម្មរវាងជនមានកម្សោយ និងឧបសគ្គផ្នែកឥរិយាបថ និងបរិស្ថាន ដែលរារាំងការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គមដោយស្មើភាពគ្នាជាមួយអ្នកដទៃបាន" (CRPD, 2006, បុព្វកថា ង)។

## ២.៣ ការវាស់វែងពិការភាព

ស្ថានភាពពិការភាពមិនអាចចាត់ទុកជាលក្ខខណ្ឌដាច់ពីគ្នា ដែលកំណត់ថាមនុស្សណាម្នាក់មានពិការភាព ឬក៏អត់នោះទេ។ ដោយសារផ្នែកនានានៃការបំពេញមុខងាររាងកាយ និងសង្គម ពាក់ព័ន្ធនឹងស្ថានភាពពិការភាពរបស់មនុស្សម្នាក់ វាគួរត្រូវបានចាត់ទុកជាដែនកំណត់ជាបន្តបន្ទាប់ ដែលអាស្រ័យលើកត្តាផ្សេងៗ (ជីវសាស្ត្រ ចិត្តសាស្ត្រ សង្គម វប្បធម៌ និងបរិស្ថាន)។ ដូច្នេះ ការវាស់វែងប្រេវ៉ាឡង់ពិការភាព និងលក្ខណៈរបស់ជនមានពិការភាព គឺជាការលំបាក។ អស់រយៈពេលជាច្រើនឆ្នាំមកហើយដែលស្ថាប័ន និងអ្នកស្រាវជ្រាវជាច្រើនព្យាយាមពិពណ៌នាពីលក្ខណៈនៃពិការភាព ដោយប្រើប្រាស់មធ្យោបាយសព្វបែបយ៉ាង។

តាំងពីឆ្នាំ ២០០១ មក ក្រុមការងារវ៉ាស៊ីនតោនស្តីពីស្ថិតិពិការភាព ដើរតួនាទីជាក្រុមការងារទីក្រុងនៃគណៈកម្មការអង្គការសហប្រជាជាតិ ដើម្បីបង្កើតវិធីសាស្ត្រមួយសម្រាប់ "ការប្រមូលទិន្នន័យស្តីពីពិការភាពដែលមានសុពលភាព អាចជឿទុកចិត្តបាន និងអាចប្រៀបធៀបបានជាអន្តរជាតិ និងការបង្កើតមធ្យោបាយដើម្បីកែលម្អស្ថិតិស្តីពីជនមានពិការភាពទូទាំងពិភពលោក" (ក្រុមការងារវ៉ាស៊ីនតោនស្តីពីស្ថិតិពិការភាព, n.d.)។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ប្រើប្រាស់វិធីសាស្ត្រដែលបង្កើតឡើងដោយក្រុមការងារវ៉ាស៊ីនតោន ដែលត្រូវបានប្រើប្រាស់ក្នុងប្រទេសជាច្រើនក្នុងជំរឿនប្រជាជន និងការអង្កេតគ្រួសារទ្រង់ទ្រាយធំ។

ក្រុមការងារវ៉ាស៊ីនតោនបានបង្កើតសំណួរ ៦ ដោយផ្អែកតាមក្របខណ្ឌ ICF សម្រាប់សាកសួរអំពីបុគ្គលម្នាក់ៗក្នុងគ្រួសារ។ ជាទូទៅ សំណួរទាំងនេះសំដៅលើកម្រងសំណួរខ្លីរបស់ក្រុមការងារវ៉ាស៊ីនតោនស្តីពីការបំពេញមុខងារ (WG-SS)។ សំណួរទាំងនេះសុទ្ធតែពាក់ព័ន្ធនឹងការលំបាករបស់មនុស្សម្នាក់ក្នុងការបំពេញមុខងារសំខាន់ៗ ដែលអាចធ្វើឱ្យពួកគេកាន់តែពិបាកចូលរួមក្នុងសង្គម ដូចជា ក្នុងការអប់រំ ការងារ ឬសកម្មភាពគ្រួសារ ដូចអ្នកគ្មានការលំបាកបំពេញមុខងារ។ សំណួរទាំង ៦ នេះក៏ត្រូវបានដាក់បញ្ចូលក្នុងកម្រងសំណួរនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ផងដែរ ៖

តារាង ២ ៖ សំណួរទាំង៦ របស់ក្រុមការងារវ៉ាស៊ីនតោន

បង្គោល ១៧ ៖ ការលំបាកបំពេញមុខងារ

តើអ្នកមានការលំបាក......

១៧.១ ក្នុងការមើលដែរឬទេ សូម្បីតែពាក់វ៉ែនតា ?

១៧.២ ក្នុងការស្ដាប់ដែរឬទេ សូម្បីតែប្រើឧបករណ៍ជំនួយ ?

១៧.៣ ក្នុងការផ្លាស់ទី ឬឡើងជណ្ដើរដែរឬទេ ?

១៧.៤ ក្នុងការចងចាំ ឬផ្ចង់អារម្មណ៍ដែរឬទេ ?

១៧.៥ ក្នុងការថែទាំខ្លួនឯងដែរឬទេ ដូចជា ងូតទឹក ឬស្លៀកពាក់ ?

១៧.៦ ក្នុងការនិយាយដែរឬទេ ឧ. ដូចជាយល់អ្នកដទៃ ឬឱ្យអ្នកដទៃយល់យល់ពីអ្នក ?

កូដសម្រាប់បង្គោល ១៧

១.ទេ មិនពិបាកអ្វីទេ

២.បាទ/ចាស់ ពិបាកខ្លះដែរ

៣.បាទ/ចាស់ ពិបាកខ្លាំង

៤.មិនអាចធ្វើអ្វីបានសោះតែម្ដង

ពិការភាពមិនមែនជាលក្ខខណ្ឌដាច់ដោយឡែកនោះទេ ប៉ុន្តែត្រូវបានកំណត់ដោយខ្សែសង្វាក់នៃកត្តារួមផ្សំជាច្រើន។ ក្នុងគោលបំណងកំណត់អត្តសញ្ញាណប្រជាជនមានពិការភាពដើម្បីឱ្យដឹងថាតើមានការបំពេញសិទ្ធិរបស់ពួកគេក្រោមអនុសញ្ញាស្តីពីសិទ្ធិជនពិការ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬយុទ្ធសាស្ត្រអ៊ីនឈាន់ ឬទេ ចាំបាច់ត្រូវកំណត់ព្រំដែនឱ្យបានច្បាស់ក្នុងខ្សែសង្វាក់នៃកត្តារួមផ្សំទាំងនោះ។ យោងតាមក្រុមការងារវ៉ាស៊ីនតោន បញ្ហាប្រឈមក្នុងការកំណត់ឱ្យបានច្បាស់ គឺការ "កំណត់អត្តសញ្ញាណក្រុមមួយដែល ដោយសារតែការលំបាកបំពេញមុខងារ ប្រឈមនឹងហានិភ័យខ្លាំងជាងប្រជាជនទូទៅ ដូចជា ការផាត់ចេញពីការចូលរួមដោយសារឧបសគ្គក្នុងបរិស្ថានជុំវិញ។ ក្នុងគោលបំណងនេះ ចាំបាច់ត្រូវស្វែងរកចំណុចសមស្របបំផុតលើខ្សែសង្វាក់នោះដើម្បីកំណត់ជាកម្រិតដៅ។ ពោលគឺការកំណត់អ្នកនៅលើកម្រិតនោះថាមានពិការភាព និងអ្នកនៅក្រោមកម្រិតនោះថាគ្មានពិការភាព។ ការជ្រើសរើសកម្រិត (ជាញឹកញាប់ហៅថា កម្រិតដៅ ឬចំណុចខណ្ឌចែក) គួរផ្អែកតាមភាពចាំបាច់នៃគោលបំណងប្រមូលទិន្នន័យ" (ក្រុមការងារវ៉ាស៊ីនតោនស្តីពីស្ថិតិពិការភាព, 2021, p.1)។ ផ្នែកដែលកំណត់ជាចំណុចខណ្ឌចែកនឹងកំណត់ប្រេវ៉ាឡង់ពិការភាព និងលក្ខណៈរបស់ជនមានពិការភាព។ គ្មានចំណុចខណ្ឌចែកជាសកលនោះទេ ប៉ុន្តែការជ្រើសរើសចំណុចខណ្ឌចែកគួររំលេចគោលបំណងនៃការប្រើប្រាស់ទិន្នន័យ។ ដូច្នេះ អត្រាប្រេវ៉ាឡង់ដែលផ្អែកលើទិន្នន័យជំរឿនរួមបញ្ចូលវិសភាគភាព (heterogeneity) យ៉ាងច្រើន។

ក្រុមការងារវ៉ាស៊ីនតោនកំណត់និយមន័យជនមានពិការភាពជា "ជនទាំងឡាយណាដែលមានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានទាំងអស់ យ៉ាងហោចណាស់មានមួយក្នុងចំណោមមុខងារលំបាកទាំងប្រាំមួយដែលបានបញ្ចូលក្នុងកម្រងសំណួរ" (ក្រុមការងារវ៉ាស៊ីនតោនស្តីពីស្ថិតិពិការភាព ២០២០)។ ទោះជាយ៉ាងណា គ្មានស្តង់ដាររួមជាក់លាក់សម្រាប់ការកំណត់ថា បុគ្គលម្នាក់មាន ឬគ្មានពិការភាពនោះទេ (ក្រុមការងារវ៉ាស៊ីនតោនស្តីពីស្ថិតិពិការភាព ២០២១)។ ក្រុមការងារវ៉ាស៊ីនតោនកត់សម្គាល់ថា ការប្រើប្រាស់កម្រិតពីរ (ការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបាន) សម្រាប់ការកំណត់ជនមានពិការភាព ធ្វើឱ្យបាត់ព័ត៌មាន។ ឧ. អ្នកមានការលំបាកខ្លាំងក្នុងការបំពេញមុខងារជាក់លាក់មួយ អាចខុសពីអ្នកដែលមិនអាចធ្វើអ្វីបានទាំងអស់ ដូចជា ការផាត់ចេញដោយសារឧបសគ្គក្នុងបរិស្ថានសង្គម។ នេះជាចំណុចសំខាន់ព្រោះជាញឹកញាប់មនុស្សដែលមិនអាចបំពេញមុខងារជាក់លាក់មួយបាន ជាក្រុមដែលប្រឈមនឹងហានិភ័យខ្ពស់នៃការផាត់ចេញ និងត្រូវការជំនួយខ្លាំងបំផុត ហើយអ្នកមានការលំបាកខ្លះ អាចមានលក្ខណៈខុសពីអ្នកគ្មានការលំបាក។

ដូច្នេះ របាយការណ៍នេះរួមបញ្ចូលកម្រិតទាំង ៣ នៃការលំបាកបំពេញមុខងារ (លំបាកខ្លះ លំបាកខ្លាំង និងមិនអាចធ្វើអ្វីបាន) ព្រោះអភិក្រមនេះផ្តល់ទិដ្ឋភាពពេញលេញស្តីពីអ្នកដែលងាយប្រឈមនឹងការផាត់ចេញក្នុងសង្គម។ អភិក្រមនេះអាចឱ្យមានការពិពណ៌នាអំពីខ្សែសង្វាក់នៃការបំពេញមុខងារ បានល្អជាងការញែកពិការភាពជាពីរទម្រង់ធម្មតា។ ទោះជាយ៉ាងណា ក្នុងករណីចាំបាច់មួយចំនួន អ្នកមានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបាន ត្រូវបានបញ្ចូលក្នុងក្រុមតែមួយ។

### តារាង ៣.១ ៖ កម្រិតពិការភាពរបស់ក្រុមការងារវ៉ាស៊ីនតោន

| កម្រិតពិការភាព | | |
|---|---|---|
| ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន |
| ↓ | ↓ | ↓ |
| អ្នកដែលមានការលំបាកខ្លះក្នុងការបំពេញមុខងារ | អ្នកដែលមានការលំបាកខ្លាំងក្នុងការបំពេញមុខងារ | អ្នកដែលមិនអាចធ្វើអ្វីបានទាំងអស់ |

មូលហេតុមួយផ្សេងទៀតនៃការគូសបញ្ជាក់ពីពិការភាពទាំង ៣ កម្រិត (ពិការខ្លះ ពិការខ្លាំង ពិការមិនអាចធ្វើអ្វីបាន) គឺដើម្បីបំពេញតម្រូវការទិន្នន័យផ្សេងៗសម្រាប់កម្រិតពិការភាពទាំងនេះ៖ កំណត់រកការគាំទ្រដែលត្រូវការចាំបាច់ និងវាយតម្លៃការរឹតត្បិតការចូលរួមក្នុងសហគមន៍ ដែលអាចផ្សារភ្ជាប់នឹងកម្រិតពិការខ្លះ ឬកម្រិតពិការមិនអាចធ្វើអ្វីបាន។ ក្នុងករណីខ្លះ អត្ថប្រយោជន៍របស់រដ្ឋាភិបាលផ្តោតលើជនមានពិការភាពមួយក្រុម ដូចជា ជនដែលមិនអាចធ្វើការងារដោយសារមិនអាចបំពេញមុខងារមួយចំនួន។ តាមការបញ្ជាក់ក្នុងមគ្គុទេសក៍របស់ ESCAP (២០១៤) ស្តីពីសូចនាករពិការភាពសម្រាប់យុទ្ធសាស្ត្រអ៊ីនឈាន់ សម្រាប់គោលបំណងផ្សេងទៀត ដូចជា ការបង្កើតប្រព័ន្ធសាលារៀនបរិយាបន្ន ប្រហែលជាចាំបាច់ត្រូវគ្របដណ្តប់លើការលំបាកទាំងអស់ ចាប់ពីការលំបាកខ្លះរហូតដល់ការលំបាកមិនអាចធ្វើអ្វីបាន។

### តារាង ៣.២ ៖ ប្រភេទចម្លើយរបស់ក្រុមការងារវ៉ាស៊ីនតោន

| ប្រភេទចម្លើយរបស់ក្រុមការងារវ៉ាស៊ីនតោន |
|---|
| ប្រសិនបើឆ្លើយសំណួរទាំងអស់ថា គ្មានការលំបាក បុគ្គលនោះត្រូវបានចាត់ទុកថា មិនពិការ។ |
| ប្រសិនបើឆ្លើយសំណួរ ១ ឬច្រើន ថា មានការលំបាកខ្លះ ប៉ុន្តែមិនឆ្លើយសំណួរណាមួយ ថា មានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានទាំងអស់ បុគ្គលនោះត្រូវបានចាត់ទុកថា ពិការខ្លះ។ |
| ប្រសិនបើឆ្លើយសំណួរ ១ ឬច្រើន ថា មានការលំបាកខ្លាំង បុគ្គលនោះត្រូវបានចាត់ទុកថា ពិការខ្លាំង។ |
| ប្រសិនបើឆ្លើយសំណួរ ១ ឬច្រើន ថា មិនអាចធ្វើអ្វីបានទាំងអស់ បុគ្គលនោះត្រូវបានចាត់ទុកថា ពិការមិនអាចធ្វើអ្វីបាន។ |

## ២.៤ ព្រំដែនកំណត់នៃការវាស់វែងពិការភាព

កត្តាជាច្រើនដែលពាក់ព័ន្ធនឹងការប្រមូល និងវិភាគទិន្នន័យ បានដាក់ដែនកំណត់លើទិន្នន័យស្ដីពីពិការភាពដែលបានប្រមូលក្នុងការជំរឿន។ កត្តាទីមួយគឺជាកត្តាទូទៅ និងពាក់ព័ន្ធនឹងដែនកំណត់ពីរក្នុងកម្រងសំណួរខ្លីរបស់ក្រុមការងារវ៉ាស៊ីនតោនស្ដីពីការបំពេញមុខងារ ដើម្បីវាយតម្លៃប្រេវ៉ាឡង់ និងលក្ខណៈនៃពិការភាពក្នុងចំណោមប្រជាជន ៖

ការកំណត់ត្រឹមអ្នកមានអាយុ ៥ ឆ្នាំឡើង ៖ កម្រងសំណួរខ្លីរបស់ក្រុមការងារវ៉ាស៊ីនតោនស្ដីពីការបំពេញមុខងារ មិនអាចអនុវត្តចំពោះកុមារអាយុក្រោម ៥ ឆ្នាំបានឡើយ ហើយសម្រាប់កុមារជាច្រើនដែលមានអាយុលើស ៥ ឆ្នាំ គ្មានការផ្ដោតលើពិការភាពផ្នែកការអភិវឌ្ឍ។ ដូច្នេះ UNICEF និងក្រុមការងារវ៉ាស៊ីនតោន បានបង្កើតម៉ូឌុលស្ដីពីការបំពេញមុខងាររបស់កុមារ ដើម្បីរួមបញ្ចូលកុមារមានពិការភាពឱ្យបានប្រសើរជាងមុន។ ម៉ូឌុលនេះមាន ២ ទម្រង់៖ ម៉ូឌុលមួយសម្រាប់កុមារអាយុ ២-៤ ឆ្នាំ និងម៉ូឌុលមួយទៀតសម្រាប់កុមារអាយុ ៥-១៧ ឆ្នាំ។ ម៉ូឌុលទាំង ២ ទម្រង់នេះត្រូវបានអនុវត្តជាមួយម្ដាយ ឬអ្នកថែទាំបឋម ចំណែកម៉ូឌុលសម្រាប់អនុវត្តជាមួយគ្រូបង្រៀន កំពុងត្រូវបានរៀបចំឡើង (ក្រុមការងារវ៉ាស៊ីនតោនស្ដីពីស្ថិតិពិការភាព ២០២០)។ ដោយសារការកំណត់ចំនួនសំណួរក្នុងជំរឿន សំណួរជាក់លាក់ស្ដីពីការលំបាកបំពេញមុខងាររបស់កុមារអាយុក្រោម ៥ ឆ្នាំ មិនត្រូវបានបញ្ចូលក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ឡើយ។ ដូច្នេះ ការវិភាគក្នុងរបាយការណ៍នេះកម្រិតត្រឹមប្រជាជនអាយុ ៥ ឆ្នាំឡើង។

មិនមែនពិការភាពគ្រប់ប្រភេទ ៖ សំណួរទាំង ៦ របស់ក្រុមការងារវ៉ាស៊ីនតោន មិនគ្របដណ្ដប់លើពិការភាពគ្រប់ប្រភេទ និងផាត់ចេញជនមានពិការភាពផ្នែកចិត្តសង្គម និងជនមានការលំបាកបំពេញមុខងាររាងកាយផ្នែកខាងលើ (ក្រុមការងារវ៉ាស៊ីនតោន ២០២០) ដែលមិនពាក់ព័ន្ធនឹងពិការភាពដែលបានកំណត់។ ឧ. មនុស្សមួយចំនួនដែលមានពិការភាពផ្នែកចិត្តសង្គម ក៏មានការលំបាកក្នុងការទំនាក់ទំនង ឬការដឹងលឺផងដែរ ហើយអ្នកមានការលំបាកបំពេញមុខងាររាងកាយផ្នែកខាងលើ អាចមានការលំបាកក្នុងការងូតទឹក និងស្លៀកពាក់។ ដោយសារជាញឹកញាប់គ្មានការពិចារណាពីពិការភាពផ្នែកចិត្តសង្គម ក្រុមការងារវ៉ាស៊ីនតោនបានបង្កើតកម្រងសំណួរ មាន៤ សំណួរបន្ថែមទៀតដើម្បីកំណត់ពិការភាពផ្នែកចិត្តសង្គម។ ប៉ុន្តែដោយសារតែសំណួរទាំងនេះត្រូវ បានបង្កើតឡើងសម្រាប់ការអង្កេតគ្រួសារ និងមិនអាចប្រើប្រាស់បានក្នុងជំរឿនប្រជាជន សំណួរទាំងនេះមិនត្រូវបានបញ្ចូលក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩នោះទេ។

ព្រំដែនកំណត់ទី ២ គឺ ក្នុងប្រទេសជាច្រើន ពិការភាពជាប្រធានបទមួយដែលពិបាកធ្វើការស្រាវជ្រាវ ដោយសារមូលហេតុផ្សេងៗ ៖

ពិការភាពជាផ្នែកមួយនៃក្របខណ្ឌវប្បធម៌ ចិត្តសាស្ត្រ និងសង្គមសេដ្ឋកិច្ច ដែលជាញឹកញាប់ ជនមានពិការភាពទទួលរងការមាក់ងាយ។ ដូច្នេះ ការប្រមូលទិន្នន័យស្ដីពីពិការភាពអាចមិនរលូន ព្រោះអ្នកឆ្លើយតបព្យាយាមលាក់បាំងព័ត៌មានមួយចំនួន ឬមិនចង់កំណត់អត្តសញ្ញាណខ្លួនឯងថាមានពិការភាព (Pettinicchio and Maroto, 2020)។ ក្រៅពីនេះ សមាជិកគ្រួសារអាចមានអារម្មណ៍ខ្មាសអៀន និងមានទំនោរ "ភ្លេច" មិនចុះឈ្មោះសមាជិកមានពិការភាព ឬមិនរាយការណ៍ពីការលំបាកបំពេញមុខងាររបស់សមាជិកគ្រួសារណាម្នាក់។

កត្តាមួយទៀតដែលអាចធ្វើឱ្យគ្មានការសម្ភាសជនមានពិការភាពឱ្យបានគ្រប់ចំនួន គឺអ្នកសម្ភាសន៍មិនចង់

សួរសំណួរចំៗដែលកំណត់ដោយក្រុមការងារ៉ាស៊ីនតោន។ ដូច្នេះ ពួកគេបំពេញចម្លើយ "គ្មានការលំបាក" សម្រាប់សំណួរទាំងអស់ ឬសួរសំណួរទូទៅស្ដីពីសមាជិកគ្រួសារទាំងអស់ រួចបំពេញចម្លើយដោយមិនសួរសំណួរលម្អិតជាក់ស្ដែង។ ហេតុនេះហើយ ការអង្កេតគ្រួសារដែលអ្នកសម្ភាសន៍ទទួលបានការបណ្ដុះបណ្ដាល និងមានការយល់ដឹងច្រើនអំពីការប្រឈមជាមួយនឹងប្រភេទសំណួរទាំងនេះ ផ្ដល់លទ្ធផលសុក្រឹតជាងការអង្កេត និងជំរឿនទូទៅ។ ទោះជាយ៉ាងណា គេអាចបណ្ដុះបណ្ដាលអ្នកសម្ភាសន៍អំពីការសួរសំណួររបស់ក្រុមការងារ៉ាស៊ីនតោន ដោយមិនប្រឈមនឹងបញ្ហាក្នុងការប្រមូលទិន្នន័យទាំងនេះ។

ក្រោមដែនកំណត់ទាំងពីរនេះ ការប៉ាន់ស្មានប្រេវ៉ាឡង់ពិការភាពក្នុងជំរឿនប្រជាជន អាចតិចជាងចំនួនជាក់ស្ដែង។ នេះជាបញ្ហាសម្រាប់ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ព្រោះប្រេវ៉ាឡង់ពិការភាពគឺទាបមិនគួរឱ្យជឿ។ ក្រុមការងារ៉ាស៊ីនតោនដឹងច្បាស់ថា កម្រងសំណួរខ្លីរបស់ក្រុមការងារ៉ាស៊ីនតោនស្ដីពីការបំពេញមុខងារ មិនកំណត់អត្តសញ្ញាណជនមានពិការភាពទាំងអស់នោះទេ និងគូសបញ្ជាក់ថា កម្រងសំណួរនេះមានគោលបំណងផ្ដល់លទ្ធភាពឱ្យអ្នកស្រាវជ្រាវពិពណ៌នាពីលក្ខណៈរបស់ប្រជាជនតាមស្ថានភាពពិការភាព។ ដូច្នេះគេមិនចាំបាច់កំណត់អត្តសញ្ញាណជនមានពិការភាពទាំងអស់នោះទេ។ សេចក្ដីផ្ដើមនៃកម្រងសំណួររបស់ក្រុមការងារ៉ាស៊ីនតោនស្ដីពីស្ថិតិពិការភាព លើកឡើងថា ៖ "មិនមានភាពចាំបាច់ក្នុងការកំណត់អត្តសញ្ញាណជនមានពិការភាពឲ្យបានភាគច្រើនលើសលប់នោះទេ លើកលែងតែយើងអាចធ្វើតាមរបៀបដែលផ្ដល់លទ្ធផលមិនលម្អៀង។ ប្រសិនបើបំពេញលក្ខខណ្ឌទាំងនេះបាន គេនឹងអាចកំណត់ភាពពាក់ព័ន្ធរវាងពិការភាព និងលទ្ធផលផ្សេងៗក្នុងទិន្នន័យ។ នៅពេលមានធនធានគ្រប់គ្រាន់ គេអាចបន្ថែមសំណួរបន្ថែមទៀតបាន។ កម្រងសំណួរខ្លីរបស់ក្រុមការងារ៉ាស៊ីនតោនស្ដីពីការបំពេញមុខងារ តំណាងឱ្យសំណួរតិចបំផុត ដែលអាចកំណត់ភាគរយជនមានពិការភាពបានច្រើនល្មមនឹងផ្ដល់អត្ថន័យគ្រប់គ្រាន់ដល់ប្រេវ៉ាឡង់ និងលទ្ធផលបែងចែកជាប្រភេទ" (ក្រុមការងារ៉ាស៊ីនតោន ២០២០)។

បញ្ហាប្រឈមក្នុងជំរឿន (រយៈពេល និងភាពស្មុគស្មាញនៃប្រតិបត្តិការនេះ) ទាមទារឱ្យមានការកម្រិតចំនួនសំណួរ និងកម្រិតនៃព័ត៌មានលម្អិត។ មានការសន្មតថា ប្រព័ន្ធប្រមូលទិន្នន័យផ្សេងទៀតប្រហែលជាត្រូវបានប្រើប្រាស់ដើម្បីទទួលបានព័ត៌មានស្ដីពីដើមហេតុបង្កការលំបាក ក្រៅពីព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការលំបាក។ ដូច្នេះជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ មិនរួមបញ្ចូលសំណួរលម្អិតបន្ថែមស្ដីពីពិការភាពឡើយ។ ទោះបីជាមិនត្រូវបានបញ្ចូលជាប្រធានបទស្នូលមួយក្នុងគោលការណ៍ និងអនុសាសន៍របស់អង្គការសហប្រជាជាតិសម្រាប់ជំរឿនប្រជាជន និងលំនៅដ្ឋានក្ដី ក៏សំណួរដ៏មានប្រយោជន៍មួយក្នុងជំរឿន គឺប្រភពបង្កការលំបាកបំពេញមុខងារក្នុងសំណួរមួយ ឬច្រើននៃកម្រងសំណួរខ្លីរបស់ក្រុមការងារ៉ាស៊ីនតោនស្ដីពីការបំពេញមុខងារ។ សំណួរស្ដីពីដើមហេតុ ត្រូវបានបញ្ចូលក្នុងជំរឿនជាច្រើន ប៉ុន្តែមិនត្រូវបានបញ្ចូលក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ឡើយ។ ឧ. កង្វះព័ត៌មានទាំងនេះមានន័យថា មិនអាចផ្ដល់ព័ត៌មានស្ដីពីចំនួនជនមានពិការភាពបានដោយសារអំពើហិង្សា គ្រាប់មីនកប់ដី ឬសំណល់ជាតិផ្ទុះពីសង្គ្រាម។ ទោះជាយ៉ាងណា កង្វះព័ត៌មានលម្អិតទាំងនេះ មិនធ្វើឱ្យប៉ះពាល់ដល់ប្រេវ៉ាឡង់ពិការភាពដែលទទួលបានពីជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ឡើយ។

# ជំពូក ៣៖ បរិបទពិការភាពក្នុងប្រទេសកម្ពុជា

នៅចន្លោះឆ្នាំ ១៩៩៨ និងឆ្នាំ ២០១៩ កម្ពុជាសម្រេចបានអត្រាកំណើនពិតជាមធ្យម ៧,៧ ភាគរយ និងត្រូវបានកំណត់ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុត ក្នុងពិភពលោក (ធនាគារពិភពលោក ២០២១)។ ថ្វីបើកម្ពុជាសម្រេចបានការអភិវឌ្ឍក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមក ដោយមាន ផសស សម្រាប់មនុស្សម្នាក់ចំនួន ១.៦៤៣,១ ដុល្លារអាមេរិក នៅឆ្នាំ ២០១៩ ក្តី ក៏ប្រទេសនេះ នៅតែជាប្រទេសក្រីក្របំផុតមួយក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (ធនាគារពិភពលោក, n.d.)។ អត្រាភាពក្រីក្រគឺ ១៣,៥ ភាគរយ នៅឆ្នាំ ២០១៤ ថយពី ៤៧,៨ ភាគរយ នៅឆ្នាំ ២០០៧ ហើយប្រជាជនក្រីក្រចំនួន ៩០ ភាគរយ រស់នៅច្រើនលើសលប់ក្នុងតំបន់ជនបទ។ មិនខុសពីប្រទេសផ្សេងទៀតនោះទេ ជំងឺរាតត្បាតកូវីដ ១៩ បានបង្កផលប៉ះពាល់លើអភិវឌ្ឍសង្គមសេដ្ឋកិច្ចនៅកម្ពុជា និងសុខុមាលភាពរបស់ប្រជាជនខ្មែរ។ ជំងឺកូវីដ ១៩ បានធ្វើឱ្យវិស័យទ្រទ្រង់កំណើនរបស់កម្ពុជា ដូចជា ទេសចរណ៍ ឧស្សាហកម្មផលិតសម្រាប់ការនាំចេញ និងសំណង់ ដែលធ្លាប់រួមចំណែកជាង ៧០ ភាគរយ ដល់កំណើន និងផ្តល់ការងារទទួលបានប្រាក់ឈ្នួលចំនួន ៤០ ភាគរយ ស្រុតចុះយ៉ាងខ្លាំង។ នៅឆ្នាំ ២០២០ សេដ្ឋកិច្ចកម្ពុជាមានអត្រាកំណើនអវិជ្ជមាន -៣,១ ភាគរយ ប៉ុន្តែគេប៉ាន់ស្មានថា សេដ្ឋកិច្ចនឹងងើបឡើងវិញក្នុងអត្រាកំណើន ៤ ភាគរយ នៅឆ្នាំ ២០២១។ ប្រជាជនខ្មែរចំនួន ៤,៥ លាននាក់រស់នៅលើគៀកខ្សែបន្ទាត់ភាពក្រីក្រ។ ដូច្នេះ ចាំបាច់ត្រូវវិភាគពិស្តារអំពីក្រុមងាយរងគ្រោះដែលរស់នៅក្នុងប្រទេសកម្ពុជា ដូចជា ជនមានពិការភាព និងរិះរកវិធីល្អបំផុតក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងឆ្លើយតប និងការបំពេញតម្រូវការរបស់ពួកគេ (ធនាគារពិភពលោក ២០២១)។ ក្នុងគោលបំណងនេះ ចំណុចសំខាន់គឺត្រូវយល់ឱ្យបានច្បាស់អំពីសាវតាពិការភាពក្នុងប្រទេសកម្ពុជា។

កម្ពុជាទើបតែរួចផុតពីស្ថានភាពអស្ថិរភាព និងជម្លោះ ដែលបានធ្វើឱ្យមនុស្សជាច្រើនបាត់បង់ជីវិត និងជួបការលំបាក។ ក្នុងសម័យខ្មែរក្រហម (១៩៧៥-១៩៧៩) ភាពអត់ឃ្លាន ការងារដោយបង្ខំ ជំងឺ ទារុណកម្ម និងការសម្លាប់រង្គាល បានធ្វើឱ្យប្រជាជនប្រមាណ ២ លាននាក់បាត់បង់ជីវិត។ ក្រៅពីនេះ ប្រជាជនជាច្រើនទទួលរងព្យសនកម្មផ្លូវកាយ និងផ្លូវចិត្ត និងប្រឈមនឹងផលវិបាកអស់មួយជីវិត។ បន្ទាប់ពីរបបនេះដួលរលំ កម្ពុជាប្រឈមការលំបាកយ៉ាងខ្លាំងក្នុងការស្តារប្រទេសឡើងវិញ ព្រោះអស្ថិរភាព និងចលាចលបន្តកើតឡើងជាច្រើនឆ្នាំ។ ខណៈដែលឯកសារពាក់ព័ន្ធបង្ហាញថា ជនមានពិការភាពមានចំនួនយ៉ាងច្រើន ការប៉ាន់ស្មានប្រែវ៉ាឡង់ប្រែប្រួលតាមនិយមន័យ និងមធ្យោបាយប្រមូលទិន្នន័យ (ឧ. ការអង្កេតគ្រួសារ ដូចជា ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា និងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ផ្តល់តួលេខខុសៗគ្នា) (Palmer, Williams & McPake, 2016)។

## ជនមានពិការភាព និងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធ

ជនមានពិការភាព នៅតែជាក្រុមដែលងាយរងគ្រោះបំផុតក្នុងសង្គម និងជាទូទៅ មិនសូវមានលទ្ធភាពស្មើភាពក្នុងការទទួលបានសេវាសុខភាព អប់រំ ទឹកពិសាសុវត្ថិភាព និងអនាម័យ ការគាំទ្រក្នុងសង្គម ការងារ ឬការបណ្តុះបណ្តាល។ល។ (ILO, 2009a; MacLeod, Pann, Cantwell & Moore, 2014)។ ជាមធ្យម ជនគ្មានពិការភាពមានលទ្ធភាពទទួលបានការថែទាំសុខភាពច្រើនជាងជនមានពិការភាពរហូតដល់ ៣ ដង (UNDESA ២០១៨)។ ប្រជាជនកម្ពុជាស្ទើរតែ ៧០ ភាគរយ គ្មានការធានារ៉ាប់រងសុខភាព ខណៈដែលប្រជាជន ៣១ ភាគរយ ទទួលបានរបបបេឡាជាតិសន្តិសុខសង្គម (គ្របដណ្តប់លើកម្មករនិយោជិតក្នុងវិស័យផ្លូវការ) និងមូលនិធិសមធម៌សុខភាព

(សម្រាប់គ្រួសារក្រីក្រ) (Nakamura et al., 2020)។ សេចក្តីរាយការណ៍បង្ហាញថា ជនមានពិការភាពមានការលំបាកក្នុងការទទួលបានសេវាថែទាំសុខភាព ដោយសារហេតុផលជាច្រើន (ទីតាំង ផ្លូវថ្នល់ មធ្យោបាយធ្វើដំណើរសាធារណៈ ឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធ ចម្ងាយ។ល។)។ កម្ពុជាមានមជ្ឈមណ្ឌល ស្តារនីតិសម្បទាចំនួន ១១ ដែលមិនអាចផ្តល់សេវាគ្រប់គ្រាន់ដល់មនុស្សគ្រប់រូបបានឡើយ (Palmer, Williams & McPake, 2016)។ ក្រៅពីនេះ ជនមានពិការភាពមានការលំបាកក្នុងការចូលរួមបោះឆ្នោត ព្រោះក្របខណ្ឌច្បាប់ធ្វើឱ្យដំណើរការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខណៈស្មុគស្មាញ ហើយការិយាល័យចុះឈ្មោះ អាចមិនផ្តល់ភាពងាយស្រួល និងមិនបំពាក់បរិក្ខារគ្រប់គ្រាន់។ ម៉្យាងវិញទៀត យុទ្ធនាការអប់រំអ្នកបោះឆ្នោត ជារឿយៗ មិនបានផ្សព្វផ្សាយដល់ជនមានពិការភាព។ ទោះជាយ៉ាងណា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសង្គមស៊ីវិលផ្សេងៗ និងអង្គការជនពិការ បានសហការគ្នាកែលម្អចំណុចនេះ (អង្គការជនពិការកម្ពុជា-CDPO ២០១៥)។

ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតសង្គមបរិយាបន្ន និងធានាសិទ្ធិរបស់ជនមានពិការភាព ស្តែងឡើងតាមរយៈការអនុម័តច្បាប់ សេចក្តីសម្រេច និងគោលនយោបាយជាតិ និងអន្តរជាតិផ្សេងៗ។ មាត្រា ៧៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា (១៩៩៣) ចែងថា "រដ្ឋជួយឧបត្ថម្ភជនពិការ និងគ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ" (Constitute Project, 2008)។

កម្ពុជាបាន និងកំពុងឆ្លើយតបនឹងតម្រូវការរបស់ជនមានពិការភាពក្រោមសន្ធិសញ្ញាអន្តរជាតិជាច្រើន ដូចជាអនុសញ្ញាស្តីពីសិទ្ធិជនពិការ (២០០៦) ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅខែ ធ្នូ ឆ្នាំ២០១២ (ប៉ុន្តែមិនមែនពិធីសារបន្ថែមនៃអនុសញ្ញានេះ)។ ក្រៅពីនេះ កម្ពុជាជាប្រទេសហត្ថលេខីនៃអនុញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលសុទ្ធតែតម្រូវឱ្យរដ្ឋសមាជិកបំពេញតម្រូវការ និងសិទ្ធិរបស់ជនមានពិការភាពតាមវិធីណាមួយ។ ក្នុងនាមជាសមាជិកគណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (UNESCAP) កម្ពុជាបានអនុម័តសេចក្តីសម្រេចលេខ ៦៨/៧ ស្តីពីទសវត្សរ៍ជនមានពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ ២០១៣-២០២២ (UNESCAP, 2019a) និងជារដ្ឋសមាជិកទីមួយដែលអនុម័តយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" (ក្រុមប្រឹក្សាសកម្មភាពជនពិការ-DAC, n.d.)។ កម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញាអូតាវ៉ាស្តីពីការហាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន នៅឆ្នាំ ១៩៩៩ (កម្រងសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ-UNTC, n.d.)។

ក្របខណ្ឌគតិយុត្តិថ្នាក់ជាតិស្តីពីពិការភាពដ៏សំខាន់ជាងគេ គឺ "ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ" ដែលត្រូវបានចុះហត្ថលេខានៅឆ្នាំ ២០០៩ និងផ្តល់សច្ចាប័ននៅខែ ធ្នូ ឆ្នាំ ២០១២។ ច្បាប់នេះជួយឱ្យកម្ពុជាបំពេញការទទួលខុសត្រូវរបស់ខ្លួនក្រោមអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ មាត្រា ២ នៃច្បាប់នេះមានគោលបំណង ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ ស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈដើម្បីធានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញ និងដោយស្មើភាពនៃជនពិការក្នុងសកម្មភាពនានារបស់សង្គម និងការពារសិទ្ធិ សេរីភាព និងផលប្រយោជន៍របស់ជនពិការ។ ក្រោមច្បាប់នេះ ក្រុមប្រឹក្សាសកម្មភាពជនពិការដើរតួនាទីជាអ្នកសម្របសម្រួល និងទីប្រឹក្សាថ្នាក់ជាតិស្តីពីពិការភាពក្នុងប្រទេសកម្ពុជា (ព្រះរាជាណាចក្រកម្ពុជា ២០០៩)។ ក្រុមប្រឹក្សាសកម្មភាពជនពិការត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៩ ក្នុងនាមជាស្ថាប័នសម្របសម្រួលពាក់កណ្តាលស្វយ័តនៅថ្នាក់ជាតិ ទទួលបន្ទុកវិស័យស្តារនីតិសម្បទា ផ្តល់យោបល់ណែនាំដល់រដ្ឋាភិបាលលើបញ្ហាពិការភាព សម្របសម្រួលសកម្មភាពពាក់ព័ន្ធរបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ (NGO) និងធានាថា វិស័យ

ឯកជន និងក្រសួងពាក់ព័ន្ធអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ យុទ្ធសាស្ត្រអ៊ីនឈាន់ និងទសវត្សរ៍ជនមានពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ ២០១៣-២០២២ (ILO, 209b; DAC, 2019)។ មាត្រាជាច្រើននៃច្បាប់នេះចែងថា ខ្លឹមសារលម្អិតនៃការអនុវត្តគួរត្រូវបានបញ្ជាក់បន្ថែមក្នុងអនុក្រឹត្យ ប្រកាស ឬសេចក្តីណែនាំរបស់ក្រសួង។ អនុក្រឹត្យមួយគ្របដណ្តប់លើវិធានការប្រឆាំងការរើសអើងក្នុងការងារ ដូចជា យថាប្រភេទនៃកូតានិយោជិតដែលមានពិការភាព ដែលគួរអនុវត្តដោយនីតិបុគ្គលសាធារណៈ និងឯកជន (ព្រះរាជាណាចក្រកម្ពុជា ២០០៩; ព្រះរាជាណាចក្រកម្ពុជា ២០១០)។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងធ្វើវិសោធនកម្មច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ វិសោធនកម្មនេះមានគោលបំណងលុបបំបាត់ការរើសអើងជនមានពិការភាព។

ខណៈដែលការអនុម័តច្បាប់នេះគឺជាបង្គោលចរដ៏សំខាន់មួយ របាយការណ៍អ្នកពាក់ព័ន្ធដែលរៀបចំឡើងដោយអង្គការជនពិការកម្ពុជា (CDPO) យល់ថា ច្បាប់នេះខ្វះចន្លោះផ្នែកសំខាន់ៗដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដូចជា គ្មានការលើកឡើងពីស្ត្រីងាយរងគ្រោះ និងកុមារមានពិការភាពមួយចំនួន និងកង្វះការលើកឡើងពី "...សិទ្ធិសំខាន់ៗ ដូចជា ការទទួលបានយុត្តិធម៌ សេរីភាពពីការកេងប្រវ័ញ្ច អំពើហិង្សា និងការបៀតបៀន សេរីភាពបញ្ចេញមតិ និងទស្សនៈ និងការទទួលបានព័ត៌មាន ការការពារជនមានពិការភាពក្នុងស្ថានភាពហានិភ័យ និងគ្រោះអាសន្នមនុស្សធម៌។ល។" (ទំ. ៣)។ ក្រៅពីនេះ របាយការណ៍នេះចោទសួរថាតើមានអនុក្រឹត្យ ប្រកាស ឬសេចក្តីណែនាំរបស់ក្រសួងទាំងអស់ ដែលត្រូវបានលើកឡើងក្នុងច្បាប់នេះ និងដែលត្រូវការចាំបាច់សម្រាប់ការអនុវត្ត ត្រូវបានរៀបចំដែរឬទេ (អង្គការ ជនពិការកម្ពុជា, n.d.)។

ដើម្បីពង្រឹងការអនុវត្តច្បាប់នេះ អនុក្រឹត្យពាក់ព័ន្ធ និងគោលនយោបាយផ្សេងទៀតដែលកម្ពុជាប្តេជ្ញាអនុវត្ត ក្រុមប្រឹក្សាសកម្មភាពជនពិការបានដឹកនាំបង្កើតផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពដំណាក់កាលទី ២ ឆ្នាំ ២០១៩-២០២៣។ ផែនការយុទ្ធសាស្ត្រនេះកំណត់ចក្ខុវិស័យថា "ជនមានពិការភាព និងក្រុមគ្រួសារ មានគុណភាពជីវិតល្អ ចូលរួមយ៉ាងសកម្មពេញលេញស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ព្រមទាំងមានការធ្វើបរិយាបន្នពិការភាពក្នុងគ្រប់វិស័យ និងការអភិវឌ្ឍ" (ក្រុមប្រឹក្សាសកម្មភាពជនពិការ ២០១៩, ទំ. ១៨)។ គោលដៅជាយុទ្ធសាស្ត្រនៃផែនការនេះមានបង្ហាញក្នុងរូប ៣.១។

ផែនការយុទ្ធសាស្ត្រនេះជំរុញឱ្យមានការផ្តល់សច្ចាប័នដល់សន្ធិសញ្ញា Marrakesh (យុទ្ធសាស្ត្រ ៩.១.៨) (DAC, 2019)។ សន្ធិសញ្ញានេះជួយសម្រួលដំណើរការផលិត និងចែកចាយសៀវភៅជាអន្តរជាតិ ដែលត្រូវបានកែសម្រួលសម្រាប់ជនពិការភ្នែក ឬជនមានកម្សោយផ្នែកគំហើញ តាមរយៈការបង្កើតកម្រងដែនកំណត់ និងករណីលើកលែងនៃច្បាប់សិទ្ធិថតចម្លងបែបប្រពៃណី និងបានចាប់ផ្តើមជាផ្លូវការនៅខែ កញ្ញា ឆ្នាំ ២០១៦ (WIPO, 2013)។

ទោះបីជាមានការសម្រេចបានវឌ្ឍនភាពយ៉ាងច្រើនក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះក្នុងការបោសសម្អាតតំបន់រងផលប៉ះពាល់ដោយសារគ្រាប់មីននៅកម្ពុជាក្តី ក៏គ្រាប់មីនកប់ដី និងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅតែជាបញ្ហាប្រឈមក្នុងតំបន់ជនបទ។ ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) រាយការណ៍ថា មានជនរងគ្រោះសរុបចំនួន ៦៤.៨៤៩ នៅចន្លោះខែ មករា ឆ្នាំ ១៩៧៩ និងខែ តុលា ឆ្នាំ ២០១៩។ នៅចន្លោះខែ មករា និងខែ តុលា ឆ្នាំ ២០១៩ មានជនរងគ្រោះសរុបចំនួន ៧១ នាក់ (ស្លាប់ ១១ នាក់)។ ក្នុងនោះ ៧៣ ភាគរយ រងគ្រោះដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាម និង ២៧ ភាគរយ រងគ្រោះដោយសារគ្រាប់មីន (CMAA, 2019)។

# ប្រេវ៉ាឡង់ពិការភាពនៅថ្នាក់សកល និងថ្នាក់ជាតិ

របាយការណ៍ពិការភាពពិភពលោកឆ្នាំ ២០១១ បង្ហាញទិដ្ឋភាពរួមនៃទិន្នន័យប្រេវ៉ាឡង់ពីប្រទេស ៥៩ ដែលចូលរួមក្នុងការអង្កេតសុខភាពពិភពលោក (ការអង្កេតសុខភាព និងពិការភាពពហុជាតិធំជាងគេ ដែលបានធ្វើឡើងនៅអំឡុងឆ្នាំ ២០០២-២០០៤)។ ដោយប្រើប្រាស់និយមន័យពិការភាពក្នុងការអង្កេតនេះ គេប៉ាន់ស្មានថា ប្រជាជនចំនួន ៩៧៨ លាននាក់ (ឬ ១៥,៣ ភាគរយ នៃចំនួនប្រជាជនពិភពលោកសរុប) ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ ប្រជាជនប្រមាណ ២,៩ ភាគរយ ពិការមិនអាចធ្វើអ្វីបាន។ ក្នុងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ គេប៉ាន់ស្មានថា ប្រជាជន ១៦,០ ភាគរយ ពិការខ្លាំង និង ២,៩ ភាគរយ ពិការមិនអាចធ្វើអ្វីបាន (WHO, 2011)។

រូប ៣.១ ៖ គោលដៅជាយុទ្ធសាស្រ្តនៃផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព ឆ្នាំ ២០១៩-២០២៣




*ទិដ្ឋភាពនៃពិការភាព ឆ្នាំ ២០១៩* (UNESCAP, 2019b)

ប្រេវ៉ាឡង់ពិការភាពក្នុងប្រទេសកម្ពុជាត្រូវបានប៉ាន់ស្មានដោយការសិក្សាថ្នាក់ជាតិ ដូចជា ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៨ ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES) និងការអង្កេតប្រជាសាស្រ្ត និងសុខភាព (DHS)។ ដោយសារការប្រើប្រាស់វិធីសាស្រ្ត និងនិយមន័យផ្សេងៗក្នុងការសិក្សាទាំងនេះ តួលេខប្រេវ៉ាឡង់

មានភាពខុសគ្នាខ្លាំង។ នៅឆ្នាំ ២០០៨ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា បញ្ចូលសំណួរមួយស្ដីពីពិការភាពផ្លូវកាយ និងពិការភាពផ្លូវចិត្តជាលើកដំបូង និងគ្របដណ្ដប់លើពិការភាព ៥ ប្រភេទ (ការមើលឃើញ ការនិយាយ ការស្ដាប់ ការធ្វើចលនា និងសតិបញ្ញា)។ ប្រសិនបើមនុស្សម្នាក់មានពិការភាពចាប់ពី ២ ប្រភេទឡើងទៅ អ្នកសម្ភាសន៍នឹងសម្រេចយកតែពិការភាពមួយប្រភេទប៉ុណ្ណោះដែលត្រូវកត់ត្រា។ យោងតាមជំរឿនឆ្នាំ ២០០៨ កម្ពុជាមានជនមានពិការភាពចំនួន ១៩២.៥៣៨ នាក់ (ក្នុងចំណោមប្រជាជនមិនរស់នៅក្នុងស្ថាប័ន) ស្មើនឹង ១,៤៤ ភាគរយនៃចំនួនប្រជាជនសរុប (វិទ្យាស្ថានជាតិស្ថិតិ ២០០៩)។

ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាចុងក្រោយ ធ្វើឡើងនៅឆ្នាំ ២០១៩/២០២០ និងប៉ាន់ស្មានថា ប្រជាជនគ្រប់វ័យចំនួន ៧២២.៦៤៣ នាក់ ឬ ៤,៧ ភាគរយ (ក្នុងចំណោមប្រជាជនមិនរស់នៅក្នុងស្ថាប័ន) មានពិការភាពយ៉ាងតិចមួយ។ ប្រភេទពិការភាពក្នុងការអង្កេតនេះរួមមាន ការមើលឃើញ ការស្ដាប់ ការនិយាយ ការធ្វើចលនា អារម្មណ៍ ឬញាណ ផ្លូវចិត្ត ការរៀនសូត្រ និងការស្រៀកពាក់ (fits)។ ប្រភេទពិការភាពទូទៅបំផុតគឺការមើលឃើញ ដោយប្រជាជន ២,៨ ភាគរយ មានការលំបាកក្នុងការមើល (NIS, 2020a)។ ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១៤ ជាឯកសារបោះពុម្ពផ្សាយចុងក្រោយបង្អស់ដែលអាចយកជាសំអាងបាន។ ក្នុងការអង្កេតនេះ ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើងដែលមានពិការភាពមួយចំនួន គឺ ១០ ភាគរយ។ ការសិក្សានេះប្រើប្រាស់កម្រងសំណួរខ្លីរបស់ក្រុមការងារវ៉ាស៊ីនតោនស្ដីពីការបំពេញមុខងារ ដូចជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ដោយបញ្ចូលការលំបាកបំពេញមុខងារចំនួន ៦ (ការមើលឃើញ ការស្ដាប់ ការដើរ ឬឡើង ការចងចាំ និងការគិត ការថែទាំខ្លួនឯង និងទំនាក់ទំនង)។ សម្រាប់ការបំពេញមុខងារនីមួយៗ អ្នកតបសម្ភាសន៍ត្រូវបានស្នើឱ្យបញ្ជាក់ពីកម្រិតនៃការលំបាកបំពេញកិច្ចការ ដូចតទៅ គ្មានលំបាក លំបាកខ្លះ លំបាកខ្លាំង និងមិនអាចធ្វើអ្វីបានទាំងអស់។ ការយល់ដឹងយ៉ាងទូលំទូលាយស្ដីពីពិការភាពត្រូវបានដាក់បញ្ចូលក្នុងការសិក្សានេះ ដែលអ្នកមានការលំបាកខ្លះត្រូវបានកំណត់ថា "មានពិការភាពណាមួយ" ហើយអ្នកមានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានទាំងអស់ ត្រូវបានកំណត់ថា "ពិការមិនអាចធ្វើអ្វីបាន"។

រូប ៣.២ បង្ហាញទិដ្ឋភាពរួមនៃប្រេវ៉ាឡង់ពិការភាពនៅអំឡុងឆ្នាំ ២០០៧-២០១៩ ដែលទទួលបានពីការអង្កេត និងជំរឿនផ្សេងៗ ដូចជា ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩។ ក្រាហ្វនេះបង្ហាញភាពខុសគ្នាខ្លាំងរវាងអត្រាប្រេវ៉ាឡង់ ដែលបានគណនាពីជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៨ និងឆ្នាំ ២០១៩ ការអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា ឆ្នាំ ២០១៣ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ ២០១៤ និងការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា[5]។ ភាពខុសគ្នាខ្លាំងគឺជារឿងធម្មតា ព្រោះប្រេវ៉ាឡង់នេះផ្អែកតាមវិធីសាស្ត្រ និងនិយមន័យដែលខុសគ្នាទាំងស្រុង។ ដូច្នេះ ក្រាហ្វនេះគ្មានគោលបំណងបង្ហាញពីទិន្នន័យដែលអាចប្រៀបធៀបបាន ឬការកើនឡើង ឬការថយចុះប្រេវ៉ាឡង់នោះទេ ប៉ុន្តែបង្ហាញពីនានាភាពនៃប្រេវ៉ាឡង់ដែលកើតចេញពីវិធីសាស្ត្រផ្សេងៗ។

ទិន្នន័យក្នុងរូប ៣.២ ដែលអាចប្រៀបធៀបបានជាមួយនឹងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ គឺទិន្នន័យពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា។ ការប្រៀបធៀបអត្រាប្រេវ៉ាឡង់នៃកម្រិតពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន ពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ ២០១៤ និងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បង្ហាញថា តួលេខក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាព គឺខ្ពស់ជាងជិត ២ ដង។ គំរូដូចគ្នានេះក៏លេចឡើងក្នុងការប្រៀបធៀបកម្រិតទាំងអស់នៃការលំបាកបំពេញមុខងារផងដែរ (ពិការខ្លះ ឬពិការមិនអាចធ្វើអ្វីបាន)។ ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ប្រជាជនអាយុ ៥ ឆ្នាំឡើងចំនួន

5 *វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ 2009 ,2009a, 2013 ,2013 ,2010a, 2014 ,2014a, 2020 ,2015*

៤,៩ ភាគរយ គូសបញ្ជាក់ថា ពួកគេមានការលំបាកខ្លះក្នុងការបំពេញមុខងារយ៉ាងតិច ១។ ក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១៤ ចំនួននេះគឺ ៩,៥ ភាគរយ (ខ្ពស់ជាងជិត ២ ដង)។ ការប្រៀបធៀបនេះបង្ហាញយ៉ាងច្បាស់ថា ការប៉ាន់ស្មានចំនួនប្រជាជនមានពិការភាពក្នុងជំរឿនគឺទាបជាងចំនួនជាក់ស្តែង ហើយប្រេវ៉ាឡង់ពិការភាពមានកម្រិតខ្ពស់ខ្លាំងជាងតួលេខនេះ។

រូប ៣.២ ៖ អត្រាប្រេវ៉ាឡង់ក្នុងជំរឿន និងការអង្កេតផ្សេងៗនៅកម្ពុជា ឆ្នាំ ២០០៧-២០១៩




ប្រភព ៖ GPCC, CDHS, CSES, IHHS.

# ជំពូក ៤៖ ចរិតលក្ខណៈទូទៅ របស់ជនមានពិការភាព

## ៤.១ ប្រេវ៉ាឡង់ពិការភាព

យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ កម្ពុជាមានប្រជាជនអាយុ ៥ ឆ្នាំឡើង ចំនួន ១៤,១ លាននាក់ (ប្រុស ៦,៨ លាននាក់, ស្រី ៧,៣ លាននាក់)។ ក្នុងចំណោមប្រជាជនអាយុ ៥ ឆ្នាំឡើង ៣,៧១ ភាគរយ មានការលំបាកខ្លះក្នុងការបំពេញមុខងារយ៉ាងតិចមួយ, ០,៨៧ ភាគរយ មានការលំបាកខ្លាំង និង ០,៣១ ភាគរយ មិនអាចបំពេញមុខងារ ១ ឬច្រើនបាន។ មានស្ត្រីច្រើនជាងបុរសដែលរាយការណ៍ថាយ៉ាងហោចណាស់ មានពិការភាពខ្លះ។ ខណៈដែលផលធៀបភេទប្រុស-ស្រីក្នុងចំណោមប្រជាជនអាយុ ៥ ឆ្នាំឡើង គឺ ៩៣,៨ ភាគរយ ផលធៀបនេះគឺត្រឹមតែ ៧១,២ ភាគរយប៉ុណ្ណោះក្នុងចំណោមជនមានពិការភាពណាមួយ[6]។ ចំណុចនេះបង្ហាញ ពីប្រេវ៉ាឡង់ពិការភាពកាន់តែខ្ពស់ក្នុងចំណោមមនុស្សស្រី (តារាង ៤.១)។

**តារាង ៤.១ ៖ របាយភាគរយប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមកម្រិតពិការភាព និងភេទ ជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩**

| | ប្រជាជនអាយុ ៥ ឆ្នាំឡើង | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន |
|---|---|---|---|---|---|
| ចំនួនប្រជាជន | | | | | |
| ទាំងពីរភេទ | ១៤.១០២.០៥២ | ១៣.៤១២.៥២០ | ៥២៣.១៦២ | ១២២.៧២៥ | ៤៣.៦៤៥ |
| ប្រុស | ៦.៨២៥.៨៧៤ | ៦.៥៣៩.២១៥ | ២១៨.១៧២ | ៤៩.៥៦៤ | ១៨.៩២៣ |
| ស្រី | ៧.២៧៦.១៧៨ | ៦.៨៧៣.៣០៥ | ៣០៤.៩៩០ | ៧៣.១៦១ | ២៤.៧២២ |
| ភាគរយប្រជាជនអាយុ ៥ ឆ្នាំឡើង | | | | | |
| ទាំងពីរភេទ | ១០០ | ៩៥,១១ | ៣,៧១ | ០,៨៧ | ០,៣១ |
| ប្រុស | ១០០ | ៩៥,៨០ | ៣,២០ | ០,៧៣ | ០,២៨ |
| ស្រី | ១០០ | ៩៤,៤៦ | ៤,១៩ | ១,០១ | ០,៣៤ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ផ្អែកតាមតួលេខជំរឿនឆ្នាំ ២០១៩ ដែលបង្ហាញក្នុងតារាង ៤.១ គេអាចគណនាអត្រាប្រេវ៉ាឡង់ពិការភាពទាំងបីកម្រិតសម្រាប់ប្រទេសកម្ពុជាបាន។ អត្រាប្រេវ៉ាឡង់ពិការភាព "ខ្លះឡើងទៅ" ផ្អែកតាមចំនួនប្រជាជនដែលរាយការណ៍ ថាមានការលំបាកបំពេញមុខងារយ៉ាងតិច ១ (លំបាកខ្លះ លំបាកខ្លាំង ឬមិនអាចធ្វើអ្វីបាន)។ ប្រេវ៉ាឡង់ពិការភាព

6 –ផលធៀបភេទជាចំនួនបុរសក្នុងចំណោមស្ត្រី ១០០ នាក់ក្នុងស្ថិតិសកលមួយ។

"ខ្លាំង ឬមិនអាចធ្វើអ្វីបាន" រួមបញ្ចូលប្រជាជនពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន សម្រាប់ការលំបាកបំពេញមុខងារយ៉ាងតិច ១ ខណៈដែលអត្រាពិការភាព "មិនអាចធ្វើអ្វីបាន" គ្របដណ្តប់លើអ្នកដែលមិនអាចធ្វើសកម្មភាពយ៉ាងតិចមួយក្នុងចំណោមសកម្មភាពទាំង ៦។

រូប ៤.១ បង្ហាញពីអត្រាប្រេវ៉ាឡង់ពិការភាពបែងចែកតាមកម្រិតពិការភាព និងភេទ។ ខណៈដែលក្នុងចំណោមមនុស្ស ២០ នាក់ដែលមានអាយុ ៥ ឆ្នាំឡើង មានស្ទើរតែម្នាក់ មានពិការភាពខ្លះ ពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានតែ ០,៣ ភាគរយ ប៉ុណ្ណោះដែលគូសបញ្ជាក់ថា ពួកគេមិនអាចធ្វើសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំង ៦ ចំណែកប្រេវ៉ាឡង់នៃពិការភាពខ្លាំងឡើងទៅ (តាមការវាយតម្លៃដោយសំណួររបស់ក្រុមការងារវ៉ាស៊ីនតោន) គឺ ១,២ ភាគរយ។

រូប ៤.១ ៖ អត្រាប្រេវ៉ាឡង់ពិការភាព បែងចែកតាមកម្រិតពិការភាព និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

ការប៉ាន់ស្មានប្រេវ៉ាឡង់នៃទម្រង់ និងប្រភេទផ្សេងៗនៃពិការភាព (ឧ. បែងចែកតាមអាយុ ភេទ និងទីតាំង) អាចផ្តល់ភស្តុតាង សម្រាប់ការធានាលទ្ធភាពប្រកបដោយសមធម៌របស់ជនមានពិការភាពក្នុងការទទួលបានសេវាពាក់ព័ន្ធ។ រូប ៤.២ បង្ហាញពីប្រភេទ និងកម្រិតផ្សេងៗនៃពិការភាពក្នុងចំណោមប្រជាជនអាយុ ៥ ឆ្នាំឡើង។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បានសម្ភាសប្រជាជនចំនួន ១៨.០០០ នាក់ (០,១៣ ភាគរយ) ដែលមិនអាចមើលឃើញ, ប្រជាជនចំនួន ១៦.០០០ នាក់ (០,១១ ភាគរយ) ដែលមិនអាចស្តាប់លឺ, ប្រជាជនចំនួន ១៧.០០០ នាក់ (០,១២ ភាគរយ) ដែលមិនអាចដើរបាន, ប្រជាជនចំនួន ១៩.០០០ នាក់ (០,១៣ ភាគរយ) ដែលមិនអាចចងចាំ ឬគិតបាន, ប្រជាជនចំនួន ២០.០០០ នាក់ (០,១៤ ភាគរយ) ដែលមិនអាចថែទាំខ្លួនឯងបាន និងប្រជាជនចំនួន ១៨.០០០ នាក់ (០,១៣ ភាគរយ) ដែលមិនអាចយល់អ្នកដទៃ ឬឱ្យអ្នកដទៃយល់បាន។ គួរកត់សម្គាល់ថា ប្រជាជនមួយចំនួនក្នុងចំណោមនេះមានការលំបាកចម្រុះ។

### រូប ៤.២ ៖ ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

នៅពេលពិចារណាពីប្រេវ៉ាឡង់ពិការភាពបែងចែកតាមប្រភេទ និងកម្រិត មានគំរូមួយលេចឡើងក្នុងចំណោមអ្នកមានការលំបាកខ្លាំង ឬមិនអាចធ្វើសកម្មភាពជាក់លាក់មួយ។ រូប ៤.៣ បង្ហាញពីប្រេវ៉ាឡង់ពិការភាពរបស់អ្នកមានអាយុ ៥ ឆ្នាំឡើងបែងចែកតាមប្រភេទ និងកម្រិតពិការភាព។ គេនឹងមិនរំពឹងថា មានភាពខុសគ្នាតិចតួចរវាងប្រភេទពិការភាពផ្សេងៗដូចការបង្ហាញក្នុងរូប ៤.៣ នោះទេ ព្រោះជាទូទៅ ទម្រង់ពិការភាពមួយចំនួន មានភាពញឹកញាប់ជាងទម្រង់ពិការភាពផ្សេងទៀត។ អត្រាប្រេវ៉ាឡង់សម្រាប់ពិការភាពខ្លាំង និងពិការភាពមិនអាចធ្វើអ្វីបាន គឺប្រហាក់ប្រហែលគ្នា (០,៥ ភាគរយ-០,៦ ភាគរយ សម្រាប់ពិការភាពខ្លាំង និង ០,១ ភាគរយ សម្រាប់ពិការភាពមិនអាចធ្វើអ្វីបាន)។ លទ្ធផលនៃប្រេវ៉ាឡង់ពិការភាពបែងចែកតាមប្រភេទពិការភាពទាំងនេះ មិនស៊ីសង្វាក់គ្នានឹងតួលេខអន្តរជាតិឡើយ។

រូប ៤.៣ ៖ ប្រេវ៉ាឡង់ពិការភាពរបស់ប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

# ៤.២ បញ្ហាប្រឈមជុំវិញទិន្នន័យស្តីពីប្រេវ៉ាឡង់ពិការភាព

ការវាស់វែងអត្រាប្រេវ៉ាឡង់ពិការភាព មិនមែនជារឿងងាយស្រួលនោះទេ។ ការប្រៀបធៀបឆ្លងប្រទេសស្តីពីអត្រាប្រេវ៉ាឡង់ពិការភាពបង្ហាញថា ជាញឹកញាប់ ប្រទេសមានប្រាក់ចំណូលខ្ពស់មានកម្រិតពិការភាពខ្ពស់ខ្លាំង ជាងប្រទេសមានប្រាក់ចំណូលទាប និងមធ្យម។ Pettinicchio & Maroto (២០២១) គូសបញ្ជាក់ថា ភាពខុសគ្នានៃអត្រាប្រេវ៉ាឡង់ដែលលេចឡើង ពាក់ព័ន្ធនឹងមជ្ឈដ្ឋានវប្បធម៌ និងស្ថាប័នរបស់ប្រទេសនានា ប៉ុន្តែភាពខុសគ្នាក៏អាចបណ្តាលមកពីការប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នាផងដែរ។

ផ្អែកមុនបង្ហាញពីប្រេវ៉ាឡង់ពិការភាពទាបក្នុងជំរឿនឆ្នាំ ២០១៩ (គំរូទូទៅដែលលេចឡើងទូទាំងតំបន់អាស៊ីអាគ្នេយ៍)។ ការប្រើប្រាស់និយមន័យរួមរបស់ក្រុមការងារវ៉ាស៊ីនតោនដែលកំណត់ថា ជនមានពិការភាពជាជនទាំងឡាយណាដែលមានការលំបាកខ្លាំង ឬមិនអាចបំពេញមុខងារយ៉ាងតិច ១ ក្នុងចំណោមមុខងារទាំង ៦ បង្ហាញថា ជំរឿនផ្សេងទៀតក៏មានអត្រាទាបនៃការរាយការណ៍អំពីការលំបាកបំពេញមុខងារទាំងនេះផងដែរ និងធ្វើឱ្យប្រេវ៉ាឡង់ពិការភាពមានអត្រាទាប។ ឧ. ជំរឿនប្រជាជន និងលំនៅដ្ឋាននៅប្រទេសមីយ៉ាន់ម៉ា ឆ្នាំ ២០១៤ បង្ហាញអត្រាប្រេវ៉ាឡង់ ១,១ ភាគរយ (នាយកដ្ឋានប្រជាជន ក្រសួងការងារ អន្តោប្រវេសន៍ និងប្រជាជន ២០១៧) ខណៈដែលការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅប្រទេសទីម័រខាងកើត ឆ្នាំ ២០១៦ ប៉ាន់ស្មានថា ប្រេវ៉ាឡង់ពិការភាពមានចំនួន ១,៦ ភាគរយ (អគ្គនាយកដ្ឋានស្ថិតិ ក្រសួងសុខាភិបាល និង ICF ២០១៨)។ អត្រាប្រេវ៉ាឡង់នេះគឺដូចគ្នានឹងអត្រា

ប្រេវ៉ាឡង់ក្នុងជំរឿននៅប្រទេសហ្វីលីពីន ឆ្នាំ ២០២០[7]។ ជំរឿននៅប្រទេសឡាវ ឆ្នាំ ២០១៥ បង្ហាញពីប្រេវ៉ាឡង់ចំនួន ០,៩ ភាគរយ (ការិយាល័យស្ថិតិឡាវ ក្រសួងផែនការ និងវិនិយោគ, គ.ជ.)។ ដូច្នេះ លទ្ធផលដែលទទួលបានក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា អាចមានអត្រាប្រេវ៉ាឡង់ប្រហាក់ប្រហែលគ្នានេះដែរ។

ការពិនិត្យបន្ថែមទៀតលើបញ្ហាទិន្នន័យ គឺការពិនិត្យចំនួនប្រជាជនមានពិការភាព បែងចែកតាមចំនួននៃការលំបាកដែលពួកគេរាយការណ៍។ ចំណុចនេះមានបង្ហាញក្នុងរូប ៤.៤ ។ គេអាចរំពឹងថា ជនមានពិការភាពភាគច្រើនមានពិការភាពតែមួយ ហើយជនមានពិការភាពភាគតិចប៉ុណ្ណោះដែលមានពិការភាពចម្រុះ។ ជាធម្មតា ដោយសារការកើនឡើងនៃចំនួនពិការភាពក្នុងមនុស្សម្នាក់ ចំនួនប្រជាជនសរុបដែលមានពិការភាពចម្រុះ នឹងថយចុះ។

រូប ៤.៤ បង្ហាញថា ប្រភេទជនមានពិការភាព ៦ ប្រភេទ មានចំនួនច្រើនមិនគួរឱ្យជឿ។ តាមពិត ចំនួនប្រជាជនដែលលើកឡើងថាមានពិការភាពខ្លះទាំង ៦ ប្រភេទ (២៤៥.០០០ នាក់) គឺមានច្រើនជាងចំនួនប្រជាជនដែលលើកឡើងថាមានពិការភាពខ្លះ ១ ប្រភេទ (២២៥.០០០ នាក់)។ ក្នុងចំណោមប្រជាជនទាំងអស់ដែលមានពិការភាព ១ ឬច្រើន មាន ៣៣,៤ ភាគរយ ត្រូវបានចុះបញ្ជីថាមានពិការភាពទាំង ៦ ប្រភេទ។ ប្រជាជនជាង ៤៥.០០០ នាក់មានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានទាំងអស់។ ការមិនអាចមើលឃើញ ស្តាប់លឺ ធ្វើចលនា ចងចាំ ថែទាំខ្លួនឯង និងប្រាស្រ័យទាក់ទង ធ្វើឱ្យមនុស្សម្នាក់ស្ទើរតែក្លាយជារុក្ខជាតិ។ ការវិភាគរហ័សស្តីពីក្រុមដែលមិនអាចបំពេញមុខងារទាំង ៦ បាន បង្ហាញថា ក្នុងចំណោមប្រជាជនទាំង ៩.៩៥៤ នាក់ក្នុងក្រុមនេះ ១.៣១៥ នាក់មានការងារធ្វើ, ៦០ នាក់គ្មានការងារធ្វើ១.០៧៥ នាក់ជាមេផ្ទះ, ៤.៣០៥ នាក់ ចេះភាសាខ្មែរ និង ៣០៦ នាក់កំពុងចូលរៀននៅសាលា។ ច្បាស់ណាស់ថា អ្នកដែលមិនអាចបំពេញមុខងារទាំង ៦ ដែលកំណត់ដោយក្រុមការងារវ៉ាស៊ីនតោន នឹងមិនអាចធ្វើសកម្មភាពទាំងនេះបានឡើយ ប៉ុន្តែគេមិនដឹងច្បាស់ថាតើអ្វីបង្កជាគំរូនេះឡើយ។

ដូច្នេះ គួរពិចារណាពីចំណុចខាងក្រោមនៅពេលបកស្រាយលទ្ធផលរកឃើញ ៖

ក. ជំរឿនឆ្នាំ ២០១៩ ប៉ាន់ស្មានប្រេវ៉ាឡង់ពិការភាពទាបជាងចំនួនជាក់ស្តែង ជាពិសេសប្រេវ៉ាឡង់ពិការភាពខ្លាំង និងពិការភាពមិនអាចធ្វើអ្វីបាន។ ដោយសារទិន្នន័យនៅកម្ពុជា និងប្រទេសជុំវិញ គុណភាពទិន្នន័យនៅមានកម្រិត មិនគួរធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ ឬជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៨ ឡើយ។

ខ. ភាគរយខ្ពស់នៃប្រជាជនដែលរាយការណ៍ពីការលំបាកបំពេញមុខងារទាំង ៦ មានន័យថារបាយនៃប្រភេទពិការភាពសម្រាប់ប្រជាជនទាំងអស់ អាចមិនសុក្រឹត។ ដូច្នេះ របាយការណ៍នេះមិនផ្តល់ការវិភាគស៊ីជម្រៅស្តីពីការលំបាកបំពេញមុខងារដោយឡែកៗ ដែលបានរាយការណ៍ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឡើយ ប៉ុន្តែផ្តោតតែលើស្ថានភាពពិការភាពទូទៅរបស់ប្រជាជន និងលក្ខណៈរបស់ពួកគេប៉ុណ្ណោះ។

ទោះបីជាមានការរាយការណ៍ពីប្រេវ៉ាឡង់ពិការភាពទាប និងការលំបាកយ៉ាងច្រើនក្នុងការបំពេញមុខងារទាំង ៦ ក្តី ក៏លទ្ធផលរកឃើញពីជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជានៅតែជាប្រភពព័ត៌មានដ៏តម្លៃបំផុត ព្រោះលទ្ធផលទាំងនោះពិពណ៌នាពីលក្ខណៈសង្គមសេដ្ឋកិច្ច និងលក្ខខណ្ឌជីវភាពរបស់ប្រជាជនចំនួន ៧០០.០០០ នាក់ដែលរាយការណ៍ពីពិការភាព។ ដូច្នេះ គួរចាត់ទុកជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ជាប្រភពមួយសម្រាប់ពិពណ៌នាពីលក្ខណៈ និងលក្ខខណ្ឌជីវភាពរបស់ជនមានពិការភាព ជាជាងជាមធ្យោបាយសម្រាប់គូសបញ្ជាក់

7 ដកស្រង់ពី ៖ https://psa.gov.ph/content/persons-disability-philippines-results-2010-census.

ពីចំនួនជាក់លាក់នៃជនមានពិការភាពក្នុងប្រទេសកម្ពុជា។ ផ្នែកផ្សេងទៀតនៃរបាយការណ៍នេះ សុទ្ធតែកត់សម្គាល់ពីចំណុចនេះ។

រូប ៤.៤ ៖ ចំនួនប្រជាជនមានពិការភាព បែងចែកតាមចំនួនពិការភាព និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០០៤, ២០០៩, ២០១៤ និង ២០១៩/២០២០

## ៤.៣ ប្រេវ៉ាឡង់ពិការភាពបែងចែកតាមអាយុ និងភេទ

មានស្ត្រីច្រើនជាងបុរសដែលរាយការណ៍ថាពិការខ្លះ ពិការខ្លាំង ពិការមិនអាចធ្វើអ្វីបាន ១ ឬច្រើនមុខងារ។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បានសម្ភាសស្ត្រីមានពិការភាពចំនួន ៤០២.៨៧៣នាក់ និងបុរសមានពិការភាពចំនួន ២៨៧.០០០ នាក់ (វិទ្យាស្ថានជាតិស្ថិតិ ២០២០)។ ខណៈដែលផលធៀបភេទក្នុងចំណោមប្រជាជនសរុបគឺ ៩៥,៧ ភាគរយ មានប្រជាជនអាយុ ៥ ឆ្នាំឡើងតែ ៧១,២ ភាគរយ ប៉ុណ្ណោះដែលមានពិការភាព[8]។ សម្រាប់កម្រិតពិការភាពនីមួយៗ ស្ត្រីមានប្រេវ៉ាឡង់ខ្ពស់ជាងបុរស ដោយមានភាពខុសគ្នាតិចបំផុតសម្រាប់ពិការភាពមិនអាចធ្វើអ្វីបាន (០,៣៤ ភាគរយ សម្រាប់ស្ត្រី និង ០,២៨ ភាគរយ សម្រាប់បុរស)។ ប្រេវ៉ាឡង់ពិការភាពខ្ពស់សម្រាប់ស្ត្រីក្នុងជំរឿននេះ ស៊ីសង្វាក់គ្នានឹងលទ្ធផលរកឃើញពីរបាយការណ៍ពិការភាពពិភពលោករបស់ WHO (WHO, 2011)។ ភាពខុសគ្នានេះបណ្តាលមកពីអត្រាខ្ពស់នៃប្រេវ៉ាឡង់តាមអាយុ បូករួមនឹងចំនួនស្ត្រីចំណាស់ដែលមានច្រើនជាងបុរសចំណាស់។

អាយុ និងពិការភាពទូទាំងពិភពលោក មានទំនាក់ទំនងវិជ្ជមានជាមួយគ្នា។ នៅពេលមនុស្សកាន់តែចាស់ ពួកគេងាយនឹងរាយការណ៍ពីពិការភាព (WHO, 2011)។ ផលប៉ះពាល់កាន់តែច្រើននៃកម្រិតពិការភាពនីមួយៗ (ពិការខ្លះ ពិការខ្លាំង ពិការមិនអាចធ្វើអ្វីបាន) អាចគូសបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃពិការភាពក្នុងដំណាក់កាលជីវិតរបស់ប្រជាជន។ រូប ៤.៥ បង្ហាញពីអត្រាប្រេវ៉ាឡង់បូកបន្តតាមអាយុសម្រាប់ក្រុមអាយុនីមួយៗ។ ក្រាហ្វនេះបង្ហាញពីគំរូគួរឱ្យចាប់អារម្មណ៍មួយចំនួន ៖

8 ផលធៀបភេទជាចំនួនបុរសក្នុងចំណោមស្ត្រី ១០០ នាក់ក្នុងស្ថិតិសកលមួយ។

១. រហូតដល់អាយុ ២៥ ឆ្នាំទើបប្រេវ៉ាឡង់នេះចុះទាបខ្លាំង។

២. ក្រោយអាយុ ៣៥ ឆ្នាំ ប្រេវ៉ាឡង់ចាប់ផ្តើមកើនឡើងយ៉ាងលឿន ដោយសារការមានពិការភាពខ្លះកាន់តែច្រើន។

៣. ប្រេវ៉ាឡង់ពិការភាពមានទំនោរកើនឡើងរហូតដល់អាយុ ៩០ ឆ្នាំ ដោយប្រជាជន ៥៧,៧ ភាគរយ គូសបញ្ជាក់ថា ពួកគេមានពិការភាព។ ក្រោយអាយុ ៩០ ឆ្នាំ អត្រានេះធ្លាក់ចុះដោយគ្មានមូលហេតុច្បាស់លាស់ (ទោះបីជាអាចបណ្តាលមកពីការប្រើសំណាកតិច ឬការរាយការណ៍តិចជាងចំនួនជាក់ស្តែងក្តី)។ នៅអាយុ ៧០ ឆ្នាំ ការកើនឡើងនៃពិការភាពបណ្តាលមកពីការកើនឡើងនៃចំនួនប្រជាជនមានពិការភាពខ្លះ ខណៈដែលចាប់ពីអាយុ ៧១ ឆ្នាំទៅការកើនឡើងនៃពិការភាព បណ្តាលមកពីការកើនឡើងនៃចំនួនប្រជាជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ នៅវ័យនេះ ប្រជាជនចំនួន ៣១ ភាគរយ មានពិការភាពខ្លះ ពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។

៤. ប្រេវ៉ាឡង់នៃពិការភាពខ្លះ ធ្លាក់ចុះក្រោយអាយុ ៨០ ឆ្នាំ។ ទោះជាយ៉ាងណា ប្រេវ៉ាឡង់ពិការភាពជារួមក្រោយវ័យនេះ បន្តកើនឡើងដោយសារការកើនឡើងនៃចំនួនប្រជាជនមានពិការភាពខ្លាំង និងពិការមិនអាចធ្វើអ្វីបាន។ប្រេវ៉ាឡង់ពិការភាពខ្ពស់ក្នុងចំណោមក្រុមអាយុវ័យចំណាស់ នឹងបង្កផលវិបាកធ្ងន់ធ្ងរមួយចំនួននាពេលអនាគត។ គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ឆ្នាំ ២០១៧-២០៣០ រំពឹងថាក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ភាគរយមនុស្សចាស់ដែលមានពិការភាពនឹងកើនឡើងយ៉ាងឆាប់រហ័ស និងចាំបាច់ត្រូវដោះស្រាយផលវិបាករបស់ប្រជាជនវ័យចាស់។ យោងតាមការព្យាករណ៍ចំនួនប្រជាជនឆ្នាំ ២០០៨ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើង នឹងកើនពី ៦,៥ ភាគរយ នៅឆ្នាំ ២០១០ ដល់ ១១,០ ភាគរយ នៅឆ្នាំ ២០៣០។ ពិការភាពពាក់ព័ន្ធនឹងវ័យជរា។ ដូច្នេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ចំនួនប្រជាជនមានពិការភាពក៏នឹងកើនឡើងយ៉ាងឆាប់រហ័សផងដែរ។ បញ្ហានេះនឹងដាក់បន្ទុកយ៉ាងធ្ងន់លើប្រព័ន្ធទ្រទ្រង់សង្គមរបស់កម្ពុជា។ ផ្អែកតាមសារៈសំខាន់ផ្នែកសង្គម គួរមានវិភាគឱ្យបានឆាប់រហ័សអំពីផលប៉ះពាល់នៃការប្រែប្រួលប្រជាសាស្ត្រលើចំនួនជាក់លាក់ និងចំនួនពាក់ព័ន្ធនៃប្រជាជនមានពិការភាពក្រោយបញ្ចប់ការព្យាករណ៍ចំនួនប្រជាជនដោយផ្អែកលើជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩។

រូប ៤.៥ ៖ ប្រេវ៉ាឡង់ពិការភាពបូកបន្តតាមអាយុ បែងចែកតាមកម្រិតសម្រាប់ប្រជាជនអាយុ ៥ ឆ្នាំឡើង និងក្រុមអាយុ ៥ ឆ្នាំ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

រូប ៤.៦ បង្ហាញពីអត្រាប្រេវ៉ាឡង់តាមអាយុសម្រាប់បុរស និងស្ត្រី បែងចែកតាមកម្រិតពិការភាព។ ក្រាហ្វនេះបង្ហាញពីពិការភាព ២ ប្រភេទ ៖ ក) ពិការខ្លះ (លំបាកខ្លះ) និង ខ) ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន (លំបាកខ្លាំង និងមិនអាចធ្វើអ្វីបានទាំងអស់)។ នៅពេលមនុស្សកាន់តែចាស់ ការកើនឡើងនៃប្រេវ៉ាឡង់ពិការភាពសម្រាប់ស្ត្រីគឺលឿនជាងបុរស។ ក្រៅពីនេះ ការកើនឡើងយ៉ាងឆាប់រហ័សនៃភាគរយប្រជាជនមានពិការភាព ចាប់ផ្តើមនៅអាយុវ័យក្មេងសម្រាប់ពិការភាពខ្លះ ជាងពិការភាពខ្លាំង/ពិការមិនអាចធ្វើអ្វីបាន។ ប្រេវ៉ាឡង់នៃពិការភាពខ្លះ មានអត្រាខ្ពស់បំផុតក្នុងក្រុមអាយុ ៨០-៨៤ ឆ្នាំ ដែលស្ត្រីចំនួន ២៩,១ ភាគរយ និងបុរសចំនួន ២៨,២ ភាគរយ មានពិការភាពខ្លះ។ ក្រោយវ័យនេះ ប្រេវ៉ាឡង់នៃពិការភាពខ្លះ ថយចុះ ខណៈដែលប្រេវ៉ាឡង់នៃពិការភាពខ្លាំង និងពិការមិនអាចធ្វើអ្វីបាន បន្តកើនឡើងរហូតដល់អាយុ ៩០ ឆ្នាំ។ ចំណុចនេះអាចបណ្តាល មកពីការវិវត្តនៃពិការភាពខ្លះ ទៅជាពិការភាពកាន់តែខ្លាំងនៅពេលវ័យកាន់តែចាស់។

រូប ៤.៦ ៖ អត្រាប្រេវ៉ាឡង់ពិការភាពតាមអាយុសម្រាប់ប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

របាយពិការភាពបែងចែកតាមអាយុ និងភេទក្នុងប្រទេសកម្ពុជា ពាក់ព័ន្ធនឹងរបាយអាយុជារួមរបស់ប្រជាជនសរុប។ រូប ៤.៧ បង្ហាញពីរ៉ាមីតអាយុ ៥ ឆ្នាំឡើងសម្រាប់ប្រជាជនទាំងអស់ និងចំណែកនៃក្រុមអាយុនីមួយៗដែលរួមផ្សំដោយជនមានពិការភាពប្រភេទណាមួយ។ នៅជិតសសរនីមួយៗ មានការបង្ហាញពីភាគរយនៃជនមានពិការភាព (សរុប ពិការខ្លះ ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន)។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ពាក់ព័ន្ធនឹងការថយចុះយ៉ាងខ្លាំងនៃចំនួនប្រជាជនក្នុងក្រុមអាយុ ៤០-៤៤ ឆ្នាំ គឺពីរ៉ាមីតនេះបង្ហាញពីការថយចុះយ៉ាងគំហុកនៃលទ្ធភាពបង្កើតកូនក្នុងរបបខ្មែរក្រហម ដោយអត្រាកំណើតដុលថយពី ៤០ នាក់ក្នុង ១.០០០ នាក់នៅទសវត្សរ៍ឆ្នាំ ១៩៦០ មកត្រឹម ២០-២៥ នាក់ក្នុង ១.០០០ នាក់នៅអំឡុងឆ្នាំ ១៩៧៥-១៩៧៩ (Dasvarma & Neupert, 2002)។ ទន្ទឹមនឹងការថយចុះអត្រាកំណើតដុល គឺអត្រាស្លាប់ខ្ពស់ដោយសារអំពើហិង្សា ភាពអត់ឃ្លាន និងជំងឺក្នុងរបបខ្មែរក្រហម។ គេអាចសន្និដ្ឋានបានថា មនុស្សជាច្រើនដែលមានពិការភាព និងមានអាយុ ៤០ ឆ្នាំឡើង ប្រហែលជាលំបាកបំពេញមុខងារនៅអំឡុងពេលនោះ។ ជំរឿននេះគ្មានសំណួរស្តីពីដើមហេតុបង្កពិការភាពឡើយ ដោយសារតែការកំណត់ចំនួនសំណួរ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា រាយការណ៍ពីដើមហេតុបង្កកម្សោយរាងកាយ និងគូសបញ្ជាក់ថា ប្រជាជន ១,៧ ភាគរយ មានកម្សោយរាងកាយ។ ដើមហេតុសំខាន់ៗរួមមាន ជំងឺ (៣៤,១ ភាគរយ) ពិការភាពពីកំណើត (១៩,៨ ភាគរយ) គ្រោះថ្នាក់ផ្សេងៗ (១៩,៤ ភាគរយ) គ្រាប់មីនកប់ក្នុងដី (១១,៤ ភាគរយ) និងកាំភ្លើង (៥,១ ភាគរយ) (វិទ្យាស្ថានជាតិស្ថិតិ ២០១១)។ វ័យជរាមិនត្រូវបានប្រើប្រាស់ជាដើមហេតុបង្កពិការភាពរាងកាយឡើយ។ ក្រៅពីនេះ ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០០០ ក៏រួមបញ្ចូលកម្សោយរាងកាយ និងដើមហេតុបង្កកម្សោយនេះផងដែរ។ ក្នុងចំណោមជនមានកម្សោយរាងកាយចំនួន ១,៦ ភាគរយ ដើមហេតុបង្កទូទៅបំផុតគឺជំងឺ (៣៦,៩ ភាគរយ) និងពិការភាពពីកំណើត (១៨,៣ ភាគរយ)។ ដើមហេតុបង្កផ្សេងទៀត រួមមានគ្រោះថ្នាក់ផ្សេងៗ (មិនមែនចរាចរណ៍)

(១៦,៤ ភាគរយ) គ្រាប់មីនកប់ក្នុងដី (១៤,៣ ភាគរយ) និងកាំភ្លើង (១១ ភាគរយ) (វិទ្យាស្ថានជាតិស្ថិតិ ២០០១)[9]។ ក្នុងការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០១៩/២០២០ មានសំណួរស្តីពីដើមហេតុបង្កការលំបាកបំពេញមុខងារនីមួយៗ និងមានការលើកឡើងពីដើមហេតុបង្កចំនួន ១៨។ គួរឱ្យសោកស្តាយដែលគ្មានការផ្តល់របាយភាគរយសម្រាប់ក្រុមប្រជាជនមានពិការភាព ប៉ុន្តែមានរបាយភាគរយសម្រាប់ប្រជាជនសរុបទៅវិញ។ លទ្ធផលបង្ហាញថា ប្រជាជនប្រហែល ០,១ ភាគរយ មានពិការភាពដោយសារគ្រាប់មីន យុទ្ធភណ្ឌមិនទាន់ផ្ទុះ ឬរបួសដោយសារសង្គ្រាម, ០,៣ ភាគរយ មានពិការភាពដោយសារគ្រោះថ្នាក់ចរាចរណ៍ ឬគ្រោះថ្នាក់ការងារ, ១,២ ភាគរយ មានពិការភាពដោយសារជំងឺ, ២,៣ ភាគរយ មានពិការភាពដោយសារវ័យជរា និង ០,៤ ភាគរយ មានពិការភាពដោយសារបញ្ហាពីកំណើត។

រូប ៤.៧ ៖ ពីរ៉ាមីតប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

រូប ៤.៨ បង្ហាញពីរ៉ាមីតប្រជាជនមានពិការភាព បែងចែកតាមកម្រិតពិការភាព។ ក្រាហ្វនេះបង្ហាញយ៉ាងច្បាស់ថា ជនមានពិការភាពច្រើនតែស្ថិតក្នុងក្រុមអាយុ ៥០ ឆ្នាំឡើង ហើយមានស្ត្រីច្រើនជាងបុរសដែលរាយការណ៍ថាមានពិការភាព។

ដើម្បីបង្ហាញពីឥទ្ធិពលនៃអាយុលើរបាយពិការភាព អាយុមធ្យមរបស់ប្រជាជនទាំងអស់ដែលមានអាយុលើស ៥ ឆ្នាំ ត្រូវបានគណនាទៅតាមកម្រិតពិការភាព។ ប្រជាជនមិនពិការដែលមានអាយុលើស ៥ ឆ្នាំ មានអាយុមធ្យម ២៧,៩ ឆ្នាំ ចំណែកប្រជាជនមានពិការភាពខ្លះ មានអាយុមធ្យម ៥៦,៤ ឆ្នាំ។ ប្រជាជនមានពិការភាពខ្លាំង មានអាយុមធ្យម ៦០,៣ ឆ្នាំ ចំណែកប្រជាជនពិការមិនអាចធ្វើអ្វីបាន មានអាយុមធ្យម ៤៩,៦ ឆ្នាំ។ គួរឱ្យភ្ញាក់ផ្អើលដែលប្រជាជនពិការមិនអាចធ្វើអ្វីបាន មានអាយុមធ្យមក្មេងជាង ប្រជាជនមានពិការភាពខ្លះ ឬពិការភាពខ្លាំង។ គេមិនដឹងច្បាស់ថា

9 គួរកត់សម្គាល់ថា ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១៤ និង ឆ្នាំ២០១០ សុទ្ធិតែមិនប្រើប្រាស់សំណួររបស់ក្រុមការងារវ៉ាស៊ីនតោន។ សំណួរសាមញ្ញមួយស្តីពីកម្សោយគឺ "តើមាននរណាម្នាក់ដែលជាទូទៅរស់នៅក្នុងគ្រួសាររបស់អ្នក មានកម្សោយរាងកាយប្រភេទណាមួយ ឬទេ?" សំណួរមួយទៀតគឺ "តើមាននរណាម្នាក់ដែលជាទូទៅរស់នៅក្នុងគ្រួសាររបស់អ្នក មានកម្សោយផ្លូវចិត្ត ឬទេ?" ទោះជាយ៉ាងណា គ្មានការលើកឡើងពីលទ្ធផលសម្រាប់សំណួរនេះក្នុងរបាយការណ៍នេះឡើយ។

តើគំរូនេះបណ្តាលមកពីអ្វីនោះទេ ប៉ុន្តែវាអាចពាក់ព័ន្ធនឹងការបាត់ព័ត៌មាននៃពិការភាព។ ជាញឹកញាប់ ពិការភាពខ្លះ និងពិការភាពខ្លាំង អាចបណ្តាលមកពីវ័យជរា ចំណែកពិការភាពមិនអាចធ្វើអ្វីបាន អាចបណ្តាលមកពីកត្តាផ្សេងទៀត ដូចជា បញ្ហាពីកំណើត ឬគ្រោះថ្នាក់ ប៉ុន្តែវាក៏អាចបណ្តាលមកពីបញ្ហាទិន្នន័យផងដែរ។ ដូច្នេះ ចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមទៀតដើម្បីពន្យល់ពីចំណុចនេះ។

រូប ៤.៨ ៖ ពីរ៉ាមីតប្រជាជនអាយុ ៥ ឆ្នាំឡើងដែលមានពិការភាព បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

រូប ៤.៩ បង្ហាញផលធៀបភេទតាមអាយុក្នុងចំណោមប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមកម្រិតពិការភាព (ពិការខ្លះ ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន)។ សម្រាប់ក្រុមអាយុវ័យក្មេង (២០ ឆ្នាំចុះក្រោម) មានបុរសច្រើនជាងស្ត្រីដែលមានពិការភាព។ ចាប់ពីអាយុ ២១ ឆ្នាំទៅ ផលធៀបភេទថយចុះតាមទម្រង់ខ្សែត្រង់ និងមានប្រមាណ ៤០ ភាគរយ នៅក្រុមអាយុចាស់ជាងគេ។ គំរូអាយុនៃផលធៀបភេទមានភាពខុសគ្នាសម្រាប់ពិការភាពខ្លាំង ធៀបនឹងពិការភាព ២ កម្រិតផ្សេងទៀត។ ខណៈដែលផលធៀបភេទសម្រាប់កម្រិតពិការខ្លះ និងពិការមិនអាចធ្វើអ្វីបាន ថយចុះក្រោម ១០០ ភាគរយ នៅអាយុ ២០ ឆ្នាំ សម្រាប់ពិការភាពខ្លាំង ផលធៀបនេះថយចុះសម្រាប់ក្រុមអាយុ ៤១ ឆ្នាំឡើង ប៉ុន្តែគេមិនដឹងច្បាស់ថាតើអ្វីបង្កជាភាពខុសគ្នានេះឡើយ។

រូប ៤.៩ ៖ ផលធៀបភេទតាមអាយុសម្រាប់ប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

## ៤.៤ ភាពខុសគ្នាតាមតំបន់រវាងទីប្រជុំជន និងជនបទ

ទីកន្លែងរស់នៅអាចជាកត្តាដ៏សំខាន់ដែលកំណត់លក្ខខណ្ឌជីវភាពរបស់ជនមានពិការភាព។ ឧ. ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១៤ បង្ហាញថា ជនមានពិការភាពដែលរស់នៅទីប្រជុំជន មានទំនោរខ្ពស់ក្នុងការស្វែងរកការព្យាបាលជំងឺ ឬរបួស ជាងជនមានពិការភាពដែលរស់នៅជនបទ រហូតដល់ ៧ ភាគរយ។ របាយការណ៍ស្តីពី "ការប្រើប្រាស់សេវាថែទាំសុខភាពដោយជនមានពិការភាពនៅកម្ពុជា" បញ្ជាក់ថា ចំណុចនេះអាចដោយសារតែមានមនុស្សជាច្រើននៅទីប្រជុំជនដែលរាយការណ៍ពីជំងឺ និងរបួស និងចំនួនយ៉ាងច្រើននៃគ្លីនិក និងឱសថស្ថានឯកជនក្នុងតំបន់ទាំងនោះ។ ផ្ទុយទៅវិញ ជនមានពិការភាពដែលរស់នៅជនបទ មានទំនោរខ្ពស់ក្នុងការប្រើប្រាស់មណ្ឌលសុខភាពសាធារណៈ ជាងជនមានពិការភាពដែលរស់នៅទីប្រជុំជន រហូតដល់ ៥ ដង។ ចំណុចនេះអាចបណ្តាលមកពីកង្វះលទ្ធភាពបង់ថ្លៃសេវា និងតម្លៃសមរម្យនៅជនបទ (Kleinitz et al., 2012; in WHO, 2017)។

យោងតាមលទ្ធផលពីជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ប្រជាជនចំនួន ៦,១ ភាគរយ (៣៩,៤ ភាគរយ) រស់នៅទីប្រជុំជន និងចំនួន ៩,៤ លាននាក់រស់នៅជនបទ។ តារាង ៤.២ បង្ហាញពីចំនួនប្រជាជនមានពិការភាព បែងចែកតាមប្រភេទទីកន្លែងរស់នៅ និងកម្រិតពិការភាព។ ក្នុងចំណោមជនមានពិការភាពទាំង ៦៨៩.៥៣២ នាក់ដែលត្រូវបានកត់ត្រាក្នុងជំរឿននេះ មាន ៣៤,៧ ភាគរយ រស់នៅទីប្រជុំជន និង ៦៥,៣ ភាគរយរស់នៅជនបទ។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៨ រកឃើញថា ជនបទមានប្រេវ៉ាឡង់ពិការភាព (១,៥ ភាគរយ) ខ្ពស់ជាងទីប្រជុំជន (១,១ ភាគរយ) (វិទ្យាស្ថានជាតិស្ថិតិ ២០០៩)។

### តារាង ៤.២ ៖ ពិការភាព បែងចែកតាមកម្រិត ភេទ និងប្រភេទលំនៅដ្ឋាន ជំងឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | | ចំនួនប្រជាជន | | | | | | |
|---|---|---|---|---|---|---|---|---|
| | | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | ពិការខ្លាំង + ពិការមិនអាចធ្វើអ្វីបាន | ចំនួនជនពិការសរុប | ចំនួនប្រជាជនសរុប |
| ប្រុស | ទីប្រជុំជន | ២.៨៩២.៨៤១ | ៧៦.០៥៨ | ១៦.៥៥៥ | ៧.៨៨៥ | ២៤.៤៤០ | ១០០.៤៩៨ | ២.៩៩៣.៣៣៩ |
| | ជនបទ | ៤.៣៩២.៣៣៧ | ១៤២.១១៤ | ៣៣.០០៩ | ១១.០៣៨ | ៤៤.០៤៧ | ១៨៦.១៦១ | ៤.៥៧៨.៤៩៨ |
| | ទីប្រជុំជន និងជនបទ | ៧.២៨៥.១៧៨ | ២១៨.១៧២ | ៤៩.៥៦៤ | ១៩.៩២៣ | ៦៨.៤៨៧ | ២៨៦.៦៥៩ | ៧.៥៧១.៨៣៧ |
| ស្រី | ទីប្រជុំជន | ៣¹០០៣.២១៨ | ១០៤.៥៦២ | ២៤.៣៧០ | ៩.៧០៥ | ៣៤.០៧៥ | ១៣៨.៦៣៧ | ៣.១៤១.៨៥៥ |
| | ជនបទ | ៤.៥៧៤.២៨៣ | ២០០.៤២៨ | ៤៨.៧៩១ | ១៥.០១៧ | ៦៣.៨០៨ | ២៦៤.២៣៦ | ៤.៨៣៨.៥១៩ |
| | ទីប្រជុំជន និងជនបទ | ៧.៥៧៧.៥០១ | ៣០៤.៩៩០ | ៧៣.១៦១ | ២៤.៧២២ | ៩៧.៨៨៣ | ៤០២.៨៧៣ | ៧.៩៨០.៣៧៤ |
| សរុប | ទីប្រជុំជន | ៥.៨៩៦.០៥៩ | ១៨០.៦២០ | ៤០.៩២៥ | ១៧.៥៩០ | ៥៨.៥១៥ | ២៣៩.១៣៥ | ៦.១៣៥.១៩៤ |
| | ជនបទ | ៨.៩៦៦.៦២០ | ៣៤២.៥៤២ | ៨១.៨០០ | ២៦.០៥៥ | ១០៧.៨៥៥ | ៤៥០.៣៩៧ | ៩.៤១៧.០១៧ |
| | ទីប្រជុំជន និងជនបទ | ១៤.៨៦២.៦៧៩ | ៥២៣.១៦២ | ១២២.៧២៥ | ៤៣.៦៤៥ | ១៦៦.៣៧០ | ៦៨៩.៥៣២ | ១៥.៥៥២.២១១ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

រូប ៤.១០ បង្ហាញថា សម្រាប់ប្រជាជនទាំងពីរភេទ ប្រេវ៉ាឡង់ពិការភាពនៅជនបទគឺខ្ពស់ជាងនៅទីប្រជុំជន ហើយប្រេវ៉ាឡង់នៃពិការភាពកម្រិតណាមួយគឺ ៤,៨ ភាគរយ សម្រាប់ជនបទ និង ៣,៩ ភាគរយ សម្រាប់ទីប្រជុំជន។ ទាំងកម្រិតពិការខ្លះ និងពិការខ្លាំង សុទ្ធតែមានប្រេវ៉ាឡង់ខ្ពស់នៅជនបទ។ ភាគរយនៃកម្រិតពិការមិនអាចធ្វើអ្វីបាន សម្រាប់ប្រជាជនទាំងពីរភេទនៅទីប្រជុំជន និងជនបទគឺប្រហែល ០,៣ ភាគរយ។ របាយការណ៍ស្តីពីពិការភាពរបស់ WHO (២០១១) បង្ហាញថា ប្រេវ៉ាឡង់ពិការភាពទូទាំងពិភពលោកមានកម្រិតខ្ពស់នៅជនបទ ជាងនៅទីប្រជុំជន។ នៅកម្ពុជា មានមូលហេតុជាច្រើនដែលធ្វើឱ្យប្រេវ៉ាឡង់នៅជនបទ ខ្ពស់ជាងប្រេវ៉ាឡង់នៅទីប្រជុំជន។ ទីមួយ ចំនួនមនុស្សចាស់នៅជនបទមានច្រើនជាងនៅទីប្រជុំជន ៖ យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ១០,៣ ភាគរយនៃប្រជាជនរស់នៅទីប្រជុំជន មានអាយុលើស ៦០ ឆ្នាំ ធៀបនឹង ១១,៩ ភាគរយសម្រាប់ជនបទ។ ទីពីរគឺការរស់នៅជនបទ មានបញ្ហាសុខភាពច្រើនជាងនៅទីប្រជុំជន ដូចជា កង្វះលទ្ធភាពទទួលបានទឹកពិសាដែលមានសុវត្ថិភាព កង្វះសម្ភារអនាម័យដែលមានការកែលម្អ និងកង្វះមូលដ្ឋានសុខភាពឯកទេស និងគ្រូពេទ្យ និងឆ្មបដែលមានគុណវុឌ្ឍិ។ ដូច្នេះ វាបង្កើនឱកាសដែលរបួស ឬជំងឺ បង្កជាពិការភាពពេញមួយជីវិត។ ទីបី ជាទូទៅគ្រាប់មីនកប់ដីមានច្រើននៅជនបទ។ ហេតុនេះ អ្នករស់នៅជនបទច្រើនតែរងគ្រោះដោយសារការផ្ទុះគ្រាប់មីនដោយចៃដន្យ។

មានភាពខុសគ្នាធំៗក្នុងប្រេវ៉ាឡង់ពិការភាពរវាងបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា។ រូប ៤.១១ បង្ហាញពីប្រេវ៉ាឡង់ពិការភាពរួម និងប្រេវ៉ាឡង់សរុបនៃកម្រិតពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន តាមខេត្តនីមួយៗ។ ការប្រៀបធៀបនេះសន្មតថា ការរាយការណ៍ពីការលំបាកបំពេញមុខងារ ១ ឬច្រើន មិនពាក់ព័ន្ធនឹងខេត្តដែលពួកគេរស់នៅនោះទេ។ ពោលគឺ កម្រិតនៃការមិនផ្តល់ឆ្លើយគឺដូចគ្នានៅគ្រប់បណ្តាខេត្តទាំងអស់។ គេមិនដឹងច្បាស់ថាតើភាពខុសគ្នាតាមខេត្ត បណ្តាលមកពីអ្វីនោះទេ។ ដើម្បីឱ្យដឹងច្បាស់ គេត្រូវធ្វើការស្រាវជ្រាវស៊ីជម្រៅស្តីពីគុណភាពទិន្នន័យថ្នាក់ខេត្ត ការរកបានសេវាគាំទ្រ ការប្រឈមនឹងកត្តាហានិភ័យ។ល។

រូប ៤.១០ ៖ ភាគរយប្រជាជនមានពិការភាព បែងចែកតាមកម្រិតពិការភាព ភេទ និងប្រភេទលំនៅដ្ឋាន ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩



ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

ខេត្តបាត់ដំបងមានភាគរយប្រជាជនមានពិការភាពខ្ពស់ជាងគេ (៦,២ ភាគរយ) បន្ទាប់មកគឺខេត្តកំពង់ឆ្នាំង (៥,៨ ភាគរយ) និងខេត្តកំពង់ចាម (៥,៦ ភាគរយ)។ ទីក្រុងភ្នំពេញ និងខេត្តរតនគិរីមានភាគរយប្រជាជនមានពិការភាពទាបជាងគេ (៣,២ ភាគរយ) ហើយបើធៀបនឹងខេត្តកំពង់ឆ្នាំង គឺស្ទើរតែទាបជាង ២ ដង។ គេមិនដឹងច្បាស់ពីដើមហេតុបង្កភាពខុសគ្នានេះទេ។ គ្មានទំនាក់ទំនងស្ថិតិរវាងកម្រិតនគរូបនីយកម្មក្នុងខេត្តនីមួយៗ និងផលប៉ះពាល់របស់វាលើប្រេវ៉ាឡង់ពិការភាពឡើយ។ ជាទូទៅ មានទំនាក់ទំនងផ្ទាល់រវាងប្រេវ៉ាឡង់នៃពិការភាពទាំងអស់ និងប្រេវ៉ាឡង់នៃកម្រិតពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ប៉ុន្តែនេះជាករណីលើកលែងសម្រាប់ខេត្តជាច្រើន។ ខេត្តព្រះសីហនុ មានអត្រាពិការភាពខ្លាំង/ពិការមិនអាចធ្វើអ្វីបាន ចំនួន ៣,០ ភាគរយ។ អត្រានេះខ្ពស់ជាងប្រេវ៉ាឡង់នៃខេត្តដែលមានប្រេវ៉ាឡង់ខ្ពស់ជាងគេទី ២ (១,៤ ភាគរយ) ដល់ទៅជាង ២ ដង (បាត់ដំបង កំពង់ចាម និងព្រៃវែង)។ ខេត្តមួយទៀតដែលបង្ហាញពីគំរូខុសប្លែកគឺខេត្តកំពង់ឆ្នាំង។ ខេត្តនេះមានប្រេវ៉ាឡង់ខ្ពស់សម្រាប់ពិការភាពទាំងអស់ (៥,៨ ភាគរយ) ប៉ុន្តែមានប្រេវ៉ាឡង់ទាបសម្រាប់កម្រិតពិការខ្លាំង/ពិការមិនអាចធ្វើអ្វីបាន (១,០ ភាគរយ)។

រូប ៤.១១.ក-ខ ៖ ប្រេវ៉ាឡង់ពិការភាព បែងចែកតាមកម្រិត និងខេត្ត ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

**ក.គ្រប់កម្រិតពិការភាព**



## ខ.ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

# ជំពូក ៥៖ ចរិតលក្ខណៈនៃគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព

ការគាំទ្រពីគ្រួសារមានសារៈសំខាន់ និងជាញឹកញាប់ ជាកត្តាចាំបាច់សម្រាប់ជីវិតរស់នៅរបស់ជនមានពិការភាព។ ខណៈដែលជំនួយពីអ្នកជំនាញ និងជំនួយពីស្ថាប័ន អាចផ្តល់ការទំនុកបម្រុងច្រើន ជំនួយទាំងនេះមិនអាចជំនួសឱ្យអារម្មណ៍កក់ក្តៅ ក្តីស្រឡាញ់ និងការថែទាំប្រកបដោយការយកចិត្តទុកដាក់ដែលផ្តល់ដោយសមាជិកគ្រួសារផ្ទាល់បានឡើយ។ គ្រួសារដែលផ្តល់ការគាំទ្រគ្រប់គ្រាន់នឹងធ្វើឱ្យជនមានពិការភាពចង់នៅផ្ទះ និងលើកកម្ពស់សមាហរណកម្មក្នុងសង្គម និងសហគមន៍។ ដូច្នេះ ការសំខាន់គឺត្រូវសិក្សាពីលក្ខណៈនៃគ្រួសារដែលមានសមាជិកមានពិការភាព។ ផ្នែកទី ១ នៃជំពូកនេះបង្ហាញពីសមាសភាគគ្រួសារដែលមានសមាជិកមានពិការភាព ចំណែកផ្នែកទី ២ ពិភាក្សាពីស្ថានភាពអាពាហ៍ពិពាហ៍របស់ជនមានពិការភាព។ ដោយសារតែជាញឹកញាប់ កុមារដើរតួនាទីយ៉ាងសកម្មក្នុងការថែទាំមនុស្សចាស់ដែលមានពិការភាព ផ្នែកចុងក្រោយនឹងបង្ហាញពីលទ្ធភាពបង្កើតកូនរបស់ស្ត្រីមានពិការភាព និងវត្តមានកុមារក្នុងគ្រួសារដែលសមាជិកមានពិការភាព។

## ៥.១ សមាសភាគនៃគ្រួសារដែលមានសមាជិកមានពិការភាព

ផ្អែកតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ចំនួនប្រជាជនសរុបគឺ ៣,៤៣ លានគ្រួសារ ស្មើនឹង ១៥,៦ លាននាក់ ហើយជាមធ្យម គ្រួសារមួយមានសមាជិក ៤,៣ នាក់ ថយពី ៤,៧ នាក់/គ្រួសារ ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៨ (វិទ្យាស្ថានជាតិស្ថិតិ ២០២០)។ ដោយសារតែជាញឹកញាប់ គ្រួសារជាប្រភពផ្តល់ការគាំទ្រសំខាន់ជាងគេដល់ជនមានពិការភាព ការសំខាន់គឺត្រូវដឹងអំពីចំនួនគ្រួសារដែលមានសមាជិកមានពិការភាព។ ការវិភាគនេះផ្តោតសំខាន់លើចំនួនគ្រួសារដែលមានសមាជិកពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ ក្នុងចំណោមគ្រួសារប្រក្រតីទាំងអស់ ប្រជាជនចំនួន ១៣៧.៦០៦ គ្រួសារមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ស្មើនឹង ៣,៤ ភាគរយ នៃចំនួនគ្រួសារសរុប។ តារាង ៥.១ បង្ហាញពីចំនួនគ្រួសារ បែងចែកតាមចំនួន (និងភាគរយ) សមាជិកពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ ចំណែកធំជាងគេគឺគ្រួសារមានសមាជិកម្នាក់មានពិការភាព (១២០.៤៨៩ គ្រួសារ) ស្មើនឹង ៣,៣៩ ភាគរយ នៃចំនួនគ្រួសារសរុប។ បន្ទាប់មកគឺគ្រួសារមានសមាជិក ២ នាក់មានពិការភាព (១៥.៣១៤ គ្រួសារ) ស្មើនឹង ០,៤៣ ភាគរយ។ គ្រួសារដែលមានសមាជិកលើស ២ នាក់មានពិការភាព មានចំនួនតិចបំផុត និងមានប្រជាជនចំនួន ១៣១ គ្រួសារដែលបញ្ជាក់ថា ពួកគេមានសមាជិកដែលមានពិការភាពលើស ១០ នាក់។

**តារាង ៥.១ ៖ ចំនួនគ្រួសារប្រក្រតី បែងចែកតាមចំនួនសមាជិកពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩**

| ចំនួនជនពិការក្នុងគ្រួសារ | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ០ | ៣.៤១៥.៤១៥ | ៩៦,១៣ |
| ១ | ១២០.៤៨៩ | ៣,៣៩ |
| ២ | ១៥.៣១៤ | ០,៤៣ |
| ៣ | ១.២០៧ | ០,០៣ |
| ៤ | ២៨៤ | ០,០១ |
| ៥ | ៩៩ | ០,០០ |
| ៦ | ៤៥ | ០,០០ |
| ៧ | ២៤ | ០,០០ |
| ៨ | ១០ | ០,០០ |
| ៩ | ៣ | ០,០០ |
| ១០⁺ | ១៣១ | ០,០០ |
| | ៣.៥៥៣.០២១ | ១០០,០០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ក្នុងចំណោមប្រជាជនអាយុ ៥ ឆ្នាំឡើងចំនួន ៦៨៩.៥៣២ នាក់ដែលមានពិការភាព មាន ១៤.៨៩៩ នាក់រស់នៅក្នុងគ្រួសារស្ថាប័ន ( តារាង ៥.២ ) ស្មើនឹង ២,២ ភាគរយ នៃចំនួនប្រជាជនមានពិការភាពទាំងអស់។ ជនមានពិការភាពយ៉ាងច្រើនលើសលប់រស់នៅក្នុងគ្រួសារប្រក្រតី។ ជំរឿននេះរាប់ប្រជាជនគ្មានផ្ទះសម្បែងចំនួន ៨.០២៨ នាក់។ ក្នុងនោះ ៣៩៤ នាក់មានពិការភាពប្រភេទណាមួយ ស្មើនឹង ៤,៩ ភាគរយនៃចំនួនប្រជាជនគ្មានផ្ទះសម្បែង។ ប្រជាជនឆ្លងកាត់ក្នុងជំរឿននេះ រួមបញ្ចូលជនដែលស្ថិតក្នុងស្ថានភាពដូចតទៅ (នៅយប់ធ្វើជំរឿន) ១) អ្នកមានវត្តមាននៅព្រលានយន្តហោះ ស្ថានីយ៍រថភ្លើង ចំណតរថយន្តក្រុង កំពង់ផែ លើសាឡាង និងក្នុងរទេះ (អ្នកធ្វើដំណើរ) ២) ជនពនេចរដែលបោះជំរំក្នុងភូមិ ៣) អ្នកស្ថិតនៅលើកប៉ាល់ក្នុងដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា និង ៤) អ្នកដែលស្ថិតនៅប៉ុស្តិ៍ត្រួតពិនិត្យតាមច្រកព្រំដែនអន្តរជាតិ។ ក្នុងចំណោមប្រជាជនឆ្លងកាត់ដែលត្រូវបានសម្ភាសន៍ទាំង ៤៧.១១៧ នាក់ មាន ២.០០៣ នាក់គូសបញ្ជាក់ថា ពួកគេមានពិការភាព (ស្មើនឹង ៤,៣ ភាគរយនៃចំនួនប្រជាជនឆ្លងកាត់សរុប)។ ក្នុងចំណោមអ្នករស់នៅលើទូក មាន ១១៧ នាក់ត្រូវបានកត់ត្រាថាមានពិការភាព ស្មើនឹង ៣,០ ភាគរយ។

## តារាង ៥.២ ៖ ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទគ្រួសារដែលពួកគេរស់នៅ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | មិនពិការ | | | ពិការខ្លះ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| គ្រួសារធម្មតា ឬប្រក្រតី | ៧.០៦៤.៩៤៦ | ៧.៤៤៧.៤៤៦ | ១៤.៥១២.៣៩២ | ២១៣.៦១០ | ៣០១.៦៤២ | ៥១៥.២៥២ |
| គ្រួសារស្ថាប័ន | ១៨៨.៩៤៨ | ១០៤.៧៩៥ | ១០៤.៧៩៥ | ៣.៦៥១ | ២.៣២០ | ៥.៩៧១ |
| គ្រួសារគ្មានផ្ទះសម្បែង | ៣.៩៤៧ | ៣.៦៨៧ | ៣.៦៨៧ | ១៥១ | ១៦៥ | ៣១៦ |
| ប្រជាជនរស់នៅលើទូក | ១.៩៥៦ | ១.៨៤០ | ១.៨៤០ | ៤៥ | ៤៨ | ៩៣ |
| ប្រជាជនឆ្លងកាត់ | ២៥.៣៨១ | ១៩.៧៣៣ | ១៩.៧៣៣ | ៧១៥ | ៨១៥ | ១.៥៣០ |
| គ្មានការបញ្ជាក់ | ០ | ០ | ០ | ០ | ០ | ០ |
| សរុប | ៧.២៨៥.១៧៨ | ៧.៥៧៧.៥០១ | ១៤.៨៦២.៦៧៩ | ២១៨.១៧២ | ៣០៤.៩៩០ | ៥២៣.១៦២ |
| របាយភាគរយ | | | | | | |
| គ្រួសារធម្មតា ឬប្រក្រតី | ៩៧,០ | ៩៨,៣ | ៩៧,៦ | ៩៧,៩ | ៩៨,៩ | ៩៨,៥ |
| គ្រួសារស្ថាប័ន | ២,៦ | ១,៤ | ២,០ | ១,៧ | ០,៨ | ១,១ |
| គ្រួសារគ្មានផ្ទះសម្បែង | ០,១ | ០,០ | ០,១ | ០,១ | ០,១ | ០,១ |
| ប្រជាជនរស់នៅលើទូក | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ប្រជាជនឆ្លងកាត់ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ |
| គ្មានការបញ្ជាក់ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

តារាង ៥.២ ៖ ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទគ្រួសារដែលពួកគេរស់នៅ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| ពិការខ្លាំង | | | ពិការមិនអាចធ្វើអីកើត | | | សរុប |
|---|---|---|---|---|---|---|
| ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | |
| ៤៦.៩៩៥ | ៧០.៣៣៧ | ១១៧.៣៣២ | ១៦.៩០២ | ២២.៦៣៣ | ៣៩.៥៣៥ | ១៥.១៨៤.៥១១ |
| ២.៣៥៥ | ២.៦០៥ | ៤.៩៦០ | ១.៩៥៦ | ២.០១២ | ៣.៩៦៨ | ៣០៨.៦៤២ |
| ៣១ | ២៨ | ៥៩ | ១១ | ៨ | ១៩ | ៨.០២៨ |
| ៩ | ៧ | ១៦ | ៥ | ៣ | ៨ | ៣.៩១៣ |
| ១៧៤ | ១៨៤ | ៣៥៨ | ៤៩ | ៦៦ | ១១៥ | ៤៧.១១៧ |
| ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៤៩.៥៦៤ | ៧៣.១៦១ | ១២២.៧២៥ | ១៨.៩២៣ | ២៤.៧២២ | ៤៣.៦៤៥ | ១៥.៥៥២.២១១ |
| របាយភាគរយ | | | | | | |
| ៩៤,៨ | ៩៦,១ | ៩៥,៦ | ៨៩,១ | ៩១,៦ | ៩០,៦ | ៩៧,៦ |
| ៤,៨ | ៣,៦ | ៤,០ | ១៩,៣ | ៨,១ | ៩,១ | ២,០ |
| ០,១ | ០,០ | ០,០ | ០,១ | ០,០ | ០,០ | ០,១ |
| ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ០,៤ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ |
| ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ក្នុងជំរឿននេះ ប្រភេទគ្រួសារត្រូវបានកំណត់ទៅតាមទំនាក់ទំនងរបស់សមាជិកម្នាក់ៗជាមួយមេគ្រួសារ[10]។ រូប ៥.១ បង្ហាញពីទំនាក់ទំនងរបស់មនុស្សទាំងអស់ក្នុងស្ថិតិសកលជាមួយមេគ្រួសារ បែងចែកតាមកម្រិតពិការភាព។ សម្រាប់ប្រជាជនដែលស្ថិតក្នុងក្រុមមានពិការភាពនីមួយៗ ទំនាក់ទំនងរបស់ពួកគេជាមួយមេគ្រួសារ ត្រូវបានកំណត់ជាក់លាក់។ ក្នុងចំណោមប្រជាជនទាំងអស់ដែលគ្មានពិការភាព មាន ២២,២ ភាគរយ ជាមេគ្រួសារ, ១៧,០ ភាគរយ ជាប្តី/ប្រពន្ធរបស់មេគ្រួសារ និង ៤២,៤ ភាគរយ ជាកូនរបស់មេគ្រួសារ។ ភាគរយនៃជនមានពិការភាពក្នុងកម្រិតណាមួយ ដែលជាមេគ្រួសារ គឺខ្ពស់ជាងជនគ្មានពិការភាព។ ក្នុងចំណោមជនមានពិការភាពខ្លះ មាន ៤៦,៣ ភាគរយ ជាមេគ្រួសារ។ ក្នុងចំណោមជនមានពិការភាពខ្លាំង មាន ៣៨,២ ភាគរយ ជាមេគ្រួសារ ហើយក្នុងចំណោមជនពិការមិនអាចធ្វើអ្វីបាន មាន ២៥,៥ ភាគរយ ជាមេគ្រួសារ។ អត្រាខ្ពស់ដូច្នេះគឺជារឿងធម្មតា ព្រោះការមានពិការភាព និងតួនាទីជាមេគ្រួសារ មានទំនាក់ទំនងជាមួយវ័យជរា។

រូប ៥.១ ៖ ភាគរយប្រជាជន បែងចែកតាមកម្រិតពិការភាព និងទំនាក់ទំនងរបស់ពួកគេជាមួយមេគ្រួសារ ឬអ្នកដឹកនាំក្នុងស្ថាប័ន ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩



ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

ចំណុចគួរឱ្យកត់សម្គាល់មួយទៀត គឺភាគរយនៃជនមានពិការភាពដែលត្រូវបានកត់ត្រាជាកូនរបស់មេគ្រួសារ មានអត្រាខ្ពស់សម្រាប់ជនពិការមិនអាចធ្វើអ្វីបាន ជាងជនមានពិការភាពខ្លះ ឬពិការភាពខ្លាំង។ ចំណុចនេះអាចដោយសារតែជនពិការមិនអាចធ្វើអ្វីបាន ច្រើនតែស្នាក់នៅផ្ទះនៅពេលចម្រើនវ័យ ជាងជនមានពិការភាពខ្លះ ឬពិការភាពខ្លាំង និងបន្តស្នាក់នៅជាមួយឪពុកម្តាយនៅពេលវ័យកាន់តែចាស់។ ខណៈដែល ឪពុកម្តាយមួយចំនួនតូចដែលគ្មានពិការភាព រស់នៅក្នុងគ្រួសារដែលមានកូនម្នាក់ (ឬច្រើននាក់) (១,២ ភាគរយ) តំរូនេះមិនលេចឡើងក្នុងចំណោមឪពុកម្តាយដែលមានពិការភាពឡើយ។ មានន័យថា ជាធម្មតា ឪពុកម្តាយរស់នៅពឹងខ្លួនឯង ប៉ុន្តែក្នុងករណីធ្លាក់ខ្លួនពិការ ពួកគាត់ត្រូវរស់នៅជាមួយគ្រួសាររបស់កូន។

10- យោងតាមនិយមន័យនៃជំរឿននេះ ៖ "សម្រាប់គោលបំណងជំរឿន មេគ្រួសារគឺជាមនុស្សដែលត្រូវបានទទួលស្គាល់ពីសមាជិកក្នុងគ្រួសារ។ មេគ្រួសារជាប្រុស ឬស្រី ជាទូទៅ គាត់ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងគ្រួសារ និងធ្វើការសម្រេចចិត្តក្នុងនាមឱ្យគ្រួសារ។ មេគ្រួសារមិនចាំបាច់ត្រូវតែជាមនុស្សចាស់ទេ ប៉ុន្តែគាត់អាចជាស្ត្រី ក្មេងស្រី ឬក្មេងប្រុសនៃសមាជិកគ្រួសារ (វិទ្យាស្ថានជាតិស្ថិតិ ២០២០, ទំ. ១៤២)។

ក្នុងចំណោមប្រជាជនទាំង ៣.៥៩៤.០៣១ លានគ្រួសារក្នុងប្រទេសកម្ពុជា គ្រួសារ ២៥,៦ ភាគរយ មានស្ត្រីជាមេគ្រួសារ (រូប ៥.២)។ ភាពជាមេគ្រួសារប្រែប្រួលទៅតាមកម្រិតពិការភាព។ ក្នុងចំណោមមេគ្រួសារដែលគ្មានពិការភាព មាន ២៤,៦ ភាគរយ ជាស្ត្រី។ ក្នុងចំណោមមេគ្រួសារដែលមានពិការភាពខ្លះ មាន ៣៦,៥ ភាគរយ ជាស្ត្រី។ ភាគរយស្ត្រីគឺខ្ពស់បំផុតក្នុងចំណោមក្រុមមេគ្រួសារដែលមានពិការភាពខ្លាំង (៤០,៨ ភាគរយ នៃមេគ្រួសារដែលមានពិការភាពខ្លាំង ជាស្ត្រី)។ ក្នុងចំណោមមេគ្រួសារដែលពិការមិនអាចធ្វើអ្វីបាន មាន ៣៦,៧ ភាគរយ ជាស្ត្រី។ ក្នុងករណីនេះ អាយុដើរតួនាទីយ៉ាងសំខាន់ ព្រោះស្ត្រីមានពិការភាពច្រើនតែមានអាយុចាស់ជាងក្រុមផ្សេងទៀត។ ក្នុងជំរឿននេះ ចំនួនមេគ្រួសារជាស្ត្រីវ័យចាស់គឺច្រើនជាងចំនួនមេគ្រួសារជាស្ត្រីវ័យក្មេង។

រូប ៥.២ ៖ ភាគរយនៃមេគ្រួសារជាស្ត្រី បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

ការសំខាន់គឺត្រូវយល់ពីប្រភេទគ្រួសារដែលមានសមាជិកមានពិការភាព ព្រោះជាញឹកញាប់ ពួកគេពឹងផ្អែកទាំងស្រុងលើសមាជិកគ្រួសារផ្សេងទៀតក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ សូមមើលប្រភេទគ្រួសារខាងក្រោម[11] ៖

- គ្រួសារមានសមាជិកតែម្នាក់
- គ្រួសារតូច ៖ ប្តី និងប្រពន្ធ (គ្មានកូន)
- គ្រួសារតូច ៖ ប្តី ប្រពន្ធ និងកូន
- គ្រួសារតូច ៖ ឪពុក/ម្តាយ និងកូន
- គ្រួសារធំ
- គ្រួសារសមាស
- គ្រួសារស្ថាប័ន គ្រួសារមិនធម្មតា
- គ្រួសារគ្មានប្រភេទច្បាស់លាស់។

11 - និយមន័យនៃប្រភេទគ្រួសារផ្សេងៗមានពន្យល់ក្នុងសទ្ទានុក្រមនៃរបាយការណ៍នេះ។

ប្រភេទគ្រួសារចុងក្រោយជាប្រភេទបន្ទាប់បន្សំ និងរួមបញ្ចូលគ្រួសារផ្តល់ព័ត៌មានមិនស៊ីសង្វាក់គ្នា ដែលធ្វើឱ្យគេមិនអាចកំណត់ប្រភេទគ្រួសារនោះបាន។ ភាពខុសគ្នារវាងគ្រួសារធំ និងគ្រួសារសមាស គឺគ្រួសារទាំងពីរប្រភេទនេះមានសមាជិកផ្សេងទៀតក្រៅពីអ្នកដែលជាប់សាច់ឈាម។ ក្នុងគ្រួសារធំ សមាជិក ទាំងអស់ពាក់ព័ន្ធគ្នា ប៉ុន្តែក្នុងគ្រួសារសមាស សមាជិកទាំងអស់មិនពាក់ព័ន្ធគ្នាទេ (UN, 2017)។

ជនមានពិការភាពជាងពាក់កណ្តាលរស់នៅក្នុងគ្រួសារធំ។ខណៈដែលជនគ្មានពិការភាពចំនួន៤០,៦ភាគរយរស់នៅក្នុងគ្រួសារធំ តួលេខនេះគឺ ៥២,១ ភាគរយសម្រាប់ជនមានពិការភាពខ្លះ, ៥៥,៧ ភាគរយសម្រាប់ជនមានពិការភាពខ្លាំង និង ៤៩,៤ ភាគរយសម្រាប់ជនពិការមិនអាចធ្វើអ្វីបាន (រូប ៥.៣)។ តួលេខទាំងនេះគូសបញ្ជាក់ថាសមាជិកគ្រួសារដែលមានពិការភាពនៅតែរស់នៅក្នុងគ្រួសារជាប់សាច់ឈាមគ្នា។ គ្មានភាពខុសគ្នាខ្លាំងរវាងទីប្រជុំជន និងជនបទ ពាក់ព័ន្ធនឹងភាគរយជនមានពិការភាពដែលរស់នៅក្នុងគ្រួសារធំឡើយ។ សម្រាប់ជនគ្មានពិការភាព ពួកគេច្រើនតែរស់នៅជុំគ្នា (៤៥,៦ ភាគរយ នៃប្រជាជនទាំងអស់)។ ជនមានពិការភាពដែលរស់នៅតែម្នាក់ឯង (គ្រួសារមានសមាជិកតែម្នាក់) ងាយរងគ្រោះបំផុត។ ដូច្នេះ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើក្រុមនេះតាមរយៈសេវាគាំពារសង្គម។ ជនមានពិការភាពខ្លាំងចំនួន ៥ ភាគរយ និងជនពិការមិនអាចធ្វើអ្វីបានចំនួន ៣ ភាគរយ រស់នៅតែម្នាក់ឯង។ ជនពិការមិនអាចធ្វើអ្វីបាន ចំនួន ១០ ភាគរយ រស់នៅក្នុងគ្រួសារស្ថាប័ន។ គួរឱ្យសោកស្តាយដែលគេមិនអាចកំណត់តើមានជនមានពិការភាពប្រភេទនេះប៉ុន្មាននាក់ ដែលកំពុងរស់នៅក្នុងស្ថាប័នថែទាំពិសេស ព្រោះជំរឿននេះគ្មានសំណួរស្តីពីចំណុចនេះឡើយ។

រូប ៥.៣ ៖ ភាគរយប្រជាជន បែងចែកតាមកម្រិតពិការភាព និងប្រភេទគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩



ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

## ៥.២. ស្ថានភាពអាពាហ៍ពិពាហ៍

យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ បុរសអាចរៀបអាពាហ៍ពិពាហ៍ បានចាប់ពីអាយុ ២០ ឆ្នាំ ហើយស្ត្រីអាចរៀបអាពាហ៍ពិពាហ៍បានចាប់ពីអាយុ ១៨ ឆ្នាំ។ ប្រសិនបើដៃគូណាម្នាក់ ឬទាំងពីរនាក់ មិនគ្រប់អាយុស្របច្បាប់ ហើយខាងស្រីមានផ្ទៃពោះ ពួកគេអាចរៀបការដោយមានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល។ ការរៀបការនៅអាយុក្មេងពេក ឬដោយការបង្ខំ ត្រូវបានហាមឃាត់ (រដ្ឋសភានៃរដ្ឋកម្ពុជា ១៩៨៩)។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ សហគមន៍អន្តរជាតិបានផ្លាស់ប្តូរគោលជំហរពាក់ព័ន្ធនឹងសិទ្ធិ និងការការពារជនមានពិការភាព ក្នុងការរៀបការ និងការធ្វើជាឪពុក/ម្តាយ។ នៅឆ្នាំ ១៩៩៤ ក្នុងកិច្ចប្រជុំលើកទី ៤៨ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តកម្រង "វិធានស្តង់ដារស្តីពីការផ្តល់ឱកាសស្មើភាពដល់ជនមានពិការភាព"។ ផ្នែក

ទី ២ នៃវិធានទី ៩ បញ្ជាក់យ៉ាងច្បាស់ពីគោលជំហររបស់សហគមន៍អន្តរជាតិចំពោះពិការភាព និងអាពាហ៍ពិពាហ៍/ភាពជាឪពុកម្តាយ (UN, 1994)។ ជនមានពិការភាពមិនគួរត្រូវបានបដិសេធចំពោះបទពិសោធន៍ផ្លូវភេទ ឬការស្ថិតក្នុងទំនាក់ទំនងផ្លូវភេទ ឬភាពជាឪពុក/ម្តាយឡើយ។ ដូច្នេះ រដ្ឋទាំងឡាយគួរផ្តល់ការពិគ្រោះយោបល់សមស្របដល់ជនមានពិការភាព ព្រោះពួកគេអាចប្រឈមការលំបាកកាន់តែខ្លាំងក្នុងការចាប់ផ្តើមគ្រួសារ ឬជីវិតអាពាហ៍ពិពាហ៍។ ចុងបញ្ចប់ វិធានទាំងនេះកំណត់ថា គួរផ្តល់លទ្ធភាពស្មើភាពក្នុងការទទួលបានព័ត៌មាន និងសេវាសុខភាព និងសិទ្ធិផ្លូវភេទ និងបន្តពូជ (UN, 1994)។ អនុសញ្ញាស្តីពីសិទ្ធិជនពិការផ្អែកតាមវិធានស្តង់ដារទាំងនេះ ហើយមាត្រា ២៣ នៃអនុសញ្ញានេះអះអាងថា រដ្ឋទាំងឡាយគួរខិតខំលុបបំបាត់ការរើសអើងពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ គ្រួសារ ទំនាក់ទំនង និងការធ្វើជាឪពុក/ម្តាយសម្រាប់ជនមានពិការភាព (UN, 2006)។ ក្នុងការអនុវត្តកិច្ចព្រមព្រៀងទាំងនេះ ចំណុចសំខាន់គឺត្រូវពិនិត្យមើលថាតើមានការបំពេញការប្តេជ្ញាចិត្តពាក់ព័ន្ធនឹងទំនាក់ទំនង ភាពជាឪពុកម្តាយ និងអាពាហ៍ពិពាហ៍ ឬទេ ឬក្នុងកម្រិតណា។

តាមប្រពៃណី ការរៀបអាពាហ៍ពិពាហ៍ក្នុងប្រទេសកម្ពុជាត្រូវមានការយល់ព្រមពីគ្រួសារទាំងសងខាង។ ស្ត្រីមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសស្វាមីឡើយ និងត្រូវរង់ចាំឱ្យបុរសជាអ្នកសុំរៀបការ ឬត្រូវរង់ចាំឱ្យគ្រួសាររបស់អនាគតស្វាមីស្នើសុំរៀបការ។ Gartrell and Becker (2017) បានពិនិត្យទិដ្ឋភាពពាក់ព័ន្ធនឹងសុខភាពផ្លូវភេទ និងបន្តពូជរបស់ស្ត្រីមានពិការភាពនៅកម្ពុជា។ តាមរយៈបទសម្ភាសន៍ស៊ីជម្រៅ និងកិច្ចពិភាក្សាក្រុមគោលដៅ ពួកគេបានប្រមូលព័ត៌មានស៊ីជម្រៅពីស្ត្រីមានពិការភាពចំនួន ៣៣ នាក់ក្នុងខេត្តកំពត។ ការសិក្សានេះបង្ហាញថា ជាញឹកញាប់ ស្ត្រីមានពិការភាពរង់ចាំការស្នើសុំពីបុរស ទោះបីជាពួកគេយល់ថា ពួកគេមិនមែនជាស្ត្រីដែលមានភាពទាក់ទាញ និងគួរឱ្យប្រតិព័ទ្ធ ដែលអាចបង្កើតកូន និងធ្វើជាម្តាយបានក្តី។ យោងតាម Gartrell, Baesel & Becker (2017) ស្ត្រីមានពិការភាព "មិនយល់ថា ពួកគេមានភាពទាក់ទាញ និងមានទំនុកចិត្តនោះទេ ដោយសារតែយេនឌ័រ និងបទដ្ឋានសង្គមពាក់ព័ន្ធនឹងពិការភាព" (ទំ. ៣៥) និង "ត្រូវបានសន្មតជាបន្ទុករបស់គ្រួសារខាងប្តី" (ទំ. ៣៦)។ ជាញឹកញាប់ ពួកគេត្រូវបានចាត់ទុកថាមិនសក្តិសមជាដៃគូអាពាហ៍ពិពាហ៍ ឬឪពុកម្តាយ និងអាចត្រូវបានចាត់ថាមានអព្យាក្រឹតយេនឌ័រ ឬជាមនុស្សគ្មានភាពទាក់ទាញផ្លូវភេទ (asexual human)(McCallum, 2020)។ ក្រៅពីនេះ ស្ត្រីមានពិការភាពងាយក្លាយជាគោលដៅនៃការរំលោភបំពាន។ ការសិក្សាដោយ Astbury and Walji (2013) បង្ហាញថា នៅកម្ពុជា ស្ត្រីមានពិការភាពងាយទទួលរងអំពើហិង្សាពីដៃគូច្រើនជាងស្ត្រីមិនពិការ។ ទោះជាយ៉ាងណា ករណីអំពើហិង្សាផ្លូវចិត្ត អំពើហិង្សាផ្លូវកាយនិងអំពើហិង្សាផ្លូវភេទដែលបង្កឡើងដោយសមាជិកគ្រួសារគឺខ្ពស់ជាងករណីដែលបង្កឡើងដោយដៃគូ។

រូប ៥.៤.ក និង ៥.៤.ខ រៀបរាប់ពីភាគរយតាមអាយុរបស់បុរស និងស្ត្រី ដែលបានរៀបការ បែងចែកតាមកម្រិតពិការភាព។ ក្រាហ្វទាំងពីរនេះបង្ហាញថា ភាគរយអ្នកដែលបានរៀបការសម្រាប់ក្រុមនីមួយៗនៃក្រុមអាយុ ៥ ឆ្នាំ គឺប្រហាក់ប្រហែលគ្នា សម្រាប់ជនគ្មានពិការភាព និងជនមានពិការភាពខ្លះ។ ចាប់ពីអាយុ ៣១ ឆ្នាំទៅ អត្រារៀបការសម្រាប់ជនមានពិការភាពខ្លះ ធ្លាក់ទាប។ អត្រាខុសគ្នារវាងក្រុមទាំងពីរនេះកើនឡើងនៅក្រុមអាយុវ័យចាស់។ ភាគរយស្ត្រី និងបុរសដែលបានរៀបការ មានកម្រិតទាបខ្លាំងក្នុងចំណោមជនពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ ឧ. ក្នុងក្រុមអាយុ ៤៥-៤៩ ឆ្នាំ បុរសពិការខ្លាំង ដែលបានរៀបការមាន ៥២,៤ ភាគរយ ធៀបនឹង ៩៣,៥ ភាគរយ នៃបុរសគ្មានពិការភាព ហើយស្ត្រីពិការខ្លាំងដែលបានរៀបការមាន ៥៤,៤ ភាគរយ ធៀបនឹង ៨៥,២ ភាគរយ នៃស្ត្រីគ្មានពិការភាព។ ភាគរយរៀបការសម្រាប់ជនមានពិការភាពខ្លាំង គឺខ្ពស់បន្តិចជាងជនពិការមិនអាចធ្វើអ្វីបាន ប៉ុន្តែនៅតែទាបជាងជនមានពិការភាពខ្លះ ឬគ្មានពិការភាព។

គួរកត់សម្គាល់ថា ក្នុងក្រុមអាយុវ័យចាស់ (៦៥ ឆ្នាំឡើងទៅ) មានភាពប្រសព្វគ្នារវាងពិការភាពទាំង ៥ ប្រភេទ (មិនពិការ ពិការខ្លះ ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន)។ ចំណុចនេះអាចបណ្តាលមកពីមនុស្សចាស់ជាច្រើនធ្លាក់ខ្លួនពិការនៅវ័យជរា និងប្រហែលជាបានរៀបការជាច្រើនឆ្នាំមកហើយ។ សម្រាប់ក្រុមអាយុវ័យចាស់ទាំងអស់ ភាគរយសម្រាប់ស្ត្រីគឺទាបជាងបុរស។ ចំណុចនេះគឺដោយសារតែស្ត្រីមានអាយុសង្ឃឹមរស់ខ្ពស់ជាងបុរស (៧៦,៨ ឆ្នាំ ទល់នឹង ៧៤,៣ ឆ្នាំ) ប៉ុន្តែក៏បណ្តាលមកពីភាពខុសគ្នានៃអាយុមធ្យមនៅពេលរៀបការលើកដំបូងផងដែរ (២៧,0 ឆ្នាំសម្រាប់បុរស និង ២៤,0 ឆ្នាំសម្រាប់ស្ត្រី) (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ២0២0)។

រូប ៥.៤.ក ៖ ភាគរយតាមអាយុនៃបុរសដែលបានរៀបការ បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




រូប ៥.៤.ខ ៖ ភាគរយតាមអាយុនៃស្ត្រីដែលបានរៀបការ បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩



ឱកាសរៀបការរបស់ជនមានពិការភាព គឺទាបទាំងសម្រាប់បុរស និងស្ត្រី។ អាយុរៀបការលើកដំបូងកើនឡើងតាមកម្រិតពិការភាព។ អាយុជាមធ្យមនៅពេលរៀបការ (SMAM)[12] បែងចែកតាមភេទ និងកម្រិតពិការភាព មានបង្ហាញក្នុងរូប ៥.៥។ មានភាពខុសគ្នាតិចតួចរវាងអាយុជាមធ្យមនៅពេលរៀបការសម្រាប់ជនគ្មានពិការភាព និងជនមានពិការភាពខ្លះ។ សម្រាប់បុរសមានពិការភាពខ្លាំង អាយុជាមធ្យមនៅពេលរៀបការគឺ ២៨,៨ ឆ្នាំ ពោលគឺលើសបុរសមានពិការភាពខ្លះប្រហែល ២ ឆ្នាំ។ បុរសពិការមិនអាចធ្វើអ្វីបាន រៀបការនៅអាយុជាមធ្យម ២៩,៥ ឆ្នាំ ពោលគឺយឺតជាងបុរសមិនពិការប្រហែល ៣ ឆ្នាំ។

រូប ៥.៥ ៖ អាយុជាមធ្យមនៅពេលរៀបការ (SMAM) បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ក្នុងចំណោមស្ត្រី អាយុនៅពេលរៀបការលើកដំបូងគឺមិនសូវខុសគ្នាទេ។ ខណៈដែលអាយុមធ្យមនៅពេលរៀបការលើកដំបូងសម្រាប់ស្ត្រីគ្មានពិការភាពគឺ ២៣,៥ ឆ្នាំ អាយុមធ្យមសម្រាប់ស្ត្រីមានពិការភាពខ្លាំងគឺ ២៥.០ ឆ្នាំ ហើយអាយុមធ្យមសម្រាប់ស្ត្រីពិការមិនអាចធ្វើអ្វីបានគឺ ២៥,១ ឆ្នាំ។ ដើម្បីពិនិត្យភាពខុសគ្នាជារួមនៃអាយុរៀបការសម្រាប់ប្រជាជនមានពិការភាព និងប្រជាជនផ្សេងទៀត ការសំខាន់គឺត្រូវគ្រប់គ្រងកត្តាអន្តរាគមន៍ផ្សេងទៀត ដូចជាកម្រិតអប់រំ ភេទ និងរបាយភូមិសាស្ត្រ ដោយប្រើប្រាស់បច្ចេកទេសស្ថិតិចម្រុះ។ ដោយសារតែអថេរចំណុះ (dependent variable) បែងចែកជាពីរ (មិនដែលរៀបការ ទល់នឹងធ្លាប់រៀបការ) ចាំបាច់ត្រូវប្រើរីហ្គ្រេសិនឡូជីស្ទិក។

ក្នុងរីហ្គ្រេសិនឡូជីស្ទិក មេគុណរីហ្គ្រេសិនជា natural logarithms នៃឱកាសរៀបការសម្រាប់មនុស្សម្នាក់ក្នុងក្រុមអាយុ ៣០-៣៤ ឆ្នាំ នៅពេលធ្វើជំរឿន។ Natural exponential (eb) នៃមេគុណរីហ្គ្រេសិន (b) ត្រូវបានគណនា និងវាស់វែងផលធៀបឱកាសនៃការរៀបការសម្រាប់មនុស្សម្នាក់ដែលស្ថិតក្នុងប្រភេទជាក់លាក់ ធៀបនឹងមនុស្សម្នាក់ក្នុងប្រភេទយោង។ ផលធៀបឱកាសជាឱកាសនៃការរៀបការ ធៀបនឹងការមិនរៀបការ។ ឧ. ប្រសិនបើ "ប្រុស"

12 -*SMAM សំដៅលើរយៈពេលមធ្យមនៃជីវិតមិនធ្លាប់រៀបការ សម្រាប់អ្នកដែលបានរៀបការមុនអាយុ ៥០ ឆ្នាំ និងត្រូវបានគណនាពីចំនួនប្រជាជនដែលមិនធ្លាប់រៀបការក្នុងក្រុមអាយុ ៥ ឆ្នាំ ពីជំរឿន ឬការអង្កេត (Hajnal 1953)*។

ជាប្រភេទយោងសម្រាប់អថេរភេទ ហើយ natural exponential នៃមេគុណរឺហ្គ្រេនសិនស្មើនឹង 0,៧ មានន័យថា ឱកាសរៀបការរបស់ស្ត្រីម្នាក់គឺត្រឹមតែ ៧០ ភាគរយ ធៀបនឹងឱកាសរៀបការរបស់បុរសម្នាក់។ ដើម្បីយល់កាន់តែច្បាស់ពីផលប៉ះពាល់សរុបនៃអថេរនីមួយៗលើឱកាសរៀបការរបស់មនុស្សម្នាក់ (៣០-៣៤ ឆ្នាំ) ផលធៀបឱកាសត្រូវបានបង្ហាញក្នុងក្រាហ្វ (សូមមើលរូប ៥.៦)។ ដោយសារតែជំពូកនេះផ្តោតលើចំនួនប្រជាជនសរុប គេមិនចាំបាច់បង្ហាញពីកម្រិតសារៈសំខាន់ឡើយ។ ក្នុងក្រាហ្វនេះ ប្រភេទយោងសម្រាប់អថេរនីមួយៗត្រូវបានបង្ហាញជាពណ៌បៃតង និងមានតម្លៃ ១.០០។ ផលធៀបឱកាសដែលខ្ពស់ជាង ១ មានន័យថា មនុស្សម្នាក់ដែលស្ថិតក្នុងប្រភេទនោះមានឱកាសមិនដែលរៀបការ ខ្ពស់ជាងមនុស្សម្នាក់ដែលស្ថិតក្នុងប្រភេទយោង ខណៈដែលមនុស្សម្នាក់ដែលស្ថិតក្នុងប្រភេទដែលមានតម្លៃតូចជាង ១ មានឱកាសទាបនៃការមិនធ្លាប់រៀបការ។

នៅកម្ពុជា មានប្រជាជនយ៉ាងច្រើនដែលរៀបការនៅអាយុ ៣០ ឆ្នាំ[13]។ ដូច្នេះ សម្រាប់ប្រជាជនដែលស្ថិតក្នុងក្រុមអាយុ ៣០-៣៤ ឆ្នាំ ការវិភាគត្រូវបានធ្វើឡើងដើម្បីស្វែងយល់ថាតើប្រជាជនក្នុងក្រុមអាយុនេះបានរៀបការឬទេ។ បន្ទាប់មក ស្ថានភាពអាពាហ៍ពិពាហ៍នេះត្រូវបានប្រើប្រាស់ជាអថេរចំណុះ និងជាអនុគមន៍នៃអថេរពន្យល់ជាច្រើន (explanatory variable) ដូចជា កម្រិតពិការភាព (មិនពិការ ពិការខ្លះ ពិការខ្លាំង ពិការមិនអាចធ្វើអ្វីបាន) និងអថេរគ្រប់គ្រងផ្សេងទៀត (control variable)។ ដោយសារតែអថេរចំណុះបែងចែកជា ២ ប្រភេទ (មិនដែលរៀបការ និងធ្លាប់រៀបការ) គេត្រូវប្រើប្រាស់រឺហ្គ្រេសសិនឡូជីស្ទិក[14]។ បន្ទាប់ពីបានធ្វើតេស្តគ្រប់ជ្រុងជ្រោយ យើងបានបញ្ចូលអថេរពន្យល់មួយចំនួនក្នុងសមីការ ៖ ខេត្ត កម្រិតអប់រំ ស្ថានភាពការងារ កម្រិតពិការភាព ភេទ និងសន្ទស្សន៍ទ្រព្យសម្បត្តិ។ សន្ទស្សន៍ទ្រព្យសម្បត្តិត្រូវបានបង្កើតឡើងដោយអ្នកសរសេររបាយការណ៍នេះ និងប្រើប្រាស់វិធីសាស្រ្តដូចក្នុងការអង្កេតប្រជាសាស្រ្ត និងសុខភាព (Rutstein, 2008)។ ការពន្យល់ពីការគណនាសន្ទស្សន៍ទ្រព្យសម្បត្តិមានបង្ហាញក្នុងឧបសម្ព័ន្ធ ២។

រូប ៥.៦ បង្ហាញពីភាពខុសគ្នាយ៉ាងខ្លាំងនៃឱកាសរៀបការរវាងអនុក្រុមតាមតំបន់ អនុក្រុមសង្គមសេដ្ឋកិច្ច និងអនុក្រុមពិការភាព។ រឺហ្គ្រេសិនឡូជីស្ទិក ផ្តោតទាំងលើលក្ខណៈទូទៅ និងលក្ខណៈពិការភាព។ ដំបូង យើងនឹងពិភាក្សាសង្ខេបអំពីលក្ខណៈទូទៅ និងភាពខុសគ្នារវាងកម្រិតពិការភាព។

ជាទូទៅ ស្ត្រីរៀបការនៅអាយុក្មេងជាងបុរស ហើយឱកាសនៃការមិនរៀបការរបស់ស្ត្រីនៅអាយុ ៣០-៣៤ ឆ្នាំ គឺតូចជាងបុរស (ផលធៀបឱកាស=0,៦៩៧)។ ការវិភាគបង្ហាញពីភាពខុសគ្នាតាមតំបន់ពាក់ព័ន្ធនឹងឱកាសមិនដែលរៀបការនៅអាយុ ៣០-៣៤ ឆ្នាំ។ ការរស់នៅក្នុងទីក្រុងភ្នំពេញបង្កើនឱកាសមិនដែលរៀបការ។ រតនគិរីជាខេត្តដែលមានឱកាសមិនរៀបការ ទាបជាងគេ។ ក្នុងខេត្តនេះ ឱកាសមិនរៀបការរបស់មនុស្សម្នាក់នៅអាយុ ៣០-៣៤ ឆ្នាំ តូចជាងឱកាសមិនរៀបការរបស់មនុស្សម្នាក់ក្នុងខេត្តបន្ទាយមានជ័យ រហូតដល់ជាង ២ ដង (ប្រភេទយោង)។ មាននិន្នាការយ៉ាងច្បាស់ពាក់ព័ន្ធនឹងការអប់រំ។ ពោលគឺប្រជាជនដែលមានកម្រិតអប់រំខ្ពស់ច្រើនតែមិនរៀបការ។ ដូច្នេះ ឱកាសមិនរៀបការ មានអត្រាខ្ពស់ក្នុងចំណោមអ្នកមានកម្រិតអប់រំខ្ពស់ អ្នកគ្មានការងារធ្វើ និងអ្នកក្នុងបន្ទុក។ ក្រៅពីនេះ ការវិភាគបង្ហាញថា ឱកាសមិនរៀបការនៅអាយុ ៣០-៣៤ ឆ្នាំ កើនឡើងទៅតាមទំហំទ្រព្យសម្បត្តិ។

13 –យោងបែងចែកតាមរបាយការណ៍ជំរឿនឆ្នាំ ២០១៩ (២០២០) បុរសចំនួន ១៧,៩% និងស្ត្រីចំនួន ១២,២% ដែល “មិនធ្លាប់រៀបការ” ស្ថិតក្នុងក្រុមអាយុ ៣០-៣៤ ឆ្នាំ (ទំ. ៣៨)។
14 –សម្រាប់សេចក្តីផ្តើមស្តីពីរឺហ្គ្រេសិនឡូជីស្ទិក សូមចូលទៅកាន់ *http://data.princeton.edu/wws509/notes/c3.pdf*។

# រូប ៥.៦ ៖ មេគុណរីហ្គ្រេសិនឡូជីស្ទិក (logistic regression) សម្រាប់អ្នកមិនដែលរៀបការ (៣០-៣៤ ឆ្នាំ)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ឱកាសមិនរៀបការរបស់មនុស្សម្នាក់នៅអាយុ ៣០-៣៤ ឆ្នាំ មានអត្រាខ្ពស់ជាងជិត ២៤ ភាគរយ ប្រសិនបើគាត់ស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទីបួន និងមានអត្រាខ្ពស់ជាង ៤៤ ភាគរយ ប្រសិនបើគាត់ស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុត។ រូប ៥.៦ បង្ហាញច្បាស់ពីផលប៉ះពាល់សរុបនៃកម្រិតពិការភាពលើឱកាសរៀបការរបស់មនុស្សម្នាក់។ ក្នុងករណីនេះ ជនគ្មានពិការភាពជាប្រភេទយោង។ បន្ទាប់ពីការគ្រប់គ្រងអថេរពន្យល់ផ្សេងទៀត ជនមានពិការភាពខ្លះមានឱកាសមិនរៀបការនៅអាយុ ៣០-៣៤ ឆ្នាំរហូតដល់ ១៩,៣ ភាគរយ ខ្ពស់ជាងស្ត្រីក្នុងក្រុមអាយុដូចគ្នាដែលគ្មានពិការភាព។ កម្រិតពិការភាពកាន់តែខ្លាំងបង្កើនឱកាសមិនរៀបការ ៖ មនុស្សម្នាក់ដែលមានពិការភាពខ្លះ មានឱកាសមិនរៀបការនៅអាយុ ៣០-៣៤ ឆ្នាំ រហូតដល់ ២.២៦ ភាគរយ ខ្ពស់ជាងជនគ្មានពិការភាព ខណៈដែលឱកាសនេះគឺខ្ពស់ជាងរហូតដល់ ២,៧៦ ដង ប្រសិនបើបុគ្គលនោះមានកម្រិតពិការភាពកាន់តែខ្លាំង។

ពិការភាពមិនត្រឹមតែពាក់ព័ន្ធនឹងការរៀបការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធនឹងការរំលាយអាពាហ៍ពិពាហ៍ទៀតផង។ រូប ៥.៧.ក និងរូប ៥.៧.ខ បង្ហាញពីភាគរយនៃបុរស និងស្ត្រីដែលបានលែងលះ ឬរស់នៅបែកគ្នា បែងចែកតាមកម្រិតពិការភាព។ ក្រាហ្វទាំងពីរនេះបង្ហាញពីគំរូស្រដៀងគ្នា។ មុនអាយុ ៤០ ឆ្នាំ ភាគរយសម្រាប់ពិការភាពទាំង ៤ កម្រិត គឺប្រហាក់ប្រហែលគ្នា ដោយមានអត្រាខ្ពស់បន្តិចសម្រាប់បុរសដែលពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ ក្រោយអាយុ ៤០ ឆ្នាំ ភាគរយនៃបុរសពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ដែលបានលែងលះ ឬរស់នៅបែកគ្នាកើនឡើងយ៉ាងគំហុក។ ភាគរយក្នុងក្រុមអាយុ ៤៥-៤៩ ឆ្នាំ គឺខ្ពស់ជាងគេ ៖ បុរសពិការខ្លាំងចំនួន ១៥,៣ ភាគរយ និងបុរសពិការមិនអាចធ្វើអ្វីបានចំនួន ៣០,៤ ភាគរយ រស់នៅបែកគ្នា ឬលែងលះ ធៀបនឹងស្ត្រីពិការខ្លាំងចំនួន ២២,៩ ភាគរយ និងស្ត្រីពិការមិនអាចធ្វើអ្វីបានចំនួន ២៧,៨ ភាគរយ។ ប៉ុន្តែនៅអាយុ ៦០ ឆ្នាំ ភាគរយខ្ពស់នៃការលែងលះ និងការរស់នៅបែកគ្នាក្នុងចំណោមបុរស និងស្ត្រីដែលពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន គឺលែងមានទៀតហើយ។ ក្រោយអាយុ ៦០ ឆ្នាំ ភាគរយនៃការលែងលះ និងរស់នៅបែកគ្នាគឺប្រហាក់ប្រហែលគ្នាសម្រាប់កម្រិតពិការភាពនីមួយៗ (ប្រមាណ ៥ ភាគរយ សម្រាប់ស្ត្រី និងទាបជាងនេះបន្តិចសម្រាប់បុរស)។ គ្មានមូលហេតុច្បាស់លាស់ថាតើហេតុអ្វីមានភាគរយខ្ពស់សម្រាប់ក្រុមអាយុ ៤០-៦០ ឆ្នាំ ប៉ុន្តែមានភាគរយទាបសម្រាប់ក្រុមអាយុក្មេងជាង និងចាស់ជាងនេះនោះទេ។ ក្រាហ្វនេះអាចបង្ហាញថា ពីមុន ពិការភាពមិនមែនជាដើមហេតុចម្បងនៃការលែងលះដូចពេលបច្ចុប្បន្នឡើយ។ អាចនិយាយបានថា ក្រាហ្វនេះមិនបញ្ជាក់ថា ពិការភាពជាដើមហេតុនៃការលែងលះនោះទេ ព្រោះអាយុ និងស្ថានភាពអាពាហ៍ពិពាហ៍ត្រូវបានច្បាមយកនៅពេលធ្វើជំរឿន ប៉ុន្តែគេមិនដឹងច្បាស់ថាតើការលែងលះ ឬការរស់នៅបែកគ្នា កើតឡើងនៅពេលណានោះទេ ហើយគេក៏មិនដឹងដែរថាតើបុគ្គលម្នាក់មានស្ថានភាពពិការភាពណាមួយនៅពេលលែងលះ ឬរស់នៅបែកគ្នា។ ទោះជាយ៉ាងណា ចំណុចគួរឱ្យចាប់អារម្មណ៍គឺការកើនឡើងយ៉ាងគំហុកនៃការលែងលះ កើតឡើងនៅពេលដែលឱកាសនៃការមានពិការភាពកើនឡើង។ ដូច្នេះ ទំនាក់ទំនងរវាងការលែងលះ/ការរស់នៅបែកគ្នា និងពិការភាព ដែលបង្ហាញក្នុងក្រាហ្វទាំងនេះបញ្ជាក់ថា មានដើមហេតុ ប៉ុន្តែចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមទៀត។

រូប ៥.៧.ក ៖ ភាគរយបុរសដែលលែងលះ ឬរស់នៅបែកគ្នា បែងចែកតាមអាយុ និងកម្រិតពិការភាព




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

រូប ៥.៧.ខ ៖ ភាគរយស្ត្រីដែលលែងលះ ឬរស់នៅបែកគ្នា បែងចែកតាមអាយុ និងកម្រិតពិការភាព




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

# ៥.៣ លទ្ធភាពបង្កើតកូន

លទ្ធភាពបង្កើតកូនត្រូវបានជំរុញដោយបំណងប្រាថ្នា និងសមត្ថភាពក្នុងការមានកូន។ ខណៈដែលជាទូទៅស្ត្រីពិការដែលស្ថិតក្នុងក្រុមអាយុបន្តពូជ នៅតែមានលទ្ធភាពបង្កើតកូន និងអាចមានផ្ទៃពោះបាន ពិការភាពអាចបន្ថែមបញ្ហាដល់ការមានផ្ទៃពោះ ការសម្រាលកូន និងការចិញ្ចឹមកូន។ ប្រភេទពិការភាពមួយចំនួនអាចបង្កការលំបាកដល់ការមានកូន ទាំងសម្រាប់បុរស និងស្ត្រី។ ក្នុងករណីផ្សេងទៀត ការចិញ្ចឹមកូនដោយគ្មានជំនួយពីសមាជិកផ្សេងទៀតក្នុងគ្រួសារ ឬអ្នកដទៃ អាចជាការលំបាក។

ជំរឿនប្រជាជន និងលំនៅដ្ឋាន អាចផ្តល់ទិន្នន័យសំខាន់ៗសម្រាប់ការបង្កើត និងវាយតម្លៃគោលនយោបាយដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ ជំរឿនប្រភេទនេះមិនត្រឹមតែផ្តល់ព័ត៌មានដ៏មានតម្លៃស្តីពីលទ្ធភាពបង្កើតកូនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានស្តីពីលក្ខណៈនៃការមានផ្ទៃពោះ និងការសម្រាលកូនទៀតផង។ ជាទូទៅ អត្រាលទ្ធភាពបង្កើតកូនដុល (TFR) ត្រូវបានប្រើប្រាស់ជាសូចនាករសម្រាប់ពិពណ៌នាពីលទ្ធភាពបង្កើតកូនរបស់ប្រជាជន។ វាស្មើនឹងចំនួនកូនជាមធ្យមដែលស្ត្រីម្នាក់អាចបង្កើតបាន ប្រសិនបើគាត់រស់នៅរហូតដល់ចុងអាយុដែលអាចបង្កើតកូនបាន (ជាទូទៅនៅអាយុ ៥០ ឆ្នាំ) និងមានកូនទៅតាមកាលវិភាគជាក់លាក់នៃអត្រាលទ្ធភាពបង្កើតកូនតាមអាយុនៅអំឡុងឆ្នាំនោះ។ អត្រាលទ្ធភាពបង្កើតកូនដុលផ្អែកលើចំនួនកំណើតរស់ក្នុងស្ត្រីម្នាក់[15]។ ជំរឿនឆ្នាំ ២០១៩ ប្រើប្រាស់មធ្យោបាយប៉ាន់ស្មានប្រយោលដើម្បីគណនាអត្រាលទ្ធភាពបង្កើតកូនដុល។ នៅឆ្នាំ ២០១៩ ស្ត្រីមានកូនជាមធ្យម ២,៥ នាក់។ លទ្ធភាពបង្កើតកូននៅជនបទមានកម្រិតខ្ពស់ (២,៨ នាក់) ជាងទីប្រជុំជន (២,២ នាក់)។ ការដែលអត្រាលទ្ធភាពបង្កើតកូនដុល (មិនកែតម្រូវ) ដែលផ្អែកតែលើការរាយការណ៍ស្តីពីចំនួនកុមារដែលបានកើតក្នុងរយៈពេល ១២ ខែ មុនពេលជំរឿន គឺត្រឹមតែ ១,៧ នាក់ក្នុងស្ត្រីម្នាក់ បង្ហាញយ៉ាងច្បាស់ថា ការរាយការណ៍ពីចំនួនកុមារដែលបានកើតក្នុងរយៈពេល ១២ ខែ មុនពេលជំរឿន គឺទាបជាងចំនួនជាក់ស្តែង (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ២០២០)។ គួរកត់សម្គាល់ថា ការរាយការណ៍ពីចំនួនទាបជាងចំនួនជាក់ស្តែងនេះក៏លេចឡើងក្នុងជំរឿនប្រជាជនឆ្នាំ ២០០៨ ផងដែរ (វិទ្យាស្ថានភាពជាតិស្ថិតិ ក្រសួងផែនការ ២០០៩)។

ការវិភាគនេះ មានគោលបំណងពិនិត្យមើលភាពគ្នារវាងកម្រិតលទ្ធភាពបង្កើតកូនក្នុងចំណោមស្ត្រីដោយយោងតាមកម្រិតពិការភាព។ ការប្រើប្រាស់បច្ចេកទេសប៉ាន់ស្មានដោយប្រយោលក្នុងការវិភាគនេះគឺមិនសូវសមស្របនោះទេ ព្រោះចំនួនកូនដែលស្ត្រីមានពិការភាពបានបង្កើត មានចំនួនតិច។ ដូច្នេះ មានតែការគណនាដោយផ្ទាល់ និងមិនកែតម្រូវលើអត្រាលទ្ធភាពបង្កើតកូនតាមអាយុ និងការគណនាអត្រាលទ្ធភាពបង្កើតកូនដុលសម្រាប់អនុប្រភេទនីមួយៗប៉ុណ្ណោះ និងមានការប្រៀបធៀបចំនួនប៉ាន់ស្មាន។ គួរកត់សម្គាល់ថា កម្រិតលទ្ធភាពបង្កើតកូនដែលបានរាយការណ៍ ជាការប៉ាន់ស្មានទាបជាកម្រិតជាក់ស្តែង ដោយសារការរាយការណ៍ចំនួនកំណើត ទាបជាងចំនួនជាក់ស្តែងក្នុងរយៈពេល ១២ ខែ មុនពេលជំរឿន។

តារាង ៥.៣.ក បង្ហាញពីចំនួនកូនដែលក្រុមស្ត្រីមានពិការភាព បានបង្កើត។ ក្នុងចំណោមស្ត្រីមានពិការភាពខ្លាំង មានកុមារតែ ៤៩៣ នាក់ប៉ុណ្ណោះដែលបានកើតក្នុងរយៈពេល ១២ ខែ មុនពេលជំរឿន។ សម្រាប់ស្ត្រីពិការមិនអាចធ្វើអ្វីបាន មានកុមារតែ ២៩១ នាក់ប៉ុណ្ណោះដែលបានកើតក្នុងរយៈពេល ១២ ខែ មុនពេលជំរឿន។ ចំនួនដ៏តិចនេះអាចបណ្តាលមកពីការរាយការណ៍ចំនួនពិការភាពក្នុងចំណោមស្ត្រីដល់វ័យបង្កើតកូន ទាបជាងចំនួនជាក់ស្តែង។ ខណៈដែលអត្រាលទ្ធភាពបង្កើតកូនដុលសម្រាប់ស្ត្រីមិនពិការគឺ ១,៧ នាក់ អត្រានេះគឺ ១,៣២ នាក់សម្រាប់ស្ត្រីមានពិការភាពខ្លាំង និង ១,២៨ នាក់សម្រាប់ស្ត្រីពិការមិនអាចធ្វើអ្វីបាន។ ធៀបនឹងស្ត្រីមិនពិការ លទ្ធភាពបង្កើតកូនដុលដែលបានរាយការណ៍សម្រាប់ស្ត្រីមានពិការភាពខ្លាំង និងស្ត្រីពិការមិនអាចធ្វើអ្វីបាន មានអត្រាទាបជាងនេះ (២១,២ ភាគរយ និង ២៣,៧ ភាគរយ)។ ស្ទើរតែគ្មានភាពខុសគ្នានៃកម្រិតលទ្ធភាពបង្កើតកូនរវាងស្ត្រីមានពិការភាពខ្លះ និងស្ត្រីមិនពិការ។ អត្រាលទ្ធភាពបង្កើតកូនដុលកាន់តែទាបសម្រាប់ស្ត្រីមានពិការភាពខ្លាំង និងស្ត្រីពិការមិនអាចធ្វើអ្វីបាន ពាក់ព័ន្ធនឹងភាគរយទាបនៃការរៀបការក្នុងចំណោមស្ត្រីមានពិការភាពខ្លាំង ឬស្ត្រីពិការមិនអាចធ្វើអ្វីបាន។

រូប ៥.៨ បង្ហាញថា គំរូអាយុនៃលទ្ធភាពបង្កើតកូនមានភាពខុសគ្នាសម្រាប់ស្ត្រីពិការមិនអាចធ្វើអ្វីបាន ធៀបនឹងក្រុមស្ត្រីដែលមានពិការភាព ៣ កម្រិតផ្សេងទៀត។ អត្រាលទ្ធភាពបង្កើតកូនខ្ពស់បំផុតសម្រាប់ស្ត្រីពិការមិនអាចធ្វើអ្វីបាន គឺនៅចន្លោះអាយុ ៣០-៣៤ ឆ្នាំ ខណៈដែលក្នុងចំណោមស្ត្រីមានពិការភាពមួយកម្រិតផ្សេងទៀត គឺនៅចន្លោះអាយុ ២៥-២៩ ឆ្នាំ។ ទោះជាយ៉ាងណា ដោយសារតែចំនួនកូនដែលស្ត្រីពិការមិនអាចធ្វើអ្វីបាន បានបង្កើត មានចំនួនតិច ចំណុចនេះអាចបណ្តាលមកពីទំហំសំណាកតូច។

15 –កំណើតរស់ សំដៅទៅលើការកើតចេញ ឬការវះយកចេញពីផ្ទៃម្តាយនូវទារក។ ពេលកើតចេញមក ទារកមានដង្ហើម ឬបង្ហាញនូវភាពមានជីវិត ដូចជា ជីពចរនៅដើរ ឬមានចលនាសាច់ដុំ។ ចលនានីមួយៗនេះ បញ្ជាក់ថាមានកំណើតរស់ (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ ២០២០ ទំ. ១៨២)។

តារាង ៥.៣.ក ៖ ចំនួនស្ត្រីបែងចែកបែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ចំនួនកុមារដែលបានកើតក្នុងរយៈពេល ១២ ខែ មុនពេលជំរឿន និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | មិនពិការ | | ពិការខ្លះ | | ពិការខ្លាំង | | ពិការមិនអាចធ្វើអ្វីបាន | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនកុមារដែលបានកើត | ចំនួនស្ត្រី | ចំនួនកុមារដែលបានកើត | ចំនួនស្ត្រី | ចំនួនកុមារដែលបានកើត | ចំនួនស្ត្រី | ចំនួនកុមារដែលបានកើត | ចំនួនស្ត្រី | ចំនួនកុមារដែលបានកើត | ចំនួនស្ត្រី |
| ១៥-១៩ | ១១.២៦៤ | ៥៣៤.០៣៥ | ៨៦ | ៣.៨០២ | ១៦ | ១.០២៤ | ១៤ | ៨៦១ | ១១.៣៨០ | ៥៤៨.៧២២ |
| ២០-២៤ | ៤៩.០៥២ | ៦២៩.២៣១ | ៤៩៨ | ៦.០៨៣ | ៩៦ | ១.៥៧៨ | ៥៤ | ១.០៣០ | ៤៩.៧០០ | ៦៣៧.៩២២ |
| ២៥-២៩ | ៦៤.៥៩៥ | ៧១១.៩៣៧ | ៧៣៨ | ៧.៩៧៣ | ១៤១ | ១.៩៩២ | ៧៤ | ១.៣៣៨ | ៦៥.៥៤៨ | ៧២៣.២៤០ |
| ៣០-៣៤ | ៤៨.២៦៨ | ៦៤៧.៥០៨ | ៦៨២ | ៩.១៧៤ | ១១៩ | ២.០០៩ | ៨០ | ១.២០១ | ៤៩.១៤៩ | ៦៥៩.៨៩២ |
| ៣៥٣٩- | ២៧.៦៩៨ | ៦៣៩.២៩៤ | ៥៥៤ | ១១.៥៦១ | ៨៦ | ២.១៨១ | ៤៤ | ១.២៣៤ | ២៨.៣៨២ | ៦៥៤.២៧០ |
| ៤០-៤៤ | ៧.៤៦៤ | ៣៦៨.៥២៥ | ២២៤ | ១១.១២០ | ២១ | ១.៧០៣ | ១៥ | ៧៩៧ | ៧.៧២៤ | ៣៨២.១៤៥ |
| ៤៥-៤៩ | ៣.០៤៤ | ៣៧៩.៦៧៨ | ១៦៦ | ១៧.៦៤២ | ១៤ | ២.៣១១ | ១០ | ៩០៣ | ៣.២៣៤ | ៤០០.៥៣៤ |
| សរុប | ២១១.៣៨៥ | ៣.៩១៩.២០៨ | ២.៩៤៨ | ៦៧.៣៥៥ | ៤៩៣ | ១២.៧៩៨ | ២៩១ | ៧.៣៦៤ | ២១៥.១១៧ | ៤.០០៦.៧២៥ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

### តារាង ៥.៣.២ ៖ អត្រាលទ្ធភាពបង្កើតកូនតាមអាយុ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | សរុប |
|---|---|---|---|---|---|
| ១៥-១៩ | ០,០២១ | ០,០២៣ | ០,០១៦ | ០.០១៦ | ០,០២១ |
| ២០-២៤ | ០,០៧៨ | ០,០៨២ | ០,០៦១ | ០,០៥២ | ០,០៧៨ |
| ២៥-២៩ | ០,០៩១ | ០,០៩៣ | ០,០៧១ | ០,០៥៥ | ០,០៩១ |
| ៣០-៣៤ | ០,០៧៥ | ០,០៧៤ | ០,០៥៩ | ០,០៦៧ | ០,០៧៤ |
| ៣៥-៣៩ | ០,០៤៣ | ០,០៤៨ | ០,០៣៩ | ០,០៣៦ | ០,០៤៣ |
| ៤០-៤៤ | ០,០២០ | ០,០២០ | ០,០១២ | ០,០១៩ | ០,០២០ |
| ៤៥-៤៩ | ០,០០៨ | ០,០០៩ | ០,០០៦ | ០,០១១ | ០,០០៨ |
| TFR | ១,៦៨ | ១,៧៤ | ១,៣២ | ១,២៨ | ១,៦៨ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

រូប ៥.៨ ៖ អត្រាលទ្ធភាពបង្កើតកូនតាមអាយុ សម្រាប់ស្ត្រីអាយុ ១៥-៤៩ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

លទ្ធភាពរបស់ស្ត្រីមានពិការភាពក្នុងការទទួលបានព័ត៌មានស្តីពីសុខភាព និងសិទ្ធិផ្លូវភេទ និងបន្តពូជ (SRHR) ពាក់ព័ន្ធនឹងស្ថានភាពអាពាហ៍ពិពាហ៍របស់ពួកគេ។ ស្ត្រីមានពិការភាពដែលរៀបការរួច ទទួលបានព័ត៌មានតាមរយៈសមាជិកគ្រួសារ មិត្តភក្តិ អ្នកជិតខាង និងមណ្ឌលសុខភាពសហគមន៍ ឬបុគ្គលិកសុខភាពឯកជន។ ស្ត្រីនៅលីវ (អាយុក្រោម ៣០ ឆ្នាំ) មានចំណេះដឹងតិចតួចស្តីពីសុខភាព និងសិទ្ធិផ្លូវភេទ និងបន្តពូជ (Gartrell, Baesel & Becker, 2017)។

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា មានសំណួរមួយស្តីពីអ្នកជួយម្តាយក្នុងពេលសម្រាលកូនដែលបានកើតក្នុងរយៈពេល ១២ ខែមុនពេលជំរឿន។ ក្រៅពីនេះ មានការសួរសំណួរថាតើកុមារត្រូវបានចុះសំបុត្រកំណើតជាមួយអាជ្ញាធរមូលដ្ឋាន ឬទេ។ គួរឱ្យសោកស្តាយដែលអ្នកតបសម្ភាសន៍ភាគច្រើនមិនបានឆ្លើយសំណួរទាំងនេះ។ ក្នុងចំណោមប្រជាជនសរុប ២១០.២១៩ នាក់ដែលគួរតែបានឆ្លើយសំណួរស្តីពីការចុះសំបុត្រកំណើត មាន ១៩៤.៥៥០ នាក់មិនផ្តល់ចម្លើយ។ គួរពិចារណាថាតើមានការជួយដល់ស្ត្រីមានពិការភាពតាមវិធីផ្សេងៗក្នុងពេលសម្រាលកូន ឬទេ និងថាតើការចុះសំបុត្រកំណើតត្រូវបានធ្វើឡើងតាមវិធីមួយផ្សេងទៀតសម្រាប់ស្ត្រីមានពិការភាព ឬទេ។ ទោះជាយ៉ាងណា ការវិភាគមិនអាចធ្វើបានឡើយ ព្រោះមិនសូវមានការឆ្លើយសំណួរនេះ។

# ជំពូក ៦៖ ជីវភាពរស់នៅ និងពិការភាព

ការដឹងពីចំណាយផ្ទាល់ និងចំណាយប្រយោលក្នុងការរស់នៅ ដែលពាក់ព័ន្ធនឹងជនមានពិការភាពក្នុងមជ្ឈដ្ឋានមិនសូវមានធនធាន ជាកត្តាសំខាន់ក្នុងការបំពេញតម្រូវការរបស់ជនមានពិការភាព។ សម្រាប់ប្រទេសកម្ពុជា តាមរយៈការប្រើប្រាស់វិធីសាស្ត្រស្តង់ដារជីវភាពដោយផ្អែកលើទិន្នន័យពីការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា Palmer, Williams and McPake (2016) បានគណនាចំណាយផ្ទាល់បន្ថែមរបស់គ្រួសារដែលមានសមាជិកមានពិការភាព ដូចជា ចំណាយបន្ថែមលើឧបករណ៍ជំនួយ សុខភាព (ថ្នាំសង្កូវ លក្ខខណ្ឌរបបអាហារ។ល។) និងការធ្វើដំណើរ ដើម្បីទទួលបានជីវភាពរស់នៅប្រហាក់ប្រហែលនឹងគ្រួសារដែលគ្មានសមាជិកមានពិការភាព។ ក្នុងប្រទេសមានប្រាក់ចំណូលខ្ពស់ ចំណាយផ្ទាល់លើពិការភាពត្រូវបានប៉ាន់ស្មានថាស្មើនឹង ១១-៥៥ ភាគរយនៃប្រាក់ចំណូលគ្រួសារ។ ការសិក្សាក្នុងប្រទេសមានប្រាក់ចំណូលទាប និងមធ្យម ដូចជា បូស្នី វៀតណាម និងចិន ប៉ាន់ស្មានថា ចំណាយផ្ទាល់លើពិការភាពគឺ៩-២០ ភាគរយ។ ក្នុងប្រទេសកម្ពុជា គ្រួសារដែលមានសមាជិកម្នាក់មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ត្រូវរ៉ាប់រងចំណាយបន្ថែមរហូតដល់ ១៩ ភាគរយក្នុងមួយខែ ប្រសិនបើចង់ឱ្យមានជីវភាពរស់នៅប្រហាក់ប្រហែលនឹងគ្រួសារដែលគ្មានសមាជិកមានពិការភាព។ ចំណាយលើការថែទាំសុខភាពរបស់ជនមានពិការភាព ដូចជា ថ្នាំសង្កូវ និងការទៅមកគ្លីនិកឯកជន ខ្ពស់ជាងចំណាយសម្រាប់ជនមិនពិការ រហូតដល់ ៣-៤ ដង។ ជារៀងរាល់ខែ គ្រួសារដែលមានសមាជិកម្នាក់មានពិការភាព ត្រូវចំណាយជាមធ្យម ៣៨ ដុល្លារអាមេរិក។ គួរកត់សម្គាល់ថា ការប៉ាន់ស្មានចំណាយជាមធ្យមទាំងនេះ និងទំហំនៃចំណាយទាំងនេះអាចខុសគ្នាខ្លាំងទៅតាមតម្រូវការទំនុកបម្រុងរបស់បុគ្គល។ ក្រៅពីនេះ គ្រួសារដែលមានសមាជិកម្នាក់មានពិការភាព មានអត្រាភាពក្រីក្រលើសគ្រួសារដែលគ្មានសមាជិកមានពិការភាព ជិត ២ ដង (១៨ ភាគរយ ទល់នឹង ៣៤ ភាគរយ) (Palmer, Williams & McPake, 2018)។

ដូចការលើកឡើងពីខាងដើម ប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការបានសច្ចាការពារសិទ្ធិរបស់ជនពិការ និងធានាថា ពួកគេមានជីវភាពរស់នៅសមរម្យ ដែលរួមបញ្ចូលទាំងការបំពេញតម្រូវការរបស់ជនពិការ ដូចជា អាហារ សម្លៀកបំពាក់ និងលំនៅដ្ឋាន និងការជួយរ៉ាប់រងចំណាយលើកិច្ចគាំពារសង្គម។ នៅចន្លោះឆ្នាំ ២០០៩ និងឆ្នាំ ២០១៤ ក្នុងចំណោមគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព មានគ្រួសារតែ ៤ ភាគរយ ប៉ុណ្ណោះដែលទទួលបានជំនួយពីរដ្ឋាភិបាល។ ភាគច្រើននៃគ្រួសារទាំងនេះមានសមាជិកវ័យចាស់ម្នាក់ដែលមានពិការភាព។ ដូច្នេះ ជំនួយនេះប្រហែលជាពាក់ព័ន្ធនឹងអាយុជាជាងពិការភាព។ គ្រួសារមួយចំនួនតូចផ្សេងទៀតបានទទួលជំនួយហិរញ្ញវត្ថុពីអង្គការមិនមែនរដ្ឋាភិបាល (ប្រហែល ២ ដុល្លារ) ហើយគ្រួសារផ្សេងទៀតទទួលបានជំនួយពីគ្រួសារ។ ជាមធ្យម ការបំពេញចំណាយផ្ទាល់លើពិការភាពក្នុងប្រទេសកម្ពុជាគឺត្រឹមតែ ៧ ភាគរយប៉ុណ្ណោះ (៣៨ ដុល្លារ) (Palmer, Williams & McPake, 2016)

## ៦.១ សន្ទស្សន៍ទ្រព្យសម្បត្តិ

សន្ទស្សន៍ទ្រព្យសម្បត្តិជាសូចនាករនៃស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារដែលមាន និងគ្មានសមាជិកមានពិការភាព។ ដើម្បីពិនិត្យស្ថានភាពទ្រព្យសម្បត្តិរបស់គ្រួសារដែលមានសមាជិកម្នាក់មានពិការភាព សន្ទស្សន៍ទ្រព្យសម្បត្តិត្រូវបានគណនា ដោយផ្អែកតាមទិន្នន័យពីជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩។ វិធីសាស្ត្រដែលយកមកប្រើប្រាស់គឺដូចគ្នានឹងវិធីសាស្ត្រសម្រាប់ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១៤។ ឧបសម្ព័ន្ធ ២ ផ្តល់ការពិពណ៌នាខ្លីស្តីពីវិធីសាស្ត្រគណនាសន្ទស្សន៍ទ្រព្យសម្បត្តិសម្រាប់គ្រួសារនីមួយៗ។

ដោយសារតែសន្ទស្សន៍ទ្រព្យសម្បត្តិបែងចែកគ្រួសារទាំងអស់ជាក្រុមទ្រព្យសម្បត្តិស្មើគ្នា ៥ ក្រុម ការបែងចែកទ្រព្យសម្បត្តិជា ៥ ក្រុមស្មើគ្នាសម្រាប់គ្រួសារដែលមានសមាជិកម្នាក់មានពិការភាព នឹងគូសបញ្ជាក់ថា គ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព មានរបាយទ្រព្យសម្បត្តិដូចប្រជាជនទូទៅ។ រូប ៦.១ បង្ហាញពីបញ្ចភាគទ្រព្យសម្បត្តិសម្រាប់គ្រួសារដែលមាន ឬគ្មានសមាជិកមានពិការភាព បែងចែកតាមភេទរបស់មេគ្រួសារ។ ក្នុងការវិភាគគេបែងចែកទ្រព្យសម្បត្តិជា ២ ប្រភេទ។ ប្រភេទទី ១ គឺគ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់ មានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ ប្រភេទទី ២ រួមបញ្ចូលគ្រួសារទាំងអស់ក្រៅពីគ្រួសារក្នុងប្រភេទទី ១ (គ្មានសមាជិកមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន)។

ចំនួនគ្រួសារដែលរាយការណ៍ថាគ្មានសមាជិកមានពិការភាព មានចំនួនស្ទើរតែ ២៥ ដង ច្រើនជាងចំនួនគ្រួសារដែលមានសមាជិកយ៉ាងតិចម្នាក់មានពិការភាព។ ចំនួនដ៏ច្រើនលើសលប់នៃគ្រួសារដែលគ្មានសមាជិកមានពិការភាព មានន័យថា នៅគ្រប់បញ្ចភាគទាំងអស់ ភាគរយគ្រួសារដែលគ្មានសមាជិកមានពិការភាព គឺប្រហែល ២០ ភាគរយ។ ទោះជាយ៉ាងណា គ្រួសារមានស្ត្រីជាមេគ្រួសារ មានភាគរយទាបក្នុងបញ្ចភាគទ្រព្យសម្បត្តិស្តុកស្តម្ភបំផុត ២ និងមានភាគរយខ្ពស់ក្នុងបញ្ចភាគទ្រព្យសម្បត្តិក្រីក្របំផុត ២។ មានន័យថា គ្រួសារមានស្ត្រីជាមេគ្រួសារមានស្ថានភាពសង្គមសេដ្ឋកិច្ចទាប។

របាយបញ្ចភាគទ្រព្យសម្បត្តិក្នុងចំណោមគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព មានភាពខុសគ្នាខ្លាំង។ ក្នុងចំណោមគ្រួសារទាំងនេះ មានគ្រួសារតែ ១៤,០ ភាគរយ ប៉ុណ្ណោះដែលស្ថិតក្នុងបញ្ចភាគស្តុកស្តម្ភបំផុត ធៀបនឹង ២០,៥ ភាគរយក្នុងចំណោមគ្រួសារដែលគ្មានសមាជិកមានពិការភាព។ ផ្ទុយទៅវិញ គ្រួសារចំនួន ២៣,៥ ភាគរយស្ថិតក្នុងបញ្ចភាគក្រីក្របំផុត ធៀបនឹង ១៩,០ ភាគរយក្នុងចំណោមដែលគ្មានសមាជិកមានពិការភាព។ ក្នុងចំណោមគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព មានភាពខុសគ្នារវាងគ្រួសារមានបុរសជាមេគ្រួសារ និងគ្រួសារមានស្ត្រីជាមេគ្រួសារ។ ខណៈដែលគ្រួសារមានបុរសជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាព ចំនួន ២៣,៥ ភាគរយ ស្ថិតក្នុងបញ្ចភាគក្រីក្របំផុត គ្រួសារមានស្ត្រីជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាព ចំនួន ២៨,៨ ភាគរយ ស្ថិតក្នុងបញ្ចភាគក្រីក្របំផុត។ ក្នុងចំណោមគ្រួសារមានស្ត្រីជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាព មានតែ ១២,៣ ភាគរយប៉ុណ្ណោះដែលស្ថិតក្នុងបញ្ចភាគស្តុកស្តម្ភបំផុត ហើយក្នុងចំណោមគ្រួសារមានបុរសជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាព មានតែ ១៤,៨ ភាគរយប៉ុណ្ណោះដែលស្ថិតក្នុងបញ្ចភាគស្តុកស្តម្ភបំផុត។ ទោះជាយ៉ាងណា អត្រាទាំងនេះនៅតែទាបខ្លាំង បើធៀបនឹងគ្រួសារដែលគ្មានសមាជិកមានពិការភាព។

កម្រិតខ្ពស់នៃភាពក្រីក្ររបស់ជនមានពិការភាព ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បង្ហាញពីគំរូមួយដែលលេចឡើងក្នុងប្រទេសជាច្រើនជុំវិញពិភពលោក។ អត្រាខ្ពស់នៃភាពក្រីក្រក្នុងចំណោមគ្រួសារដែលមានសមាជិកមានពិការភាព រងឥទ្ធិពលពីទំនាក់ទំនងទ្វេទិសរវាងភាពក្រីក្រ និងពិការភាព។

ដូចការគូសបញ្ជាក់ខាងលើ ជនមានពិការភាពប្រឈមនឹងចំណាយខ្ពស់ក្នុងការបំពេញតម្រូវការ និងលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធនឹងពិការភាពរបស់ពួកគេ (ឧ. ថ្នាំសង្កូវ ឧបករណ៍ជំនួយ និងសម្ភារផ្សេងទៀត ចំណាយលើការធ្វើដំណើរ។ល។)។ ក្នុងករណីជាច្រើន ពិការភាពរបស់សមាជិកគ្រួសារម្នាក់ក៏កាត់បន្ថយកម្រិតមូលធនមនុស្សក្នុងគ្រួសារនោះផងដែរ ព្រោះជនមានពិការភាពច្រើនតែគ្មានភាពសកម្មក្នុងសេដ្ឋកិច្ច និងត្រូវការការថែទាំ ពេលវេលា និងជំនួយហិរញ្ញវត្ថុពីសមាជិកគ្រួសារផ្សេងទៀត។ ផ្ទុយទៅវិញ ការដែលជនក្រីក្រមានកម្រិតអាហារូបត្ថម្ភទាប មិនសូវមានលទ្ធភាពទទួលបានការថែទាំសុខភាព មិនសូវទទួលបានសេវាទឹកស្អាត និងអនាម័យ និងជារឿយៗ រស់នៅក្នុងបរិយាកាសហិង្សា នឹងបង្កើនឱកាសនៃការធ្វើឱ្យមានពិការភាព។ Pinilla-Roncancio (2015) ហៅទំនាក់ទំនងនេះថា វដ្តនៃពិការភាព និងភាពក្រីក្រ។

រូប ៦.១ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមបញ្ចភាគទ្រព្យសម្បត្តិ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

# ៦.២ ស្ថានភាពលំនៅដ្ឋាន និងសម្ភារប្រើប្រាស់ក្នុងគ្រួសារ

ក្នុងជំរឿននេះគ្មានការសួរសំណួរស្តីពីសម្ភារប្រើប្រាស់និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ជនមានពិការភាពឡើយ។ ទោះជាយ៉ាងណា ទិន្នន័យជំរឿនអាចឱ្យមានការវិភាគខ្លះៗលើស្ថានភាពលំនៅដ្ឋានទូទៅ។

## កម្មសិទ្ធិផ្ទះសម្បែង

ប្រជាជនកម្ពុជាភាគច្រើន (៩២,៥ ភាគរយ) រស់នៅក្នុងផ្ទះសម្បែងដែលជាកម្មសិទ្ធិរបស់គ្រួសារ ឬសមាជិកម្នាក់ក្នុងគ្រួសារ។ តារាង ៦.១ បង្ហាញថា កម្មសិទ្ធិផ្ទះសម្បែងក្នុងចំណោមគ្រួសារដែលមានសមាជិកយ៉ាងតិចម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន គឺប្រហាក់ប្រហែលនឹងគ្រួសារដែលគ្មានសមាជិកមានពិការភាព។ តាមពិតក្នុងចំណោមគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព កម្មសិទ្ធិផ្ទះសម្បែងមានអត្រាខ្ពស់ជាងបន្តិចក្នុងចំណោមប្រជាជនគ្មានពិការភាព។ កម្មសិទ្ធិផ្ទះសម្បែងក្នុងចំណោមគ្រួសារដែលគ្មានសមាជិកមានពិការភាពគឺ ៩០,៥ ភាគរយទល់នឹង ៩៥,៥ ភាគរយនៃគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព។ មានភាពខុសគ្នាតិចតួចរវាងគ្រួសារមានបុរសជាមេគ្រួសារ និងគ្រួសារមានស្ត្រីជាមេគ្រួសារ។ ក្នុងចំណោមគ្រួសារមានស្ត្រីជាមេគ្រួសារ កម្មសិទ្ធិផ្ទះសម្បែងគឺ ៩៥,១ ភាគរយសម្រាប់គ្រួសារដែលមានសមាជិកម្នាក់មានពិការភាព ទល់នឹង ៨៩,២ ភាគរយសម្រាប់គ្រួសារដែលគ្មានសមាជិកមានពិការភាព។ សម្រាប់គ្រួសារមានបុរសជាមេគ្រួសារ ភាគរយគឺខុសពីនេះ (៩៥,៧ ភាគរយ ទល់នឹង ៩១,០ ភាគរយ)។ កម្មសិទ្ធិផ្ទះសម្បែងកាន់តែខ្ពស់អាចដោយសារតែជាទូទៅ ជនមានពិការភាពមានអាយុចាស់ជាជនមិនពិការ ហើយអត្រាកម្មសិទ្ធិផ្ទះសម្បែងគឺកាន់តែខ្ពស់ក្នុងចំណោមប្រជាជនវ័យចាស់។

តារាង ៦.១ ៖ កម្មសិទ្ធិលំនៅដ្ឋានគ្រួសារ បែងចែកទៅតាមថាតើគ្រួសារនោះមានសមាជិកម្នាក់ ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| ប្រុស | | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ |
| កម្មសិទ្ធិលំនៅដ្ឋាន | ជាម្ចាស់ | ៩១,០ | ៨៩,២ | ៩០,៥ | ៩៥,៧ | ៩៥,១ | ៩៥,៥ |
| | ជួល | ៥,៩ | ៧,៩ | ៦,៤ | ២,១ | ២,២ | ២,២ |
| | មិនអស់ថ្លៃជួល | ២,៩ | ២,៧ | ២,៨ | ១,៩ | ២,៥ | ២,១ |
| | ផ្សេងទៀត | ០,៣ | ០,២ | ០,៣ | ០,២ | ០,២ | ០,២ |
| | សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ចំនួនបន្ទប់

ចំនួនបន្ទប់ជាមធ្យម ត្រូវបានគណនាដោយប្រើប្រាស់ប្រភេទខាងលើសម្រាប់ពិការភាព និងភេទ។ ក្នុងប្រទេសកម្ពុជា ផ្ទះសម្បែងចំនួន ៤០,៣ ភាគរយមានបន្ទប់តែមួយ។ អត្រានេះគឺប្រហាក់ប្រហែលគ្នាសម្រាប់គ្រួសារដែលមាន និងគ្មានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន (៤០,៣ ភាគរយ ទល់នឹង ៣៩,៥ ភាគរយ)។ ជាមធ្យម គ្រួសារដែលមាន ឬគ្មានសមាជិកមានពិការភាព សុទ្ធតែរស់នៅក្នុងផ្ទះដែលមានបន្ទប់ចំនួន ១,៦។ ជាមធ្យម គ្រួសារមានស្ត្រីជាមេគ្រួសារ (មិនគិតថាតើមាន ឬគ្មានសមាជិកមានពិការភាព) មានបន្ទប់ចំនួន ១,៥។

## សម្ភារសាងសង់លំនៅដ្ឋាន

សម្ភារសាងសង់លំនៅដ្ឋាន រួមចំណែកដល់គុណភាពជីវិត និងកម្រិតនៃភាពស្រណុកសុខស្រួលរបស់សមាជិកគ្រួសារ។ ជំរឿនឆ្នាំ ២០១៩ មានសំណួរស្តីពីសម្ភារសម្រាប់សាងសង់ផ្ទៃបាត ដំបូល និងជញ្ជាំងផ្ទះ។ តារាង ៦.២ បង្ហាញពីភាគរយគ្រួសារ បែងចែកតាមប្រភេទសម្ភារសាងសង់។ ព័ត៌មានទាំងនេះត្រូវបានបែងចែកទៅតាមភេទរបស់មេគ្រួសារ និងថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ។ ជាទូទៅ មានភាពខុសគ្នាមធ្យមនៃប្រភេទសម្ភារសាងសង់លំនៅដ្ឋាន រវាងគ្រួសារគ្មានសមាជិកមានពិការភាព និងគ្រួសារមានសមាជិកមានពិការភាព។ ភាពខុសគ្នាទាំងនេះគឺដោយសារតែជនមានពិការភាពច្រើនតែរស់នៅក្នុងផ្ទះដែលប្រើប្រាស់សម្ភារសាងសង់ធម្មតា។ ឧ. ខណៈដែលគ្រួសារគ្មានសមាជិកមានពិការភាពចំនួន ៥០,៤ ភាគរយ រស់នៅក្នុងផ្ទះមានផ្ទៃបាតធ្វើពីឈើ ឬរនាបឫស្សី សម្រាប់គ្រួសារដែលមានសមាជិកមានពិការភាពកម្រិតណាមួយ អត្រានេះគឺខ្ពស់ជាងរហូតដល់ ៨ ភាគរយ (៥៨,៤ ភាគរយ)។ ក្រៅពីនេះ វត្ថុធាតុដំបូលក៏ខុសគ្នាផងដែរ។ ជនមានពិការភាពច្រើនតែរស់នៅក្នុងផ្ទះប្រក់ក្បឿង និងមិនសូវរស់នៅក្នុងផ្ទះប្រក់ស័ង្កសីឡើយ។ ទោះជាយ៉ាងណា មានភាពខុសគ្នាតិចតួចរវាងជនមានកម្រិតពិការភាពផ្សេងៗ។

តារាង ៦.២ ៖ ចំនួនគ្រួសារធម្មតា បែងចែកតាមសម្ភារសាងសង់លំនៅដ្ឋានដែលពួកគេរស់នៅ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| ផ្ទៃបាត | | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ |
| វត្ថុធាតុជញ្ជាំង | ដី/ដីឥដ្ឋ | ៨,៦ | ៩,១ | ៨,៧ | ៨,២ | ៩,៥ | ៨,៧ |
| | ឈើ/ទនាបឬស្សី | ៥០,០ | ៥១,៦ | ៥០,៤ | ៥៧,៧ | ៥៩,៨ | ៥៨,៤ |
| | បេតុង/ឥដ្ឋ/ថ្ម | ១៨,៣ | ១៦,៥ | ១៧,៩ | ១៦,៤ | ១៤,៨ | ១៥,៨ |
| | ថ្មខាត់ | ៤,៧ | ៤,៤ | ៤,៦ | ៣,៧ | ៣,៣ | ៣,៦ |
| | ក្តារក្រាល/ឈើរលោង | ១,៤ | ១,៣ | ១,៤ | ១,៤ | ១,៣ | ១,៣ |
| | គំនូរវិចិត្រ/ឥដ្ឋការ៉ូ | ១៦,៩ | ១៧,១ | ១៦,៩ | ១២,៦ | ១១,២ | ១២,១ |
| | ផ្សេងទៀត | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,១ |
| | សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

| ដំបូល | | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ |
| វត្ថុធាតុដំបូល | ឫស្សី/ស្បូវ/ស្លឹក/ត្រែង | ១,៩ | ២,២ | ២,០ | ១,៩ | ២,៧ | ២,២ |
| | ក្បឿង | ៣០,៥ | ៣០,៤ | ៣០,៥ | ៣៥,០ | ៣២,៣ | ៣៤,១ |
| | ឈើ/ក្តារ | ១,២ | ១,១ | ១,២ | ១,២ | ១,១ | ១,២ |
| | បេតុង/ឥដ្ឋ/ថ្ម | ៥,០ | ៥,៨ | ៥,២ | ៣,៩ | ៤,១ | ៤,០ |
| | ស័ង្កសី/អាលុយមីញ៉ូម/បន្ទះលោហៈធាតុផ្សេងៗ | ៥៤,៣ | ៥៣,៦ | ៥៤,២ | ៥១,៤ | ៥៣,៣ | ៥២,១ |
| | ហ្វីប្រូស៊ីម៉ង់ត៍ | ៦,៩ | ៦,៨ | ៦,៩ | ៦,៦ | ៦,៣ | ៦,៥ |
| | ផ្លាស្ទិក/បន្ទះជ័រ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| | ផ្សេងទៀត | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| | សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

| ជញ្ជាំង | | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ |
| វត្ថុធាតុជញ្ជាំង | ឫស្សី/ស្បូវ/ស្លៅ/ត្រែង | ៥,៥ | ៧,៥ | ៦,០ | ៦,៥ | ១០,២ | ៧,៧ |
| | ដី | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៧ |
| | ឈើ/ក្តារ | ៤៨,៧ | ៤៥,៣ | ៤៧,៩ | ៥៣,៦ | ៤៩,១ | ៥២,១ |
| | បេតុង/ឥដ្ឋ/ថ្ម | ២៧,៣ | ២៧,០ | ២៧,៣ | ២១,៦ | ១៩,៦ | ២១,០ |
| | ស័ង្កសី/អាលុយមីញ៉ូម/បន្ទះលោហៈធាតុផ្សេងៗ | ១៧,២ | ១៨,៩ | ១៧,៦ | ១៧,០ | ១៩,៨ | ១៧,៩ |
| | ហ្វីប្រូស៊ីម៉ង់ត៍ | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៤ |
| | វត្ថុធាតុកែច្នៃឡើងវិញ | ០,១ | ០,១ | ០,១ | ០,២ | ០,២ | ០,២ |
| | ផ្សេងទៀត | ០,១ | ០,០ | ០,០ | ០,១ | ០,១ | ០,១ |
| | សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ប្រភពថាមពលសម្រាប់បំភ្លឺ

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បង្ហាញថា ប្រជាជនចំនួន ៧៩,៦ ភាគរយ មានបណ្តាញអគ្គិសនីសម្រាប់ការបំភ្លឺ (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ ២០២០)។ លទ្ធភាពប្រើប្រាស់អគ្គិសនីនៅទីប្រជុំជន (៨២,៣ ភាគរយ) គឺខ្ពស់ជាងនៅជនបទ (៧២,១ ភាគរយ)។ ក្នុងប្រទេសមួយចំនួន ពិការភាពគឺជាកត្តាដ៏សំខាន់មួយដែលពាក់ព័ន្ធនឹងការប្រើប្រាស់អគ្គិសនី។ ឧ. ក្នុងប្រទេសមីយ៉ាន់ម៉ា ជនគ្មានពិការភាពចំនួន ៣៣,៦ ភាគរយរស់នៅក្នុងគ្រួសារដែលមានអគ្គិសនីសម្រាប់បំភ្លឺ។ ផ្ទុយទៅវិញ សម្រាប់ជនមានពិការភាព អត្រានេះគឺទាបជាងរហូតដល់ ៧ ភាគរយ (២៦,៦ ភាគរយ)(នាយកដ្ឋានប្រជាជន និងក្រសួងការងារ អន្តោប្រវេសន៍ និងប្រជាជន ឆ្នាំ ២០១៧) ប៉ុន្តែនៅប្រទេសកម្ពុជា គ្មានភាពខុសគ្នាខ្លាំងដូច្នេះទេ។ ទីមួយ ការភ្ជាប់បណ្តាញអគ្គិសនីមានអត្រាខ្ពស់ជាងនេះ។ ទីពីរ ការប្រើប្រាស់អគ្គិសនីរវាងគ្រួសារមានសមាជិកម្នាក់មានពិការភាព និងគ្រួសារគ្មានសមាជិកមានពិការភាព គឺប្រហាក់ប្រហែល។ គ្មានភាពខុសគ្នាជាក់ស្តែងរវាងគ្រួសារមានបុរសជាមេគ្រួសារ និងគ្រួសារមានស្ត្រីជាមេគ្រួសារឡើយ។

តារាង ៦.៣ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមប្រភពភ្លើងបំភ្លឺ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ |
| អគ្គិសនីបណ្ដាញ | ៧៩,១ | ៨១,០ | ៧៩,៦ | ៨០,១ | ៧៩,៨ | ៨០,០ |
| ម៉ាស៊ីនភ្លើង | ១,៦ | ១,៤ | ១,៦ | ១,៥ | ១,៣ | ១,៥ |
| អគ្គិសនីបណ្ដាញ និងម៉ាស៊ីនភ្លើង | ២,៩ | ២,៨ | ២,៨ | ២,៥ | ២,២ | ២,៤ |
| ប្រេងកាត | ០,៥ | ១,០ | ០,៦ | ០,៧ | ១,៩ | ១,១ |
| ទៀន | ០,២ | ០,៤ | ០,៣ | ០,៤ | ០,៩ | ០,៦ |
| អាគុយ ឬថ្មពិល | ១៣,៩ | ១២,០ | ១៣,៥ | ១៣,១ | ១២,៤ | ១២,៨ |
| ផ្សេងទៀត | ១,៧ | ១,៤ | ១,៦ | ១,៧ | ១,៥ | ១,៦ |
| សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ប្រភពទឹកពិសា

តារាង ៦.៤ បង្ហាញពីរបាយគ្រួសារ បែងចែកតាមប្រភពទឹកពិសានៃគ្រួសារដែលពួកគេរស់នៅ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ។ តារាង ៦.៤ បង្ហាញពីភាពខុសគ្នាតិចតួចរវាងគ្រួសារទាំង ២ ប្រភេទ ពាក់ព័ន្ធនឹងប្រភពទឹកពិសាចម្បង។ គេមិនអាចកំណត់និន្នាការពិតប្រាកដដោយផ្អែកតាមប្រភេទនៃការផ្គត់ផ្គង់ទឹកសម្រាប់កម្រិតពិការភាពផ្សេងៗបានឡើយ។ ភាពខុសគ្នាគួរឱ្យកត់សម្គាល់គឺ គ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព មិនសូវមានលទ្ធភាពប្រើប្រាស់ទឹកម៉ាស៊ីនបណ្ដាញក្នុងលំនៅដ្ឋាន (២៥,៦ ភាគរយសម្រាប់គ្រួសារគ្មានសមាជិកមានពិការភាព ទល់នឹង ២២,៤ ភាគរយសម្រាប់គ្រួសារមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន)។ ក្រៅពីនេះ ការវិភាគផ្ដោតលើរយៈពេលសម្រាប់ការធ្វើដំណើរទៅប្រភពទឹក ដងទឹក និងត្រឡប់មកវិញ។ គ្មានភាពខុសគ្នាជាក់លាក់រវាងគ្រួសារទាំងពីរប្រភេទនេះឡើយ។

តារាង ៦.៤ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមប្រភពទឹកពិសាសំខាន់ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ស្រី | ប្រុស | ទាំងពីរភេទ |
| ទឹកម៉ាស៊ីនបណ្ដាញ | ២៥,២ | ២៦,៧ | ២៥,៦ | ២២,២ | ២២,៩ | ២២,៤ |
| ទឹកបំពង់បណ្ដាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន | ៣,៦ | ៣,៥ | ៣,៦ | ៣,៥ | ៣,៤ | ៣,៥ |
| ទឹកបំពង់សាធារណៈ | ៣,៩ | ៣,៨ | ៣,៩ | ៣,៨ | ៣,៧ | ៣,៨ |
| ទឹកអណ្ដូងស្នប់/ទឹកអណ្ដូងជីក | ២៤,៦ | ២៦,៩ | ២៥,២ | ២៥,៦ | ២៨,២ | ២៦,៤ |
| ទឹកអណ្ដូងជីកមានគម្របការពារ | ៤,៦ | ៤,១ | ៤,៥ | ៤,៧ | ៤,៤ | ៤,៦ |
| ទឹកអណ្ដូងជីកគ្មានគម្របការពារ | ៦,០ | ៥,៧ | ៥,៩ | ៦,០ | ៥,៨ | ៥,៩ |
| ទឹកចេញក្រោមដីមានការការពារ | ០,៣ | ០,៣ | ០,៣ | ០,៤ | ០,៤ | ០,៤ |
| ទឹកចេញក្រោមដីគ្មានការការពារ | ០,៤ | ០,៣ | ០,៣ | ០,៤ | ០,៤ | ០,៤ |
| ទឹកភ្លៀង | ២,៧ | ២,៨ | ២,៧ | ៣,៤ | ៣,៧ | ៣,៥ |
| ទឹកទិញឡានស៊ីទែន | ៥,០ | ៤,៦ | ៤,៩ | ៥,២ | ៤,៨ | ៥,១ |
| ទឹកទិញធុងរទេះ | ៤,៨ | ៤,៦ | ៤,៨ | ៥,៤ | ៤,៩ | ៥,២ |
| ទឹកលើដី ( ទន្លេ អូរ បឹង ត្រពាំង... ) | ១១,០ | ៩,៤ | ១០,៦ | ១២,០ | ១០,៧ | ១១,៦ |
| ទឹកដប/ទឹកពិសាដប | ៧,៣ | ៦,៥ | ៧,១ | ៦,៧ | ៥,៨ | ៦,៤ |
| ប្រភពទឹកផ្សេងទៀត ( សូមបញ្ជាក់ ) | ០,៦ | ០,៧ | ០,៦ | ០,៨ | ១,០ | ០,៩ |
| សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

បុព្វកថានៃអនុសញ្ញាស្ដីពីសិទ្ធិជនពិការ កំណត់លទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ( ICT ) ជាកត្តាដ៏សំខាន់ដែលជំរុញឱ្យជនពិការសម្រេចបានសក្ដានុពល និងប្រើប្រាស់សិទ្ធិមនុស្ស និងសេរីភាពរបស់ពួកគេ។ ICT ជាឧបករណ៍ដ៏សំខាន់សម្រាប់ឱ្យជនពិការរស់នៅដោយឯករាជ្យ ប្រាស្រ័យទាក់ទង និងចូលរួមពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃសង្គម។ អនុញ្ញានេះអំពាវនាវឱ្យរដ្ឋាភិបាលធានាថា ជនពិការ មានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ( CRPD, 2006 )។

ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ មានកម្រងសំណួរស្តីពីការមាន និងចំនួនសម្ភារប្រើប្រាស់ក្នុងគ្រួសារ។ សម្ភារប្រើប្រាស់ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ មានបង្ហាញក្នុងតារាង ៦.៥។ តួលេខក្នុងតារាងនេះបង្ហាញពីចំនួនមធ្យមនៃសម្ភារប្រើប្រាស់ជាក់លាក់ក្នុងគ្រួសារដែលគ្មាន ឬមានសមាជិកមានពិការភាព។

**តារាង ៦.៥ ៖ ចំនួនមធ្យមនៃសម្ភារបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដែលមានក្នុងគ្រួសារធម្មតា បែងចែកទៅតាមថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩**

| | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ស្រី | ប្រុស | ទាំងពីរភេទ |
| វិទ្យុ ត្រង់ស៊ីស្ទ័រ | ០,១៨ | ០,១៧ | ០,១៨ | ០,២៩ | ០,២៦ | ០,២៨ |
| ទូរទស្សន៍ | ០,៧៧ | ០,៦៩ | ០,៧៥ | ០,៨០ | ០,៦៧ | ០,៧៦ |
| ទូរស័ព្ទ (ខ្សែ) | ០,០៣ | ០,០២ | ០,០៣ | ០,០៣ | ០,០២ | ០,០៣ |
| ទូរស័ព្ទដៃ | ២,១០ | ១,៧៩ | ២,០២ | ២,០៦ | ១,៦០ | ១,៩១ |
| កុំព្យូទ័រ | ០,១២ | ០,០៩ | ០,១២ | ០,១២ | ០,១២ | ០,១០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ការវិភាគបង្ហាញថា គ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព មានវិទ្យុប្រើប្រាស់ច្រើនជាងគ្រួសារគ្មានសមាជិកមានពិការភាព។ បើធៀបនឹងចំនួនមធ្យមនៃទូរស័ព្ទ ចំនួនវិទ្យុដ៏តិចតួចនេះគឺខុសគ្នាខ្លាំង។ ក្នុងចំណោមប្រជាជន ១០០ គ្រួសារដែលគ្មានសមាជិកមានពិការភាព មាន ១៨ គ្រួសារមានវិទ្យុមួយគ្រឿង។ សម្រាប់គ្រួសារដែលមានសមាជិកម្នាក់មានពិការភាព មាន ២៨ គ្រួសារមានវិទ្យុមួយគ្រឿង។ ចំនួនមធ្យមនៃទូរទស្សន៍គឺប្រហាក់ប្រហែលគ្នារវាងគ្រួសារទាំង ២ ប្រភេទ (០,៧៥ ទល់នឹង ០,៧៦)។ តាមពិត ភេទរបស់មេគ្រួសារជាកត្តាគូសបញ្ជាក់ពីស្ថានភាពសេដ្ឋកិច្ចខ្វះខាតរបស់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ។ ក្នុងចំណោមប្រជាជន ១០០ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មាន ៦៧ គ្រួសារមានទូរទស្សន៍មួយគ្រឿង ទល់នឹង ៨០ គ្រួសារដែលមានបុរសជាមេគ្រួសារ។ ស្ទើរតែគ្មានការប្រើប្រាស់ទូរស័ព្ទលើតុ (ជាមធ្យមគឺ ០,០៣) និងត្រូវបានជំនួសដោយទូរស័ព្ទដៃ។ ជាមធ្យម គ្រួសារដែលគ្មានសមាជិកមានពិការភាព មានទូរស័ព្ទដៃចំនួន ២,០២ គ្រឿង។ នេះជាអត្រាខ្ពស់បន្តិចជាងគ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់ ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន (១,៩១ គ្រឿង)។ សម្រាប់គ្រួសារទាំង ២ ប្រភេទនេះ គ្រួសារមានស្ត្រីជាមេគ្រួសារមានពិន្ទុទាបជាងគ្រួសារមានបុរសជាមេគ្រួសារ។លទ្ធភាពប្រើប្រាស់កុំព្យូទ័រគឺមិនសូវមាននោះទេ។ ប្រសិនបើគ្មានសមាជិកណាម្នាក់មានពិការភាព ការមានកុំព្យូទ័រប្រើប្រាស់គឺប្រហែល ១ ក្នុងចំណោម ៨ គ្រួសារ។ ក្នុងចំណោមគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព ការមានកុំព្យូទ័រប្រើប្រាស់គឺប្រហែល ១ ក្នុងចំណោម ១០ គ្រួសារ។ អត្រានេះកាន់តែទាបក្នុងចំណោមគ្រួសារមានស្ត្រីជាមេគ្រួសារ។

គ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាពមានអត្រាទាបនៃការប្រើប្រាស់អ៊ីនធឺណិត ទាំងក្នុង និងក្រៅផ្ទះ (រូប ៦.២)។ ៤០ ភាគរយនៃគ្រួសារដែលមានសមាជិកម្នាក់មានពិការភាព មានបណ្តាញអ៊ីនធឺណិតប្រើប្រាស់ក្នុងផ្ទះ និង ២៤,០ ភាគរយមានបណ្តាញអ៊ីនធឺណិតប្រើប្រាស់នៅក្រៅលំនៅដ្ឋាន។ សម្រាប់គ្រួសារដែលគ្មានសមាជិកមានពិការភាព គ្រួសារ ៤៥,៦ ភាគរយ មានបណ្តាញអ៊ីនធឺណិតប្រើប្រាស់ក្នុងផ្ទះ និង ២៨,៤ ភាគរយ មានបណ្តាញអ៊ីនធឺណិតប្រើប្រាស់នៅក្រៅលំនៅដ្ឋាន។ គ្រួសារមានស្ត្រីជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាព មានពិន្ទុទាបខ្លាំងជាងគ្រួសារមានបុរសជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាព (៣៤,៧ ភាគរយ ទល់នឹង ៤២,៦ ភាគរយ)។ មានភាពខុសគ្នាតិចតួច ប៉ុន្តែគួរឱ្យកត់សម្គាល់សម្រាប់ការភ្ជាប់បណ្តាញអ៊ីនធឺណិតប្រើប្រាស់នៅក្រៅគ្រួសារ។

រូប ៦.២ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមការប្រើប្រាស់អ៊ីនធឺណិតក្នុង និងក្រៅផ្ទះ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

សំណួរដ៏សំខាន់គឺ ថាតើភាពខុសគ្នានៃការភ្ជាប់បណ្តាញអ៊ីនធឺណិតប្រើប្រាស់រវាងគ្រួសារដែលមាន ឬគ្មានសមាជិកមានពិការភាព បណ្តាលមកពីស្ថានភាពពិការភាពរបស់គ្រួសារនេះ ឬបណ្តាលមកពីកត្តាជះឥទ្ធិពលផ្សេងទៀត។ ឧ. ប្រហែលជាគ្រួសារដែលមានសមាជិកមានពិការភាព មានមនុស្សចាស់ច្រើនក្នុងគ្រួសារ ព្រោះពិការភាពពាក់ព័ន្ធនឹងអាយុ។ ដោយសារតែមនុស្សចាស់មិនសូវភ្ជាប់បណ្តាញអ៊ីនធឺណិតប្រើប្រាស់ ដើមហេតុបង្កជាអត្រាភ្ជាប់អ៊ីនធឺណិតទាប មិនមែនពិការភាពទេ ប៉ុន្តែគឺអាយុទៅវិញ។

ដូច្នេះ រីហ្គ្រេសិនឡូជីត (logit regression) ដែលគ្របដណ្តប់លើប្រជាជនអាយុ ១៥ ឆ្នាំឡើង ត្រូវបានយកមកប្រើប្រាស់ដើម្បីបញ្ជាក់ពីចំណុចនេះ។ អថេរចំណុះក្នុងគំរូរីហ្គ្រេសិននេះ គឺថាតើបុគ្គលនោះរស់នៅក្នុងគ្រួសារដែល

ភ្ជាប់បណ្តាញអ៊ីនធឺណិតប្រើប្រាស់ក្នុងផ្ទះ ឬទេ។ អថេរពន្យល់ គឺអាយុ ៤ ក្រុម (ក្រោម ២៤ ឆ្នាំ, ២៥-២៩ ឆ្នាំ, ៥០-៧៤ ឆ្នាំ និង ៧៥ ឆ្នាំឡើង) សន្ទស្សន៍ទ្រព្យសម្បត្តិរបស់គ្រួសារ ការចូលរៀននៅសាលា (មិនដែលសោះ បច្ចុប្បន្ន អតីតកាល) និងកម្រិតពិការភាពរបស់គាត់ (មិនពិការ ពិការខ្លះ ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន)។ រូប ៦.៣ រៀបរាប់ពីផលធៀបឱកាសសម្រាប់ការវិភាគឡូជីតនេះ។

រូប ៦.៣ ៖ ផលធៀបឱកាសនៃរីហ្គ្រេសិនឡូជីស្ទិកសម្រាប់ការប្រើប្រាស់អ៊ីនធឺណិតក្នុងផ្ទះ ក្នុងចំណោមប្រជាជនអាយុ ១៥ ឆ្នាំឡើង ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

លទ្ធផលបង្ហាញថា កត្តាដ៏សំខាន់ដែលកំណត់ថាតើមនុស្សម្នាក់មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតក្នុងផ្ទះ ឬទេ គឺស្ថានភាពទ្រព្យសម្បត្តិរបស់គ្រួសារនោះ។ ប្រសិនបើគាត់រស់នៅក្នុងគ្រួសារដែលស្ថិតក្នុងបញ្ចភាគស្តុកស្តម្ភបំផុត នោះឱកាសនៃការមានបណ្តាញអ៊ីនធឺណិតប្រើប្រាស់ក្នុងគ្រួសារនោះគឺខ្ពស់ជាងរហូតដល់ ៤,៥ ដង ធៀបនឹងករណីដែលគាត់ជាសមាជិកគ្រួសារដែលស្ថិតក្នុងបញ្ចភាគក្រីក្របំផុត។ សម្រាប់បញ្ចភាគទ្រព្យសម្បត្តិនៅកម្រិតខ្ពស់នីមួយៗ មានការកើនឡើងជាលំដាប់នូវឱកាសដែលមនុស្សម្នាក់មានបណ្តាញអ៊ីនធឺណិតប្រើប្រាស់ក្នុងផ្ទះ។ យុវជនមានឱកាសខ្ពស់ក្នុងការមានបណ្តាញអ៊ីនធឺណិតប្រើប្រាស់។ចំណុចនេះពាក់ព័ន្ធនឹងចំនួនប្រជាជនដែលកំពុងសិក្សា។ កម្រិតពិការភាពរបស់មនុស្សម្នាក់ជះឥទ្ធិពលតិចតួចលើសមត្ថភាពរបស់គាត់ក្នុងការភ្ជាប់បណ្តាញអ៊ីនធឺណិតក្នុង

លំនៅដ្ឋាន។ ប្រសិនបើមនុស្សម្នាក់ពិការមិនអាចធ្វើអ្វីបាន ឱកាសនៃការភ្ជាប់បណ្ដាញអ៊ីនធឺណិតប្រើប្រាស់គឺ ០,៨៣២ ធៀបនឹងមនុស្សម្នាក់ដែលមិនពិការ។ ភាពខុសគ្នានេះគឺមិនឆ្ងាយពីគ្នាអញ្ចឹងទេ និងមិនអាចប្រៀបធៀបនឹងឥទ្ធិពលនៃកត្តាទ្រព្យសម្បត្តិបានឡើយ។ គេអាចយល់បានថា ឥទ្ធិពលនេះមានកម្រិត ព្រោះជនមានពិការភាពអាចរស់នៅក្នុងគ្រួសារស្ដុកស្ដម្ភ ឬក្រីក្រ ហើយទោះបីជាពួកគេមិនប្រើអ៊ីនធឺណិត ក៏សមាជិកគ្រួសារផ្សេងទៀតជាអ្នកប្រើប្រាស់ដែរ។ ក្នុងករណីនេះ ការប្រើប្រាស់អ៊ីនធឺណិតគឺជាសំណួរដ៏ល្អ ប៉ុន្តែសំណួរនេះមិនត្រូវបានបញ្ចូលក្នុងជំរឿននេះឡើយ។

## បង្គន់អនាម័យ

របាយការណ៍របស់អង្គការសហប្រជាជាតិស្ដីពីពិការភាព និងការអភិវឌ្ឍ (២០១៨) លើកឡើងថា ក្នុងចំណោម ៣៣ ប្រទេសនៃ ៤៤ ប្រទេសដែលត្រូវបានសិក្សាស្រាវជ្រាវនៅអឺរ៉ុប និងទួរគី ភាគរយប្រជាជនដែលរស់នៅក្នុងលំនៅដ្ឋានដែលគ្មានបង្គន់អនាម័យក្នុងផ្ទះ មានកម្រិតខ្ពស់ក្នុងចំណោមជនមានពិការភាព ជាងក្នុងចំណោមជនមិនពិការ។ ក្នុងប្រទេសចំនួន ១០ ដែលត្រូវបានសិក្សាស្រាវជ្រាវ ភាពខុសគ្នារវាងក្រុមពិការភាពទាំង ២ គឺជាង ៥ ភាគរយ។

តារាង ៦.៦ បង្ហាញពីភាគរយនៃគ្រួសារធម្មតា បែងចែកតាមប្រភេទបង្គន់អនាម័យ និងថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ។ តារាងនេះក៏បង្ហាញពីភេទរបស់មេគ្រួសារផងដែរ។ ភាគរយនៃគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់ មានកម្រិតខ្ពស់ក្នុងចំណោមគ្រួសារគ្មានសមាជិកមានពិការភាព (២៩,០ ភាគរយ) ជាងក្នុងចំណោមគ្រួសារមានសមាជិកម្នាក់មានពិការភាព (២៦,០ ភាគរយ)។ ចំនួនច្រើនជាងគេ គឺគ្រួសារដែលមានបង្គន់ចាក់ទឹក (ឬចុចបង្ហូរទឹក) តភ្ជាប់ទៅប្រព័ន្ធលូ។ ក្នុងប្រភេទនេះដែរ គ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព មានពិន្ទុខ្ពស់ជាងគ្រួសារដែលគ្មានសមាជិកមានពិការភាព (៤១,២ ភាគរយ ទល់នឹង ៣៧,៦ ភាគរយ)។ នេះជាសញ្ញាវិជ្ជមាន ព្រោះវាបង្ហាញថា លទ្ធភាពប្រើប្រាស់បង្គន់អនាម័យមានកម្រិតខ្ពស់ក្នុងចំណោមគ្រួសារងាយរងគ្រោះ។

ក្នុងផ្នែកមុនៗ យើងឃើញថា ជាទូទៅ គ្រួសារមានស្ត្រីជាមេគ្រួសារមានស្ថានភាពសមប្រកបតិចជាងគ្រួសារមានបុរសជាមេគ្រួសារ។ ពាក់ព័ន្ធនឹងអនាម័យ ស្ថានភាពនេះគឺល្អប្រសើរ។ គ្រួសារមានស្ត្រីជាមេគ្រួសារ មានចំនួនសម្ភារអនាម័យប្រហាក់ប្រហែលនឹងគ្រួសារមានបុរសជាមេគ្រួសារ លើកលែងតែបង្គន់អនាម័យ ដែលគ្រួសារមានស្ត្រីជាមេគ្រួសារ និងមានសមាជិកមានពិការភាព មានពិន្ទុល្អជាង។

តារាង ៦.៦ ៖ ភាគរយនៃគ្រួសារធម្មតា បែងចែកតាមប្រភេទបង្គន់អនាម័យ ថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ស្រី | ប្រុស | ទាំងពីរភេទ |
| មិនប្រើបង្គន់ | ២៨,៩ | ២៩,៤ | ២៩,០ | ២៦,៦ | ២៤,៨ | ២៦,០ |
| បង្គន់ចាក់ទឹក ឬ (ចុចបង្ហូរទឹក) តភ្ជាប់ទៅប្រព័ន្ធលូ | ៣៧,៦ | ៣៧,៩ | ៣៧,៦ | ៤១,៣ | ៤១,០ | ៤១,២ |
| បង្គន់ចាក់ទឹក ឬ (ចុចបង្ហូរទឹក) តភ្ជាប់ទៅអាងស្តុក ឬរណ្តៅ | ៨,៧ | ៨,៥ | ៨,៦ | ៨,២ | ៨,០ | ៨,១ |
| បង្គន់ចាក់ទឹក ឬ (ចុចបង្ហូរទឹក) បង្ហូរទៅកន្លែងផ្សេង | ៤,៤ | ៤,០ | ៤,៣ | ៤,៦ | ៤,៥ | ៤,៥ |
| បង្គន់រណ្តៅមានចានបង្គន់ | ១,៧ | ១,៦ | ១,៧ | ១,៦ | ១,៩ | ១,៧ |
| បង្គន់រណ្តៅគ្មានចានបង្គន់ | ០,៩ | ០,៧ | ០,៨ | ០,៧ | ០,៧ | ០,៧ |
| បង្គន់បត់ជើងទម្លាក់ ឬក្នុងទឹក | ០,៨ | ០,៩ | ០,៨ | ០,៨ | ១,១ | ០,៩ |
| មិនបញ្ជាក់ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## មធ្យោបាយធ្វើដំណើរ

ការរកបានមធ្យោបាយធ្វើដំណើរ ជះឥទ្ធិពលផ្ទាល់លើចល័តភាពរបស់ជនមានពិការភាព និងអាចបង្កផលប៉ះពាល់លើទិដ្ឋភាពជាច្រើនដែលកំណត់គុណភាពជីវិតរបស់ពួកគេ។ ដោយសារតែជារឿយៗ ប្រព័ន្ធធ្វើដំណើរមិនផ្តល់ភាពងាយស្រួលដល់ជនមានពិការភាព ការប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនគឺជម្រើសសមស្របតែមួយសម្រាប់ការចាកចេញពីផ្ទះ និងអាចធ្វើដំណើរបាន។ តារាង ៦.៧ បង្ហាញពីចំនួនយានជំនិះរបស់គ្រួសារធម្មតា បែងចែកទៅតាមថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំងឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ។ ភាគរយត្រូវបានគណនាសម្រាប់ជនបទ និងទីប្រជុំជន។

ភាពខុសគ្នាដ៏ធំរវាងគ្រួសារទាំងពីរប្រភេទនេះ ស្តែងចេញតាមរយៈការមានកង់ និងម៉ូតូប្រើប្រាស់។ ខណៈដែលគ្រួសារដែលមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានចំនួនកង់ប្រើប្រាស់ច្រើន (០,៨៦ គ្រឿង ទល់នឹង ០,៨០ គ្រឿងក្នុងមួយគ្រួសារ) គ្រួសារទាំងនេះមានចំនួនម៉ូតូប្រើប្រាស់ប្រហាក់ប្រហែលគ្នា (១,២៨ គ្រឿង ទល់នឹង ១,៣១ គ្រឿងក្នុងមួយគ្រួសារ)។ ចំនួនរថយន្តជាមធ្យមក៏ប្រហាក់ប្រហែលគ្នាសម្រាប់គ្រួសារទាំងពីរប្រភេទនេះផងដែរ ប៉ុន្តែគ្រួសារមានស្ត្រីជាមេគ្រួសារមានការលំបាកជាង។

តារាង ៦.៧ ៖ ចំនួនមធ្យមនៃយានយន្តធ្វើដំណើរដែលមានក្នុងគ្រួសារធម្មតា បែងចែកទៅតាមថាតើគ្រួសារនោះមានសមាជិកម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឬទេ និងភេទរបស់មេគ្រួសារ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | គ្មានសមាជិកគ្រួសារណាម្នាក់មានពិការភាព | | | យ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ស្រី | ប្រុស | ទាំងពីរភេទ |
| | សរុប | | | | | |
| កង់ | ០,៧៩ | ០,៨០ | ០,៨០ | ០,៨៦ | ០,៨៦ | ០,៨៦ |
| ម៉ូតូ | ១,៣៤ | ១,២៩ | ១,៣១ | ១,៣២ | ១,២៥ | ១,២៨ |
| រថយន្ត | ០,១៦ | ០,១៥ | ០,១៦ | ០,១៥ | ០,១៣ | ០,១៤ |
| ទូក | ០,០៥ | ០,០៤ | ០,០៥ | ០,០៥ | ០,០៥ | ០,០៥ |
| | ទីប្រជុំជន | | | | | |
| កង់ | ០,៨៣ | ០,៧៤ | ០,៧៤ | ០,៨២ | ០,៨២ | ០,៨២ |
| ម៉ូតូ | ១,១៥ | ១,៥៧ | ១,៦០ | ១,៦៨ | ១,៦០ | ១,៦៤ |
| រថយន្ត | ០,៣០ | ០,២៨ | ០,២៩ | ០,៣០ | ០,២៨ | ០,២៩ |
| ទូក | ០,០២ | ០,០២ | ០,០២ | ០,០៣ | ០,០២ | ០,០៣ |
| | ជនបទ | | | | | |
| កង់ | ០,៨៣ | ០,៨៤ | ០,៨៣ | ០,៨៨ | ០,៨៩ | ០,៨៩ |
| ម៉ូតូ | ១,១៥ | ១,១១ | ១,១៣ | ១,១២ | ១,០៦ | ១,០៨ |
| រថយន្ត | ០,០៧ | ០,០៧ | ០,០៧ | ០,០៧ | ០,០៦ | ០,០៦ |
| ទូក | ០,០៦ | ០,០៦ | ០,០៦ | ០,០៧ | ០,០៦ | ០,០៦ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

# ជំពូក ៧៖ ការអប់រំ និងពិការភាព

ការអប់រំបរិយាបន្ន និងប្រកបដោយគុណភាពសម្រាប់ប្រជាជនគ្រប់រូប រួមទាំងក្រុមងាយរងគ្រោះ (ជនមានពិការភាព) ជាចំណុចដៅមួយក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤។ ការអប់រំជាសិទ្ធិមនុស្សជាសារវន្តដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍបុគ្គល បរិយាបន្នសង្គម និងការងារសមរម្យ។ ដូច្នេះ ជនមានពិការភាពគួរមានលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា និងការរៀនសូត្រដែលមានបរិយាបន្ន អាចទទួលបាន និងមិនគិតថ្លៃ។ ជនមានពិការភាពគួរតែអាចចូលរួមដោយស្មើភាពក្នុងប្រព័ន្ធអប់រំដូចសមាជិកផ្សេងទៀតក្នុងសហគមន៍ ប៉ុន្តែពួកគេមិនសុទ្ធតែអាចទទួលបានលទ្ធភាពដូច្នេះនោះទេ។ ភាពលម្អៀងការរើសអើង គ្រូបង្រៀនដែលគ្មានគុណវុឌ្ឍិ សាលារៀនដែលមិនផ្តល់ភាពងាយស្រួល និងសម្ភារអប់រំមិនគ្រប់គ្រាន់បានរាំងស្ទះលទ្ធភាពរបស់ជនមានពិការភាពក្នុងការទទួលបានការអប់រំ (UNDESA, 2018; UNESCO, n.d.a)។

គោលដៅជាយុទ្ធសាស្ត្រទី ៣ នៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ផ្តោតលើលទ្ធភាពទទួលបានការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធានាផ្តល់ជូនជនមានពិការភាពនូវការអប់រំប្រកបដោយគុណភាព បរិយាបន្ន សមភាព និងសមធម៌ពេញមួយជីវិត ព្រមទាំងការបណ្តុះបណ្តាលជំនាញ។ យុទ្ធសាស្ត្រក្នុងការសម្រេចបានគោលដៅនេះរួមមានការការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំជនមានពិការភាព ការកែលម្អបទដ្ឋានគតិយុត្តិ ការបង្កើនស្តង់ដារនៃសម្ភារសិក្សា និងការធ្វើទំនើបកម្មកម្មវិធី ការបណ្តុះបណ្តាលមន្ត្រីរាជការ ការបង្កើតឱកាសទំនុកបម្រុង ការបង្កើនលទ្ធភាពចូលបំពេញការងារស្ម័គ្រចិត្តដើម្បីបង្កើនបទពិសោធន៍ការងារ។ល។ (DAC, 2019)។

ការអប់រំ និងពិការភាពមានទំនាក់ទំនងចាក់ស្រេះ។ បញ្ហាទីមួយពាក់ព័ន្ធនឹងគោលគំនិតនៃការអប់រំ។ ចំណុចដែលសំខាន់គឺមិនត្រឹមតែការប្រៀបធៀបថាតើក្រុមទាំងពីរនេះស្ថិតក្នុងការអប់រំ ឬយ៉ាងណានោះទេ ប៉ុន្តែថែមទាំងថាតើប្រភេទ និងគុណភាពនៃការអប់រំដែលផ្តល់ជូនកុមារដែលមាន និងគ្មានពិការភាព គឺដូចគ្នា ឬទេ។ ក្នុងមជ្ឈដ្ឋានជាច្រើនកុមារមានពិការភាពមិនអាចចូលរួមក្នុងប្រព័ន្ធអប់រំចំណេះទូទៅបានឡើយ ហើយការអប់រំ "ពិសេស" មានទម្រង់ជាការមើលថែនៅពេលថ្ងៃ (daycare)។ រយៈពេលអប់រំ និងអាយុរបស់សិស្សក៏ជាកត្តាសំខាន់ដែលត្រូវពិចារណាផងដែរ។ កុមារមានពិការភាពច្រើនតែចុះឈ្មោះចូលរៀននៅអាយុច្រើនជាងកុមារគ្មានពិការភាព និងមានអត្រាខ្ពស់នៃការបោះបង់ការសិក្សា[16]។ ក្រៅពីនេះ អាយុជាកត្តាដ៏សំខាន់ពាក់ព័ន្ធនឹងកម្រិតអប់រំរបស់ក្រុមអាយុវ័យចាស់ ព្រោះវាសំដៅលើស្ថានភាពពីមុនដែលមិនសូវមានប្រជាជនទទួលបានការអប់រំ ហើយគោលជំហរពីមុនរបស់ជនមានពិការភាព អាចនឹងខុសពីគោលជំហរនាពេលបច្ចុប្បន្ន។ ផលវិបាកមួយទៀតគឺ មនុស្សមួយចំនួនអាចមានពិការភាពពីកំណើត ខណៈដែលអ្នកផ្សេងទៀត (ភាគច្រើន) មានពិការភាពនៅដំណាក់កាលក្រោយមកទៀតក្នុងជីវិត បន្ទាប់ពីពួកគេបានបញ្ចប់ការអប់រំជាយូរមកហើយ។ គួរឱ្យសោកស្តាយដែលជំរឿននេះមិនផ្តល់ព័ត៌មានស្តីពីអាយុដែលមនុស្សមានពិការភាព ឬដើមហេតុបង្កពិការភាពសម្រាប់ការវិភាគបន្ថែម។

16 - https://www.right-to-education.org/issue-page/marginalised-groups/persons-disabilities

## ៧.១ ការចូលរៀននៅសាលា

ការសិក្សាមួយក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៤១ ប្រទេស បានធ្វើការប្រៀបធៀបការចូលរៀននៅសាលាក្នុងចំណោមជនមានពិការភាព និងជនគ្មានពិការភាព។ ក្នុងក្រុមអាយុ ១៥-២៩ ឆ្នាំ ជនមានពិការភាពចំនួន ៧៥ ភាគរយ និងជនគ្មានពិការភាពចំនួន ៨៧ ភាគរយ ត្រូវបានប៉ាន់ស្មានថា បានចូលរៀននៅសាលា។ មានការរាយការណ៍ពីគម្លាតដ៏ធំមួយក្នុងប្រទេសកម្ពុជា ៖ ក្នុងក្រុមអាយុ ១៥-២៩ ឆ្នាំ ជនមានពិការភាពចំនួន ៥១ ភាគរយ និងជនគ្មានពិការភាពចំនួន ៩៤ ភាគរយ បានចូលរៀននៅសាលា (UNDESA, 2018)។

## អត្រាទាបនៃការចូលរៀននៅសាលា

ដើម្បីវិភាគការចូលរៀននៅសាលា ដោយផ្អែកតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ កុមារ/មនុស្សពេញវ័យក្នុងក្រុមអាយុ ៤ ក្រុម ត្រូវបានលើកមកពិចារណាមុនគេ ៖ ៥-៩ ឆ្នាំ, ១០-១៤ ឆ្នាំ, ១៥-១៩ ឆ្នាំ និង ២០-២៤ ឆ្នាំ។ ក្នុងក្រុមអាយុ ៥-៩ ឆ្នាំ និង ១០-១៤ ឆ្នាំ កុមារចំនួន ៣.១២០.៩៨១ នាក់ត្រូវបានសម្ភាសន៍ (១.៤៧៣.១០៤ នាក់ មានអាយុ ៥-៩ ឆ្នាំ និង ១.៦៤៧.៨៧៧ នាក់មានអាយុ ១០-១៤ ឆ្នាំ)។ របាយការណ៍បង្ហាញថា ក្នុងចំណោមកុមារទាំង ៣,២ លាននាក់នេះ កុមារចំនួន ២៦.៤៩៣ នាក់ (០,៨៥ ភាគរយ) ពិការខ្លះ, ៦.១០៦ នាក់ (០,២០ ភាគរយ) ពិការខ្លាំង និង ៤.៩៧៦ នាក់ (០,១៦ ភាគរយ) ពិការមិនអាចធ្វើអ្វីបាន។ រូប ៧.១ និង ៧.២ សង្ខេបពីការចូលរៀននៅសាលារបស់កុមារក្នុងក្រុមអាយុទាំង ២ នេះ។ ក្រាហ្វនីមួយៗបង្ហាញដោយឡែកនូវក្មេងប្រុស និងក្មេងស្រី បែងចែកតាមកម្រិតពិការភាព។ ក្នុងជំរឿននេះ ការចូលរៀននៅសាលាត្រូវបានបែងចែកជា ៣ ប្រភេទ ៖ "មិនដែលសោះ" "បច្ចុប្បន្ន" ឬ "អតីតកាល"។ សម្រាប់ប្រជាជនក្នុងក្រុមអាយុ ៥ ឆ្នាំទាំងពីរក្រុមនេះ មានតែពីរបីនាក់ប៉ុណ្ណោះដែលបញ្ជាក់ថា "អតីតកាល" ព្រោះពួកគេធ្លាប់ចូលរៀនកាលពីក្មេង។

ក្រាហ្វនេះបង្ហាញច្បាស់ពីស្ថានភាពចាញ់ប្រៀបរបស់ក្មេងប្រុស និងក្មេងស្រីមានពិការភាព ពាក់ព័ន្ធនឹងការចូលរៀននៅសាលា។ ក្នុងក្រុមអាយុ ៥-៩ ឆ្នាំ ក្មេងប្រុសគ្មានពិការភាព ចំនួន ២២,៥ ភាគរយ មិនដែលចូលសាលា ធៀបនឹងក្មេងប្រុសពិការខ្លាំងចំនួន ៤៨,៧ ភាគរយ និងក្មេងប្រុសពិការមិនអាចធ្វើអ្វីបាន ចំនួន ៥៩,៩ ភាគរយ។ អត្រានេះគឺប្រហាក់ប្រហែលនឹងអត្រាសម្រាប់ក្មេងស្រី។ ក្នុងក្រុមអាយុ ៥-៩ ឆ្នាំដែលគ្មានពិការភាព ក្មេងប្រុសចំនួន ៧៦,៧ ភាគរយ និងក្មេងស្រីចំនួន ៧៧,៨ ភាគរយ បានចូលរៀន។ សម្រាប់កម្រិតពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន អត្រាចូលរៀនសម្រាប់ក្មេងប្រុសគឺ ៤៨,០ ភាគរយ ទល់នឹង ៣៨,៥ ភាគរយ ហើយអត្រាចូលរៀនសម្រាប់ក្មេងស្រីគឺ ៥៣,៧ ភាគរយ ទល់នឹង ៤៤,៣ ភាគរយ។ ក្នុងក្រុមអាយុ ១០-១៤ ឆ្នាំ គំរូស្រដៀងគ្នានេះមានបង្ហាញក្នុងរូប ៧.២។ ខណៈដែលក្មេងប្រុស និងក្មេងស្រីគ្មានពិការភាព ជាង ៩០ ភាគរយ ក្នុងក្រុមអាយុនេះ បានចូលរៀន អត្រាចូលរៀនរបស់កុមារពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានកម្រិតទាប។ ក្នុងចំណោមក្មេងប្រុស និងក្មេងស្រីពិការខ្លាំង ភាគរយនៃការចូលរៀននៅសាលាគឺក្រោម ៦០ ភាគរយ។ កុមារពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ប្រហែល ១/៤ មិនដែលចូលសាលា។ អត្រាចូលរៀននៅសាលាសម្រាប់ក្រុមអាយុ ១០-១៤ ឆ្នាំ មានកម្រិតទាបក្នុងចំណោមកុមារពិការខ្លាំង ជាងកុមារពិការមិនអាចធ្វើអ្វីបាន ប៉ុន្តែគេមិនដឹងច្បាស់ថាតើគំរូនេះបណ្តាលមកពីអ្វីនោះទេ។

### រូប ៧.១ ៖ ការចូលរៀននៅសាលាសម្រាប់កុមារអាយុ ៥-៩ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ភេទ និងក្រុមអាយុទូទៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

### រូប ៧.២ ៖ ការចូលរៀននៅសាលាសម្រាប់កុមារអាយុ ១០-១៤ ឆ្នាំ បែងចែកតាមពិការភាព ភេទ និងក្រុមអាយុទូទៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

មានភាពខុសគ្នាក្នុងចំណោមក្រុមអាយុ ១៥-១៩ ឆ្នាំ និងក្រុមអាយុ ២០-២៤ ឆ្នាំ។ ក្នុងក្រុមអាយុ ១៥-១៩ ឆ្នាំ ចំនួនយុវជន និងយុវតីដែលចូលរៀននៅសាលាមានកម្រិតទាបខ្លាំងសម្រាប់ជនមានពិការភាពទាំង ៣ ក្រុម។ ខណៈដែលយុវជន និងយុវតីគ្មានពិការភាពចំនួន ៥៦ ភាគរយ បានចូលរៀន អត្រានេះគឺត្រឹមតែ ២៣,២ ភាគរយសម្រាប់យុវជនពិការខ្លាំង និង ៣៤,០ ភាគរយសម្រាប់យុវជនពិការមិនអាចធ្វើអ្វីបាន និងត្រឹមតែ ២៤,៣ ភាគរយសម្រាប់យុវតីពិការខ្លាំង និង ៣៩,៥ ភាគរយសម្រាប់យុវតីពិការមិនអាចធ្វើអ្វីបាន។ ទោះជាយ៉ាងណា ក្រុមអាយុ ២០-២៤ ឆ្នាំបង្ហាញពីគំរូដ៏គួរឱ្យចាប់អារម្មណ៍មួយ។ នោះគឺភាគរយដូចគ្នារវាងបុរសពិការមិនអាចធ្វើអ្វីបាន និងបុរសគ្មានពិការភាព។ ក្នុងចំណោមស្ត្រី ភាគរយនៃស្ត្រីពិការមិនអាចធ្វើអ្វីបាន គឺខ្ពស់ជាងនេះ (១៩,៣ ភាគរយសម្រាប់ស្ត្រីពិការមិនអាចធ្វើអ្វីបាន ទល់នឹង ១១,៥ ភាគរយសម្រាប់ស្ត្រីគ្មានពិការភាព)។ ទិន្នន័យទាំងនេះបង្ហាញថា ការអប់រំសម្រាប់យុវជនពិការ

មិនអាចធ្វើអ្វីបាន មានលក្ខណៈបរិយាបន្ន ប៉ុន្តែចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមទៀតដើម្បីបញ្ជាក់ការអះអាងនេះ។ ឧ. គេមិនច្បាស់ថាតើប្រភេទ និងគុណភាពនៃការអប់រំមានកម្រិតដូចគ្នា ឬថាតើការអប់រំរបស់យុវជនមានពិការភាពគ្រាន់តែជំនួសឱ្យការថែទាំនៅពេលថ្ងៃ (daycare)។

**តារាង ៧.១ ៖ ការចូលរៀននៅសាលារបស់កុមារអាយុ ១៥–១៩ ឆ្នាំ និងមនុស្សពេញវ័យអាយុ ២០–២៤ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ភេទ និងក្រុមអាយុទូទៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩**

| ១៥-១៩ ឆ្នាំ | | | | | | |
|---|---|---|---|---|---|---|
| | ប្រុស | | | ស្រី | | |
| | មិនដែលសោះ | បច្ចុប្បន្ន | អតីតកាល | មិនដែលសោះ | បច្ចុប្បន្ន | អតីតកាល |
| មិនពិការ | ៥,៤ | ៥៥,៨ | ៣៨,៨ | ៤,៦ | ៥៦,០ | ៣៩,៥ |
| ពិការខ្លះ | ១៦,០ | ៤០,២ | ៤៣,៩ | ១៦,៨ | ៣៧,៦ | ៤៥,៦ |
| ពិការខ្លាំង | ៤៧,៥ | ២៣,២ | ២៩,៣ | ៤៤,៧ | ២៤,៣ | ៣១,០ |
| ពិការមិនអាចធ្វើអ្វីបាន | ៣៤,៤ | ៣៤,០ | ៣១,៦ | ២៨,៥ | ៣៩,៥ | ៣២,០ |
| **២០-២៤ ឆ្នាំ** | | | | | | |
| មិនពិការ | ៨,១ | ១៤,២ | ៧៧,៧ | ៧,៨ | ១១,៥ | ៨០,៧ |
| ពិការខ្លះ | ១៧,២ | ៩,២ | ៧៣,៦ | ១៧,០ | ៩,៣ | ៧៣,៦ |
| ពិការខ្លាំង | ៤៥,២ | ៩,៩ | ៤៤,៩ | ៤៦,៧ | ៩,១ | ៤៤,៣ |
| ពិការមិនអាចធ្វើអ្វីបាន | ៣៣,៤ | ១៤,៨ | ៥១,៨ | ២៨,៤ | ១៩,៣ | ៥២,៣ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

# ការចូលរៀននៅអាយុច្រើន

កុមារមានពិការភាពមិនត្រឹមតែមានអត្រាចូលរៀននៅសាលា ទាបជាងកុមារគ្មានពិការភាពប៉ុណ្ណោះទេ ប៉ុន្តែកុមារមានពិការភាពដែលបានចូលរៀនថែមទាំងមានអាយុច្រើនទៀតផង។ ការវិភាគនេះពិចារណាពីក្រុមកុមារអាយុ ៥-៩ ឆ្នាំបែងចែកតាមកម្រិតពិការភាព។ សម្រាប់ពិការភាពទាំង ៤ កម្រិត មានការបែងចែកប្រេកង់នៃកម្រិតថ្នាក់របស់ពួកគេនៅពេលធ្វើជំរឿននេះ។ លទ្ធផលនៃការវិភាគនេះមានបង្ហាញក្នុងរូប ៧.៣។ កុមារគ្មានពិការភាព មានចំនួនតិចក្នុងថ្នាក់ "0" (មុនមត្តេយ្យ/មត្តេយ្យ) ជាងកុមារមានពិការភាព។ ក្នុងចំណោមក្រុមដែលមានអាយុ ៥-៩ ឆ្នាំ ដែលបានចូលរៀន ភាគរយនៃកុមារពិការមិនអាចធ្វើអ្វីបាន ដែលចូលរៀនថ្នាក់មុនមត្តេយ្យ/មត្តេយ្យ មានអត្រាខ្ពស់ជាងកុមារគ្មានពិការភាព រហូតដល់ ២ ដង។ សម្រាប់ថ្នាក់ខ្ពស់ជាងនេះនៅបឋមសិក្សា ការចូលរៀននៅសាលាមានអត្រាខ្ពស់ក្នុងចំណោមកុមារគ្មានពិការភាព។ គួរកត់សម្គាល់ថា ដោយសារតែការវិភាគនេះផ្តោតលើកុមារអាយុ ៥-៩ ឆ្នាំ ភាគច្រើនគឺពួកគេមានវ័យក្មេងពេក មិនអាចចូលរៀនថ្នាក់ទី ៥ និងទី ៦ បាន ហើយនោះជាមូលហេតុដែលសសរនៅខាងស្តាំមានទំហំតូចជាង។ ក្រៅពីនេះ ការវិភាគពីកម្រិតថ្នាក់ខ្ពស់បំផុតក្នុងចំណោមកុមារពិការ និងកុមារមិនពិការ គឺជាការប្រៀបធៀបដ៏គួរឱ្យចាប់អារម្មណ៍មួយ ទោះបីជាសំណួរនេះមិនត្រូវបានដាក់បញ្ចូលក្នុងជំរឿនក៏ដោយ។

រូប ៧.៣ ៖ កុមារអាយុ ៥-៩ ឆ្នាំ បែងចែកតាមកម្រិតថ្នាក់ នៅពេលជំរឿន និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩



## គំរូខុសគ្នា

រីហ្គ្រេសិនឡូជីស្ទិក ត្រូវបានបង្កើតឡើងដើម្បីកំណត់ផលប៉ះពាល់សរុបនៃកម្រិតពិការភាពលើការចូលរៀនរបស់កុមារ និងយុវជន។ ការវិភាគនេះត្រូវបានកម្រិតត្រឹមក្មេងប្រុស និងក្មេងស្រីក្នុងក្រុមអាយុ ៥-២៤ ឆ្នាំ។ អថេរចំណុះក្នុងសមីការរីហ្គ្រេសិននេះគឺការចូលរៀននៅសាលា ៖ 0 ប្រសិនបើកុមារមិនបានចូលរៀន និង ១ ប្រសិនបើកុមារបានចូលរៀន។ អថេរនេះជាអនុគមន៍នៃភេទ ខេត្ត ទីប្រជុំជន/ជនបទ បញ្ចភាគទ្រព្យសម្បត្តិ និងកម្រិតពិការភាព។ ដោយសារការចូលរៀននៅសាលាសម្រាប់ក្រុមអាយុ ៥-២៤ ឆ្នាំ អាស្រ័យលើប្រភេទអាយុរបស់អ្នកតបសម្ភាសន៍ អថេរប្រភេទ "ក្រុមអាយុ" ត្រូវបានយកមកប្រើប្រាស់ដោយបែងចែកជាក្រុមអាយុ ៥ ឆ្នាំចំនួន ៤ ក្រុម ( ៥-៩ ឆ្នាំ, ១០-១៤ ឆ្នាំ, ១៥-១៩ ឆ្នាំ និង ២០-២៤ ឆ្នាំ )។ ផលធៀបឱកាសនៃប្រភេទទាំងអស់ក្នុងរីហ្គ្រេសិននេះ មានបង្ហាញក្នុងរូប ៧.៤។

រូប ៧.៤ ៖ ផលធៀបឱកាសនៃរីហ្គ្រេសិនឡូជីស្ទិកសម្រាប់ការចូលរៀននៅសាលា ក្នុងចំណោមកុមារ/មនុស្សពេញវ័យអាយុ ៥-២៤ ឆ្នាំ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩



លទ្ធផលទាំងនេះបង្ហាញថា បច្ចុប្បន្នគ្មានភាពខុសគ្នាជាក់លាក់រវាងមនុស្សទាំងពីរភេទពាក់ព័ន្ធការចូលរៀននៅសាលាឡើយ។ ឱកាសចូលរៀនសម្រាប់ក្មេងស្រីគឺខ្ពស់ជាងក្មេងប្រុស (ផលធៀបឱកាស ៖ ១,០១២)។ នៅកម្ពុជា មានភាពខុសគ្នាខ្លាំងតាមតំបន់ ពាក់ព័ន្ធនឹងការចូលរៀននៅសាលា ៖ ផលធៀបឱកាសខ្ពស់បំផុតសម្រាប់ក្រុមអាយុ ៥-២៤ ឆ្នាំដែលត្រូវចូលរៀន គឺនៅខេត្តព្រៃវែង ដែលកុមារមានឱកាសខ្ពស់នៃការចូលរៀនក្នុងសាលារហូតដល់ ១,៧៧ ដង បើធៀបនឹងខេត្តបន្ទាយមានជ័យ ដែលជាប្រភេទយោង។

ក្រៅពីនេះ មានភាពខុសគ្នាតិចតួចរវាងទីប្រជុំជន និងជនបទ ដោយមានផលធៀបឱកាស ០,៩៤៨ សម្រាប់អ្នករស់នៅជនបទ។ មានកុមារជាច្រើន (អាយុ ៥-៩ ឆ្នាំ) ដែលមិនទាន់បានចូលរៀន ៖ កុមារក្នុងក្រុមអាយុ ១០-១៤ ឆ្នាំមានឱកាសចូលរៀនច្រើនជាងកុមារក្នុងក្រុមអាយុ ៥-៩ ឆ្នាំរហូតដល់ ៤ ដង។ មានទំនាក់ទំនងគ្នារវាងស្ថានភាពទ្រព្យសម្បត្តិរបស់គ្រួសារ និងការចូលរៀនរបស់កុមារ ៖ នៅពេលគ្រួសារមានស្ថានភាពសេដ្ឋកិច្ចកាន់តែខ្ពស់ កុមារមានឱកាសចូលរៀនកាន់តែខ្ពស់។ សម្រាប់បញ្ចភាគទ្រព្យសម្បត្តិនីមួយៗនៅខាងលើក្រុមទាបបំផុត ឱកាសចូលរៀនកើនឡើងទៅតាមការកើនឡើងនៃស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ។ យុវជនម្នាក់ក្នុងក្រុមអាយុ ៥-២៤ ឆ្នាំ ដែលមកពីគ្រួសារស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុត មានឱកាសចូលរៀនខ្ពស់ជាងយុវជនម្នាក់មកពីបញ្ចភាគសេដ្ឋកិច្ចទាបបំផុត រហូតដល់ ៨០ ភាគរយ។ លទ្ធផលនៃរីហ្គ្រេសិនឡូជីស្ទិក បង្ហាញថា កម្រិតពិការភាពរបស់កុមារម្នាក់ជាកត្តាកំណត់ការមិនចូលរៀននៅសាលា។ ប្រសិនបើ កុមារម្នាក់មានពិការភាពខ្លះ គាត់មានឱកាសបន្តការសិក្សា តិចជាង ៥០ ភាគរយ បើធៀបនឹងកុមារមិនពិការ ។ ពិការភាពខ្លាំង បង្កផលប៉ះពាល់ធំជាងគេ។ កុមារម្នាក់ដែលមានពិការភាពខ្លាំង មានឱកាសចូលរៀនតិចជាងកុមារមិនពិការ ជិត ៥ ដង (មិនគិតកត្តាជះឥទ្ធិពលផ្សេងទៀត)។ គួរឱ្យភ្ញាក់ផ្អើលដែលកុមារពិការមិនអាចធ្វើអ្វីបានហាក់មានឱកាសចូលរៀនប្រសើរជាងកុមារពិការខ្លាំង (ផលធៀបឱកាសគឺ ០,២៦២ ទល់នឹង ០,២១៤)។

គេមិនដឹងច្បាស់ថាតើនិន្នាការនេះបណ្តាលមកពីអ្វីនោះទេ។ ប្រហែលជាហេដ្ឋារចនាសម្ព័ន្ធផ្តោតសំខាន់លើជនពិការមិនអាចធ្វើអ្វីបាន ជាជាងជនមានពិការភាពខ្លាំង ឬក៏ជនមានពិការភាពខ្លាំងមិនអាចទទួលបានការអប់រំជាប់លាប់ ដោយសារគ្មានធនធាន លទ្ធភាព និងបទពិសោធន៍ក្នុងការបំពេញតម្រូវការរបស់សិស្សមានពិការភាព ប៉ុន្តែគ្មានលក្ខណៈសម្បត្តិសម្រាប់ការទទួលបានការអប់រំពិសេស។ នេះជាប្រធានបទដែលគួរមានការស្រាវជ្រាវបន្ថែមនាពេលអនាគត។

មានភស្តុតាងមួយចំនួនដែលបញ្ជាក់ថា ពិការភាពបង្កផលប៉ះពាល់ដល់ការចូលរៀននៅសាលា ហើយផលប៉ះពាល់នេះមានទំហំធំធេងក្នុងប្រទេសកម្ពុជា ជាងនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។ ការសិក្សាមួយដោយ UNESCO (២០១៨) ស្តីពីការអប់រំ និងពិការភាព បានបង្ហាញពីបទពិសោធន៍នៃការអប់រំរបស់ជនមានពិការភាពក្នុង ៤៩ប្រទេសនៅជុំវិញពិភពលោកដែលភាគច្រើនជាប្រទេសកំពុងអភិវឌ្ឍន៍។ទិន្នន័យត្រូវបានប្រមូលពីការអង្កេតផ្សេងៗ ប៉ុន្តែក្នុងចំណោមប្រទេស ៦ ដែលមានការអង្កេតប្រជាសាស្ត្រ និងសុខភាព[17] កម្ពុជាមានភាពខុសគ្នាធំជាងគេរវាងអត្រាក្រៅសាលា[18] សម្រាប់កុមារដល់អាយុចូលរៀនបឋមសិក្សា (៦-១១ ឆ្នាំ) ដែលពិការ និងមិនពិការ។ អត្រាក្រៅសាលាសម្រាប់កុមារមានពិការភាពគឺ ៥៧,៤ ភាគរយ ទល់នឹង ៧,០ ភាគរយ សម្រាប់កុមារមិនពិការ។ អត្រាក្រៅសាលាជាមធ្យមសម្រាប់កុមារពិការក្នុងប្រទេសទាំង ៦ នេះគឺ ៣៤,៥ ភាគរយ (UNESCO, 2018)។

17 - រួមមានកម្ពុជា កូឡុំប៊ី ហ្គាំប៊ី ម៉ាល់ឌីវ អ៊ុយហ្គង់ដា និង យេម៉ែន។
18 –អត្រាក្រៅសាលាសម្រាប់កុមារដល់អាយុចូលរៀនបឋមសិក្សា (៦-១១ ឆ្នាំ) ជាសមាមាត្រកុមារដែលមិនបានចូលរៀននៅសាលាបឋមសិក្សា ឬមធ្យមសិក្សា (UNESCO, 2018, p.12)។

## ៧.២ អក្ខរភាព

អក្ខរភាពជាសមត្ថភាពក្នុងការអាន សរសេរ និងរាប់លេខ និងជាសមត្ថភាពកំណត់រក យល់ បកស្រាយ បង្កើត និងប្រាស្រ័យទាក់ទងក្នុងពិភពលោកដែលកំពុងធ្វើទំនើបកម្ម និងផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងផ្នែកបច្ចេកវិទ្យា និងឌីជីថលភាវូបនីយកម្ម។ "អក្ខរភាពជាលក្ខខណ្ឌតម្រូវដ៏សំខាន់មួយសម្រាប់ការសម្រេចបានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ព្រោះអក្ខរភាពផ្តល់លទ្ធភាពសម្រាប់ការប្រឡូកក្នុងទីផ្សារការងារ សុខភាព និងអាហារូបត្ថម្ភកាន់តែប្រសើរ កាត់បន្ថយភាពក្រីក្រ និងបង្កើតឱកាសកាន់តែច្រើនក្នុងជីវិតរស់នៅទូទៅ" (UNESCO, n.d.b)។

ក្នុងចំណោមប្រជាជនកម្ពុជាដែលមានអាយុ ១៥ ឆ្នាំឡើង មាន ៨៧,៧ ភាគរយ ចេះអក្សរ។ កម្រិតអក្ខរភាពសម្រាប់ប្រុសគឺខ្ពស់ជាងស្រី (៩០,៩ ភាគរយ ទល់នឹង ៨៤,៨ ភាគរយ) (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ ២០២០)។ ធៀបនឹងឆ្នាំ ២០០៩ អត្រាអក្ខរភាពមានការកើនឡើងយ៉ាងខ្លាំង។ ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៨ អត្រាអក្ខរភាពសម្រាប់ប្រជាជនអាយុ ១៥ ឆ្នាំឡើងគឺ ៧៧,៦ ភាគរយ (៨៥,១ ភាគរយសម្រាប់បុរស និង ៧០,៩ ភាគរយសម្រាប់ស្ត្រី) (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ២០០៩)។ សម្រាប់ទាំងពីរភេទ អត្រាអក្ខរភាពសម្រាប់ជនមានពិការភាព មានកម្រិតទាបខ្លាំងជាងជនមិនពិការ។ សម្រាប់ប្រុស ជនមិនពិការចំនួន ៩១,៥ ភាគរយ ចេះអាន និងសរសេរភាសាណាមួយ ហើយបុរសដែលពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានអត្រាអក្ខរភាពប្រហែល ៧៥ភាគរយ។ ស្ថានភាពលំបាករបស់ស្ត្រីពិការរំលេចដោយអត្រាអក្ខរភាពទាប។ ខណៈដែលមានភាពខុសគ្នា ៥ ភាគរយ ក្នុងអត្រាអក្ខរភាពរវាងមនុស្សប្រុស និងមនុស្សស្រីដែលមិនពិការ ភាពខុសគ្នារវាងទាំងពីរភេទសម្រាប់កម្រិតពិការភាពផ្សេងៗ គឺធំជាងនេះ។ ឧ. អត្រាអក្ខរភាពសម្រាប់បុរសមានពិការភាពខ្លាំងគឺ ៧៤,៨ ភាគរយ ចំណែកអត្រាអក្ខរភាពសម្រាប់ស្ត្រីមានពិការភាពខ្លាំងគឺ ៥៤,៤ ភាគរយ (ខុសគ្នាជាង ២០ ភាគរយ)។ ទោះបីមិនសូវមានភាពខុសគ្នារវាងទាំងពីរភេទក្តី ប៉ុន្តែវានៅតែមានទំហំធំធេង (សូមមើលរូប ៧.៥)។

ភាពខុសគ្នានៃអត្រាអក្ខរភាពរវាងកម្រិតពិការភាពផ្សេងៗត្រូវបានកំណត់ដោយគំរូអាយុជាក់លាក់។ រូប ៧.៦.ក-ខ បង្ហាញពីអត្រាអក្ខរភាពតាមអាយុ បែងចែកតាមកម្រិតពិការភាពសម្រាប់ប្រុស និងស្រី។ ក្រាហ្វនេះបង្ហាញនិន្នាការដ៏គួរឱ្យចាប់អារម្មណ៍។ ទីមួយ ក្នុងក្រុមអាយុវ័យចាស់ ភាពខុសគ្នាខ្លាំងសម្រាប់ពិការភាពទាំង ៤ ប្រភេទ បង្ហាញពីអត្រាអក្ខរភាពខ្ពស់សម្រាប់បុរស បើធៀបនឹងស្ត្រី ប៉ុន្តែភាពខុសគ្នាទាំងនេះមិនលេចឡើងសម្រាប់ក្រុមអាយុក្រោម ៣០ ឆ្នាំឡើយ។ និន្នាការនេះមិនមែនស្តែងឡើងតែក្នុងចំណោមជនមិនពិការប៉ុណ្ណោះទេ ប៉ុន្តែក៏លេចឡើងសម្រាប់ពិការភាពគ្រប់កម្រិតផងដែរ។ ទីពីរ ក្នុងក្រុមអាយុផ្សេងៗ អត្រាអក្ខរភាពសម្រាប់ជនពិការ មានកម្រិតទាបសម្រាប់ក្រុមអាយុទាំងអស់ បើធៀបនឹងជនមិនពិការ។ ក្នុងក្រុមអាយុវ័យក្មេង មានភាពខុសគ្នាតិចតួចរវាងកម្រិតពិការភាពផ្សេងៗ។ យើងបានគូសបញ្ជាក់ពីអត្រាអក្ខរភាពខ្ពស់ក្នុងចំណោមស្ត្រីពិការមិនអាចធ្វើអ្វីបាន ធៀបនឹងស្ត្រីមានពិការភាពខ្លាំង។ រូប ៧.៦.ក-ខ បង្ហាញថា ភាពខុសគ្នាទាំងនេះមិនពាក់ព័ន្ធនឹងអាយុឡើយ។ ពោលគឺក្នុងក្រុមអាយុនីមួយៗ អត្រាអក្ខរភាពមានកម្រិតខ្ពស់សម្រាប់ជនពិការមិនអាចធ្វើអ្វីបាន ជាងជនមានពិការភាពខ្លាំង។ គ្មានគំរូច្បាស់លាស់ក្នុងចំណោមបុរសឡើយ។

រូប ៧.៥ ៖ អត្រាអក្ខរភាពបែងចែកតាមកម្រិតពិការភាព និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ដើម្បីពិនិត្យមើលផលប៉ះពាល់រួមនៃកម្រិតពិការភាពលើលទ្ធភាពចេះអក្សររបស់មនុស្សម្នាក់រីហ្គ្រេសិនឡូជីស្ទិកមួយត្រូវបានបង្កើតឡើង ដោយកំណត់ស្ថានភាពអក្ខរភាពសម្រាប់មនុស្សម្នាក់ៗជាអថេរចំណុះ (0=អនក្ខរភាព, ១=អក្ខរភាព)។សំណុំអថេរពន្យល់ស្រដៀងគ្នានេះត្រូវបានប្រើប្រាស់ដូចពីមុន។ផលធៀបឱកាសនៃរីហ្គ្រេសិនឡូជីស្ទិកនេះមានបង្ហាញក្នុងរូប ៧.៧។ មានភាពខុសគ្នាយ៉ាងធំក្នុងអត្រាអក្ខរភាពនៅកម្ពុជា។ បន្ទាប់ពីក្រុមអាយុ ១០-១៤ ឆ្នាំ អត្រាអក្ខរភាពថយចុះយ៉ាងឆាប់រហ័សក្នុងក្រុមអាយុផ្សេងៗ។បន្ទាប់ពីគ្រប់គ្រងកត្តាជះឥទ្ធិពលផ្សេងទៀតអាយុក្លាយជាកត្តាដ៏សំខាន់ដែលកំណត់ឱកាសដែលមនុស្សចេះអាន និងសរសេរ។ គំរូនេះបង្ហាញពីនិន្នាការនៃអត្រាអក្ខរភាពទាបខ្លាំងកាលពីមុន។ ដូចការគូសបញ្ជាក់ខាងដើម ស្ត្រីមាន អត្រាអក្ខរភាពទាបជាងបុរស។ បន្ទាប់ពីគ្រប់គ្រងកត្តាជះឥទ្ធិពលផ្សេងទៀត មានភាពខុសគ្នាកាន់តែខ្លាំង។ គំរូអក្ខរភាពតាមតំបន់ក្នុងប្រទេសកម្ពុជា មានលក្ខណៈចម្រុះ។ ពោលគឺប្រជាជនក្នុងតំបន់មួយចំនួនមានអត្រាអនក្ខរភាពខ្ពស់ជាងប្រជាជនក្នុងតំបន់ផ្សេងទៀត រហូតដល់ ៣ ដង។ ការស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត កាត់បន្ថយឱកាសចេះអាន និងសរសេរ។ មនុស្សម្នាក់ដែលស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុត មានឱកាសចេះអាន និងសរសេរ ខ្ពស់ជាងមនុស្សម្នាក់ដែលស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុតរហូតដល់៤ដង។តាមពិតស្ថានភាពទ្រព្យសម្បត្តិរបស់គ្រួសារហាក់ជះឥទ្ធិពលខ្លាំងជាងកម្រិតពិការភាពរបស់បុគ្គល។ប្រសិនបើមនុស្សម្នាក់មានពិការភាពខ្លះ ឱកាសដែលគាត់ចេះអក្សរគឺទាប(0,៦៣៦)ធៀបនឹងមនុស្សម្នាក់ដែលមិនពិការ។ សម្រាប់ជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ឱកាសចេះអក្សរគឺកាន់តែទាប (0,៤៣៦ ទល់នឹង 0,៣៨៦)។

រូប ៧.៦.ក ៖ ភាគរយមនុស្សប្រុសអាយុ ១៥ ឆ្នាំឡើង ដែលចេះអក្សរ បែងចែកតាមកម្រិតពិការភាព អាយុ និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

រូប ៧.៦.ខ ៖ ភាគរយមនុស្សស្រីអាយុ ១៥ ឆ្នាំឡើង ដែលចេះអក្សរ បែងចែកតាមកម្រិតពិការភាព អាយុ និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

អត្រាអក្ខរភាពទាបក្នុងចំណោមជនមានពិការភាព លេចឡើងនៅជុំវិញពិភពលោក (UNESCO, 2018)។ ជាមធ្យម អត្រាអក្ខរភាពសម្រាប់ប្រជាជនអាយុ ១៥ ឆ្នាំឡើង ដែលមានពិការភាព គឺ ៦១,៩ ភាគរយសម្រាប់បុរស និង ៤៨,៥ ភាគរយសម្រាប់ស្ត្រី។ ក្នុងប្រទេសចំនួន ៤ (ប្រេស៊ីល កូស្តារីកា សាធារណរដ្ឋដូមីនីក និងអ៊ុយរ៉ាហ្គាយ) ដែលចូលរួមក្នុងការសិក្សារបស់ UNESCO (២០១៨) ស្ត្រីពិការមានអត្រាអក្ខរភាពទាបជាងបុរសពិការ។ នៅពេលពិនិត្យមើលភាពខុសគ្នានៃអត្រាអក្ខរភាពរវាងបុរស និងស្ត្រី គេគួរពិចារណាថា ជាទូទៅ មានស្ត្រីវ័យចាស់ដែលពិការច្រើនជាងបុរសវ័យចាស់ដែលពិការ។ ដោយសារមនុស្សចាស់ច្រើនតែមិនចេះអក្សរ ចំណុចនេះអាចជាហេតុផលមួយផ្នែកដែលធ្វើឱ្យមានភាពខុសគ្នាខ្លាំងនៃអត្រាអក្ខរភាពរវាងប្រជាជនទាំងពីរភេទដែលមានពិការភាព។

រូប ៧.៧ ៖ ផលធៀបឱកាសនៃរីហ្គ្រេសិនឡូជីស្ទិក (អក្ខរភាព) សម្រាប់ប្រជាជនអាយុ ១០ ឆ្នាំឡើង ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ៧.៣ កម្រិតអប់រំ

កត្តាដែលពាក់ព័ន្ធបំផុតនឹងកម្រិតអក្ខរភាពគឺកម្រិតអប់រំជារួមរបស់ប្រជាជន។ រូប ៧.៨ បង្ហាញពីស្ថានភាពអប់រំទាំង ៣ (មិនដែលសោះ បច្ចុប្បន្ន និងអតីតកាល) បែងចែកតាមកម្រិតពិការភាព និងភេទសម្រាប់ប្រជាជនទាំងអស់។ ក្រាហ្វនេះបង្ហាញថា សម្រាប់មនុស្សទាំងពីរភេទ ជនមានពិការភាពមិនសូវបានចូលរៀននៅសាលា និងមានប្រូបាប៊ីលីតេខ្ពស់នៃការមិនដែលចូលសាលា។ គំរូមិនសូវស៊ីសង្វាក់គ្នារវាងពិការភាពទាំង ៤ ប្រភេទ លេចឡើងក្នុងចំណោមអ្នកដែលបានបញ្ចប់ការអប់រំ។

រូប ៧.៨ ៖ ស្ថានភាពនៃការអប់រំ បែងចែកតាមភេទ និងពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

ទោះជាយ៉ាងណា គេមិនគួរបកស្រាយបំភ្លើសនូវលទ្ធផលក្នុងក្រាហ្វខាងលើឡើយ។ ទាំងកម្រិតពិការភាព និងកម្រិតអប់រំ សុទ្ធតែផ្អែកតាមអាយុ។ កន្លងមក ប្រូបាប៊ីលីតេនៃពិការភាពមានកម្រិតខ្ពស់ក្នុងចំណោមក្រុមអាយុវ័យចាស់។ ដោយសារតែស្ថានភាពនៃការផ្ដល់ការសិក្សាពីមុន ខុសស្រឡះពីពេលបច្ចុប្បន្ន កម្រិតអប់រំរងឥទ្ធិពលពីអាយុរបស់មនុស្ស។

សម្រាប់អ្នកដែលរៀនចប់ ការសំខាន់គឺត្រូវវាស់វែងផលប៉ះពាល់លើកម្រិតអប់រំ និងស្ថានភាពពិការភាពរបស់បុគ្គល។ ក្នុងជំរឿននេះ អ្នកតបសម្ភាសន៍ត្រូវបានសាកសួរអំពីកម្រិតថ្នាក់ខ្ពស់បំផុតរបស់ពួកគេ។ ក្រៅពីនេះ មានការសាកសួរអំពីមុខវិជ្ជាសិក្សាសម្រាប់អ្នកដែលកំពុងសិក្សាបច្ចេកទេស/វិជ្ជាជីវៈ ឬឧត្តមសិក្សា។ ការវិភាគខាងក្រោមផ្ដោតលើអ្នកដែលបញ្ចប់ការសិក្សា (ថ្នាក់ទី ១-៦ និងថ្នាក់ទី ៧-១២) ប៉ុន្តែមិនរួមបញ្ចូលអ្នកដែលកំពុងសិក្សា ឬអ្នកមិនដែលចូលសាលានោះទេ។

រូប ៧.៩ រៀបរាប់ពីភាគរយប្រជាជនអាយុ ១៥ ឆ្នាំ ដែលឈប់រៀននៅថ្នាក់ទី ១-៦ ឬថ្នាក់ទី ៧-១២ បែងចែកតាមភេទ និងកម្រិតពិការភាព។ ក្រាហ្វនេះបង្ហាញយ៉ាងច្បាស់ថា ភាគរយប្រជាជនដែលឈប់រៀននៅថ្នាក់ទី ១-៦ មានកម្រិតខ្ពស់សម្រាប់ជនមានពិការភាព ជាងជនមិនពិការ (មិនគិតភេទ)។ ក្នុងចំណោមប្រជាជនមិនពិការដែលមានអាយុ ១៥ ឆ្នាំឡើង និងបានបញ្ចប់ការអប់រំក្នុងទម្រង់មួយចំនួន មាន ៤៧,១ ភាគរយ ឈប់រៀននៅថ្នាក់ទី ១-៦។ ក្នុងចំណោមប្រជាជនមានពិការភាពខ្លះ មាន ៦០,៩ ភាគរយ ឈប់រៀននៅថ្នាក់ទី ១-៦។ អត្រាឈប់រៀននៅថ្នាក់ទី ១-៦ គឺ ៦៦,៨ ភាគរយសម្រាប់ប្រជាជនមានពិការភាពខ្លាំង និង ៦០,៣ ភាគរយសម្រាប់ប្រជាជនពិការមិនអាចធ្វើអ្វីបាន។ និន្នាការដូចគ្នាលេចឡើងក្នុងចំណោមប្រជាជនទាំងពីរភេទ។ សម្រាប់អ្នកឈប់រៀននៅថ្នាក់ទី ៧-១២ ឆ្នាំ គេអាចមើលឃើញនិន្នាការផ្ទុយពីនេះ ៖ មានជនគ្មានពិការភាព (៤៤,៨ ភាគរយ) ច្រើនជាងជនមានពិការភាពខ្លាំង (២៩,៩ ភាគរយ) ដែលឈប់រៀននៅកម្រិតថ្នាក់នេះ។ ចំណុចដ៏គួរឱ្យចាប់អារម្មណ៍គឺ សម្រាប់កម្រិតអប់រំរបស់ជនពិការដែលឈប់រៀននៅថ្នាក់ទី ៧-១២ មានស្ត្រីច្រើនជាងបុរសដែលបញ្ចប់កម្រិតថ្នាក់នេះ។ សម្រាប់ប្រភេទពិការភាពនីមួយៗ (ពិការខ្លះ ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន) កម្រិតអប់រំសម្រាប់ស្ត្រីពិការខ្ពស់ជាងបុរស ៥ ភាគរយ។ គួរកត់សម្គាល់ថា គេមិនគួរបកស្រាយបំភ្លើសនូវលទ្ធផលក្នុងការវិភាគនេះឡើយ ព្រោះកុមារដែលមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ប្រហែលជាបានចុះឈ្មោះចូលរៀននៅសាលា ដែលមានទម្រង់ជាមណ្ឌលថែទាំ ជាជាងសាលារៀនធម្មតា។

ការវិភាគស្រដៀងគ្នាត្រូវបានធ្វើឡើងសម្រាប់អ្នកដែលបានបន្តការអប់រំមួយចំនួន និងសិក្សានៅក្រៅ ឬហួសពីប្រព័ន្ធថ្នាក់ទី ១-១២។ កម្រិតថ្នាក់ទាំងនេះចែកជា ២ ក្រុម ៖ អ្នកដែលបញ្ចប់ ក) អនុវិទ្យាល័យ វិទ្យាល័យ ការសិក្សាវិជ្ជាជីវៈមុនមធ្យមសិក្សា ឬការសិក្សាវិជ្ជាជីវៈក្រោយមធ្យមសិក្សា និង ខ) អ្នកដែលបញ្ចប់កម្រិតសាកលវិទ្យាល័យ (បរិញ្ញាបត្រ អនុបណ្ឌិត ឬបណ្ឌិត)។ រូប ៧.១០ បង្ហាញថា ប្រជាជនចំនួន ៣,៧ ភាគរយ បានបញ្ចប់កម្រិតអប់រំណាមួយក្នុងក្រុម ក។ កម្រិតអប់រំសម្រាប់បុរស និងស្ត្រី មានអត្រាខ្ពស់សម្រាប់ជនមិនពិការ ជាងប្រជាជនដែលស្ថិតក្នុងពិការភាពទាំង ៣ កម្រិត។ និន្នាការដូចគ្នាលេចឡើងក្នុងក្រុមក្រុមឧត្តមសិក្សា។ ភាគរយប្រជាជនដែលបញ្ចប់ឧត្តមសិក្សា ក្នុងចំណោមក្រុមប្រជាជនដែលយ៉ាងហោចណាស់មានការអប់រំមួយចំនួន មានអត្រាខ្ពស់យ៉ាងតិច ២ ដងជាងក្នុងចំណោមអ្នកមានពិការភាពណាមួយក្នុងចំណោមពិការភាពទាំង ៣ កម្រិត។

យោងតាម ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ប្រជាជនចំនួន ៧.១៣៨ នាក់ដែលពិការខ្លះ ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន បញ្ចប់ថ្នាក់បរិញ្ញាបត្រ ប្រជាជនចំនួន ១.៧៣០ ដែលពិការខ្លាំង បញ្ចប់ថ្នាក់អនុបណ្ឌិត និងប្រជាជនចំនួន ៦០៣ នាក់ដែលពិការមិនអាចធ្វើអ្វីបាន បញ្ចប់ថ្នាក់បណ្ឌិត។ ខណៈ ដែលប្រជាជនមិនពិការចំនួន ៤,៣ ភាគរយ ដែលបន្តការអប់រំប្រភេទណាមួយ មានកម្រិតអប់រំឧត្តមសិក្សា អត្រានេះគឺត្រឹមតែ ១,៦ ភាគរយប៉ុណ្ណោះសម្រាប់ជនមានពិការភាពខ្លះ, ១,០ ភាគរយសម្រាប់ជនពិការខ្លាំង និង ២,២ ភាគរយសម្រាប់ជនពិការមិនអាចធ្វើអ្វីបាន។ សម្រាប់ប្រជាជនទាំងពីរភេទដែលមានពិការភាព អត្រាសម្រាប់ស្ត្រីគឺខ្ពស់ជាងបុរស។ សម្រាប់កម្រិតពិការភាពនីមួយៗ ភាគរយស្ត្រីដែលបញ្ចប់ឧត្តមសិក្សាគឺខ្ពស់បន្តិចជាងបុរស។

រូប ៧.៩ ៖ ភាគរយប្រជាជនអាយុ ១៥ ឆ្នាំឡើង ដែលយ៉ាងហោចណាស់មានកម្រិតអប់រំខ្លះ ដែលបានឈប់រៀននៅថ្នាក់ទី ១-៦ ឬថ្នាក់ទី ៧-១២ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

រូប ៧.១០ ៖ ភាគរយប្រជាជនអាយុ ១៥ ឆ្នាំឡើង ដែលបានបញ្ចប់ ក) អនុវិទ្យាល័យ វិទ្យាល័យ ការសិក្សាវិជ្ជាជីវៈមុនមធ្យមសិក្សា ឬការសិក្សាវិជ្ជាជីវៈក្រោយមធ្យមសិក្សា និង ខ) កម្រិតសាកលវិទ្យាល័យ (បរិញ្ញាបត្រ អនុបណ្ឌិត ឬបណ្ឌិត) បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ក៏សួរសំណួរស្ដីពីមុខវិជ្ជាសិក្សាសម្រាប់អ្នកដែលបញ្ចប់ការសិក្សាបច្ចេកទេស/វិជ្ជាជីវៈ (មុនមធ្យមសិក្សា និងក្រោយមធ្យមសិក្សា) បរិញ្ញាបត្រ អនុបណ្ឌិត បណ្ឌិត ឬអ្នកដែលបញ្ចប់វិញ្ញាបនបត្រជាន់ខ្ពស់ផ្សេងទៀតផងដែរ។ ដូច្នេះ គេអាចប្រៀបធៀបមុខវិជ្ជាសិក្សាក្នុងចំណោមជនមានកម្រិតពិការភាពផ្សេងៗ។ គេត្រូវដឹងថា ចំនួនជាក់លាក់នៃជនមានពិការភាពដែលបញ្ចប់ការសិក្សាបច្ចេកទេស/វិជ្ជាជីវៈ ឬឧត្តមសិក្សា មានតិចតួច។ នៅទូទាំងប្រទេសកម្ពុជា មុខវិជ្ជាសិក្សាត្រូវបានគូសបញ្ជាក់តែសម្រាប់ប្រជាជន ៥.៦៦៨ នាក់ដែលពិការខ្លះ, ប្រជាជន ៧៦៩ នាក់ដែលពិការខ្លាំង និងប្រជាជន ៥២២ នាក់ដែលពិការមិនអាចធ្វើអ្វីបាន។ ដូចការគូសបញ្ជាក់ពីមុនមក មានភស្តុតាងបង្ហាញពីការរាយការណ៍ប្រែប្រួលពិការភាពក្នុងជំរឿននេះ ទាបជាងចំនួនជាក់ស្ដែង។ ដូច្នេះ មានប្រជាជនបន្ថែមទៀតដែលមានការអប់រំឯកទេស ឬខ្ពស់ជាងនេះ។ តារាង ៧.២ បង្ហាញពីមុខវិជ្ជាសិក្សាចំនួន ១០ ដែលពេញនិយមជាងគេសម្រាប់ប្រជាជនអាយុ ១៥ ឆ្នាំ បែងចែកតាមកម្រិតពិការភាព។

គណនេយ្យហាក់ជាមុខវិជ្ជាសិក្សាដែលពេញនិយមជាងគេទាំងសម្រាប់ជនពិការ និងជនមិនពិការ។ មុខវិជ្ជាសិក្សាដ៏ពេញនិយមផ្សេងទៀតរួមមានធនាគារ និងហិរញ្ញវត្ថុ វេជ្ជសាស្ត្រ គ្រប់គ្រង គ្រប់គ្រងធនធានមនុស្ស និងច្បាប់។ ជាទូទៅ តារាង ៧.២ បង្ហាញថា គ្មានភាពខុសគ្នាខ្លាំងនៃជម្រើសមុខវិជ្ជាសិក្សារវាងកម្រិតពិការភាពផ្សេងៗឡើយ។ ឧ. តាមការប្រៀបធៀបជម្រើសមុខវិជ្ជាសិក្សាសម្រាប់ជនមិនពិការ និងជនពិការមិនអាចធ្វើអ្វីបាន ក្នុងចំណោមមុខវិជ្ជាសិក្សាដ៏ពេញនិយមទាំង ១០ មុខ មុខវិជ្ជាសិក្សាចំនួន ៨ មានកម្រិតដូចគ្នារវាងស្ថានភាពពិការភាពទាំងពីរ។

**តារាង ៧.២ ៖ មុខវិជ្ជាសិក្សាដ៏ពេញនិយមទាំង ១០ សម្រាប់ប្រជាជនអាយុ ១៥ ឆ្នាំឡើង បែងចែកតាមស្ថានភាពពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩**

| មិនពិការ | | ពិការខ្លះ | |
|---|---|---|---|
| គណនេយ្យ | ១៥,៨ | គណនេយ្យ | ១២,០ |
| ធនាគារ និងហិរញ្ញវត្ថុ | ៧,៩ | វេជ្ជសាស្ត្រ ( ទូទៅ និងមុខវិជ្ជាពាក់ព័ន្ធទាំងអស់ ) | ៧,២ |
| គ្រប់គ្រងធនធានមនុស្ស | ៥,៨ | ច្បាប់ | ៦,៧ |
| ច្បាប់ | ៥,៨ | គ្រប់គ្រងធនធានមនុស្ស | ៦,៥ |
| វេជ្ជសាស្ត្រ ( ទូទៅ និងមុខវិជ្ជាពាក់ព័ន្ធទាំងអស់ ) | ៥,៦ | ធនាគារ និងហិរញ្ញវត្ថុ | ៥,០ |
| គ្រប់គ្រង | ៥,១ | គ្រប់គ្រង | ៤,១ |
| ព័ត៌មានវិទ្យា | ៣,៦ | គរុកោសល្យ | ៣,២ |
| គ្រប់គ្រងពាណិជ្ជកម្ម | ៣,២ | គរុកោសល្យសង្គម | ២,៨ |
| ទីផ្សារ | ៣,២ | រដ្ឋបាលសាធារណៈ | ២,៤ |
| អក្សរសាស្ត្រអង់គ្លេស | ៣,១ | អក្សរសាស្ត្រអង់គ្លេស | ២,៣ |
| **ពិការខ្លាំង** | | **ពិការមិនអាចធ្វើអ្វីបាន** | |
| គណនេយ្យ | ៩,៦ | ធនាគារ និងហិរញ្ញវត្ថុ | ១៣,៤ |
| គ្រប់គ្រងធនធានមនុស្ស | ៨,៣ | គណនេយ្យ | ៧,៥ |
| សវនកម្ម | ៦,៦ | វេជ្ជសាស្ត្រ ( ទូទៅ និងមុខវិជ្ជាពាក់ព័ន្ធទាំងអស់ ) | ៥,០ |
| វេជ្ជសាស្ត្រ ( ទូទៅ និងមុខវិជ្ជាពាក់ព័ន្ធទាំងអស់ ) | ៦,៥ | សំណង់ស៊ីវិល | ៤,៤ |
| ច្បាប់ | ៤,៧ | គ្រប់គ្រង | ៤,៤ |
| ធនាគារ និងហិរញ្ញវត្ថុ | ៤,៤ | គ្រប់គ្រងធនធានមនុស្ស | ៣,៨ |
| បច្ចេកទេសវិជ្ជាជីវៈ | ៣,៥ | គ្រប់គ្រងពាណិជ្ជកម្ម | ៣,៤ |
| គរុកោសល្យ | ៣,៤ | ច្បាប់ | ២,៩ |
| អប់រំ | ៣,១ | ព័ត៌មានវិទ្យា | ២,៧ |
| រដ្ឋបាលសាធារណៈ | ៣,១ | អក្សរសាស្ត្រខ្មែរ | ២,៧ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

# ជំពូក ៨៖ សកម្មភាពសេដ្ឋកិច្ច និងពិការភាព

ផ្នែកដ៏សំខាន់មួយនៃសេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់មនុស្សពេញវ័យ គឺការមានការងារធ្វើ និងការងារសមរម្យ។ ការងារសមរម្យបង្កើតភាពអង់អាចផ្នែកសេដ្ឋកិច្ច ដែលអាចជួយដល់ការរស់នៅដោយឯករាជ្យ និងជាវិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការលុបបំបាត់វដ្តនៃភាពក្រីក្រ និងការលំបាក រួមទាំងក្នុងចំណោមជនមានពិការភាព (UNDESA, 2018)។ ជនមានពិការភាពប្រឈមនឹងការលំបាកក្នុងឱកាសសេដ្ឋកិច្ចដោយសារស្ថានភាព ពិការរបស់ខ្លួន ក៏ដូចជាបទដ្ឋានវប្បធម៌ផ្អែកតាមយេនឌ័រ ការមាក់ងាយ និងបទដ្ឋានសង្គមដែលបង្កជាការយល់ខុសចំពោះសមត្ថភាពរបស់ពួកគេ និងមិនទទួលស្គាល់សក្តានុពលរបស់ជនមានពិការភាព (UNDESA, 2018; Gartrell, Baesel & Becker, 2017)។ ជាធម្មតា ជនមានពិការភាពសម្រេចបានកម្រិតអប់រំទាប និងច្រើនតែគ្មានការងារធ្វើ។ ប្រសិនបើមានការងារធ្វើ ជារឿយៗគឺពួកគេទទួលបានប្រាក់ឈ្នួលទាប។ ចំណុចនេះបង្កផលប៉ះពាល់ដោយផ្ទាល់លើជីវភាពរស់នៅ និងគុណភាពជីវិតរបស់ពួកគេ ដូចជា ការរស់នៅក្នុងភាពក្រីក្រ ការផ្តាច់ខ្លួនពីសង្គម និងភាពទ្រុឌទ្រោមនៃសុខភាពផ្លូវចិត្ត (Gartrell, 2010)។

ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានប្រកាសឱ្យអនុវត្តក្រោមអនុក្រឹត្យឆ្នាំ ២០១០ មានគោលបំណងការពារស្ថានភាពការងាររបស់ជនមានពិការភាពក្នុងប្រទេសកម្ពុជា។ ច្បាប់នេះចែងថា ជនមានពិការភាពមានសិទ្ធិស្មើភាពក្នុងការទទួលបានការងារសមរម្យ។ ក្នុងនោះមានការកំណត់កូតាក្នុងការជួលនិយោជិតដែលមានពិការភាព។ Palmer et al. (2017) បង្ហាញថា ទោះបីនេះជាចេតនាល្អក្តី ក៏អត្រាមានការងារធ្វើក្នុងចំណោមជនមានពិការភាព គឺត្រឹមតែ ៩ ភាគរយប៉ុណ្ណោះក្នុងរយៈពេល ៤ ឆ្នាំក្រោយការអនុម័តច្បាប់នេះ។ អត្រាបាត់បង់ការងារក្នុងចំណោមស្ត្រីមានពិការភាព គឺខ្ពស់ជាងបុរសមានពិការភាព។ អ្នកនិពន្ធលើកឡើងថា ដោយសារតែនិយោជកជាអ្នកទទួលខុសត្រូវលើការផ្តល់កន្លែងការងារសមរម្យដល់ជនមានពិការភាព និយោជកចង់បញ្ចៀសការចំណាយទាំងនេះ តាមរយៈការមិនជួលជនមានពិការភាពឱ្យធ្វើការ (Palmer et al., 2017)។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បានផ្តល់ឱកាសថ្មីមួយក្នុងការវាយតម្លៃស្ថានភាពរបស់ជនមានពិការភាពក្នុងទីផ្សារការងារ។ ជំពូកនេះនឹងផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីស្ថានភាពរបស់ជនមានពិការភាពក្នុងទីផ្សារការងារ។

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ មានសំណួរ ៥ ស្តីពីសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជនអាយុ ៥ ឆ្នាំឡើង ដែលគ្របដណ្តប់លើសកម្មភាពសេដ្ឋកិច្ចសំខាន់ ប្រភេទការងារ ស្ថានភាពការងារ ប្រភេទសកម្មភាពក្នុងវិស័យឧស្សាហកម្ម និងវិស័យការងារ។ ទស្សនាទាន និងនិយមន័យដែលប្រើប្រាស់ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ដើម្បីវាស់វែងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជន ខុសស្រឡះពីគោលការណ៍ និងអនុសាសន៍ជំរឿនរបស់អង្គការសហប្រជាជាតិ។ ដូច្នេះ គេមិនអាចប្រើប្រាស់លទ្ធផលពីជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ដើម្បីប្រៀបធៀបស្ថានភាពក្នុងប្រទេសកម្ពុជា ទៅនឹងស្ថានភាពក្នុងប្រទេសផ្សេងទៀតបានឡើយ។ ជំនួសឱ្យការវាស់វែងសកម្មភាពសេដ្ឋកិច្ចនៅពេលធ្វើជំរឿន មានការសួរសំណួរស្តីពីសកម្មភាពសេដ្ឋកិច្ចទូទៅក្នុងរយៈពេល ១២ ខែមុនជំរឿន។ ប្រសិនបើមនុស្សម្នាក់មានការងារធ្វើរយៈពេល ៦ ខែ ក្នុងអំឡុងពេលនេះ គាត់ត្រូវបានចាត់ទុកថាមានការងារធ្វើ។ គោលការណ៍ និងអនុសាសន៍ជំរឿនរបស់អង្គការសហប្រជាជាតិកំណត់ថា គួរបែងចែកប្រជាជនជាប្រភេទក្នុង រយៈពេលយោងខ្លី (ភាគច្រើនគឺ ១ សប្តាហ៍) ដោយផ្អែក

តាមស្ថានភាពកម្លាំងពលកម្មរបស់ពួកគេ។ ភាពខុសគ្នាដ៏សំខាន់មួយទៀតគឺរបៀបពិចារណាពីភាពគ្មានការងារធ្វើ និងភាពអសកម្មសេដ្ឋកិច្ចក្នុងជំរឿននេះ។ ជាទូទៅ ភាពគ្មានការងារធ្វើត្រូវបានវាស់វែងទៅតាមសំណួរដែលពាក់ព័ន្ធនឹងថាតើមនុស្សម្នាក់កំពុងធ្វើការ ឬទេ កំពុងស្វែងរកការងារ និងអាចជួលឱ្យធ្វើការបាន។ ចំណុចនេះមិនត្រូវបានអនុវត្តក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ឡើយ។ ក្នុងជំរឿននេះ មានការសួរសំណួរមួយស្តីពីសកម្មភាពសំខាន់របស់ប្រជាជននៅអំឡុងឆ្នាំមុនការអង្កេត។ ប្រអប់ ៨.១ បង្ហាញពីប្រភេទចម្លើយសម្រាប់សំណួរនេះ។ មានន័យថា អ្នកតបសម្ភាសន៍ជាអ្នកសម្រេចថាតើពួកគេគ្មានការងារធ្វើ/អសកម្មសេដ្ឋកិច្ចក្នុងរយៈពេលយោង ១២ ខែ ឬយ៉ាងណា។ ក្រៅពីនេះ មនុស្សម្នាក់ត្រូវបានចាត់ទុកថាគ្មានការងារធ្វើ/អសកម្មសេដ្ឋកិច្ច ប្រសិនបើគាត់គ្មានការងារធ្វើចាប់ពីរយៈពេល ៦ ខែ (ឬ ១៨៣ ថ្ងៃ) ឡើងទៅក្នុងរយៈពេល ១២ ខែមុនជំរឿន។ ដោយសារតែនិយមន័យខុសគ្នានេះហើយទើបអត្រាគ្មានការងារធ្វើជារួមដែលវាស់វែងដោយជំរឿននេះ មានកម្រិតទាបត្រឹម ១,៤ ភាគរយ (១,៣ ភាគរយសម្រាប់បុរស និង ១,៥ ភាគរយសម្រាប់ស្ត្រី)។

### ប្រអប់ ៨.១ ៖ ប្រភេទចម្លើយសម្រាប់សំណួរស្តីពីសកម្មភាពសេដ្ឋកិច្ចទូទៅនៅអំឡុងឆ្នាំមុនជំរឿន

លេខកូដសម្រាប់កូឡោន ១៨

សកម្មភាពសំខាន់កាលពីឆ្នាំមុន

១.មានការងារធ្វើ (បំពេញក្នុងកូឡោន ១៩-២០)

២.គ្មានការងារធ្វើ (ធ្លាប់មានការងារធ្វើពីមុនមក) (បំពេញក្នុងកូឡោន ១៩-២២ សម្រាប់ការងារចុងក្រោយ)

៣.គ្មានការងារធ្វើ (មិនធ្លាប់មានការងារធ្វើ)

៤.មេផ្ទះ

៥.សិស្ស និស្សិត

៦.អ្នកក្នុងបន្ទុក

៧.អ្នកទទួលថ្លៃជួល អ្នកចូលនិវត្តន៍ ឬអ្នកទទួលប្រាក់ចំណូលផ្សេងទៀត

៨.ផ្សេងៗ

(សម្រាប់លេខកូដ ៣-៨ សូមដាក់សញ្ញា (-) ក្នុងកូឡោន ១៩-២២)។

រូប ៨.១ និងតារាង ៨.១ បង្ហាញពីភាពខុសគ្នាខ្លាំងនៃស្ថានភាពសកម្មភាពសំខាន់របស់ប្រជាជនដែលពិការខ្លះ ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន និងប្រជាជនមិនពិការ។ ភេទមិនត្រូវបានដាក់បញ្ចូលក្នុងការវិភាគនៅដំណាក់កាលនេះឡើយ ព្រោះទិដ្ឋភាពយេនឌ័រនឹងត្រូវបានលើកមកពិភាក្សាយ៉ាងទូលំទូលាយក្នុងជំពូកទី១២ (ពិការភាព និងយេនឌ័រ)។

សូចនាករដំបូង និងសំខាន់បំផុតដែលត្រូវពិចារណាពាក់ព័ន្ធនឹងស្ថានភាពរបស់ជនមានពិការភាពក្នុងទីផ្សារការងារ គឺផលធៀបការងារ-ប្រជាជន (EPR)។ ផលធៀបនេះត្រូវបានគណនាដោយចែកចំនួនប្រជាជនមានការងារធ្វើនឹងចំនួនប្រជាជនសរុបដែលស្ថិតក្នុងក្រុមអាយុសកម្ម (១៥-៦៤ ឆ្នាំ)។

គួរកត់សម្គាល់ថា ការគណនានេះផ្អែកតាមស្ថានភាពការងារទូទៅក្នុងរយៈពេល ១២ ខែមុនជំរឿន។ ផលធៀបការងារ-ប្រជាជន គឺ ៨០ ភាគរយសម្រាប់ប្រជាជនមិនពិការ។ តួលេខនេះថយចុះទាបជាងពាក់កណ្តាលសម្រាប់ជនពិការមិនអាចធ្វើអ្វីបាន។ រូប ៨.១ បង្ហាញច្បាស់ថាតើស្ថានភាពរបស់ជនមានពិការភាពខ្លះមានភាពស្រដៀងគ្នាខ្លាំងនឹងស្ថានភាពរបស់ជនមិនពិការ ជាងជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ដោយរបៀបណា។ ក្នុងអត្រា ៧៧,៥ ភាគរយ ផលធៀបការងារ-ប្រជាជនសម្រាប់ជនមានពិការភាពខ្លះ តិចជាងជនមិនពិការត្រឹមតែ ៣,២ ភាគរយប៉ុណ្ណោះ។ ផលធៀបការងារ-ប្រជាជនក្នុងចំណោមប្រជាជនមានពិការភាពខ្លាំង ទាបជាងប្រជាជនមិនពិការ ជាង ២០ ភាគរយ ហើយផលធៀបការងារ-ប្រជាជនក្នុងចំណោមប្រជាជនពិការមិនអាចធ្វើអ្វីបាន ទាបជាងប្រជាជនមិនពិការជាង ៣០ ភាគរយ។

ភាពខុសគ្នាក្នុងចំណោមប្រជាជនគ្មានការងារធ្វើក្នុងរយៈពេល ១២ ខែមុនជំរឿន បង្ហាញយ៉ាងច្បាស់ពីស្ថានភាពចាញ់ប្រៀបរបស់ជនមានពិការភាពក្នុងទីផ្សារការងារនៅកម្ពុជា។ ខណៈដែលអត្រាអត់ការងារធ្វើក្នុងចំណោមប្រជាជនអាយុ ១៥-៦៤ ឆ្នាំដែលមិនពិការ គឺ ០,៣ ភាគរយ ក្នុងរយៈពេលលើស ៦ ខែមុនជំរឿន អត្រានេះគឺ ១,២ ភាគរយក្នុងចំណោមប្រជាជនមានពិការភាពខ្លះ, ៦,០ ភាគរយក្នុងចំណោមប្រជាជនមានពិការភាពខ្លាំង និង ១០,៣ ភាគរយក្នុងចំណោមប្រជាជនពិការមិនអាចធ្វើអ្វីបាន។ គួរកត់សម្គាល់ថា តួលេខទាំងនេះមិនមែនជាអត្រាគ្មានការងារធ្វើនោះទេ (ដែលត្រូវបានគណនាជាភាគរយនៃប្រជាជនគ្មានការងារធ្វើ ចែកនឹងចំនួនសរុបនៃប្រជាជនមាន និងគ្មានការងារធ្វើ)។ ផ្ទុយទៅវិញ វាជាភាគរយនៃប្រជាជនដែលគ្មានការងារធ្វើ ធៀបនឹងភាគរយនៃប្រជាជនសរុបក្នុងអនុក្រុមពិការភាពជាក់លាក់។ ខណៈដែលប្រជាជនអាយុ ១៥-៦៤ ឆ្នាំដែលពិការខ្លះ ពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានចំនួន ៣,៧ ភាគរយនៃចំនួនប្រជាជនសរុបក្នុងក្រុមអាយុនោះ ចំនួននេះគឺ ២៥,២ ភាគរយនៃចំនួនប្រជាជនសរុបដែលគ្មានការងារធ្វើលើស ៦ ខែក្នុងរយៈពេល ១២ ខែមុនជំរឿន។ ទំនាក់ទំនងនេះកាន់តែជ្រាលជ្រៅប្រសិនបើយើងពិនិត្យមើលប្រជាជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបនា។ ក្នុងជំរឿននេះប្រជាជនអាយុ ១៥-៦៤ ឆ្នាំតែ ០,៨ ភាគរយ ប៉ុណ្ណោះដែលបញ្ជាក់ថា ពួកគេពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ប៉ុន្តែបើគិតជាក្រុមគឺស្មើនឹង ១៥,៣ ភាគរយនៃចំនួនប្រជាជនសរុបដែលគ្មានការងារធ្វើ។

ក្នុងភាគរយនៃប្រជាជនដែលមាន និងគ្មានការងារធ្វើនៃចំនួនប្រជាជនសរុប ស្ថានភាពសកម្មភាពផ្សេងទៀតបង្ហាញពីគំរូផ្សេងៗដោយផ្អែកតាមកម្រិតពិការភាព។ ខណៈដែលប្រជាជនអាយុ ១៥-៦៤ ចំនួន ១,៥ ភាគរយគូសបញ្ជាក់ថា ពួកគេរស់នៅក្នុងបន្ទុកគ្រួសារ ចំនួនអ្នករស់នៅក្នុងបន្ទុកគ្រួសារគឺ ១៤,៣ ភាគរយសម្រាប់ជនមានពិការភាពខ្លាំង និង ១៨,៧ ភាគរយសម្រាប់ជនពិការមិនអាចធ្វើអ្វីបាន។ ភាគរយប្រជាជនដែលជាសិស្សនិស្សិតបង្ហាញពីគំរូដ៏គួរឱ្យចាប់អារម្មណ៍។ ក្រុមប្រជាជនមិនពិការដែលបញ្ជាក់ថា ពួកគេជាសិស្សនិស្សិតមានចំនួន ១០,៣

ភាគរយនៃប្រជាជនសរុបដែលមានអាយុ ១៥-៦៤ ឆ្នាំ។ អត្រាសិស្សនិស្សិតគឺ១,៩ ភាគរយក្នុងចំណោមប្រជាជនមានពិការភាពខ្លះ និងត្រឹមតែ ២,៤ ភាគរយ ក្នុងចំណោមប្រជាជនមានពិការភាពខ្លាំង។ ធៀបនឹងក្រុមទាំងពីរនេះ ជនពិការមិនអាចធ្វើអ្វីបានដែលជាសិស្សនិស្សិត មានចំនួន ៦,៤ ភាគរយ។ គេមិនច្បាស់ថាតើនេះជានិន្នាការពិតប្រាកដ ឬបណ្ដាលមកពីភាពមិនប្រក្រតីក្នុងទិន្នន័យ។

និន្នាការការងារស្រដៀងគ្នាក្នុងចំណោមជនមានពិការភាព លេចឡើងនៅជុំវិញពិភពលោក។ UNDESA (2018) រាយការណ៍ថា "ក្នុងតំបន់ភូមិសាស្ត្រចំនួន ៨ ផលធៀបការងារ-ប្រជាជន (EPR) ជាមធ្យមសម្រាប់ជនមានពិការភាពដែលមានអាយុ ១៥ ឆ្នាំឡើងគឺ ៣៦ ភាគរយ ចំណែកផលធៀបការងារ-ប្រជាជនសម្រាប់ជនមិនពិការគឺ ៦០ ភាគរយ (ទំ. ១៥២)"។ ក្រៅពីនេះ ជនមានពិការភាពច្រើនតែត្រូវបានជួលឱ្យធ្វើការក្នុងវិស័យក្រៅផ្លូវការ ឬធ្វើអាជីវកម្មផ្ទាល់ខ្លួន ជាហេតុធ្វើឱ្យការងាររបស់ពួកគេមិនសូវជាប់លាប់ (UNDESA, 2018)។

រូប ៨.១ ៖ ស្ថានភាពសកម្មភាពសំខាន់ បែងចែកតាមកម្រិតពិការភាពរបស់ប្រជាជនអាយុ ១៥-៦៤ ឆ្នាំ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## តារាង ៨ ៖ ស្ថានភាពសកម្មភាពសំខាន់ បែងចែកតាមកម្រិតពិការភាពរបស់ប្រជាជនអាយុ ១៥-៦៤ ឆ្នាំ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | មានការងារធ្វើ | គ្មានការងារធ្វើ | មិនដែលធ្វើការសោះ | មេផ្ទះ | សិស្សនិស្សិត | អ្នកក្នុងបន្ទុក | អ្នកទទួលប្រាក់ចំណូល | ផ្សេងទៀត | មិនដឹង | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| **ចំនួនប្រជាជន** | | | | | | | | | | |
| មិនពិការ | ៧.៨២៩.៥៤៩ | ២៧.៧៣៨ | ៥៥.៧៩៣ | ៦០៧.៣៣២ | ៩៩៤.១០៥ | ១២៦.៦៩៨ | ២៧.៧២៧ | ១៨.៨៨៧ | ៨.៤៣១ | ៩.៦៩៦.២៦០ |
| ពិការខ្លះ | ២២៨.៦០៩ | ៣.៦៥១ | ៣.៣៥៨ | ៣៣.៣៩០ | ៥.៥៨៨ | ១៤.៨០១ | ៤.៨១០ | ៥០៧ | ៣៦៩ | ២៩៥.០៨៣ |
| ពិការខ្លាំង | ៣២.២០០ | ៣.២២២ | ១.៥៩៦ | ៥.៩១២ | ១.២៨៨ | ៧.៦៥១ | ១.២២៦ | ២៤៣ | ១០៥ | ៥៣.៤៤៣ |
| ពិការមិនអាចធ្វើអ្វីបាន | ១១.៤២៤ | ២.៤៦៦ | ៧៦៤ | ២.៥៤៨ | ១.៥១៩ | ៤.៤៦៤ | ៤២៥ | ១៦៦ | ៦៣ | ២៣.៨៣៩ |
| សរុប | ៨.១០១.៧៨២ | ៣៧.០៧៧ | ៦១.៥១១ | ៦៤៩.១៨២ | ១.០០២.៥០០ | ១៥៣.៦១៤ | ៣៤.១៨៨ | ១៩.៨០៣ | ៨.៩៦៨ | ១០.០៦៨.៦២៥ |
| **របាយភាគរយ** | | | | | | | | | | |
| មិនពិការ | ៨០,៧ | ០,៣ | ០,៦ | ៦,៣ | ១០,៣ | ១,៣ | ០,៣ | ០,២ | ០,១ | ១០០,០ |
| ពិការខ្លះ | ៧៧,៥ | ១,២ | ១,១ | ១១,៣ | ១,៩ | ៥,០ | ១,៦ | ០,២ | ០,១ | ១០០,០ |
| ពិការខ្លាំង | ៦០,៣ | ៦,០ | ៣,០ | ១១,១ | ២,៤ | ១៤,៣ | ២,៣ | ០,៥ | ០,២ | ១០០,០ |
| ពិការមិនអាចធ្វើអ្វីបាន | ៤៧,៩ | ១០,៣ | ៣,២ | ១០,៧ | ៦,៤ | ១៨,៧ | ១,៨ | ០,៧ | ០,៣ | ១០០,០ |
| សរុប | ៨០,៥ | ០,៤ | ០,៦ | ៦,៤ | ១០,០ | ១,៥ | ០,៣ | ០,២ | ០,១ | ១០០,០ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ផលធៀបការងារ-ប្រជាជនតាមអាយុ ក្នុងរូប ៨.២ បង្ហាញពីស្ថានភាពមិនអនុគ្រោះសម្រាប់ជនមានពិការភាពក្នុងទីផ្សារការងារ នៅគ្រប់ក្រុមអាយុទាំងអស់។ ឧ. អត្រាការងារ-ប្រជាជនសម្រាប់ប្រជាជនទាំងអស់ដែលមានអាយុ ៣៥-៣៩ ឆ្នាំ គឺ ៩១,៦ ភាគរយ (ធៀបនឹង ៩១,៩ ភាគរយសម្រាប់ជនមិនពិការ)។ ការប្រឡូកក្នុងទីផ្សារការងារថយចុះទៅតាមកម្រិតធ្ងន់ធ្ងរនៃពិការភាព។ ឧ. ក្នុងក្រុមអាយុ ៣៥-៣៩ ឆ្នាំ ប្រជាជនមានពិការភាពខ្លះចំនួន ៨៦,៦ ភាគរយមានភាពសកម្មសេដ្ឋកិច្ច (ធៀបនឹង ៧០,៦ ភាគរយនៃប្រជាជនមានពិការខ្លាំង និង ៥៩,៥ ភាគរយនៃប្រជាជនពិការមិនអាចធ្វើអ្វីបាន)។ គួរកត់សម្គាល់ថា ក្នុងក្រុមអាយុវ័យក្មេងបំផុត ជនមានពិការភាពខ្លះហាក់ឆាប់ប្រឡូកក្នុងទីផ្សារការងារជាងជនមិនពិការ។ ទោះបីជាមានភាពខុសគ្នាតិចតួចក៏ដោយ ប៉ុន្តែវាអាចដោយសារតែពួកគេឆាប់បោះបង់ការសិក្សានៅអាយុវ័យក្មេង (សូមមើលជំពូកមុន) ឬប្រឡូកក្នុងពលកម្មកុមារ។

រូប ៨.២ ៖ អត្រាការងារ-ប្រជាជនតាមអាយុ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

វិធីមួយផ្សេងទៀតដើម្បីដឹងពីស្ថានភាពរបស់ជនមានពិការភាពក្នុងទីផ្សារការងារ គឺត្រូវពិនិត្យមើលអត្រាគ្មានការងារធ្វើ បែងចែកតាមកម្រិតពិការភាព។ ភាពគ្មានការងារធ្វើជាភាគរយនៃកម្លាំងពលកម្មសរុបដែលគ្មានការងារធ្វើ ដោយកម្លាំងពលកម្មជាចំនួនសរុបនៃអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ។ អត្រាអត់ការងារធ្វើត្រូវបានគណនាសម្រាប់ប្រជាជនដែលស្ថិតក្នុងក្រុមអាយុសកម្ម ដូចជា ក្រុមអាយុ ១៥-៦៤ ឆ្នាំ។ ភាពគ្មានការងារធ្វើរបស់ប្រជាជនត្រូវបានពិនិត្យមើលពេញមួយឆ្នាំ មុនជំរឿន និងគូសបញ្ជាក់ថាតើមនុស្សម្នាក់គ្មានការងារធ្វើស្ទើរតែពេញមួយឆ្នាំ ឬទេ។ ក្រុមប្រជាជនគ្មានការងារធ្វើរួមបញ្ចូលប្រជាជនដែលឆ្លើយថា "ធ្លាប់គ្មានការងារធ្វើពីមុនមក" ឬ "គ្មានការងារធ្វើ (មិនដែលមានការងារធ្វើ)"។ អត្រាគ្មានការងារធ្វើសម្រាប់ប្រជាជនទាំងអស់ក្នុងក្រុមអាយុនេះគឺ ១,២ ភាគរយ។ អត្រាទាបនៃភាពគ្មានការងារធ្វើបណ្ដាលមកពីការកំណត់ខុសគ្នានូវនិយមន័យនៃភាពគ្មានការងារធ្វើក្នុងជំរឿននេះ។ សៀវភៅណែនាំអ្នកសម្ភាសន៍គូសបញ្ជាក់ថា មនុស្សម្នាក់គួរត្រូវបានចាត់ទុកថាគ្មានការងារធ្វើ ប្រសិនបើគាត់ "គ្មានការងារធ្វើ ប៉ុន្តែកំពុងស្វែងរកការងារ ឬអាចជួលឱ្យធ្វើការបាន" (NIS, 2018)។ ប្រជាជនមិនពិការ មានអត្រាគ្មានការងារធ្វើ ១,១ ភាគរយ ចំណែកប្រជាជនមានពិការភាពខ្លះ មានអត្រាគ្មានការងារធ្វើ ៣,០ ភាគរយ។ ភាពគ្មានការងារធ្វើមានកម្រិតខ្ពស់ក្នុងចំណោមប្រជាជនមានពិការភាពខ្លាំង (១៣,០ ភាគរយ) និងកាន់តែខ្ពស់ក្នុងចំណោមប្រជាជនពិការមិនអាចធ្វើអ្វីបាន (២២,០ ភាគរយ)។

ភាពគ្មានការងារធ្វើក្នុងចំណោមប្រជាជនកម្ពុជាដែលមានពិការភាព ផ្អែកតាមអាយុ។ រូប ៨.៣ បង្ហាញពីអត្រាគ្មានការងារធ្វើបែងចែកតាមអាយុ សម្រាប់ក្រុមពិការភាពនីមួយៗ។ ខណៈដែលគ្មានគំរូអាយុពិតប្រាកដសម្រាប់ប្រជាជនមិនពិការ ឬប្រជាជនមានពិការភាពខ្លះ ប្រជាជនដែលមានពិការភាពខ្លាំង និងពិការមិនអាចធ្វើអ្វីបាន បង្ហាញពីគំរូអាយុដូចគ្នា ដោយមានអត្រាខ្ពស់នៃភាពគ្មានការងារធ្វើក្នុងក្រុមអាយុ ២៥-២៩ ឆ្នាំ និងមានអត្រាខ្ពស់បំផុតក្នុងក្រុមអាយុ ៤៥-៤៩ ឆ្នាំ។ គំរូទាំងនេះបង្ហាញថា កម្លាំងពលកម្មវ័យក្មេង និងមានពិការភាព ដែលប្រឡូកក្នុងទីផ្សារការងារ មានការលំបាកក្នុងការស្វែងរកការងារធ្វើ។ ភាពគ្មានការងារធ្វើសម្រាប់ក្រុមអាយុ ២៥-២៩ ឆ្នាំគឺ ២,៤ ភាគរយសម្រាប់ប្រជាជនមិនពិការ ប៉ុន្តែមានកម្រិត ១៣,៩ ភាគរយសម្រាប់ប្រជាជនមានពិការភាពខ្លាំង និង ១២,៣ ភាគរយសម្រាប់ប្រជាជនពិការមិនអាចធ្វើអ្វីបាន។ ក្រោយអាយុ ៤០ ឆ្នាំ ភាពគ្មានការងារធ្វើក្នុងចំណោមប្រជាជនមានពិការភាពខ្លាំងគឺ ២៦,៣ ភាគរយ ធៀបនឹង ៤២,៨ ភាគរយក្នុងចំណោមប្រជាជនពិការមិនអាចធ្វើអ្វីបាន ក្នុងក្រុមអាយុ ៤៥-៤៩ ឆ្នាំ។ ភាពគ្មានការងារធ្វើធ្លាក់ចុះយ៉ាងគំហុកសម្រាប់ក្រុមអាយុទាំងពីរក្រោយអាយុ ៥០ ឆ្នាំ។

រូប ៨.៣ ៖ អត្រាគ្មានការងារធ្វើតាមអាយុ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ស្ថានភាពកម្លាំងពលកម្មរបស់ជនមានពិការភាព និងជនមិនពិការ មានសង្ខេបក្នុងរូប ៨.៤។ ក្រាហ្វនេះបង្ហាញយ៉ាងច្បាស់ថា នៅពេលបុគ្គលមានកម្រិតពិការភាពកាន់តែធ្ងន់ធ្ងរ ឱកាសទទួលបានការងារគឺកាន់តែទាប ហើយបុគ្គលនោះងាយនឹងគ្មានការងារធ្វើក្នុងរយៈពេល ១២ ខែមុនជំរឿន។ តួលេខទាំងនេះបង្ហាញថា ទោះបីជាកម្ពុជាមានវិធានការ និងបទប្បញ្ញត្តិសម្រាប់ការផ្តល់ឱកាសការងារដល់ជនមានពិការភាពក្តី ក៏ប្រទេសនេះត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងសម្រេចបានសមភាពក្នុងទីផ្សារការងារ។

រូប ៨.៤ ៖ ភាគរយប្រជាជនអាយុ ១៥-៦៤ ឆ្នាំដែលប្រឡូកក្នុងកម្លាំងពលកម្ម បែងចែកតាមស្ថានភាពមានការងារធ្វើ និងគ្មានការងារធ្វើ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ប្រភេទការងាររបស់ប្រជាជនពិការ បង្ហាញពីគំរូដ៏គួរឱ្យចាប់អារម្មណ៍ និងគួរឱ្យភ្ញាក់ផ្អើល (រូប ៨.៥)។ ក្នុងជំរឿននេះ មានចំណាត់ស្ថានភាពការងារចំនួន ៥ ៖ និយោជក និយោជិតមានប្រាក់ឈ្នួល អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល និងស្ថានភាពការងារផ្សេងទៀត។ គេរំពឹងថា ប្រជាជនពិការមិនអាចធ្វើអ្វីបាន នឹងមានស្ថានភាពការងារខុសពីប្រជាជនមិនពិការ ប៉ុន្តែគឺមិនដូច្នេះទេ។ តាមពិត អត្រាមានការងារធ្វើក្នុងចំណោមប្រជាជនពិការមិនអាចធ្វើអ្វីបាន ស្ទើរតែដូចគ្នានឹងប្រជាជនមិនពិការ។ គំរូសម្រាប់ប្រជាជនមានពិការភាពខ្លះ និងពិការភាពខ្លាំង គឺខុសគ្នា ដោយភាគច្រើនមានស្ថានភាពជាអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន។ ប្រជាជនមិនពិការ ឬពិការមិនអាចធ្វើអ្វីបាន ជាង ៤០ ភាគរយ ស្ថិតក្នុងក្រុមនេះ ខណៈដែលប្រជាជនមានពិការភាពខ្លះ ឬពិការភាពខ្លាំង ជាង ៥០ ភាគរយ មានស្ថានភាពជាអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន។ ស្ទើរតែ ១/៤ នៃប្រជាជនទាំងអស់ដែលមានការងារធ្វើក្នុងប្រទេសកម្ពុជា មានស្ថានភាពជាអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល។ មានភាពខុសគ្នាតិចតួចរវាងក្រុមពិការភាពផ្សេងៗ។ ទោះជាយ៉ាងណា អត្រាអ្នកធ្វើការមានប្រាក់ឈ្នួល មានភាពខុសប្លែកខ្លាំងរវាងប្រជាជនមានពិការភាពខ្លះ ឬពិការភាពខ្លាំង និងប្រជាជនមិនពិការ ឬពិការមិនអាចធ្វើអ្វីបាន។ គេមិនដឹងច្បាស់ពីដើមហេតុបង្កស្ថានភាពការងារនេះឡើយ។

រូប ៨.៥ ៖ ស្ថានភាពការងាររបស់ប្រជាជនមានការងារធ្វើទាំងអស់ (១៥-៦៤ ឆ្នាំ) បែងចែកតាមកម្រិតពិការភាព CPHC ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

# ជំពូក ៩៖ ពិការភាព និងទេសន្តរប្រវេសន៍

ទេសន្តរប្រវេសន៍សំដៅលើ "បំលាស់ទីដោយស្ម័គ្រចិត្ត (ឧ. កម្មករទេសន្តរប្រវេសន៍) និងបំលាស់ទីដោយមិនស្ម័គ្រចិត្ត (ឧ. ជនភៀសខ្លួន) របស់ស្ត្រី និងបុរស ឆ្លងកាត់ព្រំដែនភូមិសាស្ត្រអន្តរជាតិ ឬក្នុងប្រទេស ដើម្បីស្វែងរកជីវិតប្រសើរជាងមុន (UNDESA, n.d.)"។ ជាញឹកញាប់ បញ្ហាប្រជាជនពិការមិនត្រូវបានលាតត្រដាងក្នុងប្រធានបទស្តីពីទេសន្តរប្រវេសន៍។ ការស្រាវជ្រាវបង្ហាញថា ជារឿយៗ ជនទេសន្តរប្រវេសន៍ដែលមានពិការភាព មិនត្រូវបានកំណត់អត្តសញ្ញាណ និងផ្តល់ការព្យាបាលគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ពួកគេឡើយ" (បណ្តាញសង្គមអឺរ៉ុប, n.d.)។

យោងតាម CHPC ឆ្នាំ ២០១៩ ភាគរយនៃជនទេសន្តរប្រវេសន៍មួយជីវិតក្នុងប្រទេសកម្ពុជា គឺ ២១,៥ ភាគរយ។ ទីប្រជុំជនមានអត្រាជនទេសន្តរប្រវេសន៍ខ្ពស់ជាងជនបទ (៣៥,៥ ភាគរយ ទល់នឹង ១២,៤ ភាគរយ)។ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ការធ្វើទេសន្តរប្រវេសន៍មានការកើនឡើង ដោយគ្មានភាពខុសគ្នាជាក់ស្តែងរវាងបុរស និងស្ត្រី។ ការធ្វើទេសន្តរប្រវេសន៍ភាគច្រើនគឺឆ្លងពីខេត្តមួយទៅខេត្តមួយ ដោយអ្នករស់នៅជនបទធ្វើបំលាស់ទីទៅតំបន់ប្រជុំជនដែលមានការអភិវឌ្ឍខ្លាំង។ គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣ ចែងពីរបៀបដែលរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងទីផ្សារទេសន្តរប្រវេសន៍ការងារ និងធានាថា ទីផ្សារនេះមាននិរន្តរភាព ប្រសិទ្ធភាព និងផ្អែកតាមសិទ្ធិ (ILO, 2018)។

ក្រៅពីសំណួរមួយស្តីពីទីកន្លែងរស់នៅបច្ចុប្បន្ន ជំរឿននេះមានសំណួរ៤ដើម្បីកំណត់ស្ថានភាពទេសន្តរប្រវេសន៍របស់ប្រជាជន។ ទីមួយ ទីកន្លែងកំណើតសម្រាប់សមាជិកម្នាក់ៗក្នុងគ្រួសារ ត្រូវបានចុះបញ្ជី (ឃុំ/សង្កាត់ ស្រុក/ខណ្ឌ/ក្រុង) នៅថ្នាក់ខេត្ត ប្រសិនបើបុគ្គលនោះកើតក្នុងប្រទេសកម្ពុជា។ ប្រសិនបើគាត់កើតនៅក្រៅប្រទេសកម្ពុជា គេនឹងបញ្ចូលឈ្មោះប្រទេសនោះ។ បន្ទាប់មកគឺសំណួរស្តីពីទីកន្លែងរស់នៅពីមុន ដោយមានជម្រើសមួយដែលគូសបញ្ជាក់ថា បុគ្គលនោះរស់នៅទីកន្លែងនោះជាអចិន្ត្រៃយ៍។ ទីបី សម្រាប់បុគ្គលម្នាក់ៗ គឺការសួរអំពីរយៈពេលដែលគាត់រស់នៅក្នុងភូមិកំណើតបច្ចុប្បន្ន និងចុងបញ្ចប់គឺការសួរអំពីមូលហេតុនៃការធ្វើទេសន្តរប្រវេសន៍។ ផ្អែកតាមចម្លើយទាំងនេះ គេអាចកំណត់បានថាតើបុគ្គលនោះជាជនទេសន្តរប្រវេសន៍មួយជីវិតឬទេ (ឧ. ទីកន្លែងរស់នៅបច្ចុប្បន្នរបស់គាត់ ខុសពីទីកន្លែងកំណើត)។ ក្រៅពីនេះ គេអាចពិនិត្យថាតើបុគ្គលនោះបានធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេលថេរមុនជំរឿនឬទេ។ ក្នុងការវិភាគនេះ ការពិចារណាផ្តោតលើការធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេល ៥ ឆ្នាំមុនជំរឿន។ អ្នកដែលរស់នៅ ៥ ឆ្នាំក្នុងស្រុកមួយផ្សេងពីស្រុកដែលគាត់កំពុងរស់នៅ ក្នុងពេលធ្វើជំរឿន ត្រូវបានចាត់ទុកជាជនទេសន្តរប្រវេសន៍។ គួរកត់សម្គាល់ថា ចំណុចនេះក៏រួមបញ្ចូលប្រជាជនដែលបានរស់នៅក្រៅប្រទេសកម្ពុជាអស់រយៈពេល ៥ ឆ្នាំផងដែរ។

យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ក្នុងចំណោមប្រជាជនចំនួន ១៤.១០២.០៥២ នាក់ ដែលមានអាយុ ៥ ឆ្នាំឡើង មាន ១.០៨៣.២៩០ នាក់ ធ្វើទេសន្តរប្រវេសន៍ទៅក្នុងស្រុកដែលពួកគេកំពុងរស់នៅក្នុងពេលធ្វើជំរឿន អស់រយៈពេល ៥ ឆ្នាំមកហើយ (ស្មើនឹង ៧,៧ ភាគរយនៃចំនួនប្រជាជនសរុប ៖ រូប ៩.១)។ បុរសធ្វើទេសន្តរប្រវេសន៍ច្រើនជាងស្ត្រី (៥៧២.៩១២ នាក់ ឬ ៨,៤ ភាគរយ ទល់នឹង ៥១០.៣៧៨ នាក់ ឬ ៧ ភាគរយ)។ ខណៈដែលប្រជាជនភេទប្រុសមានចំនួន ៤៨,៤ ភាគរយនៃចំនួនប្រជាជនសរុប ពួកគេមានចំនួន ៥២,៩ ភាគរយនៃចំនួនជនទេសន្តរប្រវេសន៍សរុបនាពេលបច្ចុប្បន្ន។ ក្នុងចំណោមជនទេសន្តរប្រវេសន៍ចំនួន ១.០៨៣.២៩០ នាក់ មាន ៩០១.៦៤២ នាក់កំពុងរស់នៅក្នុងគ្រួសារមិនមែនស្ថាប័ននៅពេលធ្វើជំរឿន និង ១៨១.៦៤៨ នាក់កំពុងរស់នៅក្នុងគ្រួសារស្ថាប័ន។

រូប ៩.១ ៖ ភាគរយប្រជាជនអាយុ ៥ ឆ្នាំឡើងដែលបានធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

សម្រាប់ទាំងពីរភេទ ភាគរយប្រជាជនដែលរស់នៅក្នុងស្រុកបច្ចុប្បន្នអស់រយៈពេល ៥ ឆ្នាំមកហើយ មានចំនួនច្រើនបំផុតក្នុងចំណោមប្រជាជនពិការមិនអាចធ្វើអ្វីបាន។ ក្នុងចំណោមប្រជាជនទាំងពីរភេទ ខណៈដែលអត្រាប្រជាជនដែលបានចូលមករស់នៅក្នុងស្រុកដែលពួកគេកំពុងរស់នៅបច្ចុប្បន្ន អស់រយៈពេល ៥ ឆ្នាំមុនជំរឿន មានចំនួន ៧,៧ ភាគរយ អត្រានេះគឺ ១២,៤ ភាគរយសម្រាប់ប្រជាជនពិការមិនអាចធ្វើអ្វីបាន។ សម្រាប់ក្រុមប្រជាជនមិនពិការ និងសម្រាប់ក្រុមប្រជាជនពិការមិនអាចធ្វើអ្វីបាន ភាគរយនេះមានកម្រិតខ្ពស់ក្នុងចំណោមបុរសជាងស្ត្រី។ ប្រជាជនមានពិការភាពខ្លះ ហាក់មិនសូវធ្វើទេសន្តរប្រវេសន៍ ខណៈដែលប្រជាជនមានពិការភាពខ្លាំង មានអត្រាធ្វើទេសន្តរប្រវេសន៍ទាបជាងប្រជាជនមិនពិការ។

មូលហេតុដែលធ្វើឱ្យប្រជាជនចាកចេញឆ្ងាយពីទីកន្លែងរស់នៅចាស់ បង្ហាញពីគំរូដ៏គួរឱ្យកត់សម្គាល់សម្រាប់កម្រិតពិការភាពផ្សេងៗ (តារាង ៩.១)។ ដោយសារមានមូលហេតុផ្សេងៗនៃការធ្វើទេសន្តរប្រវេសន៍សម្រាប់ប្រជាជនដែលស្ថិតក្នុងគ្រួសារស្ថាប័ន និងគ្រួសារមិនមែនស្ថាប័ន ដូច្នេះ ព័ត៌មានត្រូវបានបង្ហាញក្នុងតារាង ២ ផ្សេងគ្នា។ សម្រាប់បុរស និងស្ត្រីមិនពិការដែលស្ថិតក្នុងគ្រួសារមិនមែនស្ថាប័ន មូលហេតុចម្បងនៃការធ្វើទេសន្តរប្រវេសន៍រួមមាន "ការស្វែងរកការងារ" និង "គ្រួសារផ្លាស់ទីលំនៅ"។ បុរសចំនួន ២៧,៤ ភាគរយ និងស្ត្រីចំនួន ២៨,៧ ភាគរយ ដែលមិនពិការ និងកំពុងរស់នៅក្នុងគ្រួសារមិនមែនស្ថាប័ន បញ្ជាក់ថា ការស្វែងរកការងារជាកត្តាជំរុញឱ្យពួកគេចាកចេញទីកន្លែងរស់នៅ។ សម្រាប់បុរសមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ការស្វែងរកការងារក៏ជាមូលហេតុដ៏សំខាន់មួយផងដែរ។ ក្នុងចំណោមបុរសធ្វើទេសន្តរប្រវេសន៍ចំនួន ៥ នាក់ដែលពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានម្នាក់ធ្វើទេសន្តរប្រវេសន៍ដើម្បីរកការងារធ្វើ។ អត្រាធ្វើទេសន្តរប្រវេសន៍ដើម្បីរកការងារធ្វើគឺ ១៤,៦ ភាគរយ សម្រាប់

ស្ត្រីមានពិការភាពខ្លាំង និង ២១,២ ភាគរយសម្រាប់ស្ត្រីពិការមិនអាចធ្វើអ្វីបាន។ សម្រាប់ប្រជាជនមានពិការភាពខ្លះ ការស្វែងរកការងារក៏ជាមូលហេតុដ៏សំខាន់មួយផងដែរ (២៣,៩ ភាគរយសម្រាប់បុរស និង ១៩,៦ ភាគរយសម្រាប់ស្ត្រី)។ ទោះជាយ៉ាងណា មូលហេតុសំខាន់ជាងនេះសម្រាប់ក្រុមប្រជាជនមានពិការភាពខ្លះ គឺគ្រួសារផ្លាស់ទីលំនៅដ្ឋាន។ មូលហេតុនេះត្រូវបានលើកឡើងដោយបុរសចំនួន ៣៤,៤ ភាគរយ និងស្ត្រីចំនួន ៤៧.៨ ភាគរយ។ មូលហេតុដ៏សំខាន់មួយទៀត ជាពិសេសសម្រាប់បុរសធ្វើទេសន្តរប្រវេសន៍ គឺការប្តូរកន្លែងធ្វើការ។ ១៤ ភាគរយនៃបុរសមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន លើកឡើងថា ការប្តូរកន្លែងធ្វើការជាមូលហេតុចម្បងនៃការធ្វើបំលាស់ទី។

ក្នុងចំណោមប្រជាជនដែលរស់នៅក្នុងគ្រួសារស្ថាប័ន និងធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេល ៥ ឆ្នាំ មុនជំរឿន មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍មានភាពខុសគ្នាខ្លាំង។ ក្នុងចំណោមអ្នករស់នៅក្នុងគ្រួសារស្ថាប័ន ខណៈដែលការប្តូរកន្លែងធ្វើការ និងការស្វែងរកការងារគឺជាមូលហេតុចម្បង "ការមកលេង" ជាមូលហេតុចម្បងនៃការធ្វើបំលាស់ទីសម្រាប់ប្រជាជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។ បុរស និងស្ត្រីដែលមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបានចំនួន ៧០ ភាគរយ និយាយថា ពួកគេគ្រាន់តែមកលេងគ្រួសារស្ថាប័ន។ ភាគរយស្ត្រីដែលលើកឡើងថាការមកលេងជាមូលហេតុនៃការធ្វើទេសន្តរប្រវេសន៍ មានចំនួនច្រើនជាងបុរស ជិត ២ ដង។

ក្នុងការឆ្លើយថា "មកលេង" ពួកគេអាចគូសបញ្ជាក់ថា ពួកគេនឹងស្នាក់នៅក្នុងគ្រួសារស្ថាប័នក្នុងរយៈពេលណាមួយ ដូចជា ដើម្បីទទួលបានការថែទាំសុខភាព។ ការសង្កេតមួយទៀតគឺភាគរយខ្ពស់នៃស្ត្រីមិនពិការ (៤៥,៦ ភាគរយ) ដែលនិយាយថា "ការមកលេង" ជាមូលហេតុនៃការធ្វើទេសន្តរប្រវេសន៍។ គេមិនដឹងច្បាស់ថាតើហេតុអ្វីប្រជាជនយ៉ាងច្រើនក្នុងគ្រួសារស្ថាប័ន លើកឡើងពីមូលហេតុនេះឡើយ។ ប្រហែលជាអ្នករស់នៅក្នុងគ្រួសារទាំងនេះចង់គូសបញ្ជាក់ពីការស្នាក់នៅបណ្តោះអាសន្នក្នុងស្ថាប័ននេះ។

តារាង ៩.១ ៖ មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | ប្រុស | | | | ស្រី | | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន |
| ប្តូរកន្លែងធ្វើការ | ១៦,១ | ១៦,៩ | ១៣,៩ | ១៤,២ | ១៣,៧ | ១០,៦ | ៩,៣ | ១២,១ | ១៤,៩ | ១៣,៤ | ១១,៥ | ១៣,១ |
| ស្វែងរកការងារ | ២៧,៤ | ២៣,៩ | ១៨,២ | ២២,៤ | ២៨,៧ | ១៩,៦ | ១៤,៦ | ២១,២ | ២៨,០ | ២១,៥ | ១៦,៣ | ២១,៧ |
| ការសិក្សា | ៤,២ | ១,៩ | ៣,៤ | ៣,៨ | ៤,០ | ១,៥ | ១,៥ | ១,៥ | ៤,១ | ១,៧ | ២,៤ | ២,៦ |
| រៀបអាពាហ៍ពិពាហ៍ | ១៦,៧ | ១១,៧ | ១២,៥ | ១២,៦ | ១០,៩ | ៦,១ | ៦,១ | ១០,៣ | ១៣,៩ | ៨,៦ | ៩,១ | ១១,៤ |
| គ្រួសារផ្លាស់ទីលំនៅ | ២៩,៦ | ៣៤,៤ | ៣៧,៣ | ៣៦,៨ | ៣៦,៨ | ៤៧,៨ | ៤៨,៣ | ៤២,៨ | ៣៣,១ | ៤១,៨ | ៤៣,១ | ៣៩,៩ |
| បាត់បង់ដីធ្លី/បាត់បង់ទីលំនៅ | ០,៤ | ០,៩ | ១,០ | ០,៥ | ០,៤ | ០,៩ | ១,១ | ០,៩ | ០,៤ | ០,៩ | ១,០ | ០,៧ |
| គ្រោះធម្មជាតិ | ០,១ | ០,១ | ០,១ | ០,៤ | ០,១ | ០,១ | ០,២ | ០,១ | ០,១ | ០,១ | ០,១ | ០,២ |
| ត្រូវឱ្យផ្លាស់ទីកន្លែងដោយសារសង់ទំនប់វារីអគ្គិសនី | ០,១ | ០,១ | ០,៣ | ០,០ | ០,១ | ០,១ | ០,៣ | ០,៦ | ០,១ | ០,១ | ០,៣ | ០,៣ |
| ត្រូវឱ្យផ្លាស់ទីកន្លែងដោយសារប៉ះពាល់គម្រោង | ០,២ | ០,៣ | ០,៥ | ០,១ | ០,១ | ០,២ | ០,២ | ០,២ | ០,១ | ០,២ | ០,៣ | ០,២ |
| អសន្តិសុខ | ០,១ | ០,៧ | ១,២ | ០,១ | ០,២ | ០,៩ | ២,១ | ០,៤ | ០,១ | ០,៨ | ១,៧ | ០,៣ |
| មាតុភូមិនិវត្តន៍/មកភូមិកំណើតវិញ | ០,៣ | ០,៩ | ១,២ | ១,៥ | ០,៣ | ០,៩ | ១,៨ | ០,៧ | ០,៣ | ០,៩ | ១,៥ | ១,០ |
| កូនក្រុំពា | ០,១ | ០,២ | ០,៧ | ០,៩ | ០,១ | ០,២ | ០,៥ | ០,០ | ០,១ | ០,២ | ០,៦ | ០,៤ |
| មកលេង | ២,៤ | ៤,៤ | ៤,៥ | ៣,២ | ២,៥ | ៧,២ | ៨,២ | ៥,៥ | ២,៤ | ៦,០ | ៦,៥ | ៤,៤ |
| ផ្សេងទៀត | ២,៤ | ៣,៦ | ៥,០ | ៣,៥ | ២,០ | ៤,១ | ៥,៩ | ៣,៧ | ២,២ | ៣,៩ | ៥,៥ | ៣,៦ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## តារាង ៩.១.១ ៖ មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក បែងចែកតាមភេទ និងកម្រិតពិការភាពសម្រាប់ប្រជាជនដែលរស់នៅក្នុងគ្រួសារស្ថាប័ន CPHC ឆ្នាំ ២០១៩

| | ប្រុស | | | | ស្រី | | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន |
| ប្តូរកន្លែងធ្វើការ | ២៨,៤ | ២០,៤ | ១៥,៧ | ១៥,០ | ១១,៧ | ១៨,៨ | ០,៧ | ១,៨ | ២២,១ | ១៩,៩ | ៧,៤ | ៨,២ |
| ស្វែងរកការងារ | ២៩,៧ | ១៦,៥ | ២៤,៤ | ២១,៤ | ២៥,៤ | ៤២,៣ | ៣,៨ | ៣,៩ | ២៨,០ | ២៤,៤ | ១៣,០ | ១២,៤ |
| ការសិក្សា | ១០,៧ | ៨,១ | ២,៤ | ៤,៨ | ៧,៨ | ៥,២ | ០,៣ | ១,៧ | ៩,៦ | ៧,២ | ១,២ | ៣,២ |
| រៀបអាពាហ៍ពិពាហ៍ | ១,១ | ០,៦ | ០,៨ | ២,១ | ០,៨ | ០,៨ | ០,៥ | ០,៧ | ១,០ | ០,៧ | ០,៦ | ១,៤ |
| គ្រួសារផ្លាស់ទីលំនៅ | ២,៨ | ៣,៩ | ០,៤ | ០,៥ | ៤,៩ | ១១,០ | ០,៧ | ០,៧ | ៣,៦ | ៦,១ | ០,៦ | ០,៦ |
| បាត់បង់ដីធ្លី/បាត់បង់ទីលំនៅ | ០,៤ | ០,០ | ០,០ | ១,៥ | ០,២ | ០,៣ | ០,០ | ០,០ | ០,៣ | ០,១ | ០,០ | ០,៧ |
| គ្រោះធម្មជាតិ | ០,១ | ០,០ | ០,១ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| តម្រូវឱ្យផ្លាស់ទីកន្លែងដោយសារសង់ទំនប់វារីអគ្គិសនី | ០,២ | ០,០ | ០,៧ | ០,០ | ០,០ | ០,២ | ០,០ | ០,០ | ០,១ | ០,១ | ០,៣ | ០,០ |
| តម្រូវឱ្យផ្លាស់ទីកន្លែងដោយសារប៉ះពាល់គម្រោង | ០,៤ | ០,២ | ២,៧ | ០,០ | ០,១ | ០,២ | ០,០ | ០,០ | ០,៣ | ០,២ | ១,២ | ០,០ |
| អសន្តិសុខ | ០,០ | ០,០ | ០,១ | ០,០ | ០,០ | ០,៣ | ០,០ | ០,០ | ០,០ | ០,១ | ០,០ | ០,០ |
| មាតុភូមិនិវត្តន៍/មកភូមិកំណើតវិញ | ២,០ | ០,១ | ២,១ | ០,៧ | ០,៤ | ០,២ | ១,៧ | ០,០ | ១,៤ | ០,១ | ១,៨ | ០,៣ |
| កូនកំព្រា | ០,៩ | ០,៥ | ១,៥ | ២,៧ | ០,៦ | ០,៧ | ០,១ | ០,១ | ០,៨ | ០,៥ | ០,៨ | ១,៤ |
| មកលេង | ១០,៤ | ២,៦ | ៤០,៨ | ៤៩,៩ | ៤៥,៦ | ៣,០ | ៩០,៨ | ៩១,០ | ២៣,៧ | ២,៧ | ៦៨,៥ | ៧១,០ |
| ផ្សេងទៀត | ១២,៩ | ៤៧,៣ | ៨,៥ | ១,៣ | ២,៣ | ១៦,៩ | ១,៣ | ០,២ | ៨,៩ | ៣៧,៩ | ៤,៥ | ០,៧ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

# ជំពូក ១០៖ កុមារ និងយុវជន និងពិការភាព

អង្គការជាតិ និងអន្តរជាតិនានា ប្រើប្រាស់និយមន័យផ្សេងៗសម្រាប់ពាក្យ "យុវជន"។ ឧ. អង្គការ UN Habitat កំណត់យុវជនជាមនុស្សដែលមានអាយុ ១៥-៣២ ឆ្នាំ ខណៈដែលអង្គការ UNICEF និង UNFPA ចាត់ទុកយុវជន មនុស្សម្នាក់ដែលមានអាយុ ១៥-២៤ ឆ្នាំ។ ក្នុងរបាយការណ៍នេះ កុមារត្រូវបានកំណត់ជាមនុស្សដែលមានអាយុ ៥-១៤ ឆ្នាំ ចំណែកយុវជនត្រូវបានកំណត់ជាមនុស្សដែលមានអាយុ ១៥-២៤ ឆ្នាំ។ កុមារអាយុក្រោម ៥ ឆ្នាំ មិនត្រូវបាន រួមបញ្ចូលក្នុងការវិភាគនេះឡើយ ព្រោះកម្រងសំណួរខ្លីរបស់ក្រុមការងារវ៉ាស៊ីនតោនស្តីពីពិការភាព មិនអាចអនុវត្តបាន សម្រាប់ក្រុមអាយុ ០-៤ ឆ្នាំ។ ជម្រើសនេះគាំទ្រដោយទឡ្ហីករណ៍របស់អង្គការសហប្រជាជាតិ ដែលថា "និយមន័យ ដែលកំណត់ក្រុមអាយុ ១៥-២៤ ឆ្នាំជាយុវជន បម្រើឱ្យគោលបំណងស្ថិតិសម្រាប់ការវាយតម្លៃតម្រូវការរបស់យុវជន និងការផ្តល់គោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍយុវជន" (UNDESA, n.d.b.)។

នៅជុំវិញពិភពលោក កុមារមានពិការភាព ប្រឈមនឹងការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរ។ ពិការភាពរបស់កុមារអាច ត្រូវបានកំណត់រក ឬកត់សម្គាល់យឺតពេល ដែលធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការផ្តល់ការយកចិត្តទុកដាក់ និងការ ថែទាំដែលពួកគេត្រូវការ។ ដោយសារពិការភាពទាំងនេះ ជារឿយៗ កុមារត្រូវបានមាក់ងាយ ផាត់ចេញពីការអប់រំ ឬការ ចូលរួមក្នុងសង្គម ប្រឈមនឹងការលំបាកក្នុងការប្រើប្រាស់មធ្យោបាយធ្វើដំណើរ និងហេដ្ឋារចនាសម្ព័ន្ធ ខណៈដែល ឪពុកម្តាយអាចនឹងខិតខំរក្សាតុល្យភាពរវាងជីវិតការងារ និងការមើលថែកុមារពិការ។ ក្រៅពីនេះ ក្នុងចំណោមក្មេងប្រុស និងក្មេងស្រីទូទាំងពិភពលោកដែលមានអាយុក្រោម ១៨ ឆ្នាំ និងមានពិការភាពសតិបញ្ញា ឬការអភិវឌ្ឍ មានក្មេងប្រុស ចំនួន ៦៨ ភាគរយ និងក្មេងស្រីចំនួន ៣០ ភាគរយ ទទួលរងការរំលោភបំពានផ្លូវភេទ។ អ្វីដែលសំខាន់គឺ សិទ្ធិរបស់ កុមារមានពិការភាពផ្អែកតាមគោលការណ៍ដែលធានាថា ពួកគេអាចធំធាត់ជាមួយគ្រួសារ មានលទ្ធភាពទទួលបាន ការអប់រំ និងសេវាគាំទ្រសង្គមគ្រប់គ្រាន់ និងអាចចូលរួមក្នុងសហគមន៍របស់ពួកគេ (UNICEF, n.d.)។

## ១០.១ ប្រេវ៉ាឡង់ពិការភាពក្នុងចំណោមកុមារ និងយុវជន

តាមការវាស់វែងដោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ភាគរយកុមារ និងយុវជន ដែលមានពិការភាពក្នុងប្រទេសកម្ពុជា មានកម្រិតទាប។ រូប ១០.១ បង្ហាញពីភាគរយសម្រាប់កុមារ និងយុវជន បែងចែកតាមភេទ និងកម្រិតពិការភាព។ ក្នុងចំណោមប្រជាជនអាយុ ៥-២៤ ឆ្នាំ មាន ០,៨២ ភាគរយបញ្ជាក់ថាពិការ ខ្លះ, ០,២១ ភាគរយបញ្ជាក់ថាពិការខ្លាំង និង ០,១៧ ភាគរយបញ្ជាក់ថាពិការមិនអាចធ្វើអ្វីបាន។ ពោលគឺ ក្នុងចំណោម ប្រជាជន ៦០០ នាក់ដែលមានអាយុ ៥-១៤ ឆ្នាំ កម្រិតពិការមិនអាចធ្វើអ្វីបាន បង្កផលប៉ះពាល់តែលើប្រជាជនម្នាក់ ប៉ុណ្ណោះ។ ច្បាស់ណាស់ថា ក្នុងជំរឿននេះ តួលេខពិការភាពសម្រាប់កុមារ និងយុវជន មានចន្លោះប្រហោងដូចតួលេខ ពិការភាពសម្រាប់មនុស្សពេញវ័យ និងប្រជាជនវ័យចាស់ដែរ ដែលធ្វើឱ្យមានការរាប់ចំនួនប្រជាជនពិការទាបជាង ចំនួនជាក់ស្តែង។

## ១០.២ ស្ថានភាពគ្រួសារ

កត្តាដ៏សំខាន់មួយដែលកំណត់សុខុមាលភាពរាងកាយ និងផ្លូវចិត្តរបស់កុមារ និងយុវជនមានពិការភាព គឺមជ្ឈដ្ឋានដែលពួកគេធំធាត់។ ជំរឿននេះផ្តល់សូចនាករ ២ ប្រភេទដែលពិពណ៌នាពីស្ថានភាពរស់នៅរបស់កុមារ និងយុវជន ៖ ក) ប្រភេទគ្រួសារដែលពួកគេរស់នៅ និង ខ) ថាតើម្តាយរបស់កុមារកំពុងរស់នៅក្នុងគ្រួសារតែមួយ ឬទេ។ ចំណុចសំខាន់គឺត្រូវយល់ថាតើកុមាររស់នៅផ្ទះ ឬក្នុងស្ថាប័ន ព្រោះជារឿយៗ ការធានាថា កុមារអាចធំធាត់ជាមួយគ្រួសារនៅផ្ទះ គឺជាដំណោះស្រាយល្អបំផុត។ ការរកឃើញជាសកលបង្ហាញថា កុមារពិការមានអត្រាខ្ពស់នៃការធំធាត់ក្នុងស្ថាប័ន ជាងកុមារផ្សេងទៀត រហូតដល់ ១៧ ដង។ អន្តរជាតិកំពុងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើសេវាផ្សព្វផ្សាយដើម្បីគាំទ្រដល់គ្រួសារ តាមរយៈកម្មវិធីចុះតាមផ្ទះស្តីពីកិច្ចការពារកុមារ សុខភាព អាហារូបត្ថម្ភ និងការអភិវឌ្ឍកុមារតូច ដើម្បីធានាថា កុមារធំធាត់ក្នុងគ្រួសាររបស់ពួកគេ និងទទួលបានសេវាឯកទេសដែលពួកគេត្រូវការចាំបាច់ (UNICEF, n.d.)។

*រូប ១០.១ ៖ ភាគរយកុមារអាយុ៥-១៤ ឆ្នាំ និងយុវជនអាយុ ១៥-២៤ ឆ្នាំ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩*




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ប្រជាជនអាយុ ៥-២៤ ឆ្នាំចំនួន ១៩០.១២០ នាក់ កំពុងរស់នៅក្នុងគ្រួសារស្ថាប័ននៅពេលជំរឿន (ប្រុស ១៤៧.១៩៧ នាក់, ស្រី ៤២.៩២៣ នាក់)។ ក្នុងជំរឿននេះ គ្មានការញែកប្រភេទគ្រួសារស្ថាប័នឡើយ។ ដូច្នេះ គេមិនអាចដឹងពីចំនួនកុមារ និងយុវជនដែលរស់នៅក្នុងវត្តអារាម មណ្ឌលកុមារកំព្រា មណ្ឌលថែទាំជនមានពិការភាព ឬពន្ធនាគារនោះទេ។ រូប ១០.២ បង្ហាញពីភាគរយប្រជាជនអាយុ ៥-២៤ ឆ្នាំ ដែលរស់នៅក្នុងគ្រួសារស្ថាប័ន បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព។

**រូប ១០.២ ៖ ភាគរយប្រជាជនអាយុ ៥-២៤ ឆ្នាំដែលរស់នៅក្នុងគ្រួសារស្ថាប័ន បែងចែកតាមភេទ ក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩**




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

រូប ១០.២ បង្ហាញយ៉ាងច្បាស់ថា កុមារ និងយុវជនដែលពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានទំនោររស់នៅក្នុងស្ថាប័ន ជាងកុមារមិនពិការ ឬពិការខ្លះ ជាពិសេសក្រោយអាយុ ១០ ឆ្នាំ។ កុមារអាយុ ១០-១៤ ឆ្នាំ ដែលពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ច្រើនតែរស់នៅក្នុងគ្រួសារស្ថាប័ន។ សម្រាប់ក្មេងប្រុសពិការមិនអាចធ្វើអ្វីបាន មានម្នាក់ក្នុងចំណោម ៤ នាក់ កំពុងរស់នៅក្នុងស្ថាប័ន ដែលជាអត្រាខ្ពស់បន្តិចជាងក្មេងស្រីពិការមិនអាចធ្វើអ្វីបាន ឬពិការខ្លាំង។ ខណៈដែលគេមិនដឹងច្បាស់ពីប្រភេទស្ថាប័នដែលជាជម្រករបស់នៅរបស់កុមារទាំងនេះ គេមិនដឹងច្បាស់ថាតើសាលារៀនតាមវត្តអារ៉ាមដើរតួនាទីជាស្ថាប័នប្រភេទណា សម្រាប់ជាជម្រករស់នៅរបស់កុមារ និងយុវជនមានពិការភាពនោះទេ។ ឯកសារបោះពុម្ពផ្សាយដោយ UNICEF (២០១៨) គូសបញ្ជាក់ថា ក្នុងសាលារៀនទាំងនេះ សិស្សពិការមិនត្រូវបានទទួលយកជាជនពិការឡើយ ប៉ុន្តែត្រូវបានចាត់ទុកជាអ្នកមានបញ្ហារូបរាងកាយ និង/ឬផ្លូវចិត្ត ដោយសារកម្មពីជាតិមុន" (Lunsfort, ២០១៨ ទំ. ៤៥)។ ដើម្បីយល់ច្បាស់ពីប្រភេទគ្រួសារស្ថាប័នដែលជាជម្រករស់នៅរបស់កុមារ និងយុវជន ចាំបាច់ត្រូវមានការស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅ។

សម្រាប់កុមារគ្រប់រូប ជាពិសេសកុមារមានពិការភាព ម្តាយ និងឪពុកដើរតួនាទីយ៉ាងសំខាន់ក្នុងការថែទាំ និងសុខុមាលភាពរបស់កុមារ។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ សុំឱ្យប្រជាជនម្នាក់ៗកំណត់អត្តសញ្ញាណរបស់ម្តាយ និងថាតើម្តាយពួកគេកំពុងរស់នៅក្នុងផ្ទះ ឬទេ។

រូប ១០.៣ ៖ ភាគរយកុមារអាយុ ៥-១៤ ឆ្នាំ ដែលគ្មានម្ដាយរស់នៅក្នុងគ្រួសារតែមួយ បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និង កម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ភាគរយកុមារអាយុ ៥-៩ ឆ្នាំ និង ១០-១៤ ឆ្នាំ ដែលរស់នៅក្នុងគ្រួសារដោយគ្មានម្ដាយ មានបង្ហាញក្នុងរូប ១០.៣។ សម្រាប់ក្រុមអាយុទាំង ២ ក្រុមនេះ ព័ត៌មានត្រូវបានបែងចែកតាមភេទ និងកម្រិតពិការភាពរបស់កុមារ។ ក្នុងក្រុមអាយុ ៥-៩ ឆ្នាំ កុមារាចំនួន ១៦,៨ ភាគរយ និងកុមារីចំនួន ១៦,៧ ភាគរយ ដែលគ្មានពិការភាព រស់នៅក្នុងគ្រួសារដោយគ្មានម្ដាយ។ សម្រាប់ក្រុមអាយុ ១០-១៤ ឆ្នាំ អត្រានេះគឺ ១៨,៥ ភាគរយ។ រូប ១០.៣ បង្ហាញថា សម្រាប់ក្រុមអាយុនីមួយៗ ភាគរយកុមារដែលមិនរស់នៅជាមួយម្ដាយ មានកម្រិតខ្ពស់បន្តិចទៅតាមការកើនឡើងនៃកម្រិតពិការភាពនីមួយៗ។ ក្រុមដែលមានភាគរយខ្ពស់ជាងគេនៃការគ្មានម្ដាយរស់នៅជាមួយ គឺក្មេងប្រុសអាយុ ១០-១៤ ឆ្នាំ ដែលពិការមិនអាចធ្វើអ្វីបាន (២៦,៧ ភាគរយ មិនរស់នៅក្នុងគ្រួសារជាមួយម្ដាយ)។ សម្រាប់កម្រិតពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ជាទូទៅ ភាគរយសម្រាប់ក្មេងប្រុសគឺខ្ពស់បន្តិចជាងក្មេងស្រី។

មានសូវមានការសម្ភាសន៍កុមារ និងយុវជនពិការ ដែលគ្មានផ្ទះសម្បែង ឬរស់នៅលើទូក ឬជាប្រជាជនឆ្លងកាត់ក្នុងពេលធ្វើជំរឿននេះឡើយ (កុមារ ៥ នាក់គ្មានផ្ទះសម្បែង, កុមារ ៧ នាក់រស់នៅលើទូក និង កុមារ ៦៦ នាក់ជាប្រជាជនឆ្លងកាត់)។

## ១០.៣ កុមារ និងយុវជនក្នុងកម្លាំងពលកម្ម

ពលកម្មកុមារ និងការងារកុមារជាទស្សនាទានពីរខុសគ្នា។ ពលកម្មកុមារពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៨ ឆ្នាំ ដែលប្រឡូកក្នុងសកម្មភាពសេដ្ឋកិច្ចណាមួយក្នុងរយៈពេលចាប់ពី ១ ម៉ោងឡើងទៅក្នុងមួយសប្តាហ៍ (សម្រាប់កុមារអាយុ ៥-១១ ឆ្នាំ) ពាក់ព័ន្ធក្នុងសកម្មភាពសេដ្ឋកិច្ចដែលអាចអនុញ្ញាតបាន (មិនបង្កគ្រោះថ្នាក់) ក្នុងរយៈពេលលើស ១២ ម៉ោងក្នុងមួយសប្តាហ៍ ឬតិចជាង ១២ ម៉ោង ប៉ុន្តែធ្វើការក្នុងឧស្សាហកម្ម និងការងារដែលត្រូវបានកំណត់ថាមានគ្រោះថ្នាក់ (សម្រាប់កុមារអាយុ ១២-១៤ ឆ្នាំ) ឬប្រឡូកក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងរយៈពេលលើស ៤៨ ម៉ោងក្នុងមួយសប្តាហ៍ ឬតិចជាង ៤៨ ម៉ោង ប៉ុន្តែធ្វើការក្នុងឧស្សាហកម្ម និងការងារដែលត្រូវបានកំណត់ថាមានគ្រោះថ្នាក់ (សម្រាប់កុមារអាយុ ១៥-១៧ ឆ្នាំ)។ ចំនួនសរុបនៃពលករជាកុមារ ជាចំនួនសរុបនៃកុមារដែលចាត់ចូលក្នុងប្រភេទទាំងនេះ (ILO, 2013)។

យោងតាមការអង្កេតស្តីពីកម្លាំងពលកម្ម និងពលកម្មកុមារនៅកម្ពុជា ឆ្នាំ ២០១២ គេប៉ាន់ស្មានថាកុមារចំនួន ៧៥៥.២៤៥ នាក់ (អាយុ ៥-១៧ ឆ្នាំ) ជាជនសកម្មសេដ្ឋកិច្ច (ស្មើនឹង ១៩,១ ភាគរយនៃចំនួនកុមារសរុប)។ ក្នុងនោះកុមារចំនួន ២៧៦.០០០ នាក់មានអាយុក្រោម ១៥ ឆ្នាំ។ ក្នុងចំណោមកុមារដែលសកម្មសេដ្ឋកិច្ច មាន ៥៦,៩ ភាគរយជាពលករកុមារ និង ៣១,១ ភាគរយ ត្រូវធ្វើការងារគ្រោះថ្នាក់ (ILO, 2013)។

ផ្អែកតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា គេមិនអាចកំណត់ចំនួនពលករជាកុមារបានឡើយ ព្រោះគ្មានការសួរសំណួរស្តីពីទំហំ ឬភាពគ្រោះថ្នាក់នៃការងារដែលពួកគេធ្វើ។ ផ្ទុយទៅវិញ ជំរឿននេះផ្តល់លទ្ធភាពសម្រាប់ការវិភាគស្តីពីសកម្មភាពសេដ្ឋកិច្ចសម្រាប់ប្រជាជនអាយុ ៥-១៧ ឆ្នាំ ដែលធ្វើការលើស ៦ ខែក្នុងរយៈពេល ១២ ខែមុនជំរឿន (អាចកំណត់ជា "ការងារកុមារ")។

រូប ១០.៤ រៀបរាប់ពីភាគរយកុមារអាយុ ៥-១៧ ឆ្នាំដែលជាទូទៅធ្វើការនៅអំឡុងឆ្នាំមុនជំរឿន បែងចែកតាមភេទ និងកម្រិតពិការភាព។ ក្រាហ្វនេះបង្ហាញថា ភាគរយនៃការងារកុមារគឺ ៧,៨ ភាគរយ សម្រាប់ក្មេងប្រុស និង ៦,៤ ភាគរយសម្រាប់ក្មេងស្រី។ គួរកត់សម្គាល់ថា ភាគរយទាំងនេះមានកម្រិតទាបខ្លាំងជាងភាគរយដែលរកឃើញក្នុងការអង្កេតស្តីពីកម្លាំងពលកម្ម និងពលកម្មកុមារនៅកម្ពុជា ឆ្នាំ ២០១២ ដែលការងារកុមារមានចំនួន ១៩,១ ភាគរយ (ILO, 2013)។ គេមិនដឹងច្បាស់ពីមូលហេតុនៃភាពខុសគ្នានេះទេ ប៉ុន្តែវាអាចដោយសារតែតួលេខក្នុងការអង្កេតស្តីពីពលកម្មកុមារ ផ្អែកលើស្ថានភាពការងារបច្ចុប្បន្ន (ឧ. ក្នុងរយៈពេល ១ សប្តាហ៍មុនពេលសម្ភាសន៍) ខណៈដែលទិន្នន័យជំរឿនផ្អែកលើស្ថានភាពទូទៅ ដែលកំណត់ថា កុមារត្រូវធ្វើការលើស ៦ ខែក្នុងអំឡុងឆ្នាំនោះ (យ៉ាងតិច ៦ ខែ) ដើម្បីអាចកំណត់ថា មានការងារធ្វើ។ មានភាពខុសគ្នាតិចតួចរវាងភាគរយនៃកុមារមិនពិការ និងកុមារមានពិការភាពខ្លះ ឬពិការខ្លាំង និងមានភាពខុសគ្នាតិចតួចក្នុងចំណោមកុមារពិការមិនអាចធ្វើអ្វីបាន។ ពោលគឺភាគរយនៃកុមារដែលកំពុងធ្វើការ មានកម្រិតទាបជាងនេះ។ ទោះបីជាការអង្កេតស្តីពីកម្លាំងពលកម្ម និងពលកម្មកុមារនៅកម្ពុជា ឆ្នាំ ២០១២ បញ្ចូលសំណួររបស់ក្រុមការងារវ៉ាស៊ីនតោនស្តីពីពិការភាពក្តី ប៉ុន្តែគ្មានការវិភាគអំពីស្ថានភាពរបស់កុមារ និងយុវជនមានពិការភាពក្នុងកម្លាំងពលកម្មទេ (ILO, 2013)។

រូប ១០.៤ ៖ ភាគរយកុមារអាយុក្រោម ១៨ ឆ្នាំ ដែលជាទូទៅធ្វើការនៅអំឡុងឆ្នាំមុនពេលជំរឿន បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

វិធីដ៏សំខាន់មួយទៀតក្នុងការពិនិត្យមើលស្ថានភាពរបស់យុវជនក្នុងទីផ្សារការងារ គឺភាគរយរបស់យុវជន (អាយុ ១៥-២៤ ឆ្នាំ) ដែល "មិនកំពុងទទួលបានការអប់រំ មានការងារធ្វើ ឬទទួលបានការបណ្តុះបណ្តាល" (NEET)។ ជំរឿនឆ្នាំ ២០១៩ ប្រមូលព័ត៌មានស្តីពីស្ថានភាពការងារ និងការចូលរៀននៅសាលារបស់យុវជន ប៉ុន្តែគ្មានសំណួរស្តីពីប្រភេទការបណ្តុះបណ្តាលផ្សេងទៀត។ ដូច្នេះ ការវិភាគនេះផ្តោតសំខាន់លើយុវជនដែលមិនកំពុងទទួលបានការអប់រំ ឬមានការងារធ្វើ (NEE) ទោះបីជាគេអាចប្រើប្រាស់ NEE សម្រាប់ការប៉ាន់ស្មាន NEET ក្តី។ យោងតាមជំរឿនឆ្នាំ ២០១៩ NEE សម្រាប់ប្រជាជនអាយុ ១៥-២៤ ឆ្នាំ គឺ ៨,២ ភាគរយ (៧,០ ភាគរយសម្រាប់បុរសវ័យក្មេង និង ៩,៣ ភាគរយសម្រាប់ស្ត្រីវ័យក្មេង)។

រូប ១០.៥ បង្ហាញថា នៅពេលកម្រិតពិការភាពកើនឡើង ចំនួនយុវជនដែលមិនកំពុងទទួលបានការអប់រំ ឬមានការងារធ្វើ ក៏កើនឡើងផងដែរ។ ក្នុងចំណោមយុវជនមិនពិការដែលមានអាយុ ១៥-១៩ ឆ្នាំ មាន ៧ ភាគរយ មិនកំពុងទទួលបានការអប់រំ ឬមានការងារធ្វើ។ សម្រាប់យុវជនទាំងពីរភេទដែលមានពិការភាពខ្លះ អត្រា NEE គឺ ១៨ ភាគរយ។ ភាគរយគឺខ្ពស់ជាងនេះ សម្រាប់ប្រជាជនមានពិការភាពខ្លាំង (៤៤,៨ ភាគរយសម្រាប់បុរស និង ៤៣,៦ ភាគរយសម្រាប់ស្ត្រី) និងថយចុះសម្រាប់ប្រជាជនពិការមិនអាចធ្វើអ្វីបាន។ អត្រា NEE សម្រាប់បុរសវ័យក្មេង (១៥-១៩ ឆ្នាំ) ដែលពិការមិនអាចធ្វើអ្វីបាន គឺ ៤១,៨ ភាគរយ (ទល់នឹង ៣៧,៧ ភាគរយសម្រាប់ស្ត្រីវ័យក្មេង)។ សម្រាប់ស្ត្រីមិនពិការដែលអត្រា NEE កើនពី ៧,៥ ភាគរយ ដល់ ១១,០ ភាគរយ រវាងក្រុមអាយុ ១៥-១៩ ឆ្នាំ និងក្រុមអាយុ

២០-២៤ ឆ្នាំ NEE សម្រាប់កម្រិតពិការភាពផ្សេងទៀត ថយចុះ នៅពេលប្រៀបធៀបរវាងក្រុមអាយុ ១៥-១៩ ឆ្នាំ និងក្រុមអាយុ ២០-២៤ ឆ្នាំ។ ចំណុចនេះអាចដោយសារតែនៅពេលយុវជនមានអាយុកាន់តែច្រើន លទ្ធភាពមានការងារធ្វើក៏កើនឡើងផងដែរ ព្រោះពួកគេប្រឡូកក្នុងទីផ្សារការងារ។ ភាគរយ NEE បង្ហាញយ៉ាងច្បាស់ពីស្ថានភាពចាញ់ប្រៀបរបស់ប្រជាជនមានពិការភាពក្នុងទីផ្សារការងារ។

*រូប ១០.៥ ៖ ភាគរយយុវជន “ដែលមិនកំពុងទទួលបានការអប់រំ ឬមានការងារធ្វើ” បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩*




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ១០.៤ អាពាហ៍ពិពាហ៍កុមារ

ដើម្បីការពារក្មេងស្រីពីអំពើហិង្សាផ្លូវភេទ និងការអនុវត្តផ្សេងទៀតក្នុងសង្គមដែលបង្កគ្រោះថ្នាក់ ឪពុកម្ដាយមួយចំនួនចង់កាត់បន្ថយហានិភ័យទាំងនេះដោយរៀបការកូនស្រីនៅវ័យក្មេង។ អាពាហ៍ពិពាហ៍កុមារ (ប្ដី/ប្រពន្ធ ឬទាំងប្ដី និងប្រពន្ធរៀបការមុនអាយុ ១៨ ឆ្នាំ) ជាការគំរាមយ៉ាងធ្ងន់ធ្ងរលើជីវិតរស់នៅ សុខភាព និងអនាគតរបស់ក្មេងស្រី និងជាការរំលោភសិទ្ធិមនុស្សរបស់ពួកគេផងដែរ។ ទោះជាយ៉ាងណា នេះជាតថភាពជីវិតសម្រាប់គ្រួសារជាច្រើនក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ ២០១៩ កុមារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកចំនួន ២៦ ភាគរយ រៀបការនៅអាយុ ១៨ ឆ្នាំ (UNFPA, 2020)។ អាយុរៀបការស្របច្បាប់ក្នុងប្រទេសកម្ពុជាគឺ ១៨ ឆ្នាំសម្រាប់ក្មេងស្រី និង ២០ ឆ្នាំសម្រាប់ក្មេងប្រុស ប៉ុន្តែនៅពេលមានការយល់ព្រមពីឪពុកម្ដាយ ឬអាណាព្យាបាល ពួកគេអាចរៀបការនៅអាយុក្មេងជាងនេះបាន។ គ្មានភាពខុសគ្នាជាអន្តរជាតិរវាងក្មេងប្រុស និងក្មេងស្រីឡើយ ហើយកម្រិតអាយុសម្រាប់ទាំងពីរភេទគឺ ១៨ ឆ្នាំ (រដ្ឋសភានៃរដ្ឋកម្ពុជា ១៩៨៩)។

រូបខាងក្រោមបង្ហាញពីអត្រាអាពាហ៍ពិពាហ៍កុមារ (ទាំងពីរភេទ) ទៅតាមស្ថានភាពពិការភាពរបស់ពួកគេ។ ការវិភាគផ្អែកតាមអាយុរៀបការស្របច្បាប់ (១៨ ឆ្នាំសម្រាប់ស្ត្រីវ័យក្មេង និង ២០ ឆ្នាំសម្រាប់បុរសវ័យក្មេង)។ ក្នុងរបាយការណ៍នេះ អត្រាអាពាហ៍ពិពាហ៍កុមារសំដៅលើភាគរយរបស់ស្ត្រីអាយុ ២០-២៤ ឆ្នាំ ដែលបានរៀបការមុនអាយុ ១៨ ឆ្នាំ។ សម្រាប់បុរស គេកំណត់យកអាយុ ២០ ឆ្នាំ។ ជាញឹកញាប់ ក្រៅពីអាយុ ១៨ ឆ្នាំ គេកំណត់អាយុ ១៥ ឆ្នាំជាចំណុចគោលសម្រាប់វាស់វែងការរៀបការវ័យក្មេង។ ទោះជាយ៉ាងណា ក្នុងជំរឿនឆ្នាំ ២០១៩ អាយុអប្បបរមានៅពេលរៀបការលើកដំបូងគឺ ១៦ ឆ្នាំ។ ដូច្នេះ គេមិនអាចគណនាអត្រានេះបានឡើយ។

រូប ១០.៦ បង្ហាញពីភាគរយនៃបុរស និងស្ត្រីដែលរៀបការមុនអាយុស្របច្បាប់នៅកម្ពុជា (១៨ ឆ្នាំសម្រាប់ស្ត្រី និង ២០ ឆ្នាំសម្រាប់បុរស) បែងចែកតាមកម្រិតពិការភាព។ ការរៀបការវ័យក្មេងមានអត្រាខ្ពស់ក្នុងចំណោមស្ត្រីជាងក្នុងចំណោមបុរស ៖ ក្នុងចំណោមស្ត្រីអាយុ ២០-២៤ ឆ្នាំដែលមិនពិការ មាន ១៤,៩ ភាគរយ បានរៀបការមុនអាយុ ១៨ ឆ្នាំ ធៀបនឹងបុរសចំនួន ៨,១ ភាគរយ ដែលរៀបការមុនអាយុ ២០ ឆ្នាំ។ សម្រាប់ទាំងពីរភេទ ប្រជាជនមានពិការភាពខ្លះ មានអត្រារៀបការវ័យក្មេង ខ្ពស់បន្តិចជាងប្រជាជនមិនពិការ ប៉ុន្តែមានកម្រិតទាបសម្រាប់ប្រជាជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន។

រូប ១០.៦ ៖ ភាគរយប្រជាជនអាយុ ២០-២៤ ឆ្នាំដែលបានរៀបការមុនអាយុរៀបការស្របច្បាប់ (១៨ ឆ្នាំសម្រាប់ស្ត្រី និង ២០ ឆ្នាំសម្រាប់បុរស) បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

រូប ១០.៧.ក ៖ ភាគរយស្ត្រីដែលបានរៀបការមុនអាយុ ១៨ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

រូប ១០.៧.ខ ៖ ភាគរយបុរសដែលបានរៀបការមុនអាយុ ២០ ឆ្នាំ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ដើម្បីពិនិត្យមើលនិន្នាការពីពេលមួយទៅពេលមួយ ក្នុងក្រុមអាយុ ៥ ឆ្នាំនីមួយៗ មានការគណនាភាគរយនៃស្ត្រី និងបុរសដែលរៀបការមុនអាយុ ១៨ ឆ្នាំ (ស្រី) និងមុនអាយុ ២០ ឆ្នាំ (ប្រុស) សម្រាប់ប្រភេទពិការភាពនីមួយៗ។ លទ្ធផលមានបង្ហាញក្នុងរូប ១០.៧.ក និង ១០.៧.ខ។ ក្រាហ្វទាំងពីរនេះបង្ហាញយ៉ាងច្បាស់ថា ភាគរយនៃអាពាហ៍ពិពាហ៍កុមារពីមុន មានអត្រាខ្ពស់សម្រាប់ពិការភាពទាំង ៤ ប្រភេទ។ ឧ. ខណៈដែលស្ត្រីអាយុ ២០-២៤ ឆ្នាំ ចំនួន ១៦,៣ ភាគរយ បានរៀបការមុនអាយុ ១៨ ឆ្នាំ អត្រានេះគឺ ២១,២ ភាគរយសម្រាប់ស្ត្រីអាយុ ៤០-៤៤ ឆ្នាំ។ គេមិនច្បាស់ពីមូលហេតុដែលធ្វើឱ្យមានការថយចុះអត្រាអាពាហ៍ពិពាហ៍វ័យក្មេងក្នុងចំណោមពិការភាពគ្រប់កម្រិត សម្រាប់បុរសក្នុងក្រុមអាយុ ៦០-៦៤ ឆ្នាំឡើយ។ ទំនោរនៃការរៀបការវ័យក្មេងកាន់តែច្រើនក្នុងចំណោមប្រជាជនមានពិការភាពខ្លាំងធៀបនឹងប្រជាជនមិនពិការ មិនត្រឹមតែស្តែងឡើងនាពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្លាប់លេចឡើងតាំងពីមុនមកផងដែរ។ ផ្នែកដ៏សំខាន់ដែលត្រូវចងចាំគឺ ស្ថានភាពពិការភាពរបស់មនុស្សម្នាក់ជាលក្ខណៈដែលត្រូវបានវាស់វែងនៅពេលធ្វើជំរឿន។ ផ្ទុយទៅវិញ អាយុនៅពេលរៀបការជាអ្វីដែល (យ៉ាងហោចណាស់សម្រាប់អាយុវ័យចាស់) បានកើតឡើងជាច្រើនឆ្នាំមកហើយ។ ប្រជាជនដែលមានអាយុកាន់តែច្រើន និងកំពុងមានពិការភាព អាចគ្មានពិការភាពនៅពេលរៀបការ។ នេះអាចជាមូលហេតុដែលធ្វើឱ្យភាគរយប្រជាជនទាំងពីរភេទដែលបានរៀបការមុនអាយុស្របច្បាប់ (១៨ និង ២០ ឆ្នាំ) ប្រហាក់ប្រហែលនឹងភាគរយសម្រាប់ប្រជាជនមិនពិការ ក្រោយអាយុ ៥០-៥៥ ឆ្នាំ។ ទោះជាយ៉ាងណា (ជាពិសេសស្ត្រី) មានភាពខុសគ្នារវាងក្រុមអាយុទាំងអស់ និងគូសបញ្ជាក់ថា កន្លងមក មិនសូវមានអាពាហ៍ពិពាហ៍កុមារក្នុងចំណោមក្មេងប្រុស និងក្មេងស្រីដែលពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបានឡើយ។

# ជំពូក ១១៖ មនុស្សចាស់ និងពិការភាព

ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនវ័យចាស់ គឺជាបាតុភូតសកល។ គិតត្រឹមឆ្នាំ ២០៥០ គេរំពឹងថា ប្រជាជនទូទាំងពិភពលោកចំនួន ២១ ភាគរយ នឹងមានអាយុលើស ៦០ ឆ្នាំ។ មនុស្សចាស់ (៦០ ឆ្នាំឡើងទៅ) ស្ថិតក្នុងចំណោមប្រជាជនជួបការលំបាកបំផុតក្នុងពិភពលោក ហើយនឹងក្លាយជាក្រុមអាយុធំជាងគេដែលមានពិការភាព។ ក្នុងប្រទេសជាច្រើន ប្រេវ៉ាឡង់ពិការភាពកើនឡើងតាមអាយុ និងមានអត្រាខ្ពស់ក្នុងចំណោមក្រុមអាយុវ័យចាស់។ ការរើសអើងផ្អែកតាមអាយុរបស់មនុស្ស និងការរើសអើងដែលលម្អៀងទៅរកជនមិនពិការ នឹងបង្កើនការរំលោភសិទ្ធិមនុស្សចាស់ក្នុងផ្នែកជាច្រើន (អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនមានពិការភាព ២០១៩)។

នៅចន្លោះឆ្នាំ ២០០៥ និងឆ្នាំ ២០១៥ អាយុសង្ឃឹមរស់ក្នុងប្រទេសកម្ពុជា កើនពី ៦០,៨ ឆ្នាំ ដល់ ៦៧,៦ ឆ្នាំ[19]។ ដោយសារតែស្ត្រីមានអាយុសង្ឃឹមរស់ខ្ពស់ជាងបុរស (៦៩,៦ ឆ្នាំ ទល់នឹង ៦៥,៥ ឆ្នាំ) ស្ត្រីវ័យចាស់ក៏ងាយរងគ្រោះជាងបុរសវ័យចាស់ផងដែរ (ឧ. ការផាត់ចេញ ការរំលោភបំពាន និងការផ្តាច់ខ្លួនពីសង្គម)។ នៅពេលប្រជាជនមានអាយុកាន់តែវែង ចំនួនប្រជាជនសរុបនឹងមានអត្រាកាន់តែខ្ពស់នៃប្រជាជនវ័យចាស់ដែលមានពិការភាព។ ដូច្នេះ គោលនយោបាយ និងការរៀបចំផែនការគួររំលេចគំរូប្រែប្រួលនេះដើម្បីធានាភាពប្រសព្វគ្នារវាងប្រជាជនវ័យចាស់ និងពិការភាព (UNDESA, n.d.a)។ មនុស្សចាស់ដែលមានពិការភាព គឺងាយរងគ្រោះ។ ឧ. ក្រោយភាពសកម្មក្នុងសេដ្ឋកិច្ចអស់រយៈពេលជាច្រើនឆ្នាំ ពួកគាត់ងាយរងគ្រោះក្នុងសេដ្ឋកិច្ច ព្រោះពួកគាត់មានប្រាក់សោធនតិច ឬលែងមានប្រភពប្រាក់ចំណូល និងអាចរស់នៅពឹងផ្អែកលើកូន ឬសាច់ញាតិផ្សេងទៀត។ ដោយសារពិការភាព មនុស្សចាស់អាចពឹងផ្អែកទាំងស្រុងលើជំនួយពីអ្នកដទៃក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ។ ការដែលស្ត្រីមានកូនតិច មានន័យថា នៅពេលអនាគត មនុស្សវ័យចាស់ដែលមានពិការភាពនឹងមិនសូវមានកូនចាំមើលថែ។ ទាំងនេះជាចំណុចសំខាន់ៗដែលត្រូវពិចារណា ដើម្បីធានាសុខុមាលភាពរបស់មនុស្សចាស់ដែលមានពិការភាព។

## ១១.១ ប្រភេទគ្រួសារ

ដោយសារជារឿយៗ មនុស្សចាស់ដែលមានពិការភាពត្រូវការជំនួយ ពួកគាត់គួររស់នៅក្នុងគ្រួសារដែលមានមនុស្សចាំជួយមើលថែ។ នេះជាចំណុចសំខាន់ក្នុងបរិបទកម្ពុជា ព្រោះមិនសូវមានមនុស្សចាស់ដែលមានពិការភាពរស់នៅក្នុងគ្រួសារស្ថាប័នឡើយ។ ក្នុងសង្គមជាច្រើន មនុស្សចាស់ ជាពិសេសមនុស្សចាស់ដែលមានពិការភាព ច្រើនតែផ្លាស់ទៅរស់នៅក្នុងផ្ទះចូលនិវត្តន៍នៅអាយុជាក់លាក់។ ក្នុងកម្ពុជា គ្មានគំរូរស់នៅបែបនេះឡើយ។ យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ក្នុងចំណោមប្រជាជនអាយុ ៦០ ឆ្នាំឡើង មានតែ ១,១ ភាគរយប៉ុណ្ណោះដែលរស់នៅក្នុងគ្រួសារស្ថាប័នប្រភេទណាមួយ។ ១,១ ភាគរយនៃមនុស្សចាស់ដែលមានពិការភាពខ្លះ, ០,៩ ភាគរយនៃមនុស្សចាស់ដែលមានពិការភាពខ្លាំង និង ០,៧ ភាគរយនៃមនុស្សចាស់ដែលពិការមិនអាចធ្វើអ្វីបាន រស់នៅក្នុងគ្រួសារស្ថាប័ន។ គួរកត់សម្គាល់ថា ក្នុងជំរឿននេះ គ្មានការកំណត់ភាពខុសគ្នារវាងប្រភេទគ្រួសារស្ថាប័នផ្សេងៗឡើយ ហើយតួលេខទាំងនេះក៏រួមបញ្ចូលប្រភេទស្ថាប័នផ្សេងទៀតផងដែរ (ឧ. ផ្ទះជួល សណ្ឋាគារខ្នាតតូច អាផាតមិន ផ្ទះសង្គ្រោះ ពន្ធនាគារ វត្តអារ៉ាម)។ សម្រាប់កម្រិតពិការភាពនីមួយៗ ភាគរយបុរសដែលរស់នៅក្នុងគ្រួសារស្ថាប័នគឺខ្ពស់ជាងស្ត្រី។ ឧ. ក្នុងចំណោមបុរសអាយុលើស ៦០ ឆ្នាំ ដែលពិការមិនអាចធ្វើអ្វីបាន មាន ០,៩ ភាគរយ រស់នៅក្នុង

---

19 - តួលេខស្តីពីអាយុសង្ឃឹមរស់ ដកស្រង់ពីគេហទំព័ររបស់ UNSTAT ៖ https://data.un.org/_Docs/SYB/PDFs/SYB201907_246_62_Population20%growth20%and20%indicators20%of20%fertility20%and20%mortality.pdf

គ្រួសារស្ថាប័ន (ទល់នឹង ០,៧ ភាគរយសម្រាប់ស្ត្រី)។ គេអាចរំពឹងថា ចំនួនមនុស្សចាស់នឹងកើនឡើងតាមអាយុ ប៉ុន្តែជំរឿននេះមិនបង្ហាញពីការកើនឡើងជាក់ស្តែងនៃចំនួនមនុស្សចាស់ដែលរស់នៅក្នុងគ្រួសារស្ថាប័នឡើយ។

មនុស្សចាស់ដែលមានពិការភាព គឺងាយរងគ្រោះ ប្រសិនបើគាត់រស់នៅតែម្នាក់ឯង ហើយមនុស្សចាស់មានពិការភាព ដែលរស់នៅជាមួយដៃគូម្នាក់ដែលជាទូទៅមានអាយុស្របាលគ្នា និងអាចមានបញ្ហាក្នុងការមើលថែដៃគូដែលមានពិការភាព ក៏អាចនឹងងាយរងគ្រោះផងដែរ។ រូប ១១.១ បង្ហាញថា ក្នុងចំណោមប្រជាជនអាយុ ៦០ ឆ្នាំឡើង ប្រជាជនមានពិការភាពខ្លាំងចំនួន ៦,៩ ភាគរយ និងប្រជាជនពិការមិនអាចធ្វើអ្វីបានចំនួន ៥,៦ ភាគរយ រស់នៅតែម្នាក់ឯង (គ្មានសមាជិកគ្រួសារ)។ គួរកត់សម្គាល់ថា ភាគរយនេះគឺកាន់តែខ្ពស់សម្រាប់មនុស្សចាស់ដែលមិនពិការ (៣,៨ ភាគរយ)។ សម្រាប់មនុស្សចាស់ដែលមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ភាគរយស្ត្រីដែលរស់នៅម្នាក់ឯងគឺខ្ពស់ជាងបុរស រហូតដល់ ២ ដង។

រូប ១១.១ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំដែលរស់នៅក្នុងគ្រួសារមានសមាជិកតែម្នាក់ ឬគ្រួសារដែលមានតែប្តី និងប្រពន្ធ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

មនុស្សចាស់ដែលមានពិការភាព (អាយុ ៦០ ឆ្នាំឡើង) ចំនួន ៩,៨ ភាគរយ រស់នៅក្នុងគ្រួសារដែលមានតែប្តី និងប្រពន្ធ។ ចំនួនស្ត្រីវ័យចាស់ដែលពិការ និងរស់នៅក្នុងគ្រួសារមានសមាជិកតែម្នាក់ ខ្ពស់ជាងចំនួនបុរសវ័យចាស់ដែលពិការ និងរស់នៅក្នុងគ្រួសារមានសមាជិកតែម្នាក់ ប៉ុន្តែមាននិន្នាការផ្ទុយពីនេះសម្រាប់មនុស្សចាស់មានពិការភាពដែលរស់នៅក្នុងគ្រួសារមានតែប្តី និងប្រពន្ធ។ ច្បាស់ណាស់ថា និន្នាការនេះពាក់ព័ន្ធនឹងអាយុសង្ឃឹមរស់ខ្ពស់របស់ស្ត្រីដែលធ្វើឱ្យស្ត្រីមានឱកាសខ្ពស់ក្នុងការរស់នៅជាស្ត្រីមេម៉ាយ និងរស់នៅម្នាក់ឯងក្នុងគ្រួសារ។ មានភាពខុសគ្នាខ្លាំងរវាងមនុស្សទាំងពីរភេទដែលរស់នៅក្នុងគ្រួសារដែលមានតែប្តី និងប្រពន្ធ ៖ អត្រាបុរសមានពិការភាពខ្លាំងដែលរស់នៅ

ក្នុងគ្រួសារនេះ គឺ ១៤,៤ ភាគរយ ទល់នឹង ៥,៤ ភាគរយសម្រាប់ស្ត្រីមានពិការភាព។

រូប ១១.២ បង្ហាញថា និន្នាការនៃការរស់នៅម្នាក់ឯងក្នុងចំណោមមនុស្សចាស់ អាស្រ័យលើអាយុ។ ចាប់ពីអាយុ ៦០ ឆ្នាំ រហូតដល់អាយុ ៧៥-៧៩ ឆ្នាំ ភាគរយនៃប្រជាជនមិនពិការ ឬពិការខ្លះ ឬពិការខ្លាំង កើនឡើងយ៉ាងខ្លាំង ប៉ុន្តែថយចុះក្រោយអាយុទាំងនេះ។ ភាគរយខ្ពស់បំផុតគឺក្នុងចំណោមប្រជាជនអាយុ៧៥-៧៩ ឆ្នាំដែលពិការខ្លាំង។ នៅវ័យនេះ ៨,៤ ភាគរយនៃប្រជាជនទាំងអស់ដែលពិការខ្លាំង រស់នៅម្នាក់ឯង (ម្នាក់ក្នុងចំណោម ១២ នាក់)។ ភាគរយនៃគ្រួសារដែលមានសមាជិកតែម្នាក់ ក្នុងចំណោមប្រជាជនពិការមិនអាចធ្វើអ្វីបាន ថយចុះសម្រាប់ក្រុមអាយុ ៦៥-៦៩ ឆ្នាំ។ សម្រាប់ក្រុមអាយុទាំងអស់ ប្រជាជនមិនពិការ មានអត្រាទាបនៃការរស់នៅម្នាក់ឯងក្នុងគ្រួសារដែលមានសមាជិកតែម្នាក់។ នេះអាចជាចំណុចដ៏គួរឱ្យភ្ញាក់ផ្អើល ព្រោះគេរំពឹងថា ប្រជាជនពិការមិនអាចធ្វើអ្វីបាន នឹងមានអត្រាទាបនៃការរស់នៅដោយខ្លួនឯង ជាងប្រជាជនមិនពិការ។ គេនឹងរំពឹងថាមនុស្សចាស់ដែលពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន នឹងមិនសូវរស់នៅម្នាក់ឯងដូចប្រជាជនមិនពិការ (ពិការខ្លះ) ឡើយ ព្រោះពួកគាត់ត្រូវការជំនួយក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ ប៉ុន្តែនេះមិនមែនជាការពិតនោះទេ។ ផ្ទុយទៅវិញ ប្រជាជនពិការមិនអាចធ្វើអ្វីបាន ច្រើនតែមិនរៀបការ។ ដូច្នេះ ពួកគាត់មានប្រូបាប៊ីលីតេខ្ពស់នៃការរស់នៅម្នាក់ឯង។

មានមនុស្សចាស់ពិការយ៉ាងច្រើនដែលរស់នៅក្នុងគ្រួសារធំ។ ក្នុងចំណោមប្រជាជនអាយុ ៦០ ឆ្នាំចំនួន ៨៩.២៨២ នាក់ដែលពិការខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មាន ៦១.១០៥ នាក់រស់នៅក្នុងគ្រួសារធំ (៦៨,៤ ភាគរយ)។ រូប ១១.៣ បង្ហាញថា ស្ត្រីដែលមាន ឬគ្មានពិការភាព ច្រើនតែរស់នៅក្នុងគ្រួសារធំ ជាងបុរសវ័យចាស់។ មានភាពខុសគ្នាប្រហែល ១២ ភាគរយ រវាងប្រជាជនទាំងពីរភេទដែលពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន។

រូប ១១.២ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលរស់នៅម្នាក់ឯង បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

រូប ១១.៣ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំដែលរស់នៅក្នុងគ្រួសារធំ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ១១.២ ស្ថានភាពអាពាហ៍ពិពាហ៍

ការរៀបការនៅអាយុវ័យចាស់ ជាពិសេសប្រសិនបើមនុស្សម្នាក់មានពិការភាព អាចជួយដល់សុខភាព និងសុខុមាលភាពរបស់គាត់។ ដោយសារស្ត្រីមានអាយុសង្ឃឹមរស់ខ្ពស់ជាងបុរស ភាគរយស្ត្រីបានរៀបការដែលមានអាយុលើស ៦០ ឆ្នាំ មានអត្រាទាបជាងបុរស។ ក្នុងចំណោមបុរសអាយុ ៦០ ឆ្នាំឡើង មាន ៨៨,៩ ភាគរយ បានរៀបការ (ធៀបនឹង ៦២,៥ ភាគរយសម្រាប់ស្ត្រីអាយុ ៦០ ឆ្នាំ)។ រូប ១១.៤ បង្ហាញពីចំនួនប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលមិនបានរៀបការនៅពេលជំរឿន បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ ភេទ និងកម្រិតពិការភាព។ ក្រាហ្វនេះបង្ហាញថា ក) ភាគរយនៃប្រជាជនមេម៉ាយ/ពោះម៉ាយ និងលែងលះ/រស់នៅបែកគ្នាក្នុងចំណោមស្ត្រី គឺខ្ពស់ខ្លាំងជាងក្នុងចំណោមបុរស និង ខ) បុរស និងស្ត្រីមានពិការភាព មានលទ្ធភាពខ្ពស់នៃការបែកបាក់ចំណងអាពាហ៍ពិពាហ៍ ក្នុងទម្រង់ពោះម៉ាយ/មេម៉ាយ ឬការលែងលះ/ការរស់នៅបែកគ្នា។ ខណៈដែលស្ត្រីមិនពិការចំនួន ២៤,៣ ភាគរយ ក្លាយជាស្ត្រីមេម៉ាយនៅពេលជំរឿន អត្រានេះគឺ ៣៤,៨ ភាគរយសម្រាប់ស្ត្រីមានពិការភាពខ្លះ, ៤៤,៤ ភាគរយសម្រាប់ស្ត្រីពិការខ្លាំង និង ៤២,៦ ភាគរយសម្រាប់ស្ត្រីពិការមិនអាចធ្វើអ្វីបាន។ សម្រាប់បុរស អត្រានេះគឺ ១០,៤ ភាគរយសម្រាប់បុរសមានពិការភាពខ្លះ, ១៦,៦ ភាគរយសម្រាប់បុរសពិការខ្លាំង និង ១៦,៨ ភាគរយសម្រាប់បុរសពិការមិនអាចធ្វើអ្វីបាន។ ភាគរយនៃការលែងលះ/រស់នៅបែកគ្នាក្នុងចំណោមប្រជាជនមានពិការភាព គឺខ្ពស់ជាងក្នុងចំណោមប្រជាជនមិនពិការ។

រូប ១១.៤ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើង ដែលបច្ចុប្បន្នមិនទាន់រៀបការ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ និង កម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ក្រុមប្រជាជនអាយុ ៦០ ឆ្នាំឡើង ជាក្រុមចម្រុះដែលរួមបញ្ចូលប្រជាជនអាយុ ៦០ ឆ្នាំ ដែលនៅ "ក្មេង" និង មានភាពសកម្ម និងប្រជាជនអាយុចាស់ជាងនេះដែលអាចពឹងផ្អែកទាំងស្រុងលើជំនួយខាងក្រៅ។ នៅពេលវ័យកាន់តែចាស់ មានឱកាសកាន់តែខ្ពស់នៃការបាត់បង់ប្តី/ប្រពន្ធ។ រូប ១១.៥ បង្ហាញពីកើនឡើងយ៉ាងគំហុកនៃចំនួនប្រជាជនមេម៉ាយ/ពោះម៉ាយ ក្នុងក្រុមអាយុ ៦០ ឆ្នាំ និង ៨០ ឆ្នាំឡើង។ ខណៈដែលប្រជាជនមានពិការភាពខ្លាំងក្នុងក្រុមអាយុ ៦០-៦៤ ឆ្នាំ ចំនួន ១៦.៣ ភាគរយ បានបាត់បង់ប្តី/ប្រពន្ធ អត្រានេះគឺ ៤៤,៥ ភាគរយក្នុងក្រុមអាយុ ៨០-៨៤ ឆ្នាំ។ គួរកត់សម្គាល់ថា សម្រាប់ប្រជាជនពិការ ចំនួនប្រជាជនមេម៉ាយ/ពោះម៉ាយមានអត្រាខ្ពស់ក្នុងក្រុមអាយុទាំងអស់ ជាងប្រជាជនមិនពិការ។ គ្មានមូលហេតុច្បាស់លាស់នោះទេ ប៉ុន្តែវាអាចបណ្តាលមកពីកត្តាដែលពាក់ព័ន្ធនឹងការមានពិការភាព ដូចជា កង្វះការថែទាំសុខភាព ភាពក្រីក្រ កង្វះទឹកស្អាត និងអនាម័យ ឬអាហារូបត្ថម្ភ ដែលសុទ្ធតែពាក់ព័ន្ធនឹងការបាត់បង់ដៃគូ និងឱកាសខ្ពស់នៃការមានពិការភាព។ ទិន្នន័យទាំងនេះបង្ហាញយ៉ាងច្បាស់ថា នៅដំណាក់កាលក្រោយមកទៀតក្នុងជីវិត ប្រជាជនជាច្រើនមិនត្រឹមតែត្រូវប្រឈមនឹងបញ្ហារាងកាយ និងបញ្ហាផ្លូវចិត្ត ដែលបង្កដោយកម្រិតពិការភាពផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់ក៏ប្រហែលជាត្រូវប្រឈមមុខជាមួយនឹងការបាត់បង់ដៃគូជីវិតផងដែរ។

រូប ១១.៥ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលពោះម៉ាយ/មេម៉ាយ បែងចែកតាមកម្រិតពិការភាព និងអាយុ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

រូប ១១.៦ បង្ហាញពីភាពខុសគ្នារវាងប្រជាជនទាំងពីរភេទដែលមេម៉ាយ/ពោះម៉ាយ បែងចែកតាមអាយុ ភេទ និងកម្រិតពិការភាព។ ក្រាហ្វនេះបង្ហាញយ៉ាងច្បាស់ថា មានគំរូដូចគ្នាសម្រាប់ប្រជាជនទាំងពីរភេទ រវាងកម្រិតពិការភាពទាំង ៤។ ក្រៅពីនេះ វាបង្ហាញថា ប្រជាជនមានពិការភាពក្នុងក្រុមអាយុទាំងអស់ ប្រឈមនឹងហានិភ័យខ្ពស់នៃការរស់នៅដោយមេម៉ាយ/ពោះម៉ាយ ធៀបនឹងបុរស និងស្ត្រីមិនពិការ។ ចំណុចដ៏គួរឱ្យកត់សម្គាល់មួយទៀតគឺ ស្ត្រី (មិនគិតស្ថានភាពពិការភាព) មានប្រូបាប៊ីលីតេនៃការបាត់បង់ដៃគូជីវិត ខ្ពស់ជាងបុរស។ ឧ. ក្នុងចំណោមស្ត្រីអាយុ ៧៥-៧៩ ឆ្នាំ ដែលពិការមិនអាចធ្វើអ្វីបាន មាន ៤៣,២ ភាគរយ ជាស្ត្រីមេម៉ាយនៅពេលធ្វើជំរឿន (ធៀបនឹងបុរសពោះម៉ាយចំនួន ១៤,៣ ភាគរយ)។ ភាពខុសគ្នានេះអាចដោយសារតែស្ត្រីមានអាយុសង្ឃឹមរស់វែងជាងបុរស ហើយជាទូទៅ បុរសមានអាយុចាស់ជាងស្ត្រី នៅពេលរៀបការ។

រូប ១១.៦ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើង ដែលពោះម៉ាយ/មេម៉ាយ បែងចែកតាមកម្រិតពិការភាព អាយុ និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ១១.៣ ភាពក្រីក្រ

គេអាចវាស់វែងភាពក្រីក្រក្នុងចំណោមប្រជាជនពិការ ដោយប្រើសន្ទស្សន៍ទ្រព្យសម្បត្តិ។ ភាគរយនៃប្រជាជនដែលជាសមាជិកនៃគ្រួសារស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត ២ (ទាបជាងគេ ៤០ ភាគរយ) យោងតាមកម្រិតពិការភាពរបស់ពួកគេ ត្រូវបានលើកមកពិចារណាក្នុងការវិភាគនេះ។ ប្រសិនបើគ្មានភាពខុសគ្នាពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរវាងពិការភាពទាំង ៤ កម្រិត ភាគរយសម្រាប់ប្រភេទពិការភាពនីមួយៗគឺត្រឹមតែ ៤០ ភាគរយប៉ុណ្ណោះ។ តម្លៃក្រោម ៤០ ភាគរយ មានន័យថា ប្រជាជនក្នុងប្រភេទនេះមិនសូវស្ថិតក្នុងក្រុមប្រជាជនក្រីក្របំផុតក្នុងសង្គម ចំណែកតម្លៃលើស ៤០ ភាគរយ មានន័យថា ក្រុមនេះមានប្រជាជនក្រីក្រច្រើន។ ដើម្បីជួយដល់ការប្រៀបធៀប រូប ១១.៧ បញ្ចូលប្រជាជនអាយុ ០-១៤ ឆ្នាំ និង ១៥-៥៩ ឆ្នាំ។ ខណៈដែលប្រជាជនមិនពិការអាយុ ៦០ ឆ្នាំឡើងចំនួន ៣៧,៧ ភាគរយ ស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត ២ អត្រានេះគឺ ៤៦,២ ភាគរយ សម្រាប់មនុស្សចាស់ដែលពិការខ្លាំង និង ៤៤,៧ ភាគរយ សម្រាប់ប្រជាជនពិការមិនអាចធ្វើអ្វីបាន។ គួរកត់សម្គាល់ថា ភាគរយនៃប្រជាជនដែលស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត ២ គឺប្រហាក់ប្រហែលគ្នានឹងប្រជាជនដែលស្ថិតក្នុងក្រុមអាយុ ១៥-៥៩ ឆ្នាំ និង ៦០ ឆ្នាំឡើង។ មានតែប្រជាជនអាយុក្រោម ១៥ ឆ្នាំប៉ុណ្ណោះដែលមានអត្រាខ្ពស់នៃការស្ថិតក្នុងក្រុមមានទ្រព្យសម្បត្តិទាប ជាងក្រុមអាយុវ័យចាស់ ប្រសិនបើពួកគេមិនពិការ ឬមានពិការភាពខ្លះ។

រូប ១១.៧ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត ២ បែងចែកតាមកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ១១.៤ ការចូលរួមក្នុងកម្លាំងពលកម្ម

ប្រជាជនអាយុ ៦០ ឡើងនៅតែចូលរួមយ៉ាងច្រើនក្នុងកម្លាំងពលកម្មនៅកម្ពុជា។ យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ក្នុងចំណោមប្រជាជនអាយុ ៦០ ឡើងចំនួន ១.៣៧៨.៦៨៨ នាក់ មាន ៨១២.៥៦០ នាក់ មានការងារធ្វើ (ស្មើនឹង ៥៩,៤ ភាគរយ[20] នៃចំនួនប្រជាជនអាយុ ៦០ ឆ្នាំឡើង) និង ៩.៤៤៦ នាក់ផ្សេងទៀតគ្មានការងារធ្វើ។ ដូច្នេះ អត្រាគ្មានការងារធ្វើសម្រាប់ក្រុមអាយុនេះគឺ ១,១ ភាគរយ។ តួលេខទាំងនេះផ្អែកតាមស្ថានភាពទូទៅរបស់ប្រជាជនក្នុងរយៈពេល ១២ ខែ មុនជំរឿន។ ទោះបីជាការមានការងារធ្វើក្នុងចំណោមប្រជាជនវ័យចាស់មិនកំណត់ត្រឹមប្រជាជនដែលគ្មានការលំបាកបំពេញមុខងារក្តី ប៉ុន្តែកម្រិតនៃការមានការងារធ្វើរបស់មនុស្សចាស់នៅតែអាស្រ័យលើកម្រិតពិការភាពរបស់ពួកគាត់។ ខណៈដែល ២/៣ នៃមនុស្សចាស់ដែលមិនពិការ មានការងារធ្វើ អត្រានេះគឺត្រឹមតែ ៤៤,២ ភាគរយសម្រាប់ជនមានពិការភាពខ្លះ, ២៥,៥ ភាគរយសម្រាប់ជនមានពិការភាពខ្លាំង និង ១៩,៣ ភាគរយសម្រាប់ជនពិការមិនអាចធ្វើអ្វីបាន (រូប ១១.៨)។ ក្នុងក្រុមពិការភាពនីមួយៗ កម្រិតនៃការមានការងារធ្វើសម្រាប់បុរសគឺខ្ពស់ខ្លាំងជាងស្ត្រី។ ឧ. ៣៤,៨ ភាគរយនៃបុរសមានពិការភាពខ្លាំងមានការងារធ្វើ ធៀបនឹង ២០,៨ ភាគរយនៃស្ត្រីមានពិការភាពខ្លាំង។

20 - *ភាគរយនេះពិចារណាពីស្ថានភាពសកម្មភាពមិនច្បាស់លាស់សម្រាប់ប្រជាជនចំនួន ១០.៩៩៣ នាក់។*

រូប ១១.៨ ៖ ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើងដែលមានការងារធ្វើ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ការពិនិត្យមើលភាពខុសគ្នានៃអត្រាមានការងារធ្វើរវាងកម្រិតពិការភាពផ្សេងៗ ក្នុងចំណោមប្រជាជនអាយុ ៦០ ឆ្នាំឡើង ងាយនាំទៅរកការបកស្រាយខុស ព្រោះជាមធ្យម ប្រជាជនពិការ មានអាយុចាស់ជាងប្រជាជនមិនពិការ។ នៅពេលរួមបញ្ចូលកត្តាអាយុ ភាគរយប្រជាជនដែលមានការងារធ្វើ រំលេចដោយក្រុមអាយុ ៥ ឆ្នាំ (រូប ១១.៩)។ ក្រាហ្វនេះបង្ហាញពីបន្ទាត់នៃកម្រិតពិការភាពផ្សេងៗដែលស្ទើរតែរត់ស្របគ្នា ដោយមានកម្រិតកាន់តែខ្ពស់ក្នុងក្រុមអាយុទាំងអស់សម្រាប់ប្រជាជនមិនពិការ។ គ្មានភាពខុសគ្នាច្រើននោះទេរវាងកម្រិតនៃការមានការងារធ្វើក្នុងចំណោមប្រជាជនដែលមានពិការភាពខ្លាំង និងប្រជាជនពិការមិនអាចធ្វើអ្វីបាន។ ការដែលអត្រាមានការងារធ្វើ មានកម្រិតទាបក្នុងចំណោមប្រជាជនពិការ មិនមានន័យថា ប្រជាជនពិការគ្មានតម្រូវការការងារនោះទេ។ តាមពិត ចំនួនប្រជាជនពិការដែលកំពុងស្វែងរកការងារក្រោយអាយុ ៦០ គឺច្រើនជាងចំនួនប្រជាជនមិនពិការ។ យោងតាមជំរឿននេះ អត្រាគ្មានការងារធ្វើគឺ ០,៦ ភាគរយក្នុងចំណោមប្រជាជនមិនពិការ ទល់នឹង ៣,៦ ភាគរយ សម្រាប់ប្រជាជនមានពិការភាពខ្លះ ៥,០ ភាគរយសម្រាប់ប្រជាជនមានពិការភាពខ្លាំង និង ៤,៨ ភាគរយសម្រាប់ប្រជាជនពិការមិនអាចធ្វើអ្វីបាន។

រូប ១១.៩ ៖ ភាគរយប្រជាជនមានការងារធ្វើ បែងចែកតាមអាយុ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩



# ជំពូក ១២៖ យេនឌ័រ និងពិការភាព

ជាទូទៅ ស្ត្រីពិការប្រឈមនឹងឧបសគ្គក្នុងជីវភាពសង្គម នយោបាយ និងសេដ្ឋកិច្ច ច្រើនជាងបុរសពិការ ឬបុរសមិនពិការ។ ស្ត្រីប្រឈមនឹងឧបសគ្គប្រសព្វគ្នា ដូចជា យេនឌ័រ ពិការភាព និងកត្តាផ្សេងទៀត (ផ្លូវភេទ ជាតិពន្ធុ សាសនា។ល។) ដែលបង្កើតជាអត្តសញ្ញាណរបស់ស្ត្រី។ ប្រទេសជាច្រើននៅតែញែកយេនឌ័រ និងពិការភាពក្នុងគោលនយោបាយ និងកម្មវិធីរបស់ខ្លួន (UNDESA, 2018)។ ក្រៅពីភាពក្រីក្រ ការរស់នៅជនបទ បូករួមនឹងប្រភេទ និងកម្រិតពិការភាព បានធ្វើឱ្យស្ត្រីពិការជួបការលំបាកបន្ថែមទៀត និងធ្វើឱ្យពួកគាត់មិនអាចទទួលបានធនធានគ្រប់គ្រាន់ (ទាំងសម្ភារ និងមិនមែនសម្ភារ)។ ស្ត្រីពិការងាយប្រឈមនឹងការរំលោភបំពានផ្លូវកាយ ការរំលោភបំពានជាពាក្យសម្តី និងការរំលោភបំពានផ្លូវភេទ ជាងស្ត្រីមិនពិការ។ ផ្នត់គំនិតយេនឌ័រ បូករួមនឹងការយល់ខុសក្នុងសង្គមស្តីពីពិការភាព ធ្វើឱ្យស្ត្រីពិការបាត់បង់អំណាចក្នុងសង្គម និងជួបការលំបាកផ្នែកសេដ្ឋកិច្ចជាងស្ត្រីមិនពិការ។ ជាញឹកញាប់ ស្ត្រីពិការត្រូវបានគេចាត់ទុកថាមិនគួរឱ្យគោរពស្រឡាញ់ និងមិនអាចសម្រេចសក្តានុពលពេញលេញ និងរស់នៅប្រកបដោយអត្ថន័យបាន (Gartrell, Baesel & Becker, 2017)។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (២០១៩-២០២៣) របស់កម្ពុជា មានគោលដៅជាក់លាក់មួយ (៦.២) ក្នុងការ "ផ្តល់សេវាយុត្តិធម៌ដល់ជនមានពិការភាព ជាពិសេសស្ត្រី និងក្មេងស្រីមានពិការភាព" (DAC, 2019)។

ជាទូទៅ ការវិភាគយេនឌ័រមានគោលបំណង ១) សិក្សាពីភាពខុសគ្នារវាងជីវិតរស់នៅរបស់បុរស និងស្ត្រី ២) ពន្យល់ពីឫសគល់នៃវិសមភាពរវាងស្ត្រី និងបុរស និងក្មេងប្រុស និងក្មេងស្រី និង ៣) ផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពយេនឌ័រសំខាន់ៗក្នុងវិសមភាព និងរិះរកវិធីបង្កើនគោលជំហររបស់ស្ត្រី និងក្មេងស្រីក្នុងសង្គម (UNFPA, n.d.)។ ខណៈដែលជំរឿនជាឧបករណ៍ដ៏សមស្របសម្រាប់ពិពណ៌នាពីភាពខុសគ្នាទូទៅរវាងលក្ខណៈសង្គមសេដ្ឋកិច្ចរបស់ស្ត្រី និងបុរស ជំរឿនមិនផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់ការសិក្សាពីឫសគល់នៃភាពខុសគ្នាទាំងនេះឡើយ ដោយសារតែដែនកំណត់នៃវិសាលភាព និងភាពជ្រាលជ្រៅរបស់វា។ យេនឌ័រជាបញ្ហាអន្តរវិស័យ ដូច្នេះ មានឯកសារជាច្រើនពិភាក្សាពីទិដ្ឋភាពជាច្រើនដែលពាក់ព័ន្ធនឹងយេនឌ័រ។ ក្នុងជំពូកនេះ ប្រធានបទមួយចំនួនដែលលើកមកពិភាក្សាពីដំបូង ត្រូវបានកែសម្រួល និងផ្តល់ព័ត៌មានកាន់តែស៊ីជម្រៅ។ ទោះបីជាការប៉ាន់ស្មានប្រេវ៉ាឡង់ពិការភាពពីជំរឿននេះ ទាបជាងចំនួនជាក់ស្តែងក្តី ក៏ការប៉ាន់ស្មានទាំងនេះបង្ហាញថា ទាំងចំនួនដាច់ខាត និងភាគរយនៃស្ត្រីមានពិការភាព គឺខ្ពស់ជាងចំនួនដាច់ខាត និងភាគរយនៃបុរសមានពិការភាព។

## ១២.១ អាពាហ៍ពិពាហ៍

ស្ត្រីមានពិការភាព មានប្រូបាប៊ីលីតេទាបនៃការស្ថិតក្នុងសម្ព័ន្ធអាពាហ៍ពិពាហ៍។ ឱកាសរបស់ស្ត្រីមានពិការភាពគឺទាបជាងបុរស និងស្ត្រីមិនពិការ និងទាបជាងបុរសមានពិការភាព។ រូប ១២.១ បង្ហាញពីផលធៀបរវាងភាគរយនៃបុរស និងភាគរយនៃស្ត្រីដែលបានរៀបការនៅពេលជំរឿន បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព។ ប្រសិនបើផលធៀបស្មើ ១ មានន័យថា ភាគរយនៃបុរសដែលមានអាយុជាក់លាក់ និងមានពិការភាពប្រភេទណាមួយ ដែលបានរៀបការនៅពេលជំរឿន គឺដូចគ្នានឹងភាគរយនៃស្ត្រីដែលមានអាយុ និងមានប្រភេទពិការភាពដូចគ្នា។ ប្រសិនបើផលធៀបលើស ១ មានន័យថា ភាគរយនៃបុរសក្នុងក្រុមអាយុ/ពិការភាពដែលបានរៀបការ គឺខ្ពស់ជាងភាគរយនៃស្ត្រីក្នុងក្រុមអាយុ/ពិការភាពដែលបានរៀបការ។ ប្រសិនបើផលធៀបតូចជាង ១ មានន័យថា ភាគរយនៃស្ត្រីដែលបានរៀបការគឺខ្ពស់ជាងបុរស។

រូប ១២.១ ៖ ផលធៀបនៃភាគរយបុរសទល់នឹងស្ត្រី ដែលរៀបការហើយ បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

ទម្រង់ជារួមនៃខ្សែកោងផ្សេងៗ បង្ហាញពីគំរូរំពឹងទុកមួយ។ នៅអាយុវ័យក្មេង សម្រាប់ក្រុមពិការភាពទាំងអស់ ផលធៀបនេះគឺទាបជាង ១ ព្រោះនៅពេលរៀបការលើកដំបូង (សម្រាប់ពិការភាពទាំង ៤ ប្រភេទ) ស្ត្រីមានអាយុក្មេងជាងបុរស។ ដោយសារបុរសមានអាយុសង្ឃឹមរស់ខ្លីជាងស្ត្រី ផលធៀបនេះកើនលើស ១ និងបន្តកើនឡើងរហូតដល់អាយុ ៨០ ឆ្នាំ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺ ក្រោយអាយុ ៤០ ឆ្នាំ ក្រុមពិការភាពផ្សេងៗ ប្រសព្វគ្នា ហើយផលធៀបសម្រាប់ស្ត្រីមានពិការភាពទាំង ៣ ក្រុម (ពិការខ្លះ ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន) កើនឡើងលឿនជាងស្ត្រីមិនពិការ។ មានន័យថា លទ្ធភាពរៀបការរបស់ស្ត្រីធៀបនឹងបុរស (ក្នុងកម្រិតពិការភាពដូចគ្នា) មានកម្រិតទាបខ្លាំង ប្រសិនបើពួកគាត់មានពិការភាពក្នុងទម្រង់ណាមួយ។ ឧ. ស្ត្រីអាយុ ៧០-៧៤ ឆ្នាំដែលមានពិការភាពខ្លាំង ចំនួន ៤៨,៩ ភាគរយ បានរៀបការនៅពេលជំរឿន (ធៀបនឹងបុរសក្នុងក្រុមអាយុដូចគ្នាដែលមានពិការភាពខ្លាំងចំនួន ៨៣,០ ភាគរយ)។ ចំណុចនេះធ្វើឱ្យផលធៀបរវាងភេទទាំងពីរស្មើនឹង ១,៧០។ ផ្ទុយទៅវិញ ក្នុងចំណោមស្ត្រីមិនពិការដែលមានអាយុ ៧០-៧៥ ឆ្នាំ មាន ៦០,៣ ភាគរយ បានរៀបការ ធៀបនឹងបុរសដែលស្ថិតក្នុងក្រុមអាយុ/ពិការភាពដូចគ្នា ចំនួន ៨៨,៩ ភាគរយ ដែលធ្វើឱ្យផលធៀបរវាងភេទទាំងពីរស្មើនឹង ១,៤៨។ ផលធៀបកាន់តែខ្ពស់សម្រាប់ជនមានពិការភាពខ្លាំង ធៀបនឹងជនមិនពិការ បង្ហាញថា ការមានពិការភាពបង្កើនលទ្ធភាពដែលស្ត្រីនៅតែរៀបការនៅអាយុវ័យចាស់។

## ១២.២ ភាពក្រីក្រ

ឯកសារបង្ហាញថា គ្រួសារមានស្ត្រីជាមេគ្រួសារមានប្រវ៉ាឡង់ភាពក្រីក្រីខ្ពស់ជាងគ្រួសារមានបុរសជាមេគ្រួសារ។ ក្នុងប្រទេសជាច្រើន គេរកឃើញថា គ្រួសារដែលមានសមាជិកតែម្នាក់ (ស្ត្រី) ឬគ្រួសារដែលមានតែម្តាយ និងកូន មានអត្រាភាពក្រីក្រខ្ពស់ជាងគ្រួសារដែលមានសមាជិកតែម្នាក់ (បុរស) ឬគ្រួសារដែលមានតែឪពុក និងកូន។ ទោះជាយ៉ាងណា សម្រាប់ប្រទេសមួយចំនួននៅអាហ្វ្រិក គ្រួសារមានស្ត្រីជាមេគ្រួសារ មានជីវភាពធូរធាជាងគ្រួសារមានបុរសជាមេគ្រួសារ (អង្គការសហប្រជាជាតិ ២០១០)។ ការវិភាគនាពេលថ្មីៗនេះបង្ហាញថា ភាគរយខ្ពស់នៃគ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព (មិនគិតភេទរបស់មេគ្រួសារ) ស្ថិតក្នុងបញ្ចភាគក្រីក្របំផុតនៃសន្ទស្សន៍ទ្រព្យសម្បត្តិ (សូមមើលរូប ៦.១)។ ក្រៅពីនេះ ប្រសិនបើគ្រួសារនោះមានស្ត្រីជាមេគ្រួសារ ភាគរយនៃគ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព ដែលស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត គឺខ្ពស់ (២៨,៨ ភាគរយ) ជាងក្នុងចំណោមគ្រួសារមានបុរសជាមេគ្រួសារ (២០,៩ ភាគរយ)។ លទ្ធផលនេះបង្ហាញថា មានទំនាក់ទំនងរវាងមេគ្រួសារជាស្ត្រី និងពិការភាព ហើយអ្នកមកពីគ្រួសារមានស្ត្រីជាមេគ្រួសារ មានឱកាសខ្ពស់នៃការរស់នៅក្នុងភាពក្រីក្រជាងអ្នកមកពីគ្រួសារមានបុរសជាមេគ្រួសារ។ លទ្ធផលរកឃើញនេះគាំទ្រដោយការពិតថា ក្នុងគ្រួសារមួយដែលមានស្ត្រីជាមេគ្រួសារ ហើយសមាជិកយ៉ាងតិចម្នាក់មានពិការភាព គ្រួសារនោះមានចំនួនទូរស័ព្ទដៃ កុំព្យូទ័រ និងទូរទស្សន៍ប្រើប្រាស់តិចជាងគ្រួសារមានបុរសជាមេគ្រួសារ។ ខណៈដែល ៤២,៦ ភាគរយនៃគ្រួសារមានបុរសជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាព មានអ៊ីនធឺណិតប្រើប្រាស់ក្នុងផ្ទះ អត្រានេះគឺត្រឹមតែ ៣៤,៧ ភាគរយប៉ុណ្ណោះក្នុងចំណោមគ្រួសារមានស្ត្រីជាមេគ្រួសារ និងមានសមាជិកម្នាក់មានពិការភាព (រូប ៦.២)។ ដូចគ្នានេះដែរ គ្រួសារទាំងនេះមិនសូវមានយានយន្តធ្វើដំណើរ ដូចគ្រួសារមានបុរសជាមេគ្រួសារ និងមានសមាជិកមានពិការភាពឡើយ។

វិធីមួយទៀតដើម្បីពិនិត្យមើលទិដ្ឋភាពយេនឌ័រនៃពិការភាព និងយេនឌ័រ គឺការពិចារណាពីស្ថានភាពពិការភាពរបស់មេគ្រួសារ។ រូប ១២.២ បង្ហាញពីភាគរយនៃគ្រួសារមានបុរសជាមេគ្រួសារ និងគ្រួសារមានស្ត្រីជាមេគ្រួសារក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត បែងចែកតាមកម្រិតពិការភាព។ ដោយសារបញ្ចភាគទ្រព្យសម្បត្តិបែងចែកចំនួនគ្រួសារក្នុងប្រទេសមួយជា ៥ ចំណែកស្មើគ្នា ប្រសិនបើអនុក្រុមមួយនៃគ្រួសារមានភាគរយខ្ពស់ជាង ២០ ភាគរយ មានន័យថា ក្រុមនោះមានភាពក្រីក្រខ្លាំង។ ក្រាហ្វនេះបង្ហាញយ៉ាងច្បាស់ពីភាគរយខ្ពស់នៃគ្រួសារមានស្ត្រីជាមេគ្រួសារក្នុងបញ្ចភាគគ្រួសារក្រីក្របំផុត។ ខណៈដែលគ្រួសារមានបុរសជាមេគ្រួសារ និងមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន មានចំនួនច្រើនក្នុងបញ្ចភាគក្រីក្របំផុត (២៦,៧ ភាគរយ ទល់នឹង ២៣,២ ភាគរយ) មានគ្រួសារមានស្ត្រីជាមេគ្រួសារកាន់តែច្រើនដែលស្ថិតក្នុងបញ្ចភាគក្រីក្របំផុត។ នៅកម្ពុជា ក្នុងចំណោមគ្រួសារទាំងអស់ដែលមានស្ត្រីជាមេគ្រួសារ និងមានពិការភាពខ្លះ មាន ២៧,៨ ភាគរយ ស្ថិតក្នុងបញ្ចភាគក្រីក្របំផុត។ ក្នុងចំណោមគ្រួសារមានស្ត្រីជាមេគ្រួសារ និងមានពិការភាពខ្លាំង មាន ៣៦,១ ភាគរយ ស្ថិតក្នុងបញ្ចភាគក្រីក្របំផុត (ខ្ពស់ជាងគ្រួសារមានបុរសជាមេគ្រួសារ និងមានពិការភាពខ្លាំង ចំនួន ១០ ភាគរយ)។ ក្នុងកម្រិតពិការខ្លាំង មានភាពខុសគ្នារវាងគ្រួសារមានស្ត្រីជាមេគ្រួសារ និងគ្រួសារមានបុរសជាមេគ្រួសារ (៣៣,៧ ភាគរយ ទល់នឹង ២៣,២ ភាគរយ)។

លទ្ធផលបង្ហាញថា គ្រួសារមានជនពិការជាមេគ្រួសារ មានភាគច្រើនខ្ពស់ក្នុងបញ្ចភាគក្រីក្របំផុតចំនួន ២០ ភាគរយ។ អត្រានេះកាន់តែខ្ពស់ ប្រសិនបើមេគ្រួសារជាស្ត្រី។

រូប ១២.២ ៖ ភាគរយគ្រួសារដែលស្ថិតក្នុងបញ្ចភាគក្រីក្របំផុត បែងចែកតាមភេទរបស់មេគ្រួសារ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

## ១២.៣ ការអប់រំ

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បង្ហាញថា ជនមានពិការភាពមានអត្រាអក្ខរភាពទាបជាងជនមិនពិការ។ ក្នុងចំណោមជនមានពិការភាព ស្ត្រីមានកម្រិតអក្ខរភាពទាបជាងបុរស។ រូប ៧.៦.ក-ខ បង្ហាញពីភាពខុសគ្នាកាន់តែខ្លាំងរវាងអត្រាអក្ខរភាពសម្រាប់ស្ត្រី និងបុរសមានពិការភាព នៅអាយុវ័យចាស់ ខណៈដែលគ្មានឬមានភាពខុសគ្នាតិចតួចនៅអាយុវ័យក្មេង។ ចំណុចនេះបង្ហាញពីវឌ្ឍនភាពក្នុងរយៈពេលជាច្រើនឆ្នាំនៃការលុបបំបាត់វិសមភាពក្នុងលទ្ធផលអប់រំរវាងបុរស និងស្ត្រីដែលមានពិការភាព។ គំរូស្រដៀងគ្នាលេចឡើងក្នុងអត្រាចូលរៀននៅសាលារវាងក្មេងប្រុស និងក្មេងស្រីដែលមានពិការភាព។ ទោះបីជាមានអត្រាទាបនៃការចូលរៀននៅសាលារវាងកុមារមានពិការភាពក្តី ប៉ុន្តែគ្មានភាពខុសគ្នាជាក់លាក់រវាងក្មេងប្រុស និងក្មេងស្រីនោះទេ។ សម្រាប់ក្រុមអាយុ ៥-៩ ឆ្នាំ និង ១០-១៤ ឆ្នាំ ភាគរយនៃក្មេងស្រីសម្រាប់ប្រភេទពិការភាពនីមួយៗ (ពិការខ្លះ ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន) ដែលកំពុងសិក្សា គឺខ្ពស់ជាងក្មេងប្រុស (សូមមើលរូប ៧.១ និង ៧.២)។ ឧ. ក្នុងចំណោមក្មេងស្រីអាយុ ៥-៩ ឆ្នាំដែលពិការខ្លាំង អត្រាចូលរៀននៅសាលាគឺ ៥៣,៧ ភាគរយ ធៀបនឹង ៤៨,០ ភាគរយសម្រាប់ក្មេងប្រុសដែលស្ថិតក្នុងក្រុមដូចគ្នា។ ភាគរយសម្រាប់ក្មេងស្រីពិការមិនអាចធ្វើអ្វីបានគឺ ៤៤,៣ ភាគរយ ធៀបនឹង ៣៨,៥ ភាគរយ សម្រាប់ក្មេងប្រុសពិការមិនអាចធ្វើអ្វីបាន។ តួលេខទាំងនេះបង្ហាញយ៉ាងច្បាស់ថាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនក្នុងការកាត់បន្ថយគម្លាតរវាងក្មេងស្រី និងក្មេងប្រុសមានពិការភាព។ ទោះជាយ៉ាងណា ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការធានាលទ្ធភាពទទួលបានការអប់រំដែលមានគុណភាពសម្រាប់កុមារមានពិការភាពគ្រប់រូប។

# ១២.៤ កម្លាំងពលកម្ម

ជំពូកស្តីពីកម្លាំងពលកម្មផ្តោតសំខាន់លើការចូលរួមក្នុងកម្លាំងពលកម្ម ដោយផ្អែកតាមកម្រិតពិការភាពរបស់បុគ្គល។ រូប ៨.២ បង្ហាញពីភាពខុសគ្នាខ្លាំងនៃការចូលរួមក្នុងកម្លាំងពលកម្ម សម្រាប់ជនមានពិការភាព ធៀបនឹងជនមិនពិការ។ ការវិភាគផ្អែកតាមយេនឌ័រស្តីពីអត្រាមានការងារធ្វើ បែងចែកតាមកម្រិតពិការភាព បង្ហាញពីភាពខុសគ្នាសំខាន់ៗរវាងបុរស និងស្ត្រី។ រូប ១២.៣ បង្ហាញថា សម្រាប់បុរស និងស្ត្រីក្នុងក្រុមអាយុ ១៥-៦៤ ឆ្នាំ អត្រាមានការងារធ្វើក្នុងចំណោមបុរសគឺខ្ពស់ជាងស្ត្រី (សម្រាប់កម្រិតពិការភាពនីមួយៗ)។ ភាគរយនៃបុរសអាយុ ១៥-៦៤ ឆ្នាំដែលមានការងារធ្វើ និងមិនពិការ គឺ ៨៥,០ ភាគរយ ទល់នឹង ៧៦,៨ ភាគរយសម្រាប់ស្ត្រី។ សម្រាប់បុរស មានភាពខុសគ្នាតិចតួចរវាងជនគ្មានពិការភាព និងជនមានពិការភាពខ្លះ (៨៥-៨៦ ភាគរយ) ខណៈដែលមានភាពខុសគ្នា ៥ ភាគរយសម្រាប់ស្ត្រី។ សម្រាប់ទាំងពីរភេទ ភាពមានការងារធ្វើថយចុះទៅតាមការកើនឡើងនៃកម្រិតពិការភាព ទោះបីជាអត្រាមានការងារធ្វើសម្រាប់ស្ត្រីតែងតែទាបជាងបុរសក្តី។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺភាពខុសគ្នានៃភាពមានការងារធ្វើរវាងប្រជាជនទាំងពីរភេទ រួមតូចទៅតាមភាពធ្ងន់ធ្ងរនៃពិការភាព។ ខណៈដែលមានភាពខុសគ្នាចំនួន ១៥ ភាគរយរវាងបុរស និងស្ត្រីមានពិការភាពខ្លះ ភាពខុសគ្នានេះគឺ ១០ ភាគរយសម្រាប់ជនមានពិការភាពខ្លាំង និង ៥ ភាគរយសម្រាប់ជនពិការមិនអាចធ្វើអ្វីបាន។

ការដែលជនមានពិការភាពមានអត្រាការងារទាប មិនមែនន័យថា ពួកគេមិនចង់ធ្វើការនោះទេ។ រូប ១២.៤ បង្ហាញពីអត្រាគ្មានការងារធ្វើសម្រាប់ក្រុមអាយុ ១៥-៦៤ ឆ្នាំបែងចែកតាមភេទ និងកម្រិតពិការភាព។ ដូចការពិភាក្សាពីខាងដើម អត្រាគ្មានការងារធ្វើក្នុងជំរឿននេះត្រូវបានគណនាដោយផ្អែកលើស្ថានភាពធម្មតាមុនជំរឿន (ឧ. ដើម្បីអាចចាត់ទុកថាគ្មានការងារធ្វើ មនុស្សម្នាក់ត្រូវគ្មានការងារធ្វើលើស ៦ ខែ)។ ជាទូទៅ វិធីសាស្ត្រនេះផ្តល់អត្រាគ្មានការងារធ្វើទាបជាងវិធីសាស្ត្រដែលផ្អែកលើរយៈពេលយោងខ្លី មុនពេលជំរឿន។ ធៀបនឹងជនមិនពិការ ឬជនមានពិការភាពខ្លះ មានអត្រាខ្ពស់នៃភាពគ្មានការងារធ្វើក្នុងចំណោមជនមានពិការភាពខ្លាំង និងពិការមិនអាចធ្វើអ្វីបាន៖ បុរសពិការមិនអាចធ្វើអ្វីបានចំនួន ១៧,០ ភាគរយ និងស្ត្រីពិការមិនអាចធ្វើអ្វីបានចំនួន ១៨,៥ ភាគរយ បញ្ជាក់ថា ពួកគេគ្មានការងារធ្វើ។ ក្នុងចំណោមជនមានពិការភាពខ្លាំង អត្រានេះគឺ ៧,៦ ភាគរយសម្រាប់បុរស និង ១០,៧ ភាគរយសម្រាប់ស្ត្រី។

រូប ១២.៣ ៖ អត្រាមានការងារធ្វើសម្រាប់ប្រជាជនអាយុ ១៥-៦៤ ឆ្នាំ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

រូប ១២.៤ ៖ អត្រាគ្មានការងារធ្វើសម្រាប់ប្រជាជនអាយុ ១៥-៦៤ ឆ្នាំ បែងចែកតាមភេទ និងកម្រិតពិការភាព ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩

តារាង ១០ បង្ហាញថា ស្ថានភាពសកម្មភាពរបស់ប្រជាជនអាយុ ១៥-៦៤ ឆ្នាំដែលកំពុងធ្វើការ មានភាពខុសគ្នាខ្លាំងសម្រាប់បុរស និងស្ត្រី អាស្រ័យលើស្ថានភាពពិការភាពរបស់ពួកគេ។ ភាគរយនៃបុរស និងស្ត្រីដែលសកម្មក្នុងសេដ្ឋកិច្ច (ក្នុងនាមជានិយោជក) មានអត្រាទាបបំផុត។ សម្រាប់ប្រជាជនទាំងពីរភេទ ភាគរយនៃប្រជាជនដែលដើរតួនាទីជានិយោជក មានអត្រាខ្ពស់ក្នុងចំណោមជនមានពិការភាព ជាងក្នុងចំណោមជនមិនពិការ។ សម្រាប់ប្រភេទពិការភាពទាំងអស់ ភាគរយនៃបុរសដែលធ្វើជានិយោជក មានកម្រិតខ្ពស់បន្តិចជាងស្ត្រី។ ភាពខុសគ្នាដ៏ធំបំផុតរវាងប្រជាជនទាំងពីរភេទ គឺក្នុងចំណោមអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និងអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល។ បុរសដែលធ្វើការ មានអត្រាភាគរយខ្ពស់នៃការធ្វើការដោយទុនផ្ទាល់ខ្លួន ជាងស្ត្រីដែលធ្វើការ។ ក្នុងចំណោមបុរសដែលមានពិការភាពខ្លាំង មាន ៥៨,៣ ភាគរយ ជាអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន ធៀបនឹង ៤៥,០ ភាគរយសម្រាប់ស្ត្រី។ ក្រៅពីនេះមានភាពខុសគ្នាស្រដៀងគ្នារវាងប្រជាជនទាំងពីរភេទ សម្រាប់កម្រិតពិការភាពផ្សេងទៀត។ ក្នុងទីផ្សារការងារ ស្ត្រីងាយរងគ្រោះជាងបុរស ព្រោះស្ត្រីមានភាគរយខ្ពស់ក្នុងចំណោមអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល។ ភាពខុសគ្នាដ៏ធំបំផុតរវាងបុរស និងស្ត្រីដែលធ្វើការ លេចឡើងក្នុងចំណោមជនមានពិការភាពខ្លះ។ ខណៈដែលបុរសមានពិការភាពខ្លះចំនួន ៨,៦ ភាគរយ ជាអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល ស្ត្រីចំនួន ៣៦,៦ ភាគរយ ធ្វើការមិនយកប្រាក់ឈ្នួលក្នុងអាជីវកម្ម ឬកសិដ្ឋានគ្រួសារ។ សម្រាប់កម្រិតពិការភាពនីមួយៗ ភាគរយនៃនិយោជិតទទួលបានប្រាក់ឈ្នួលក្នុងចំណោមប្រជាជនមានការងារធ្វើទាំងអស់ មានកម្រិតខ្ពស់ក្នុងចំណោមបុរស ជាងក្នុងចំណោមស្ត្រី។

**តារាង ១០ ៖ ស្ថានភាពការងាររបស់ប្រជាជនទាំងអស់ដែលមានការងារធ្វើ (១៥–៦៤ ឆ្នាំ) បែងចែកតាមកម្រិតពិការភាព និងភេទ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩**

| | | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | សរុប |
|---|---|---|---|---|---|---|
| បុរស | និយោជក | ០,៧ | ១,១ | ១,២ | ០,៩ | ០,៧ |
| | និយោជិតទទួលបានប្រាក់ឈ្នួល | ៣៥,៤ | ២៤,៩ | ២៦,៤ | ៣៤,៥ | ៣៥,០ |
| | អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន | ៤៨,៣ | ៦៥,២ | ៥៨,៣ | ៤៧,៧ | ៤៨,៨ |
| | អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល | ១៥,៤ | ៨,៦ | ១៤,០ | ១៦,៦ | ១៥,២ |
| | ផ្សេងៗ | ០,២ | ០,២ | ០,១ | ០,៣ | ០,២ |
| ស្ត្រី | និយោជក | ០,៥ | ០,៧ | ០,៨ | ០,៨ | ០,៥ |
| | និយោជិតទទួលបានប្រាក់ឈ្នួល | ៣១,៣ | ១៥,៩ | ២០,៨ | ៣១,៥ | ៣០,៨ |
| | អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន | ៣៣,១ | ៤៦,៧ | ៤៥,០ | ៣៦,៣ | ៣៣,៦ |
| | អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល | ៣៥,០ | ៣៦,៦ | ៣៣,៣ | ៣១,២ | ៣៥,០ |
| | ផ្សេងៗ | ០,១ | ០,១ | ០,១ | ០,២ | ០,១ |
| សរុប | និយោជក | ០,៦ | ០,៩ | ១,០ | ០,៩ | ០,៦ |
| | និយោជិតទទួលបានប្រាក់ឈ្នួល | ៣៣,៤ | ២០,៤ | ២៣,៦ | ៣៣,០ | ៣៣,០ |
| | អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន | ៤០,៨ | ៥៥,៨ | ៥១,៨ | ៤២,០ | ៤១,៣ |
| | អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល | ២៥,០ | ២២,៨ | ២៣,៤ | ២៣,៩ | ២៤,៩ |
| | ផ្សេងៗ | ០,២ | ០,១ | ០,១ | ០,២ | ០,២ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ GPCC ២០១៩*

# ជំពូក ១៣៖ សេចក្ដីសន្និដ្ឋាន និងភាពពាក់ព័ន្ធផ្នែកគោលនយោបាយ

ការកើនឡើងនៃចំនួនប្រជាជនវ័យចាស់គឺជាបាតុភូតសកល។ ក្នុងប្រទេសកម្ពុជា ប្រជាជនដែលមានអាយុ ៦០ ឆ្នាំឡើង កើនពី ៦,៣ ភាគរយ នៅឆ្នាំ ២០០៨ ដល់ ៨,៩ ភាគរយ នៅឆ្នាំ២០១៩ (NIS, n.d.; NIS, 2020)។ ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនវ័យចាស់ បានបង្កើនប្រេវ៉ាឡង់ជំងឺមិនឆ្លង និងបង្កជាបញ្ហាពិការភាពបណ្ដោះអាសន្ន និងអចិន្ត្រៃយ៍។ រដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមជុំវិញពិការភាព តាមរយៈការប្ដេជ្ញាអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដែលជាត្រីវិស័យនៃសកម្មភាពជាក់លាក់ក្នុងការបំពេញតម្រូវការរបស់ជនមានពិការភាព។ កម្ពុជាបានបង្ហាញគោលជំហរយ៉ាងច្បាស់លាស់ក្នុងការកែលម្អជីវិតរស់នៅរបស់ជនមានពិការភាព ក្នុងប្រទេសតាមរយៈការផ្ដល់សច្ចាប័នដល់អនុសញ្ញាស្ដីពីសិទ្ធិជនពិការនៅ ឆ្នាំ ២០១២ ការប្ដេជ្ញាចិត្តអនុវត្តទសវត្សរ៍ជនមានពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (២០១៣-២០២២) និងយុទ្ធសាស្ត្រអ៊ីនឈាន់ ការអនុម័តច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការនៅ ឆ្នាំ២០១២ និងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព (២០១៩-២០២៣)។

ការសម្រេចបានការប្ដេជ្ញាចិត្តទាំងនេះអាស្រ័យលើទិន្នន័យលម្អិត និងមានគុណភាពដែលជាមគ្គុទេសក៍សម្រាប់ ការតាក់តែងគោលនយោបាយ និងការរៀបចំកម្មវិធី។ កម្ពុជាមិនសូវមានទិន្នន័យប្រភេទនេះទេ ហើយការសិក្សានាពេលកន្លងមកបានផ្ដល់តួលេខខុសៗគ្នាស្ដីពីប្រេវ៉ាឡង់ពិការភាព។ ចំណុចនេះបានរាំងស្ទះដល់ការពិនិត្យតាមដានឱ្យបានគ្រប់ជ្រុងជ្រោយ លើការសម្រេចបានគោលដៅនៃអនុសញ្ញាស្ដីពីសិទ្ធិជនពិការ យុទ្ធសាស្ត្រអ៊ីនឈាន់ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០។ល។ របាយការណ៍នេះមានគោលបំណងលុបបំបាត់គម្លាតទាំងនេះ តាមរយៈការពិពណ៌នាពីលក្ខខណ្ឌរស់នៅរបស់ជនមានពិការភាព ដោយធ្វើការវិភាគទិន្នន័យដែលប្រមូលបានពីជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩។ ខណៈដែលជំរឿននេះជាប្រភពដ៏សំខាន់ដែលគូសបញ្ជាក់ពីស្ថានភាពជាក់ស្ដែង ជាទូទៅជំរឿននេះគ្មានព័ត៌មានស្ដីពីមូលហេតុបញ្ជាក់នោះទេ។ ដូច្នេះ ភាពពាក់ព័ន្ធផ្នែកគោលនយោបាយក្នុងរបាយការណ៍នេះមិនត្រូវបានពិពណ៌នាក្បោះក្បាយ ឡើយ។

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ប៉ាន់ស្មានថា ក្នុងចំណោមប្រជាជនសរុបចំនួន ១៤,១ នាក់ ដែលមានអាយុ ៥ ឆ្នាំឡើងក្នុងប្រទេសកម្ពុជា ប្រជាជនចំនួន ៦៨៩.៥៣២ នាក់មានពិការភាព។ ក្នុងនោះប្រជាជនភាគច្រើន (៥២៣.១៦២ នាក់) មានពិការភាពខ្លះ ខណៈដែលប្រជាជនចំនួន ១២២.៧២៥ នាក់មានពិការភាពខ្លាំង និង ៤៣.៦៤៥ នាក់ពិការមិនអាចធ្វើអ្វីបាន។ សរុប ចំនួនជនមានពិការភាព (ពិការខ្លះ ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន) នៅកម្ពុជាគឺស្មើនឹង ៤,៨៩ ភាគរយនៃចំនួនប្រជាជនកម្ពុជាសរុប។ ប្រសិនបើគេពិចារណាតែប្រជាជនដែលមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន តួលេខនេះគឺត្រឹមតែ ១,១៨ ភាគរយ ប៉ុណ្ណោះ។ គេមិនអាចកំណត់ថាតើតួលេខទាំងនេះជាការកើនឡើង ឬការថយចុះ បើធៀបនឹងលទ្ធផលរកឃើញក្នុងជំរឿនឆ្នាំ ២០០៨ នោះទេ ព្រោះមានការសួរសំណួរខុសគ្នាក្នុងការធ្វើជំរឿនទាំងពីរលើកនេះ។ ក្រៅពីនេះ ចំនួនសរុបនៃជនមានពិការភាពគួរត្រូវបានចាត់ទុកជាការវាយតម្លៃទាបជាងស្ថានការណ៍ជាក់ស្ដែង ព្រោះប្រេវ៉ាឡង់ក្នុងប្រទេសកម្ពុជាមានកម្រិតទាបខ្លាំងជាងប្រទេសមួយចំនួនផ្សេងទៀត ដែលប្រើប្រាស់និយមន័យ និងមធ្យោបាយប្រមូលទិន្នន័យស្រដៀងគ្នា។ ដោយសារ

តែប្រធានបទក្នុងជំរឿនមានភាពទូលំទូលាយ ហើយនិតិវិធីនៃការប្រមូលទិន្នន័យ មិនសមស្របសម្រាប់ការប្រមូលទិន្នន័យស្តីពីពិការភាព ជាញឹកញាប់គេចាត់ទុកថា ជំរឿននេះជាឧបករណ៍ខ្វះចន្លោះសម្រាប់ការវាស់វែងប្រេវ៉ាឡង់ពិការភាព។ ផ្នែកខាងក្រោមបង្ហាញពីរបៀបកែលម្អការប្រមូលទិន្នន័យស្តីពីពិការភាព បូករួមនឹងអនុសាសន៍ទូទៅស្តីពីភាពចាំបាច់ក្នុងការដោះស្រាយឧបសគ្គចំពោះមុខ ដែលផាត់ចេញ និងរើសអើងជនមានពិការភាព។

## ១៣.១ ការដោះស្រាយឧបសគ្គធំៗដែលធ្វើឱ្យមានការផាត់ចេញជនមានពិការភាព

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ បង្ហាញថា ជនមានពិការភាពនៅតែប្រឈមនឹងបញ្ហាកង្វះខាតផ្នែកបរិយាបន្នសង្គមគួរឲ្យកត់សម្គាល់។ ក្នុងផ្នែកអប់រំ សកម្មភាពសេដ្ឋកិច្ច លទ្ធភាពបង្កើតកូន អាពាហ៍ពិពាហ៍ ភាពក្រីក្រ និងផ្នែកផ្សេងទៀត ជនមានពិការភាពមិនទទួលបានជំនួយគាំទ្រពេញលេញនោះទេ។ ដូច្នេះការសំខាន់គឺត្រូវដោះស្រាយឧបសគ្គ និងកង្វះខាតទាំងនេះ។

កង្វះបទបញ្ញត្តិដែលគ្របដណ្តប់លើជនមានពិការភាព មិនមែនជាបញ្ហាចោទនោះទេ។ អ្វីដែលសំខាន់គឺការតម្រឹមតម្រង់ និងការអនុវត្តច្បាប់ទាំងនេះ និងការបន្ស៊ីគ្នានឹងអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដើម្បីបង្កើតគំរូសង្គមផ្អែកតាមសិទ្ធិដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងការការពារជនមានពិការភាព និងលើកកម្ពស់សមាហរណកម្មពួកគេក្នុងឯកសារគោលនយោបាយសង្គមគ្រប់កម្រិត ដូចជា គោលដៅជាយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (២០១៩-២០២៣) ដែលជាលិខិតុបករណ៍ដ៏សំខាន់មួយ។ ចាំបាច់ត្រូវបន្ស៊ីផែនការការងារ ការរៀបចំថវិកា និងក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ទៅនឹងលិខិតុបករណ៍នេះ ដើម្បីធានាការអនុវត្ត និងពង្រឹងគណនេយ្យភាពប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ ក្រៅពីនេះ ការលុបបំបាត់ឧបសគ្គរាំងជនមានពិការភាព មិនត្រឹមតែទាមទារការបង្កើត និងការអនុវត្តច្បាប់ គោលនយោបាយ និងកម្មវិធីដែលមាននិរន្តរភាពសម្រាប់ពិការភាព និងការបញ្ជ្រាបយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានការកសាងសមត្ថភាព បច្ចេកវិទ្យាជំនួយ ភាពជាដៃគូពហុភាគី ភាពស៊ីសង្វាក់គ្នាផ្នែកគោលនយោបាយ និងស្ថាប័ន ការយល់ដឹង ការតស៊ូមតិ និងការយល់ដឹងជាសាធារណៈ ហិរញ្ញប្បទានគ្រប់គ្រាន់ ការពង្រឹងការចូលរួមរបស់អង្គការជនពិការក្នុងការរៀបចំផែនការ និងការអនុវត្ត និងទិន្នន័យដែលមានគុណភាព និងបែងចែកជាប្រភេទ (UN, 2018)។ ការធានាការចូលរួមប្រកបដោយអត្ថន័យរបស់ជនមានពិការភាពក្នុងការរៀបចំផែនការ និងការអនុវត្ត គឺជាកត្តាសំខាន់ក្នុងការធានាបាននូវសំឡេងរបស់ជនមានពិការភាព និងបំពេញតម្រូវការរបស់ក្រុមគោលដៅ។ ផ្អែកតាមទិន្នន័យស្តីពីពិការភាពក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ជាបន្ទាន់លើឧបសគ្គសំខាន់ៗដូចខាងក្រោម ៖

### ការអប់រំ

មានក្របខណ្ឌជាតិ និងអន្តរជាតិជាច្រើនសម្រាប់លើកកម្ពស់ការអប់រំសម្រាប់ជនមានពិការភាព។ នៅឆ្នាំ ២០១៨ កម្ពុជាបានបង្កើតគោលនយោបាយស្តីពីការអប់រំបរិយាបន្នដែលមានគោលបំណង "បណ្តុះការអប់រំដល់ជនស្ថិតក្នុងសេចក្តីត្រូវការពិសេសឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញ ដើម្បីចូលរួមអភិវឌ្ឍន៍សង្គមជាតិ" (អរយក ២០១៨, ទំ. ៤)។ សម្រាប់ក្របខណ្ឌអន្តរជាតិ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ លើកកម្ពស់ការអប់រំបរិយាបន្នសម្រាប់ជនមានពិការភាព។ ការអប់រំបរិយាបន្ន

"ពាក់ព័ន្ធនឹងការផ្លាស់ប្តូរ និងកែសម្រួលជាប្រព័ន្ធលើខ្លឹមសារមេរៀន យុទ្ធវិធី ទម្រង់ និងយុទ្ធសាស្ត្រក្នុងការអប់រំដើម្បីជម្នះឧបសគ្គផ្នែកគំហើញ សំដៅធ្វើយ៉ាងណាឱ្យអ្នកសិក្សាគ្រប់វ័យទទួលបានបទពិសោធន៍ និងបរិយាកាសរៀនសូត្រប្រកបដោយសមធម៌ និងមានការចូលរួម ដែលឆ្លើយតបបានល្អបំផុតទៅនឹងលក្ខខណ្ឌតម្រូវ និងការចង់បានរបស់ពួកគេ" (CRPD, 2016, p.3)។ យុទ្ធសាស្ត្រអ៊ីនឈាន់ អនុវត្តតាមគោលការណ៍នេះ។ ដើម្បី "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" គោលដៅទី ៥ មានគោលបំណងពង្រីកអន្តរាគមន៍ទាន់ពេលវេលា និងការអប់រំរបស់កុមារមានពិការភាព និងមានចំណុចដៅសំខាន់ៗ ២ ៖

១. បង្កើនវិធានការសម្រាប់ការកំណត់រក និងធ្វើអន្តរាគមន៍ទាន់ពេលវេលាសម្រាប់កុមារមានពិការភាពចាប់ តាំងពីពេលកើតរហូតដល់អាយុចូលរៀនថ្នាក់មុនមត្តេយ្យ។

២. កាត់បន្ថយពាក់កណ្តាលនូវគម្លាតរវាងកុមារមានពិការភាព និងកុមារមិនពិការក្នុងអត្រាចុះឈ្មោះចូលរៀនសម្រាប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា (UNESCAP, 2012, p. 8)។

ចំណុចដៅទី ១ មិនស្ថិតក្នុងវិសាលភាពនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ឡើយព្រោះគ្មានការសួរព័ត៌មានស្តីពីពិការភាពដែលពាក់ព័ន្ធនឹងកុមារក្នុងក្រុមអាយុចូលរៀនថ្នាក់មុនមត្តេយ្យ។ ការសង្កេតក្នុងជំរឿននេះបង្ហាញថា មានភាពខុសគ្នាយ៉ាងខ្លាំងក្នុងការចូលរៀននៅសាលារវាងកុមារអាយុ ៥-៩ ឆ្នាំ និង ១០-១៤ ឆ្នាំដែលមានពិការភាពខ្លាំង និងពិការមិនអាចធ្វើអ្វីបាន និងកុមារមិនពិការ ហើយកម្ពុជាត្រូវចាត់វិធានការជាជំហានៗដើម្បីលុបបំបាត់គម្លាតរវាងក្រុមទាំងពីរនេះ។ ចំណុចដែលពាក់ព័ន្ធនឹងភាគរយខ្ពស់នៃកុមារដែលស្ថិតនៅក្រៅប្រព័ន្ធអប់រំគឺ ជនមានពិការភាពមានអត្រាអក្ខរភាព និងកម្រិតអប់រំទាបខ្លាំងជាងជនមិនពិការ។ មានន័យថា ចំណុចដៅ ៤.៥ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលមានគោលបំណង "លុបបំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាការទទួលបានភាពស្មើភាពគ្នាក្នុងការអប់រំគ្រប់កម្រិត និងនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ក្រុមជនងាយរងគ្រោះ រួមទាំងក្រុមជនដែលបាត់បង់សមត្ថភាពពលកម្ម ប្រជាជន និងកុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ" គឺមិនអាចនឹងសម្រេចបាននោះទេ (UNESCO, n.d.)។

ជំរឿននេះមិនផ្តល់ព័ត៌មានស្តីពីមូលហេតុដែលកុមារមានពិការភាព មិនចុះឈ្មោះចូលរៀនក្នុងអត្រាប្រហាក់ប្រហែលនឹងកុមារគ្មានពិការភាពនោះទេ។ នៅឆ្នាំ ២០១៨ ការវិភាគស្ថានភាពនៃការអប់រំរបស់កុមារក្នុងប្រទេសកម្ពុជាត្រូវបានធ្វើឡើងដោយ RTI International ក្រោមការគាំទ្រពី UNAID (Kirby, 2018)។ ការវិភាគនេះគូសបញ្ជាក់ថា មានការតាក់តែងច្បាប់ដើម្បីលើកកម្ពស់លទ្ធភាពរបស់កុមារមានពិការភាព ក្នុងការទទួលបានការអប់រំសមស្របប៉ុន្តែច្បាប់ទាំងនេះមិនស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងអនុសញ្ញាស្តីពីសិទ្ធិជនពិការឡើយ។ អ្នកពាក់ព័ន្ធមិនបានចូលរួមពេញលេញក្នុងការបង្កើតច្បាប់ទាំងនេះទេ ហើយសាធារណជនក៏មិនបានដឹងថាមានច្បាប់ទាំងនេះដែរ។ ចំណុចសំខាន់គឺរដ្ឋាភិបាលកម្ពុជាត្រូវតម្រឹមតម្រង់បទបញ្ញត្តិជាតិទៅនឹងការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ខ្លួនស្តីពីការអប់រំ និងពិការភាព។ គួរផ្តោតការយកចិត្តទុកដាក់លើការជំរុញការចូលរួមរបស់អង្គការដែលតំណាងឱ្យជនមានពិការភាព ក្នុងការបង្កើតច្បាប់ និងគោលនយោបាយទាំងនេះ និងធ្វើឱ្យជនមានពិការភាពបានដឹងពីសិទ្ធិរបស់ពួកគេ។

គួរមានប្រព័ន្ធអប់រំមានគុណភាពប្រកបដោយបរិយាបន្នសម្រាប់កុមារ និងយុវជនគ្រប់រូប។ ជនមានពិការភាពគួរមានលទ្ធភាពស្មើភាពក្នុងការទទួលបានការអប់រំទូទៅ ជាជាងត្រូវចូលរៀនវគ្គសិក្សាពិសេស (Erickson, 2005)។ មានន័យថា គ្រូបង្រៀនត្រូវទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ដើម្បីបង្រៀនកុមារមានពិការភាពក្នុងការអប់រំចំណោះទូទៅ ហើយហេដ្ឋារចនាសម្ព័ន្ធទាំងអស់ក្នុងសាលារៀនត្រូវបំពេញភាពចាំបាច់ជាក់លាក់របស់កុមារ និងយុវជន

មានពិការភាព។ ក្រៅពីនេះ ប្រហែលជាត្រូវកែសម្រួលវិធីសាស្ត្របង្រៀន សៀវភៅពុម្ព និងសៀវភៅគ្រូ ដើម្បីបំពេញតម្រូវការរបស់សិស្ស ហើយអគារសិក្សាត្រូវផ្តល់ភាពងាយស្រួល។ ចំណុចសំខាន់គឺត្រូវអប់រំកុមារមានពិការភាពក្នុងមជ្ឈដ្ឋានដែលស្រដៀងគ្នានឹងបរិស្ថានរស់នៅរបស់ពួកគេ ជាជាងបំបែកពួកគេពីគ្រួសារ និងដាក់បញ្ចូលពួកគេក្នុងស្ថាប័នសិក្សារយៈពេលវែង ដែលពួកគេត្រូវទទួលការអប់រំក្នុងទម្រង់ដាច់ដោយឡែក និងឆ្ងាយពីក្រុមគ្រួសារ និងសហគមន៍។ ការសម្រេចចំណុចទាំងនេះគឺជាការលំបាក ប៉ុន្តែវាអាចជួយបញ្ចៀសការដាត់ចេញក្នុងសង្គម និងភាពក្រីក្រ និងផ្តល់លទ្ធភាពឱ្យជនមានពិការភាពចូលរួមក្នុងទីផ្សារការងារ និងសង្គម។ ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ២០១៩-២០២៣ រៀបរាប់ពីជំហានរយៈពេលខ្លី និងជំហានរយៈពេលវែងសម្រាប់ដោះស្រាយបញ្ហាទាំងនេះ ឱ្យតែមានការវិនិយោគហិរញ្ញវត្ថុគ្រប់គ្រាន់។ គោលដៅទី ៨ នៃយុទ្ធសាស្ត្រនេះមានគោលបំណង "បង្កើនភាពអាចជឿទុកចិត្តបាន និងភាពអាចប្រៀបធៀបបាននៃទិន្នន័យពិការភាព" (អរយក, ២០១៩ ទំ. ២)។ ដូចការលើកឡើងពីខាងដើម ការធានានូវនិយមន័យរួមមួយ និងវិធីសាស្ត្រស៊ីសង្វាក់គ្នានៅថ្នាក់ជាតិ និងអន្តរជាតិ ជាកត្តាសំខាន់ដែលជួយឱ្យសម្រេចបានគោលដៅនេះ។

ត្រូវមានការគ្រប់គ្រងព័ត៌មានយ៉ាងហ្មត់ចត់ ដើម្បីតាមដានវឌ្ឍនភាពនៃការសម្រេចបានការអប់រំបរិយាបន្នសម្រាប់ជនមានពិការភាព។ ព័ត៌មានទាំងនេះគ្របដណ្តប់លើសពីជំរឿនប្រជាជន និងពាក់ព័ន្ធនឹងទិន្នន័យរដ្ឋបាល និងការអង្កេតឯកទេស។ ឧ. គួរមានព័ត៌មានកាន់តែច្រើនស្តីពីលទ្ធផលសិក្សារបស់កុមារមានពិការភាព ចំនួន និងមូលហេតុនៃការបោះបង់ការសិក្សា បញ្ហាហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនដើម្បីបំពេញតម្រូវការពិសេសរបស់សិស្សមានពិការភាព ប្រភេទ និងគុណភាពនៃប្រព័ន្ធអប់រំសម្រាប់កុមារមានពិការភាព និងជំនាញរបស់គ្រូបង្រៀន ដើម្បីបំពេញតម្រូវការពិសេសរបស់កុមារមានពិការភាព។ គួរផ្តល់ព័ត៌មានទាំងនេះដល់ភាគីទាំងអស់ដែលពាក់ព័ន្ធក្នុងការកែលម្អស្ថានភាពអប់រំរបស់កុមារ និងយុវជនមានពិការភាព។

## លទ្ធភាពបង្កើតកូន និងសុខភាពបន្តពូជ

ក្នុងរបាយការណ៍នេះ មានការវិភាគស្តីពីលទ្ធភាពបង្កើតកូន ដោយប្រើបច្ចេកទេសប៉ាន់ស្មានផ្ទាល់ និងមានការប៉ាន់ស្មានទាបលើកម្រិតលទ្ធភាពបង្កើតកូន ជាងការប៉ាន់ស្មានដោយប្រើវិធីសាស្ត្រប្រយោល។ ដើម្បីតាមដានវឌ្ឍនភាពនៃការមានផ្ទៃពោះ និងការសម្រាលកូនដោយសុវត្ថិភាព ការសំខាន់គឺត្រូវយល់ពីស្ថានភាពជុំវិញការមានផ្ទៃពោះ និងការសម្រាលកូន (ឧ. ថាតើមានការពិនិត្យផ្ទៃពោះមុនពេលសម្រាលដោយអ្នកឯកទេសសុខភាពឱ្យបានយ៉ាងតិច ៨ ដងផ្អែកតាមអនុសាសន៍របស់ WHO ឬទេ ថាតើការសម្រាលកូនធ្វើឡើងដោយឆ្មបជំនាញ ឬទេ និងថាតើមានការថែទាំជិតដល់ក្រោយពេលសម្រាល ឬទេ។ ខណៈដែលក្នុងជំរឿន មានការសួរសំណួរស្តីពីការសម្រាលកូនដោយឆ្មបជំនាញ និងការធ្វើសំបុត្រកំណើត អ្នកតបសម្ភាសន៍ភាគច្រើនមិនបានឆ្លើយសំណួរទាំងនេះឡើយ។ គួរមានការកែលម្អក្នុងជំរឿនលើកក្រោយ ដោយពន្យល់ពីវិធីសាស្ត្រត្រឹមត្រូវក្នុងពេលបណ្តុះបណ្តាល និងក្នុងសៀវភៅណែនាំ។ ក្រៅពីនេះ គួរគូសបញ្ជាក់ពីសារៈសំខាន់នៃការឆ្លើយសំណួរទាំងអស់។ ក្នុងការបណ្តុះបណ្តាល គេអាចផ្តល់ឧទាហរណ៍នៃការបាត់ទិន្នន័យស្តីពីការសម្រាលកូនដោយឆ្មបជំនាញក្នុងជំរឿនបច្ចុប្បន្ន និងពន្យល់ពីផលវិបាកនៃការមិនឆ្លើយសំណួរនេះ។ ដើម្បីលើកកម្ពស់សុខភាព និងសិទ្ធិផ្លូវភេទ និងបន្តពូជរបស់ប្រជាជនទាំងអស់ ការសំខាន់គឺស្ត្រី និងក្មេងស្រីមានពិការភាពត្រូវមានលទ្ធភាពជាសកលក្នុងការទទួលបានព័ត៌មាន និងសេវាដែលមានគុណភាពសម្រាប់ការរៀបចំផែនការគ្រួសារ និងសុខភាពផ្លូវភេទ និងបន្តពូជ។ ទោះជាយ៉ាងណា ជំរឿនមិនមែនជាឧបករណ៍ល្អបំផុតសម្រាប់ការប្រមូលព័ត៌មានស្តីពីសុខភាពបន្តពូជរបស់ស្ត្រីមានពិការភាពនោះទេ។ យកល្អគួរប្រមូលព័ត៌មាន

លម្អិតបន្ថែមទៀតស្ដីពីបញ្ហាទាំងនេះ តាមរយៈការអង្កេតឯកទេស ដូចជា ការអង្កេតប្រជាសាស្ត្រ និងសុខភាព និងការអង្កេតសុខភាពផ្សេងទៀត។

## ជីវិតរស់នៅសមរម្យ

ជាញឹកញាប់ ការដាក់បញ្ចូលជនមានពិការភាពក្នុងស្ថាប័ន មិនត្រូវបានលើកទឹកចិត្តនោះទេ ព្រោះការរស់នៅជាមួយគ្រួសារក្នុងសហគមន៍ ឬការរស់នៅដោយឯករាជ្យ ផ្ដល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ជនមានពិការភាព។ យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ក្នុងចំណោមប្រជាជនចំនួន ៦៨៩.៥៣២ នាក់ ដែលមានអាយុ ៥ ឆ្នាំឡើង និងមានពិការភាព មាន ១៤.៨៩៩ នាក់រស់នៅក្នុងគ្រួសារស្ថាប័ន (ស្មើនឹង ២,២ ភាគរយនៃចំនួនប្រជាជនមានពិការភាពសរុប)។ ដោយសារតែជំរឿននេះគ្មានសំណួរស្ដីពីយថាប្រភេទស្ថាប័ន គេមិនអាចដឹងច្បាស់ថាតើប្រជាជនទាំងនេះរស់នៅទីណាខ្លះនោះទេ។ ដូច្នេះ គួរមានការស្រាវជ្រាវបន្ថែមអំពីអនុក្រុមនេះដើម្បីបញ្ជាក់ពីប្រភេទគ្រួសារស្ថាប័ន និងស្វែងរកជម្រើសផ្សេងទៀតក្រៅពីការដាក់បញ្ចូលក្នុងស្ថាប័ន។ វិធានការនេះនឹងអាចឱ្យមានការបង្កើតគោលនយោបាយកាន់តែប្រសើរដែលលើកកម្ពស់ជីវិតរស់នៅដោយឯករាជ្យ និងងាកចេញពីទម្លាប់ដាក់បញ្ចូលក្នុងស្ថាប័ន។

## សកម្មភាពសេដ្ឋកិច្ច

ភាពមានការងារធ្វើរបស់ជនមានពិការភាព ពាក់ព័ន្ធនឹងកម្រិតអប់រំរបស់ពួកគេ។ ចំណុចសំខាន់គឺប្រសិនបើជនមានពិការភាពទទួលបានការអប់រំល្អ ពួកគេនឹងមានឱកាសប្រើប្រាស់ចំណេះដឹង និងជំនាញដែលទទួលបាន ក្នុងទីផ្សារការងារ។ ការរើសអើងជនមានពិការភាពក្នុងទីផ្សារការងារ និងបញ្ហាជុំវិញការផ្ដល់ភាពងាយស្រួលក្នុងកន្លែងធ្វើការ នៅតែជាការគំរាមកំហែងដ៏ធំ។ ការវាស់វែងស្ថានភាពមានការងារធ្វើរបស់ជនមានពិការភាពក្នុងជំរឿន គឺជាលំបាក ដោយសារតែរបៀបនៃការវាស់វែងភាពមានការងារធ្វើ។ ក្នុងជំរឿននេះ ស្ថានភាពមានការងារធ្វើរបស់ជនមានពិការភាព ផ្អែកលើស្ថានភាពជាក់ស្ដែងរបស់បុគ្គល (ឧ. មនុស្សម្នាក់ត្រូវមាន ឬគ្មានការងារធ្វើក្នុងរយៈពេលលើស ៦ខែមុនជំរឿន ដើម្បីអាចចាត់ទុកជាជនដែលមាន ឬគ្មានការងារធ្វើ។ ជាអនុសាសន៍ ក្នុងការអង្កេត និងជំរឿនលើកក្រោយគួរអនុវត្តតាមអនុសាសន៍របស់ ILO និងគួរកំណត់ស្ថានភាពការងារនៅពេលសម្ភាសន៍ ជាជាងសកម្មភាពសេដ្ឋកិច្ចទូទៅ។

មាត្រា ២៧ នៃអនុសញ្ញាស្ដីពីសិទ្ធិជនពិការទទួលស្គាល់សិទ្ធិរបស់ជនពិការក្នុងការមានការងារធ្វើ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ (UN, n.d.b.)។ ច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ចែងថាជនពិការដែល "មានលក្ខណៈសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងមានសិទ្ធិចូលបម្រើការងារ ដោយគ្មានការរើសអើង" (ព្រះរាជាណាចក្រកម្ពុជា ២០០៩ ជំពូក ៧ មាត្រា ៣៣)។ នៅឆ្នាំ ២០០៨ កម្ពុជាបានចេញអនុក្រឹត្យដែលកំណត់កូតាសម្រាប់ការជ្រើសរើសជនមានពិការភាពឱ្យចូលបម្រើការ។ ក្រឹត្យនេះបញ្ជាក់ថា ក្រសួង និងស្ថាប័នរដ្ឋ ដែលមាននិយោជិតលើស ៥០ នាក់ ត្រូវផ្ដល់ការងារដល់ជនមានពិការភាពឱ្យបានយ៉ាងតិច ២ ភាគរយ ហើយរូបវន្តបុគ្គល/នីតិបុគ្គលដែលមាននិយោជិតលើស ១០០ នាក់គួរផ្ដល់ការងារដល់ជនមានពិការភាពឱ្យបានយ៉ាងតិច ១ ភាគរយ។ សម្រាប់ស្ថាប័ន និងអាជីវកម្មឯកជនដែលមិនអនុវត្តតាមបទបញ្ញត្តិនេះនឹងត្រូវទទួលពិន័យ។ ទោះជាយ៉ាងណា ឯកសារពាក់ព័ន្ធនាពេលថ្មីៗនេះបង្ហាញថា មិនទាន់មានការអនុវត្តពេញលេញនូវកូតានេះ ដើម្បីបង្កើនអត្រាការងារសម្រាប់ជនមានពិការភាពនៅកម្ពុជានោះទេ (Hutt, 2016)។ គ្មានរបាយការណ៍

វាយតម្លៃផ្លូវការស្ដីពីប្រធានបទនេះក្នុងគេហទំព័រណាមួយឡើយ។ ដូចនេះ គួរមានការស្រាវជ្រាវបន្ថែម និងផ្ដល់មតិគាំទ្រស្ដីពីផលប៉ះពាល់លើប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ប្រសិនបើជនមានពិការភាពគ្មានការងារធ្វើគ្រប់គ្រាន់។ ក្រៅពីនេះ ការរើសអើងក៏ជាឧបសគ្គមួយដែលរារាំងលទ្ធភាពទទួលបានការងារផងដែរ។ រដ្ឋាភិបាលកម្ពុជាគួរពង្រឹងច្បាប់ និងគោលនយោបាយរបស់ខ្លួន ក៏ដូចជាបង្កើតរបបគាំពារសង្គម និងរបបហិរញ្ញវត្ថុ ដែលលើកកម្ពស់ និងជំរុញការអនុវត្តច្បាប់ និងគោលនយោបាយទាំងនោះ។ ការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងស្ដីពីពិការភាពដែលផ្ដោតលើនិយោជក ក៏ជាវិធីដ៏សំខាន់មួយក្នុងការជំរុញដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះផងដែរ។ យុទ្ធនាការទាំងនេះមិនគួរកំណត់គោលដៅតែលើនិយោជក និងនិយោជិតប៉ុណ្ណោះទេ ប៉ុន្តែក៏គួរមានការបង្វឹកបង្ហាត់ និងការណែនាំដល់ជនមានពិការភាពដើម្បីបង្កើនទំនុកចិត្ត និងពង្រឹងជំនាញរបស់ពួកគេផងដែរ។ វិស័យសំខាន់មួយទៀតដែលគួរចាត់វិធានការបន្ថែម គឺការធ្វើឱ្យកន្លែងធ្វើការកាន់តែផ្ដល់ភាពងាយស្រួលដល់ជនមានពិការភាព។ ជាញឹកញាប់ ជនមានពិការភាពមិនអាចធ្វើការងារជាក់លាក់ណាមួយបាន ដោយសារគ្មានការកែសម្រួលកន្លែងធ្វើការឱ្យបំពេញតម្រូវការពិសេសរបស់ពួកគេ។ ក្រៅពីនេះ គួរមានការកែសម្រួលប្រព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធទូទៅ ដើម្បីអាចឱ្យជនមានពិការភាពធ្វើដំណើរដល់កន្លែងធ្វើការដោយសុវត្ថិភាព និងប្រសិទ្ធភាព។

## ភាពក្រីក្រ

ក្នុងជំពូកនេះ ស្ថានភាពសង្គមសេដ្ឋកិច្ចរបស់គ្រួសារ ត្រូវបានវាស់វែងតាមរយៈសន្ទស្សន៍ទ្រព្យសម្បត្តិ។ ការវិភាគបង្ហាញថា គ្រួសារដែលមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព មានសមាសភាគច្រើនក្នុងបញ្ចភាគខាងក្រោមនៃសន្ទស្សន៍ទ្រព្យសម្បត្តិ។ មានន័យថា ក្នុងចំណោមនេះ មានគ្រួសារកាន់តែច្រើនដែលមានជីវភាពក្រីក្រ។

ទោះបីជាមិនមែនជនមានពិការភាពគ្រប់រូបសុទ្ធតែរស់នៅក្នុងគ្រួសារក្រីក្រក្ដី ក៏កង្វះការអប់រំ ភាពគ្មានការងារធ្វើ និងភាពក្រីក្រ នៅតែជាផ្នែកមួយនៃវដ្ដដែលគ្របដណ្ដប់លើជីវិតរស់នៅរបស់ជនមានពិការភាពជាច្រើននៅកម្ពុជា។ គួរកត់សម្គាល់ថា គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព អាចមានសមាសភាគច្រើននៅចុងខាងក្រោមបង្អស់នៃវិសាលភាពសេដ្ឋកិច្ច។ ទោះបីជារដ្ឋាភិបាលកម្ពុជា មានកម្មវិធីមួយចំនួនដើម្បីកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរក្នុងចំណោមជនមានពិការភាពក្ដី ប៉ុន្តែអាទិភាពចម្បងគឺការរំដោះអនុក្រុមជនមានពិការភាពឱ្យរួចផុតពីភាពក្រីក្រ តាមរយៈការផ្ដល់លទ្ធភាពឱ្យពួកគេទទួលបានការងារសមរម្យ។ ចំណុចនេះមិនត្រឹមតែលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចរបស់ជនមានពិការភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំបង្កើនគុណភាពជីវិតជារួមរបស់ពួកគេ បង្កើនតម្លៃផ្ទាល់ខ្លួន សេចក្ដីថ្លៃថ្នូរ និងភាពអង់អាច ក៏ដូចជាការទទួលបានសិទ្ធិមនុស្សទៀតផង។

ភាពក្រីក្រពាក់ព័ន្ធនឹងសមត្ថភាពរបស់បុគ្គលក្នុងការរកបានការងារសមរម្យ និងផ្ដល់ប្រាក់ចំណូលដល់ពួកគេ និងក្រុមគ្រួសារ។ ដោយសារតែមិនសូវមានការងារក្នុងទីផ្សារការងារ គួរលើកទឹកចិត្ត និងជួយដល់ជនមានពិការភាពក្នុងការចិញ្ចឹមជីវិត តាមរយៈការប្រកបមុខរបរខ្លួនឯង និងការបង្កើតសហគ្រាសខ្នាតមីក្រូ និងខ្នាតតូច។ ប៉ុន្តែការប្រកបមុខរបរខ្លួនឯងតម្រូវឱ្យមានការវិនិយោគពីដំបូង។ ដូច្នេះ គួរមានការផ្ដល់ឥណទានពិសេសដល់ជនមានពិការភាពក្នុងការចាប់ផ្ដើមសហគ្រាសខ្នាតមីក្រូ និងខ្នាតតូច។

## អាពាហ៍ពិពាហ៍

ស្ថានភាពពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន ជាកត្តាកំណត់ស្ថានភាពអាពាហ៍ពិពាហ៍ទាំងសម្រាប់បុរស និងស្ត្រី។ ជនមានពិការភាព ជាពិសេសជនមានពិការភាពខ្លាំង និងពិការមិនអាចធ្វើអ្វីបាន ច្រើនតែនៅលីវ។ ពោល គឺរស់នៅក្នុងគ្រួសារ ប៉ុន្តែមិនងាយមានទំនាក់ទំនងជាមួយដៃគូ។ និន្នាការនេះលេចឡើងក្នុងចំណោមស្ត្រី ច្រើនជាងក្នុងចំណោមបុរស។ ភាគរយរៀបការក្នុងចំណោមជនមានពិការភាពខ្លាំង មានអត្រាខ្ពស់បន្តិចជាងជនពិការមិនអាចធ្វើអ្វីបាន ប៉ុន្តែទាបជាងជនមានពិការភាពខ្លះ ឬជនមិនពិការ។ ពិការភាព (ពិការខ្លាំង និងពិការមិនអាចធ្វើអ្វីបាន) មានទំនាក់ទំនងទៅនឹងការកើនឡើងនៃការរស់នៅបែកគ្នា ឬការលែងលះគ្នា ដែលអាចដោយសារតែពិការភាពបង្កភាពតានតឹង ឬដាក់សម្ពាធកាន់តែខ្លាំងលើអាពាហ៍ពិពាហ៍។ ប៉ុន្តែគ្មានការសួរសំណួរស្តីពីមូលហេតុនោះទេ។

ការដែលជនមានពិការភាពខ្លាំង ឬពិការមិនអាចធ្វើអ្វីបាន ច្រើនតែនៅលីវ និងរស់នៅដោយគ្មានដៃគូ ឬប្តី/ប្រពន្ធ និងមានការលំបាកក្នុងការទទួលបានការងារ និងចិញ្ចឹមជីវិត ធ្វើឱ្យពួកគេកាន់តែងាយប្រឈមនឹងភាពក្រីក្រ ជាពិសេសស្ត្រីមានពិការភាព។

ដូច្នេះ ជនមានពិការភាពច្រើនតែពឹងផ្អែកលើសាច់ញាតិ ដើម្បីទទួលបានការការពារផ្នែកសេដ្ឋកិច្ច និងសង្គម ហើយពួកគេត្រូវតែមានលទ្ធភាពទទួលបានកិច្ចការពារសង្គម និងជំនួយសម្រាប់គ្រួសារ។ ក្រៅពីនេះ ការអប់រំ ការបណ្តុះបណ្តាល និងការងារត្រូវតែផ្តល់ភាពងាយស្រួល និងកែសម្រួលទៅតាមតម្រូវការរបស់ពួកគេ។

## យេនឌ័រ

របាយការណ៍នេះបង្ហាញថា ពិការភាពគឺជាបញ្ហាយេនឌ័រក្នុងប្រទេសកម្ពុជា។ មានស្ត្រីច្រើនជាង បុរសដែលលើកឡើងថា យ៉ាងហោចណាស់មានពិការភាពខ្លះ។ ចំណុចនេះបណ្តាលមកពីពិការភាពក្នុងប្រទេសកម្ពុជាមានទំនាក់ទំនងជាវិជ្ជមានទៅនឹងអាយុ។ នៅពេលមនុស្សកាន់តែចាស់ មានលទ្ធភាពកាន់តែច្រើននៃការលើកឡើងពីពិការភាព។ ស្ត្រីរស់នៅបានយូរជាងបុរស និងមានឱកាសធ្លាក់ខ្លួនពិការ ច្រើនជាងបុរស។ ក្នុងទិដ្ឋភាពជាច្រើន ស្ត្រី និងក្មេងស្រីក្នុងប្រទេសកម្ពុជា ត្រូវបានរើសអើង ឬស្ថិតក្នុងស្ថានភាពចាញ់ប្រៀបបុរស និងក្មេងប្រុស។ ដូច្នេះ ស្ត្រី និងក្មេងស្រីដែលមានពិការភាពមិនត្រឹមតែត្រូវបានរើសអើងដោយសារយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារពិការភាពរបស់ពួកគេទៀតផង។ របាយការណ៍នេះបង្ហាញថា គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងមានសមាជិកម្នាក់ ឬច្រើននាក់មានពិការភាព មានសមាសភាគច្រើនក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត (២៨,៨ ភាគរយ) ជាងគ្រួសារមានបុរសជាមេគ្រួសារ (២០,៩ ភាគរយ)។ មេគ្រួសារដែលមានពិការភាព និងស្ថិតក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបបំផុត ច្រើនតែជាស្ត្រី ប៉ុន្តែមានករណីលើកលែងក្នុងវិស័យអប់រំ។ បច្ចុប្បន្ន អត្រាចូលរៀនរបស់ក្មេងស្រីគឺខ្ពស់ជាងក្មេងប្រុស ប៉ុន្តែអត្រាអក្ខរភាពក្នុងចំណោមស្ត្រីមានពិការភាពនៅតែទាបជាងបុរសមានពិការភាព។

ដើម្បីទប់ស្កាត់បញ្ហានេះក្នុងការតាក់តែងគោលនយោបាយ ការសំខាន់គឺត្រូវបញ្ជ្រាបពិការភាព និងយេនឌ័រក្នុងគោលនយោបាយ និងវដ្តជីវិត។ ក្នុងន័យនេះ កម្មវិធីអន្តរាគមន៍ទាន់ពេលវេលា ដែលមានការបញ្ជ្រាបយេនឌ័រ ផ្អែកតាមអាយុ មានលក្ខណៈកុមារមេត្រី ផ្តោតលើគ្រួសារ និងសហគមន៍ គួរពិចារណាថា តម្រូវការ និងសមត្ថភាពជាក់លាក់របស់ជនមានពិការភាព ជាពិសេសស្ត្រី និងក្មេងស្រីមានពិការភាព មានសារៈសំខាន់ខ្លាំងណាស់។ ពាក់ព័ន្ធនឹងគោលនយោបាយជាតិ និងអន្តរជាតិ ដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គេគួរបញ្ជ្រាបយេនឌ័រក្នុងការអនុវត្តគោលនយោបាយទាំងនេះក្នុងវិស័យមួយចំនួន ដូចជា កិច្ចការពារសង្គម ការអប់រំ ការងារ ទឹកស្អាត និងអនាម័យ សេវាសុខភាព ជាមពលជាដើម (UN, 2018)។

គោលនយោបាយ និងកម្មវិធីគួរបាញ់ឆ្ពោះទៅរកក្រុមចម្រុះនៃជនមានពិការភាព (heterogenous group) ព្រោះក្រុមនីមួយៗមានប្រភេទពិការភាព បរិស្ថាន វប្បធម៌ ប្រពៃណី និងស្ថានភាពសង្គមសេដ្ឋកិច្ចខុសៗគ្នា។ ពាក់ព័ន្ធនឹងការស្រាវជ្រាវ ជំរឿននេះមិនមែនជាឧបករណ៍ល្អបំផុតសម្រាប់បញ្ជាក់ពីទិដ្ឋភាពយេនឌ័រនៃពិការភាពឡើយ ព្រោះជំរឿននេះមិនបានស្រាវជ្រាវលម្អិតអំពីការរើសអើង អំពើហិង្សា ឬការផាត់ចេញស្ត្រី និងក្មេងស្រីនោះទេ។ ដូច្នេះ គួរមានការសិក្សាដែលផ្តោតលើពិការភាពដើម្បីលុបបំបាត់គម្លាតទិន្នន័យស្តីពីយេនឌ័រ និងពិការភាព។ ជាទូទៅ ទិន្នន័យ និងស្ថិតិទាំងអស់គួរផ្តល់ទិន្នន័យបែងចែកតាមភេទ និងគួរផ្តល់ទិន្នន័យដោយឡែកពីគ្នាសម្រាប់បុរសមានពិការភាព និងស្ត្រីមានពិការភាព។ ក្រៅពីនេះ គួរមានការសិក្សាអំពីភាពងាយរងគ្រោះផ្សេងទៀតសម្រាប់ស្ត្រីមានពិការភាព ដើម្បីបង្កើនការយល់ដឹងពីជីវិតរស់នៅរបស់ស្ត្រីមានពិការភាព។ ក្រុមងាយរងគ្រោះ មានដូចជា ក្រុមជាតិពន្ធ និងសាសនាភាគតិច ក្រុមស្រីស្រឡាញ់ស្រី និងស្ត្រីប្តូរយេនឌ័រ អ្នកជាប់ពន្ធនាគារ ស្ត្រីមេម៉ាយ និងជនទេសន្តរប្រវេសន៍ និងជនភៀសខ្លួន។

## ភាពខុសគ្នាតាមតំបន់រវាងទីប្រជុំជន និងជនបទ

ជនមានពិការភាពភាគច្រើនរស់នៅជនបទ។ ដោយសារជនមានពិការភាពច្រើនតែរស់នៅប្រមូលផ្តុំក្នុងជនបទ និងនៅតាមតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា គួរផ្តោតអាទិភាពនៃកិច្ចខិតខំប្រឹងប្រែងគាំទ្រ និងការផ្តល់សេវានៅតាមតំបន់ទាំងនោះ។ ចំណុចសំខាន់គឺត្រូវបំបែកក្របខណ្ឌគោលនយោបាយ គោលដៅ និងចំណុចដៅថ្នាក់ជាតិ និងកែសម្រួលរបៀបវារៈឱ្យស្របនឹងស្ថានភាពតាមខេត្ត ស្រុក និងសហគមន៍ តាមរយៈការជំរុញការចូលរួមរបស់អង្គការជនពិការ និងក្រុមគោលដៅ។ បន្ទាប់មក គឺការរៀបចំផែនការ និងថវិកាដើម្បីផ្តល់ធនធានគ្រប់គ្រាន់ដល់សហគមន៍មូលដ្ឋាន ដែលមានភាពខ្វះខាតបំផុត។ ក្រៅពីនេះ គួរផ្តល់ការគាំទ្រខ្នាតតូចដែលត្រូវបានកែសម្រួលទៅតាមតម្រូវការ ដូចជា សកម្មភាពផ្សព្វផ្សាយ ដល់ជនមានពិការភាពដែលរស់នៅក្នុងតំបន់មិនសូវប្រមូលផ្តុំ និងលំបាកចូលដល់។ ផ្អែកតាមការវិភាគនេះ គេមិនអាចកំណត់បានថាតើហេតុអ្វីតំបន់មួយចំនួនមានអត្រាពិការភាពខ្ពស់ជាងតំបន់ផ្សេងទៀតនោះទេ (អាចបណ្តាលមកពីកំហុសផ្នែកទិន្នន័យ ឬបណ្តាលមកពីគំរូជាក់ស្តែង។ នេះអាចជាផ្នែកមួយសម្រាប់ការស្រាវជ្រាវបន្ថែមនាពេលអនាគត ព្រោះវិធីទប់ស្កាត់ និងឆ្លើយតបនឹងពិការភាព អាចត្រូវបានកំណត់តាមវិធីនេះ។

## ១៣.២ ការពង្រឹងការប្រមូលទិន្នន័យស្តីពីពិការភាពក្នុងប្រទេសកម្ពុជា

ដើម្បីយល់ពីស្ថានភាពរបស់ជនមានពិការភាព គេត្រូវមានទិន្នន័យបែងចែកជាប្រភេទ និងការស្រាវជ្រាវ។ កង្វះ ទិន្នន័យ និងការស្រាវជ្រាវរាំងដល់ការពិនិត្យតាមដានវឌ្ឍនភាព និងប្រសិទ្ធភាព និងប្រសិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែង។ ក្នុងករណីជាច្រើន គ្មានការបែងចែកទិន្នន័យទៅតាមស្ថានភាពពិការភាព និងគ្មានការវិភាគ ឬបោះពុម្ពផ្សាយទិន្នន័យទាំងនោះ។ អនុសាសន៍ក្នុងផ្នែកនេះពាក់ព័ន្ធនឹងការប្រមូលទិន្នន័យតាមរយៈការអង្កេតគ្រួសារ និងជំរឿន។ អនុសាសន៍ទាំងនេះមិនគ្របដណ្តប់លើអនុសាសន៍សម្រាប់ទិន្នន័យរដ្ឋបាល ព្រោះគ្មានការប្រើប្រាស់ប្រភពទាំងនេះក្នុងពេលចុះប្រមូលទិន្នន័យ។ ទោះជាយ៉ាងណា ការមិនប្រើប្រាស់ប្រភពទិន្នន័យមានស្រាប់នឹងបង្កើនព័ត៌មានដ៏មានតម្លៃស្តីពីពិការភាពក្នុងប្រទេសកម្ពុជា និងជាការអនុវត្តល្អសម្រាប់ការស្រាវជ្រាវនាពេលអនាគត។

១. សំណួរសំខាន់ៗរបស់ក្រុមការងារវ៉ាស៊ីនតោន មិនមែនសម្រាប់វាស់វែងប្រេវ៉ាឡង់ពិការភាពរបស់កុមារ

អាយុក្រោម ៥ ឆ្នាំឡើយ ហើយជាញឹកញាប់ គ្មានទិន្នន័យស្តីពីពិការភាពផ្នែកការអភិវឌ្ឍសម្រាប់កុមារអាយុ ៥ ឆ្នាំឡើងទេ។ នៅឆ្នាំ ២០១៦ ក្រុមការងារវ៉ាស៊ីនតោន បានសហការជាមួយអង្គការ UNICEF បង្កើតម៉ូឌុលស្តីពីការបំពេញមុខងាររបស់កុមារ (CFM) ដែលជាវិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យពិការភាពក្នុងចំណោមកុមារអាយុ ២-៤ ឆ្នាំ និងកុមារអាយុ ៥-១៧ ឆ្នាំ។ អ្នកជំនាញមួយក្រុមបានផលិតកម្រងឯកសារដែលកំណត់សារៈតាសម្រាប់ការបង្កើតម៉ូឌុលនេះ។ ឯកសារទាំងនោះបង្ហាញពីការងារកន្លងមក និងបញ្ហាប្រឈមក្នុងការវាស់វែងពិការភាពរបស់កុមារ និងបានធ្វើការសាកល្បងតាមមូលដ្ឋាន ដើម្បីបង្កើតវិធីសាស្ត្រដែលផ្តល់ទិន្នន័យស្តីពីការបំពេញមុខងាររបស់កុមារ ដែលអាចប្រៀបធៀបជាអន្តរជាតិ (Loeb et al., 2018; Cappa et al., 2018)។ ផ្នែកពីរនៃម៉ូឌុលនេះវាស់វែងការបំពេញមុខងារ ដូចតទៅ ការមើលឃើញ ការស្តាប់លឺ ចល័តភាព ការប្រាស្រ័យទាក់ទង/ការយល់ អាកប្បកិរិយា និងការរៀនសូត្រ (គ្រប់វ័យ) ភាពប៉ិនប្រសប់ និងការលេង (២-៤ ឆ្នាំ) និងការថែទាំខ្លួនឯង ការចងចាំ ការផ្តោតអារម្មណ៍ ការប្រឈមមុខនឹងការផ្លាស់ប្តូរ ទំនាក់ទំនង និងអារម្មណ៍ (៥-១៧ ឆ្នាំ)[21]។ បច្ចុប្បន្ន ម៉ូឌុល នេះត្រូវបានដាក់បញ្ចូលក្នុងការអង្កេតកម្រងសូចនាករចម្រុះរបស់ UNICEF (MICS)។ ដើម្បីទទួលបានទិដ្ឋភាពត្រឹមត្រូវស្តីពីកុមារមានពិការភាពនៅកម្ពុជា គេគួរធ្វើការអង្កេត MICS (ដោយបញ្ចូលម៉ូឌុល ស្តីពីការបំពេញមុខងាររបស់កុមារ ជាផ្នែកមួយនៃការអង្កេតនេះ) ឬបញ្ចូលម៉ូឌុលស្តីពីការបំពេញមុខងាររបស់កុមារក្នុងការអង្កេតគ្រួសារទ្រង់ទ្រាយធំ (ឧ. ការអង្កេតប្រជាសាស្ត្រ និងសុខភាព លើកក្រោយ)។

២. សំណួរទាំង ៦ របស់ក្រុមការងារវ៉ាស៊ីនតោន មិនគ្របដណ្តប់ទាំងស្រុងលើពិការភាពគ្រប់កម្រិតឡើយ។ ដូច្នេះ គេមិនអាចបង្កើតទិដ្ឋភាពរួមនៃស្ថានភាពបច្ចុប្បន្នបានឡើយ។ គួរប្រើប្រាស់កម្រងសំណួរបន្ថែមរបស់ក្រុមការងារវ៉ាស៊ីនតោនដែលផ្តោតសំខាន់លើចលនារាងកាយផ្នែកខាងលើ ការបាក់ទឹកចិត្ត និងភាពថប់បារម្ភ ការឈឺចាប់ និងភាពល្ហិតល្ហៃ។ មិនគួរអនុវត្តដូច្នេះក្នុងជំរឿនឡើយ ព្រោះវាត្រូវការសំណួរច្រើនពេក ប៉ុន្តែក្នុងការអង្កេតមួយចំនួន ជាពិសេសក្នុងវិស័យសុខភាព គួរបញ្ចូលសំណួរទាំងនេះ។ កម្រងសំណួរខ្លីរបស់ក្រុមការងារវ៉ាស៊ីនតោន គឺជាជម្រើសមួយ ព្រោះវាផ្តល់តែសំណួរ ៤ បន្ថែមស្តីពីចិត្តសង្គម និងសំណួរ ២ ស្តីពីផ្នែកខាងលើនៃរាងកាយ ដែលដកស្រង់ពីកម្រងសំណួរបន្ថែមរបស់ក្រុមការងារវ៉ាស៊ីនតោន[22]។

៣. ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ មិនសូវមានសំណួរស្តីពីមូលហេតុដែលធ្វើឱ្យមនុស្សម្នាក់មានពិការភាព។ នេះជាគុណវិបត្តិក្នុងសំណុំទិន្នន័យជំរឿន ព្រោះកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍មួយចំនួន អាចនឹងផ្តោតលើជនមានពិការភាពដោយសារមូលហេតុជាក់លាក់មួយ (ឧ. កម្មវិធីស្តីពីការគាំទ្រផ្នែកសង្គមសម្រាប់អ្នករស់រានពីសង្គ្រាម ដូចជា គ្រាប់មីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាម)។ ដូច្នេះ ការអង្កេតនាពេលខាងមុខគួរបន្ថែមសំណួរមួយស្តីពីមូលហេតុជាក់លាក់ដែលបង្កឱ្យមានពិការភាព។ ជំរឿនជាច្រើនក្នុងតំបន់នេះ មានសំណួរមួយស្តីពីមូលហេតុបង្កពិការភាព។ ដូច្នេះ គួរបន្ថែមសំណួរនេះក្នុងជំរឿនលើកក្រោយនៅកម្ពុជា។ គួរកត់សម្គាល់ថា ការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១៤ ក៏គ្មានសំណួរស្តីពីរបៀបដែលអ្នកតបសម្ភាសន៍ដែលមានពិការភាព មិនអាចបំពេញមុខងារក្នុងផ្នែកមួយចំនួនផងដែរ។ ក្នុងបរិបទប្រទេសកម្ពុជាដែលធ្លាប់ឆ្លងកាត់ជម្លោះហិង្សា គេអាចបញ្ចូលសំណួរប្រភេទនេះ

2 ផ្នែកទាំង ២ នៃម៉ូឌុលនេះអាចទាញយកពីគេហទំព័រ ៖ https://www.washingtongroup-disability.com/question-sets/wgunicef-child-functioning-module-cfm/។

2 សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងកម្រងសំណួរបន្ថែមរបស់ក្រុមការងារវ៉ាស៊ីនតោនស្តីពីការបំពេញមុខងារ សូមចូលទៅកាន់ https://www.washingtongroup-disability.com/question-sets/wg-short-set-on-functioning-%e-93%80%2enhanced-wg-ss-enhanced/។

ក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពលើកក្រោយ។ សំណួរមួយទៀតដែលមិនសូវបានដាក់បញ្ចូលគឺអាយុនៅពេលចាប់ផ្តើមមានពិការភាព។ គេអាចនឹងលំបាកកំណត់អាយុជាក់លាក់នៅពេលមានពិការភាពដំបូង និងប្រហែលជាគួរបញ្ចូលប្រភេទចម្លើយ ដូចតទៅ ក) នៅពេលកើត ខ) នៅវ័យកុមារ (០-១៤ ឆ្នាំ) គ) ក្នុងវ័យធ្វើការ (១៥-៦៤ ឆ្នាំ) នៅវ័យចាស់ (៦៥ ឆ្នាំឡើង)។ ព័ត៌មានពីសំណួរនេះនឹងអាចឱ្យគេធ្វើការវិភាគស៊ីជម្រៅអំពីទំនាក់ទំនងរវាងពិការភាព និងលក្ខណៈសង្គម និងប្រជាសាស្ត្រផ្សេងទៀត។

៤. ការកែលម្អទិន្នន័យមិនត្រឹមតែអាស្រ័យលើព័ត៌មាន ដែលពាក់ព័ន្ធផ្ទាល់នឹងស្ថានភាពពិការភាពរបស់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែដើម្បីទទួលបានទិដ្ឋភាពកាន់តែគ្រប់ជ្រុងជ្រោយស្តីពីស្ថានភាពរស់នៅរបស់ជនមានពិការភាព គេក៏គួរប្រមូលព័ត៌មានសារតាបន្ថែមទៀតផងដែរ។ ឧ. សម្រាប់ការរៀបចំផែនការ គួរមានព័ត៌មានស្តីពីប្រភេទគ្រួសារស្ថាប័នដែលជនមានពិការភាពរស់នៅ។ ដូច្នេះ គេមិនអាចកំណត់ចំនួនជនមានពិការភាព ដែលរស់នៅក្នុងគ្រួសារស្ថាប័នដែលផ្តល់ការថែទាំពិសេសបានឡើយ។ ចំណុចគួរឱ្យចាប់អារម្មណ៍គឺការប្រមូលព័ត៌មានស្តីពីតម្រូវការ និងការគាំទ្រសម្រាប់ជនមានពិការភាព។

៥. ផ្នែកមួយដែលមិនសូវមានការផ្តោតការយកចិត្តទុកដាក់ គឺតម្រូវការ និងការគាំទ្រសម្រាប់ជនមានពិការភាព។ តើសមាជិកគ្រួសារជាអ្នកផ្តល់ការគាំទ្រចម្បង ឬ? តើជនមានពិការភាពទទួលបានការគាំទ្រកម្រិតណាពីអ្នកជំនាញ? ដើម្បីវាស់វែងការគាំទ្រដែលជនមានពិការភាព ទទួលបានពីសមាជិកគ្រួសារផ្សេងទៀត គេអាចសួរសំណួរមួយស្តីពីរយៈពេលដែលសមាជិកគ្រួសារផ្សេងទៀតជួយដល់ជនមានពិការភាព។

៦. ក្នុងករណីមួយចំនួន (ឧ. សកម្មភាពសេដ្ឋកិច្ច) សំណួរក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ មិនអនុលោមតាមគោលការណ៍ និងអនុសាសន៍អន្តរជាតិឡើយ។ ដូច្នេះ ការអង្កេតគ្រួសារ និងជំរឿនលើកក្រោយគួរអនុលោមទាំងស្រុងតាមអនុសាសន៍អន្តរជាតិទាំងនេះ។ ធ្វើដូច្នេះទើបគេអាចធ្វើការប្រៀបធៀបជាអន្តរជាតិប្រកបដោយអត្ថន័យ។

អនុសាសន៍ដែលលើកឡើងខាងលើគ្របដណ្តប់លើសពីជំរឿន និងមានសារៈសំខាន់សម្រាប់ការអង្កេតគ្រួសារទាំងអស់ដែលត្រូវបានរៀបចំឡើង។ អ្វីដែលសំខាន់គឺជំរឿន និងការអង្កេតគ្រួសារត្រូវច្បាមយកកម្រិតបរិយាបន្នក្នុងសង្គមកម្ពុជា។ ដើម្បីយល់ពីការប្រែប្រួលស្ថានភាពរបស់ជនមានពិការភាពក្នុងគ្រប់ទិដ្ឋភាពជីវិត ទិន្នន័យដែលទទួលបានពីការអង្កេតផ្សេងៗត្រូវអាចប្រៀបធៀបគ្នាបាន។

ចាំបាច់ត្រូវធ្វើការបែងចែកទិន្នន័យតាមពិការភាព និងយេនឌ័រ ដើម្បីកំណត់ទិដ្ឋភាពរបស់ក្រុមជួបការលំបាកទាំងនេះ។ ក្រៅពីនេះ របាយការណ៍ឈានមុខរបស់អង្គការសហប្រជាជាតិស្តីពីពិការភាព (UN 2018) ក៏ស្នើឱ្យមានការបែងចែកទិន្នន័យជាប្រភេទផ្សេងទៀតដែរ និងគួរក្លាយជាស្តង់ដារសម្រាប់គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល និងសង្គមស៊ីវិល ៖

- ពិការភាព និងភេទ (កំណត់អត្តសញ្ញាណស្ត្រី និងក្មេងស្រីដែលមានពិការភាព)
- ពិការភាព និងអាយុ (កំណត់អត្តសញ្ញាណកុមារ និងមនុស្សចាស់ដែលមានពិការភាព)
- ពិការភាព និងប្រាក់ចំណូល (កំណត់អត្តសញ្ញាណជនក្រីក្រដែលមានពិការភាព)
- ប្រភេទនៃពិការភាព (ដូចជា ពិការភាពផ្នែកសតិបញ្ញា និងចិត្តសង្គម)
- ពិការភាព និងក្រុមសង្គម (ឧ. កំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិចដែលមានពិការភាព)
- គួរប្រមូលទិន្នន័យស្តីពីចំណាយបន្ថែមដែលពាក់ព័ន្ធនឹងពិការភាព។

ការកែលម្អព័ត៌មានស្តីពីពិការភាពមិនកម្រិតត្រឹមការបន្ថែមសំណួរ ឬការបែងចែកជាប្រភេទផ្សេងទៀតនោះទេ។ អ្វីដែលសំខាន់គឺត្រូវរិះរកវិធីបង្កើនគុណភាពទិន្នន័យដែលប្រមូលបាន។ ការវិភាគបង្ហាញថា នៅចំណុចផ្សេងៗ គេអាចកែលម្អគុណភាពនៃទិន្នន័យស្តីពីពិការភាពដែលប្រមូលបានក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ ចាប់ពីការទទួលបានចំនួនប៉ាន់ស្មានដែលកំណត់យ៉ាងល្អិតល្អន់ និងកាន់តែសុក្រឹតស្តីពីប្រេវ៉ាឡង់នៃពិការភាព រហូតដល់ការរាយការណ៍កាន់តែប្រសើរស្តីពីប្រភេទពិការភាព។ ដូចការគូសបញ្ជាក់ក្នុងរបាយការណ៍នេះ មានចំនួនប្រជាជនច្រើនមិនគួរឱ្យជឿដែលបញ្ជាក់ថា ពួកគេមានបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹងការបំពេញមុខងារទាំង ៦ ប្រភេទ ឬមិនអាចធ្វើអ្វីបាន សោះ។ ខាងក្រោមនេះជាការកែសម្រួលដែលត្រូវបានដាក់ស្នើសម្រាប់កម្រងសំណួរក្នុងជំរឿន និងការអង្កេតផ្សេងទៀត ៖

សំណួររបស់ក្រុមការងារវ៉ាស៊ីនតោនត្រូវបានបង្ហាញជាទម្រង់បំព្រួញក្នុងកម្រងសំណួរ (សូមមើលរូប ១៣.១)។ ការបង្ហាញសំណួរក្នុងទម្រង់នេះអាចប៉ះពាល់ដល់គុណភាពនៃព័ត៌មាន និងអាចធ្វើឱ្យមានការកំណត់កូដមនុស្សជាច្រើនថាមានការលំបាកបំពេញមុខងារទាំង ៦ ប្រភេទ។ យកល្អមិនគួរច្របាច់បញ្ចូលកម្រងសំណួរខ្លីទាំង ៦ របស់ក្រុមការងារវ៉ាស៊ីនតោនក្នុងសំណួរតែមួយទេ ប៉ុន្តែត្រូវបង្ហាញសំណួរនីមួយៗដាច់ដោយឡែកពីគ្នា ដើម្បីកុំឱ្យអ្នកសម្ភាសន៍មានការយល់ច្រលំ និងប្រព្រឹត្តកំហុស ហើយនេះជាបញ្ហាចោទក្នុងទម្រង់បច្ចុប្បន្ន។ ចំណុចមួយទៀតគឺអ្នកសម្ភាសន៍អាចនឹងយល់ថាសំណួរ "តើអ្នកមានការលំបាក....?" ជាសំណួរផ្តើមទូទៅជាជាងផ្នែកដំបូងនៃសំណួរផ្សេងៗគ្នាទាំង ៦។ ក្រុមការងារវ៉ាស៊ីនតោនដាស់តឿនម្តងហើយម្តងទៀតចំពោះការប្រើប្រាស់សំណួរផ្តើមទូទៅ (ក្រុមការងារវ៉ាស៊ីនតោន ២០២០) ព្រោះសំណួរនេះកាត់បន្ថយការរាយការណ៍ពីការលំបាកបំពេញមុខងារ។ ចំណុចសំខាន់គឺត្រូវសួរសំណួរម្តងមួយៗស្តីពីសមាជិកគ្រួសារទាំងអស់ក្នុងបញ្ជីឈ្មោះ។ នេះជាចំណុចសំខាន់នៅពេលគេប្រើប្រាស់អ្នកតបសម្ភាសន៍គ្រួសារដូចក្នុងករណីជំរឿនភាគច្រើន។ ផ្អែកតាមគំរូពីប្រទេសផ្សេងទៀតក្នុងតំបន់ ជំរឿនលើកក្រោយ ឬការអង្កេតគ្រួសារផ្សេងទៀត អាចប្រើប្រាស់តាប្លេត (tablet) ឬស្មាតហ្វូន (ជាជាងកម្រងសំណួរលើក្រដាស) ដែលនឹងជួយដោះស្រាយបញ្ហានៃការខ្វះចន្លោះសរសេរលើក្រដាសបានដោយស្វ័យប្រវត្តិ។

រូប ១៣.១ ៖ ទម្រង់សំណួរស្តីពីពិការភាពក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| ការលំបាកបំពេញមុខងារ | កូឡេាន ១៧ ៖ ការលំបាកបំពេញមុខងារ<br>តើអ្នកមានការលំបាក.........<br>១៧.១ ក្នុងការមើល ទោះបីជាប្រើវ៉ែនតា ឬទេ ?<br>១៧.២ ក្នុងការស្តាប់ ទោះបីប្រើគ្រឿងជំនួយស្តាប់ ឬទេ ?<br>១៧.៣ ក្នុងការដើរ ឬឡើងជណ្តើរ ឬទេ ?<br>១៧.៤ ក្នុងការចងចាំ ឬការគិត ឬទេ ?<br>១៧.៥ ក្នុងការថែទាំខ្លួនឯង ដូចជា ងូតទឹក ស្លៀកពាក់ ឬទេ ?<br>១៧.៦ ក្នុងការប្រើប្រាស់ភាសាទូទៅ (ធម្មតា) តើអ្នកមានការលំបាកក្នុងការនិយាយ ដូចជា យល់អ្នកដទៃ ឬឱ្យអ្នកដទៃយល់ ឬទេ ? |
|---|---|
| ១៧ | |
| សូមមើលកំណត់សម្គាល់ខាងក្រោម<br>(បញ្ចូលកូដពីក្នុងបញ្ជីខាងក្រោម) | កូដសម្រាប់កូឡេាន ១៧<br>១.ទេ មិនលំបាកទេ<br>២.បាទ លំបាកខ្លះដែរ<br>៣.បាទ លំបាកខ្លាំង<br>៤.មិនអាចធ្វើអ្វីទាំងអស់។ |

- ការមាក់ងាយ និងការរើសអើងអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃលទ្ធផលទិន្នន័យស្តីពីពិការភាពក្នុងប្រទេសកម្ពុជា ព្រោះកត្តាទាំងនេះអាចជះឥទ្ធិពលលើដំណើរការប្រមូលទិន្នន័យ។ អ្នកសម្ភាសន៍អាចចាត់ទុកថា សំណួរស្តីពីពិការភាពជាសំណួរដែលប៉ះពាល់អារម្មណ៍ ដោយសារតែឥរិយាបថអវិជ្ជមានផ្ទាល់ខ្លួនចំពោះពិការភាព ដែលបណ្តាលមកពីការយល់ច្រលំ។ ដើម្បីបញ្ចៀសបញ្ហានេះ អ្នកសម្ភាសន៍នឹងមិនអានសំណួរនោះទេ ប៉ុន្តែអាចមានការផ្អាកបន្តិចដើម្បីកុំឱ្យអ្នកសម្ភាសន៍បន្តទៅសំណួរបន្ទាប់។ សមាសភាគដ៏សំខាន់មួយគឺការលើកឡើងរបស់ក្រុមការងារវ៉ាស៊ីនតោនស្តីពីរបៀបពិភាក្សាអំពីពិការភាពបច្ចុប្បន្នជាមួយអ្នកតបសម្ភាសន៍។ មិនគួរប្រើពាក្យ "ពិការភាព" (disability/handicap) ក្នុងកម្រងសំណួរ ឬក្នុងវគ្គ បណ្តុះបណ្តាលឡើយហើយក៏មិនគួររំលឹកពាក្យទាំងនេះក្នុងសៀវភៅណែនាំការបណ្តុះបណ្តាល ឬឯកសារផ្សេងទៀតដែរ។ ប្រសិនបើមានប្រយោគផ្តើមដំបូង មិនគួរប្រើពាក្យ "ពិការភាព" នោះទេ។ គួរយល់ឱ្យបានច្បាស់ថា សំណួរនេះផ្តោតលើបញ្ហាក្នុងការបំពេញមុខងារ ប៉ុន្តែមិនសំដៅដោយផ្ទាល់លើ "ពិការភាព" ឡើយ (ក្រុមការងារវ៉ាស៊ីនតោន ២០២០)។ ក្នុងពេលសម្ភាសន៍ អ្នកសម្ភាសន៍ និងអ្នកសួរសំណួរគួរប្រើប្រាស់វាក្យស័ព្ទដែលពាក់ព័ន្ធនឹងសកម្មភាព និងការបំពេញមុខងារឱ្យបាន

ត្រឹមត្រូវ។ ក្នុងពេលបណ្តុះបណ្តាលក៏គួរអនុវត្តដូចគ្នានេះដែរ។ ការកែសម្រួលទូទៅ ប៉ុន្តែមានសារៈសំខាន់ ដូចជា ការអនុវត្តខាងលើ អាចបង្កផលប៉ះពាល់យ៉ាងធំធេងលើគុណភាពនៃទិន្នន័យស្តីពីពិការភាព។ គួរកត់សម្គាល់ថា កម្រងសំណួរ ក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ ២០១៤ កំណត់យក "ពិការភាព" ជាពាក្យប្រើប្រាស់ទូទៅក្នុងកម្រងសំណួររបស់ក្រុមការងារវ៉ាស៊ីនតោន។ ដូច្នេះ មិនគួរប្រើពាក្យនេះក្នុងការអង្កេតលើកក្រោយឡើយ។

- គួរផ្តោតការយកចិត្តទុកដាក់លើការបកប្រែសំណួររបស់ក្រុមការងារវ៉ាស៊ីនតោន។ ប្រសិនបើក្នុងជំរឿនមួយ កម្រងសំណួរត្រូវបានបកប្រែជាភាសាផ្សេង សំណួរ និងចម្លើយទាំងអស់គួរមានអត្ថន័យដូចអត្ថន័យក្នុងទម្រង់ដើម។ ជាការល្អ គួរបកប្រែកម្រងសំណួរដែលបានបកប្រែហើយ ជាភាសាអង់គ្លេសវិញ ដោយអ្នកបកប្រែអាជីពដែលមិនធ្លាប់ចូលរួមក្នុងការបកប្រែពីមុន។ ការបកប្រែនេះ អាចយកទៅប្រៀបធៀបជាមួយសំណួរដើមជាភាសាអង់គ្លេសរបស់ក្រុមការងារវ៉ាស៊ីនតោន។ ក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ ការបកប្រែចម្លើយពាក់ព័ន្ធនឹងប្រភេទពិការភាពធ្វើបានត្រឹមត្រូវ លើកលែងតែចម្លើយ "A lot of difficulty" ដែលត្រូវបានបកប្រែថា "លំបាកខ្លាំង ឬលំបាកមិនអាចធ្វើអ្វីបាន"។ គួរបញ្ចៀសបញ្ហានេះឱ្យបាន។

- វគ្គបណ្តុះបណ្តាលស៊ីជម្រៅសម្រាប់អ្នកសម្ភាសន៍ ស្តីពីរបៀបដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសំណួរស្តីពីពិការភាព ជាធាតុផ្សំដ៏សំខាន់នៃការផលិតទិន្នន័យដែលមានគុណភាពខ្ពស់។ ជាទូទៅ គួរផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើចំណុចនេះក្នុងសៀវភៅណែនាំការបណ្តុះបណ្តាល។ បច្ចុប្បន្ន សៀវភៅណែនាំអ្នកសម្ភាសន៍ និងអ្នកសួរសំណួរក្នុងប្រទេសជាច្រើន ហាក់ផ្តោតលើការពន្យល់ខ្លឹមសារនៃសំណួរស្តីពីពិការភាព ប៉ុន្តែមិនសូវមានការផ្តោតការយកចិត្តទុកដាក់លើបច្ចេកទេសសម្ភាសន៍ដើម្បីទទួលបានទិន្នន័យដែលមានសុពលភាព និងគុណភាពខ្ពស់ស្តីពីពិការភាពឡើយ។ ការប្រើប្រាស់កម្រងសំណួរទម្រង់ឌីជីថលអាចជួយដល់ការប្រមូលទិន្នន័យស្តីពីប្រធានបទទាំងអស់ រួមទាំងពិការភាព។ ឧ. អាចបញ្ចូលសារថតទុកជាមុនដែលជំរុញឱ្យអ្នកតបសម្ភាសន៍ឆ្លើយសំណួរឱ្យបានត្រឹមត្រូវ។ ក្រោយបញ្ចប់ការប្រមូលទិន្នន័យ ត្រូវសម្អាតព័ត៌មានទាំងអស់ដោយអនុវត្តយ៉ាងត្រឹមត្រូវតាមវិធាននៃការកែសម្រួល និងត្រូវធ្វើការវាយតម្លៃគុណភាពទិន្នន័យ។ ក្រៅពីនេះ ការប្រើប្រាស់កម្រងសំណួរទម្រង់ឌីជីថលក្នុងតាប្លេត ឬស្មាតហ្វូនផ្តល់គុណសម្បត្តិជាច្រើនពាក់ព័ន្ធនឹងគុណភាពទិន្នន័យ បើធៀបនឹងកម្រងសំណួរលើក្រដាស។ នៅពេលប្រើទម្រង់ស្វ័យប្រវត្តិ គេអាចបញ្ចៀសកំហុសឆ្គងជាច្រើនពាក់ព័ន្ធនឹងការរំលងសំណួរ។ ក្នុងកម្រងសំណួរទម្រង់ឌីជីថល គេអាចបញ្ចូលការត្រួតពិនិត្យ និងការក្រើនរំលឹកដើម្បីបញ្ចៀសបញ្ហាសង្គតិភាព។ ច្បាស់ណាស់ថា ការប្រើប្រាស់កម្រងសំណួរទម្រង់ឌីជីថលដោយមានការពិនិត្យការកែសម្រួលត្រឹមត្រូវ អាចជួយបញ្ចៀសបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងទិន្នន័យក្នុងជំរឿន។ បញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងទិន្នន័យស្តីពីពិការភាពក្នុងជំរឿននេះ ក៏លេចឡើងញឹកញាប់ក្នុងជំរឿនផ្សេងទៀត និងការអង្កេតគ្រួសារផងដែរ។

- ដូចការគូសបញ្ជាក់ក្នុងរបាយការណ៍នេះ ជំរឿនជាច្រើនក្នុងតំបន់អាស៊ី ប្រឈមនឹងបញ្ហាដូចគ្នានឹងជំរឿនក្នុងប្រទេសកម្ពុជា ដូចជា ការសម្ភាសន៍ចំនួនជនមានពិការភាពតិចជាងចំនួនជាក់ស្តែង និងបញ្ហាសង្គតិភាពទិន្នន័យ។ ដូច្នេះ គួរបង្កើត និងសាកល្បងជាអន្តរជាតិនូវវិធីកែលម្អការប្រមូលទិន្នន័យស្តីពីពិការភាព។ ជាការល្អ គួរធ្វើការវាយតម្លៃជារួមលើគុណភាពនៃទិន្នន័យជំរឿន និងការអង្កេតក្នុងតំបន់ដោយប្រើសំណួររបស់ក្រុមការងារវ៉ាស៊ីនតោន និងរិះរកបច្ចេកទេសកែលម្អគុណភាពនៃទិន្នន័យទាំងនេះ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១

**តារាង ក១ ចំនួនមនុស្ស បែងចែកតាមក្រុមអាយុ ៥ ឆ្នាំ ភេទ និងកម្រិតពិការភាព**

| ក្រុមអាយុ | ប្រុស | | | | | ស្រី | | | | | សរុប | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | សរុប | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | សរុប | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | សរុប |
| ០-៤ | ៧៤៥.៩៦៣ | - | - | - | ៧៤៥.៩៦៣ | - | - | - | - | ៧០៤.១៩៦ | - | - | - | - | ១.៤៥០.១៥៩ |
| ៥-៩ | ៧៤២.២៩២ | ៨.៤៧៧ | ១.៦៦៧ | ១.១០៥ | ៧៥៣.៥៤១ | ៧០៩.២៧០ | ៧.៨៦៣ | ១.៥៣២ | ៨៩៨ | ៧១៩.៥៦៣ | ១.៤៥១.៥៦២ | ១៦.៣៤០ | ៣.១៩៩ | ២.០០៣ | ១.៤៧៣.១០៤ |
| ១០-១៤ | ៨៣៤.៥៦៩ | ៥.២៨៧ | ១.៤៩៧ | ១.៥៣៨ | ៨៤២.៨៩១ | ៧៩៧.២៧៥ | ៤.៨៦៦ | ១.៤១០ | ១.៤៣៥ | ៨០៤.៩៨៦ | ១.៦៣១.៨៤៤ | ១០.១៥៣ | ២.៩០៧ | ២.៩៧៣ | ១.៦៤៧.៨៧៧ |
| ១៥-១៩ | ៧០២.៩៧៨ | ៤.៥៨៦ | ១.៤៤៧ | ១.២២៦ | ៧១០.២៣៧ | ៦៩១.៩៧១ | ៤.៧៣៥ | ១.២៨៣ | ១.១២៤ | ៦៩៩.១១៣ | ១.៣៩៤.៩៤៩ | ៩.៣២១ | ២.៧៣០ | ២.៣៥០ | ១.៤០៩.៣៥០ |
| ២០-២៤ | ៦០២.៩០៥ | ៥.៤៣១ | ១.៨៤០ | ១.២០១ | ៦១១.៣៧៧ | ៦៣៤.៧៧៧ | ៦.១១៣ | ១.៦៨៧ | ១.២២៦ | ៦៤៣.៨ ០៣ | ១.២៣៧.៦៨២ | ១១.៥៤៤ | ៣.៥២៧ | ២.៤២៧ | ១.២៥៥.១៨០ |
| ២៥-២៩ | ៦៨៧.២១០ | ៧.៦៤៧ | ២.២២៥ | ១.៤០៣ | ៦៩៨.៤៨៥ | ៧១៨.០១៦ | ៨.០១២ | ២.២១១ | ១.៥២៤ | ៧២៩.៧៦៣ | ១.៤០៥.២២៦ | ១៥.៦៥៩ | ៤.៤៣៦ | ២.៩២៧ | ១.៤២៨.២៤៨ |
| ៣០-៣៤ | ៦២៧.២៦៩ | ៨.៨៨២ | ២.២៣៩ | ១.២៧២ | ៦៣៩.៦៦២ | ៦៥៣.៦១៤ | ៩.២១១ | ២.២០៦ | ១.៣១៨ | ៦៦៦.៣៤៩ | ១.២៨០.៨៨៣ | ១៨.០៩៣ | ៤.៤៤៥ | ២.៥៩០ | ១.៣០៦.០១១ |
| ៣៥-៣៩ | ៦៣០.៨៨៥ | ១១.០៥៣ | ២.៦៧០ | ១.៣១៤ | ៦៤៥.៩២២ | ៦៤៥.០១២ | ១១.៦០៦ | ២.៣០៣ | ១.៣៧៩ | ៦៦០.៣០០ | ១.២៧៥.៨៩៧ | ២២.៦៥៩ | ៤.៩៧៣ | ២.៦៩៣ | ១.៣០៦.២២២ |
| ៤០-៤៤ | ៣៥៤.២៥៧ | ៩.៧៩១ | ១.៧៧០ | ៨៩៤ | ៣៦៦.៧១២ | ៣៧២.២៨៥ | ១១.១៦៥ | ១.៨៦៦ | ៩៨៥ | ៣៨៦.៣០១ | ៧២៦.៥៤២ | ២០.៩៥៦ | ៣.៦៣៦ | ១.៨៧៩ | ៧៥៣.០១៣ |
| ៤៥-៤៩ | ៣៦១.២១០ | ១៥.៥០៦ | ២.៧០៧ | ១.២២៨ | ៣៨០.៦៥១ | ៣៨៦.៨៥៩ | ១៧.៦៨៥ | ២.៩៣៩ | ១.២០០ | ៤០៨.៦៨៣ | ៧៤៨.០៦៩ | ៣៣.១៩១ | ៥.៦៤៦ | ២.៤២៨ | ៧៨៩.៣៣៤ |
| ៥០-៥៤ | ៣០៦.៦៦៤ | ២០.៤៨៦ | ៣.១៦៨ | ៩៨៤ | ៣៣១.៣០២ | ៣៥៣.៣៣១ | ២៥.៤៩៣ | ៣.៤៦១ | ១.២២៩ | ៣៨៣.៥១៤ | ៦៥៩.៩៩៥ | ៤៥.៩៧៩ | ៦.៦២៩ | ២.២១៣ | ៧១៤.៨១៦ |
| ៥៥-៥៩ | ២៦៦.៤៦៧ | ២៤.១៨៨ | ៣.៩០៩ | ១.០៤៩ | ២៩៥.៦១៣ | ៣០៧.៨០៤ | ៣១.២៧៣ | ៤.៣៣១ | ១.១៨៨ | ៣៤៤.៥៩៦ | ៥៧៤.២៧១ | ៥៥.៤៦១ | ៨.២៤០ | ២.២៣៧ | ៦៤០.២០៩ |
| ៦០-៦៤ | ១៦០.៨៨៩ | ២៣.១៦៤ | ៣.៦១៤ | ៨១៨ | ១៨៨.៤៨៥ | ២៣១.៨៥៧ | ៣៩.០៥៦ | ៥.៥៦៧ | ១.២៧៧ | ២៧៧.៧៥៧ | ៣៩២.៧៤៦ | ៦២.២២០ | ៩.១៨១ | ២.០៩៥ | ៤៦៦.២៤២ |
| ៦៥-៦៩ | ១១៨.៥០២ | ២១.៨០០ | ៣.៥៨៥ | ៨៨៧ | ១៤៤.៧៧៤ | ១៦៧.៨៥១ | ៣៨.៥២០ | ៦.៩០៤ | ១.៤៤៥ | ២១៤.៧២០ | ២៨៦.៣៥៣ | ៦០.៣២០ | ១០.៤៨៩ | ២.៣៣២ | ៣៥៩.៤៩៤ |
| ៧០-៧៤ | ៦៩.៨៦២ | ២០.៨៥៤ | ៤.៥៧៣ | ៩៦៦ | ៩៦.២៥៥ | ៩៧.៦៨៣ | ៣៦.៥០៤ | ៩.២៧០ | ១.៦៦៨ | ១៤៥.១២៥ | ១៦៧.៥៤៥ | ៥៧.៣៥៨ | ១៣.៨៤៣ | ២.៦៣៤ | ២៤១.៣៨០ |
| ៧៥-៧៩ | ៤១.២០៧ | ១៥.១៩៧ | ៤.១៩៤ | ៨៨៧ | ៦១.៤៨៥ | ៥៧.០៥៥ | ២៥.៥០៣ | ៨.៧៣០ | ១.៧៧១ | ៩៣.០៥៩ | ៩៨.២៦២ | ៤០.៧០០ | ១២.៩២៤ | ២.៦៥៨ | ១៥៤.៥៤៤ |
| ៨០-៨៤ | ១៩.២៥៨ | ៩.៦២៣ | ៤.២៩២ | ៩២២ | ៣៤.០៩៥ | ២៨.៨៨៥ | ១៦.២៩៤ | ៨.៧៩៦ | ២.០៥៧ | ៥៦.០៣២ | ៤៨.១៤៣ | ២៥.៩១៧ | ១៣.០៨៨ | ២.៩៧៩ | ៩០.១២៧ |
| ៨៥-៨៩ | ៩.០២២ | ៤.៧១១ | ២.៦០១ | ៦៧០ | ១៧.០០៤ | ១៤.៤១៤ | ៨.២៩៤ | ៥.៤៩០ | ១.៦៣៤ | ២៩.៨៣២ | ២៣.៤៣៦ | ១៣.០០៥ | ៨.០៩១ | ២.៣០៤ | ៤៦.៨៣៦ |
| ៩០-៩៤ | ២.១២០ | ១.១២១ | ១.១៣៤ | ៣៨៣ | ៤.៧៥៨ | ៣.៥៤៤ | ២.០១៣ | ២.១៩២ | ៨៩៧ | ៨.៦៤៦ | ៥.៦៦៤ | ៣.១៣៤ | ៣.៣២៦ | ១.២៨០ | ១៣.៤០៤ |
| ៩៥-៩៩ | ៧៧៤ | ១៨៣ | ២៣៧ | ១០១ | ១.២៩៥ | ៩៩៧ | ៤១៨ | ៥៧៣ | ២៣៥ | ២.២២៣ | ១.៧៧១ | ៦០១ | ៨១០ | ៣៣៦ | ៣.៥១៨ |
| ១០០+ | ៨៧៥ | ១៨៥ | ១៩៥ | ៧៥ | ១.៣៣០ | ៨០៥ | ៣៦៦ | ៤១០ | ២៣២ | ១.៨១៣ | ១.៦៨០ | ៥៥១ | ៦០៥ | ៣០៧ | ៣.១៤៣ |
| សរុប | ៧.២៨៥.១៧៨ | ២១៨.១៧២ | ៤៩.៥៦៤ | ១៨.៩២៣ | ៧.៥៧១.៨៣៧ | ៧.៥៧៧.៥០១ | ៣០៤.៩៩០ | ៧៣.១៦១ | ២៤.៧២២ | ៧.៩៨០.៣៧៤ | ១៤.៨៦២.៦៧៩ | ៥២៣.១៦២ | ១២២.៧២៥ | ៤៣.៦៤៥ | ១៥.៥៥២.២១១ |

## តារាង ក២ ចំនួនមនុស្ស តាមកំរិតពិការភាព ភេទ និងខេត្ត ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

| | ប្រុស | | | | | ស្រី | | | | | សរុប | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | សរុប | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | សរុប | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | ពិការមិនអាចធ្វើអ្វីបាន | សរុប |
| បន្ទាយមានជ័យ | ៤០៨.២៥១ | ១៥.៣៧២ | ៣.៣៥០ | ៩៧២ | ៤២៧.៩៤៥ | ៤០៩.៤៤៨ | ១៨.៩៩៧ | ៤.២៤៦ | ១.២៤៧ | ៤៣៣.៩៣៨ | ៨១៧.៦៩៩ | ៣៤.៣៦៩ | ៧.៥៩៦ | ២.២១៩ | ៨៦១.៨៨៣ |
| បាត់ដំបង | ៤៦៤.០២៣ | ២០.៦០៦ | ៤.៧០២ | ១.០៩៣ | ៤៩០.៤២៤ | ៤៧១.៤៧៦ | ២៧.៥៧២ | ៦.៣៥៥ | ១.៣៤២ | ៥០៦.៧៤៥ | ៩៣៥.៤៩៩ | ៤៨.១៧៨ | ១១.០៥៧ | ២.៤៣៥ | ៩៩៧.១៦៩ |
| កំពង់ចាម | ៤១០.៩៣២ | ១៥.៤៣៩ | ៣.៣៤១ | ១.៦១៥ | ៤៣១.៣២៧ | ៤៣៨.៥៧៣ | ២២.៣០៥ | ៥.៣០៨ | ២.២៧៨ | ៤៦៨.៤៦៤ | ៨៤៩.៥០៥ | ៣៧.៧៤៤ | ៨.៦៤៩ | ៣.៨៩៣ | ៨៩៩.៧៩១ |
| កំពង់ឆ្នាំង | ២៤០.៥៦១ | ៩.៦៥៩ | ១.៦០៣ | ៣៦២ | ២៥២.១៨៥ | ២៥៥.៨៦១ | ១៥.៦៣៤ | ២.៨៤៤ | ៥០៣ | ២៧៤.៨៤២ | ៤៩៦.៤២២ | ២៥.២៩៣ | ៤.៤៤៧ | ៨៦៥ | ៥២៧.០២៧ |
| កំពង់ស្ពឺ | ៤១០.៤៥៨ | ១១.១០៧ | ២.៤៦៨ | ១.០៦៩ | ៤២៥.១០២ | ៤៣១.៤៤៥ | ១៥.៦៨៥ | ៣.៩៤៥ | ១.៣៤៦ | ៤៥២.៤២១ | ៨៤១.៩០៣ | ២៦.៧៩២ | ៦.៤១៣ | ២.៤១៥ | ៨៧៧.៥២៣ |
| កំពង់ធំ | ៣១៧.១៧២ | ១០.០៦១ | ២.៤២៧ | ៩៤២ | ៣៣០.៦០២ | ៣៣២.១៩៨ | ១៤.០៦៥ | ៣.៥០៨ | ១.១៧៦ | ៣៥០.៩៤៧ | ៦៤៩.៣៧០ | ២៤.១២៦ | ៥.៩៣៥ | ២.១១៨ | ៦៨១.៥៤៩ |
| កំពត | ២៧៨.២១៣ | ៦.៩៦០ | ១.៧៣២ | ៦៨៥ | ២៨៧.៥៩០ | ២៩២.៨៤៥ | ១០.០៩៧ | ២.៤៥១ | ៨៤៦ | ៣០៦.២៣៩ | ៥៧១.០៥៨ | ១៧.០៥៧ | ៤.១៨៣ | ១.៥៣១ | ៥៩៣.៨២៩ |
| កណ្ដាល | ៥៥៩.៨៦៧ | ១៦.៦០១ | ៣.៥១៤ | ១.៥៨១ | ៥៨១.៥៦៣ | ៥៨៨.៩៩០ | ២៣.៥៦០ | ៥.៣៤៧ | ២.១២១ | ៦២០.០១៨ | ១.១៤៨.៨៥៧ | ៤០.១៦១ | ៨.៨៦១ | ៣.៧០២ | ១.២០១.៥៨១ |
| កោះកុង | ៦១.៣៧៨ | ១.៦៣៤ | ៣២៤ | ១០៨ | ៦៣.៤៤៤ | ៥៩.៧២៣ | ២.១៥៩ | ៤០៥ | ១៧១ | ៦២.៤៥៨ | ១២១.១០១ | ៣.៧៩៣ | ៧២៩ | ២៧៩ | ១២៥.៩០២ |
| ក្រចេះ | ១៨០.៣១៣ | ៤.៧៩០ | ១.១៥៤ | ៤០១ | ១៨៦.៦៥៨ | ១៧៩.៥១១ | ៦.៥២៧ | ១.៥២៣ | ៥៣៦ | ១៨៨.០៩៧ | ៣៥៩.៨២៤ | ១១.៣១៧ | ២.៦៧៧ | ៩៣៧ | ៣៧៤.៧៥៥ |
| មណ្ឌលគិរី | ៤៥.៣៣៨ | ១.៥៣០ | ២៨៥ | ៨៩ | ៤៧.២៤២ | ៤២.៨៨៩ | ១.៦៥៨ | ៣១២ | ១១២ | ៤៤.៩៧១ | ៨៨.២២៧ | ៣.១៨៨ | ៥៩៧ | ២០១ | ៩២.២១៣ |
| ភ្នំពេញ | ១.០៧៤.០៤៣ | ២៥.០៣១ | ៤.១៨៤ | ២.១៣៦ | ១.១០៥.៣៩៤ | ១.១៣៣.៤៩៧ | ៣៣.៥៤២ | ៦.២៣៩ | ២.៧០៥ | ១.១៧៥.៩៨៣ | ២.២០៧.៥៤០ | ៥៨.៥៧៣ | ១០.៤២៣ | ៤.៨៤១ | ២.២៨១.៣៧៧ |
| ព្រះវិហារ | ១២២.៩៥៥ | ៤.២២៣ | ៩១៩ | ៣៣៩ | ១២៨.៤៣៦ | ១១៩.៧៤០ | ៥.២០០ | ១.០៩៦ | ៣៥៥ | ១២៦.៣៩១ | ២៤២.៦៩៥ | ៩.៤២៣ | ២.០១៥ | ៦៩៤ | ២៥៤.៨២៧ |
| ព្រៃវែង | ៤៧៨.០៤៨ | ១៥.១៦៩ | ៤.២០៤ | ១.២៩០ | ៤៩៨.៧១១ | ៥២៣.៤៨១ | ២៥.៧៤៧ | ៧.៧៩៣ | ១.៩៨៨ | ៥៥៩.០០៩ | ១.០០១.៥២៩ | ៤០.៩១៦ | ១១.៩៩៧ | ៣.២៧៨ | ១.០៥៧.៧២០ |
| ពោធិ៍សាត់ | ១៩៥.៩០៨ | ៦.៦០៦ | ១.៣៤៩ | ៣០៩ | ២០៤.១៧២ | ២០២.៩៤០ | ៩.៨៩៤ | ២.៤៨៦ | ៤៦០ | ២១៥.៧៨០ | ៣៩៨.៨៤៨ | ១៦.៥០០ | ៣.៨៣៥ | ៧៦៩ | ៤១៩.៩៥២ |
| រតនៈគិរី | ១០៦.៧០៨ | ២.៦០៨ | ៥០២ | ១៦០ | ១០៩.៩៧៨ | ១០៣.៦៩៥ | ២.៩៦៩ | ៦៣៩ | ១៧២ | ១០៧.៤៧៥ | ២១០.៤០៣ | ៥.៥៧៧ | ១.១៤១ | ៣៣២ | ២១៧.៤៥៣ |
